សមាគមច្បាប់ខ្មែរ
Khmer Law's Association

# នីតិក្រុមហ៊ុន



លោកមេធាវី អ៊ីខ ប៉ូលី

២០០៨

រក្សាសិទ្ធិគ្រប់យ៉ាង

គេហទំព័រ ៖www.law-society.asia

# សារបាន

ការសិក្សាទៅលើនីតិក្រុមហ៊ុន គឺជាការពិចារណាបន្ថែមទៅលើនីតិពាណិជ្ជកម្ម ដោយរចនាសម្ព័ន្ធនៃនីតិពាណិជ្ជកម្ម មានសាខា ឬផ្នែកជាច្រើន ដែលក្នុងចំណោមមែកធាងទាំងនោះ មាននីតិក្រុមហ៊ុន ផងដែរ។ នៅក្នុងប្រតិបត្តិការនានា ផ្នែកពាណិជ្ជកម្ម ទម្រង់សហគ្រាស ជាទម្រង់ដែលមានសកម្មភាពខ្លាំងក្លា នៅក្នុងចំណោមពាណិជកិច្ចទាំងឡាយ ដែលតាមរយៈនេះ ទម្រង់សហគ្រាស តែងតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍ប្រទេស ដែលវាបានជំរុញឱ្យសេដ្ឋកិច្ចរបស់ប្រទេសមានការរីកចម្រើនឥតឈប់ឈរ។ រាល់សកម្មភាពទាំងឡាយរបស់សហគ្រាស អាចធ្វើបានតាមទម្រង់ជាច្រើន ដែលពេលខ្លះសកម្មភាពសហគ្រាសទាំងនេះមានលក្ខណៈឯកជនសុទ្ធសាធ ពេលខ្លះធ្វើឡើងដោយរដ្ឋ និងពេលខ្លះមានការចូលរួមពីសកលលោក តាមរយៈអ្នកវិនិយោគបរទេស ដែលយល់ថាមានសក្តានុពលនៅទីកន្លែងណាមួយ ដើម្បីទទួលបាននូវ ទីផ្សារនៃការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់អ្នកមានតម្រូវការ។

ការចូលរួមធ្វើប្រតិបត្តិការសហគ្រាស អាចធ្វើបានតាមរយៈសហគ្រាសពាណិជ្ជកម្ម សហគ្រាសសាធារណៈ និងសហគ្រាសពហុជាតិ ដែលមានបទដ្ឋានគតិយុត្តគាំទ្រជាច្រើន ដូចជា ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងបទដ្ឋានវិស័យពាណិជ្ជកម្មមួយចំនួនទៀត ដូចជា ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹងនានា ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់ក្រុមហ៊ុន ឬសហគ្រាស។ មួយវិញទៀត នៅក្នុងក្របខណ្ឌនៃការសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ គោលការណ៍អន្តរានិស្សរភាពនៃទ្រឹស្តី បទដ្ឋានច្បាប់ និងការអនុវត្ត រួមជាមួយកាលានុវត្តភាពនៃក្រមកម្មពាក់ព័ន្ធ ត្រូវតែមានទំនាក់ទំនងគ្នា ក្នុងគោលដៅធានាឱ្យបាននូវភាពប្រទាក់ក្រឡាគ្នានៃរចនាសម្ព័ន្ធការងារ និងទ្រឹស្តី។ លើសពីនេះទៅទៀតការសិក្សានីតិក្រុមហ៊ុនទាមទារឱ្យមានភាពប៉ិនប្រសព្វ និងវិរិយភាពនៃការស្រាវជ្រាវ ទើបទទួលបានលទ្ធផលជាផ្លែផ្កា ដែលអាចប្រែក្លាយទ្រឹស្តី ទៅជាការអនុវត្តពេញលេញ ទើបអាចគោរពគោលការណ៍សមូទីកម្ម និងផ្តល់ផលប្រយោជន៍ដល់អ្នកសិក្សា អ្នកស្រាវជ្រាវ អ្នកអនុវត្ត ឬអ្នកពាក់ពន្ធ័។

ជាចុងក្រោយនេះ ខ្ញុំបាទរីករាយនឹងទទួលយកការរិះគន់ក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាន និងស្ថាប័ននានា ក្នុងគោលដៅបំពេញនូវការខ្វះខាតទាំងឡាយ រួមទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធដែលកើតមានឡើងជាយថាហេតុ ដោយអចេតនា លើកម្រងសិក្សាស្រាវជ្រាវនេះ។

ភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨

**សាស្ត្រាចារ្យ**

**មេធាវី អ៊ីវ ប៉ូលី**

# នីតិក្រុមហ៊ុន

## មាតិកា

ទំព័រ


**សារបាន**........................................................a

**សេចក្តីផ្តើម**........................................................០១

**ភាគទី ១:សហគ្រាសសាធារណៈ**

**ជំពូកទី ១: សញ្ញាណទូទៅនៃសហគ្រាសសាធារណៈ**........................................................០៩

**ផ្នែកទី ១: អត្ថន័យនៃសហគ្រាសសាធារណៈ**........................................................០៩

កថាខណ្ឌទី ១: របបគតិយុត្តនៃសហគ្រាសសាធារណៈ........................................................១០

ក-គោលការណ៍គ្រប់គ្រងពាណិជ្ជកម្ម........................................................១០

ខ-គោលការណ៍គ្រប់គ្រងឯកទេសភាព........................................................១០

គ-គោលការណ៍នៃការគ្រប់គ្រងបុគ្គលិក........................................................១០

កថាខណ្ឌទី ២: ទំនាក់ទំនងសហគ្រាសសាធារណៈ និងរដ្ឋ........................................................១២

ក-ការត្រួតពិនិត្យរបស់រដ្ឋ........................................................១២

ខ-ចលនាសេរីភាវូបនីយកម្ម........................................................១៤

**ផ្នែកទី ២: សិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ**........................................................១៤

កថាខណ្ឌទី ១: ភារកិច្ច និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាភិបាល........................................................១៤

កថាខណ្ឌទី ២: កាតព្វកិច្ចរបស់សហគ្រាសសាធារណៈ........................................................១៦

**ផ្នែកទី ៣: ការត្រួតពិនិត្យសហគ្រាសសាធារណៈ**........................................................១៦

កថាខណ្ឌទី ១: ស្ថាប័នរដ្ឋដែលគ្រប់គ្រងសេវាសាធារណៈ........................................................១៧

កថាខណ្ឌទី ២: ស្ថាប័នឯកជនដែលគ្រប់គ្រងសេវាសាធារណៈ........................................................១៨

**ជំពូកទី ២: ប្រភេទនៃសហគ្រាសសាធារណៈ**........................................................២០

**ផ្នែកទី ១: គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច**........................................................២០

**ផ្នែកទី ២: ក្រុមហ៊ុនរដ្ឋ**........................................................២១




រក្សាសិទ្ធិគ្រប់យ៉ាង ©
អ៊ឹម ប៉ូលី

**ផ្នែកទី ៣: ក្រុមហ៊ុនចម្រុះ**......................................................................២១

## ភាគទី ២: សហគ្រាសពហុជាតិ

**ជំពូកទី ១: ការបង្កើតសហគ្រាសពហុជាតិ**...................................................២៦

**ផ្នែកទី ១: សារជាតុនៃសហគ្រាសពហុជាតិ**.....................................................២៦

កថាខណ្ឌទី ១: អត្ថន័យ.............................................................................២៦

កថាខណ្ឌទី ២: លក្ខណៈសំគាល់សហគ្រាសពហុជាតិ..........................................២៧

កថាខណ្ឌទី ៣: រចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ...........................................២៨

**ផ្នែកទី ២: សណ្ឋាននៃសហគ្រាសពហុជាតិ**.....................................................២៩

កថាខណ្ឌទី ១: ជម្រើសនៃសហគ្រាសពហុជាតិ..................................................២៩

កថាខណ្ឌទី ២: មូលហេតុនៃការបណ្តាក់ទុននៅបរទេស.......................................៣១

កថាខណ្ឌទី ៣: រូបភាពនៃការបណ្តាក់ទុនរបស់សហគ្រាសពហុជាតិ........................៣១

កថាខណ្ឌទី ៤: សញ្ជាតិនៃសហគ្រាសពហុជាតិ...................................................៣២

កថាខណ្ឌទី ៥: ការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា................................................៣២

**ជំពូកទី ២:ដំណើរការសហគ្រាសពហុជាតិ**.........................................................៣៣

**ផ្នែកទី ១ : សញ្ញាណទូទៅនៃសហគ្រាសពហុជាតិ**............................................៣៣

កថាខណ្ឌទី ១: ភាគហ៊ុន.............................................................................៣៤

ក-សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់ហ៊ុន.........................................................៣៥

ខ-បណ្ណឹង..........................................................................................៣៥

កថាខណ្ឌទី ២: ការបង់ពន្ធនៃសហគ្រាសពហុជាតិ..............................................៣៦

ក-គោលការណ៍នៃការបង់ពន្ធ.....................................................................៣៦

ខ-ការបង់ពន្ធរបស់សហគ្រាសពហុជាតិនៅកម្ពុជា.............................................៣៧

១-ប្រភេទ និងតម្លៃពន្ធ.......................................................................៣៧

២-ដំណាក់កាលនៃការបង់ពន្ធ..................................................................៤០

កថាខណ្ឌទី ៣-ការខកខានមិនបានបង់ពន្ធ.....................................................៤០
ក-មូលហេតុ.....................................................................................៤១
ខ-ការពិន័យ.....................................................................................៤១
**ផ្នែកទី ២: ទំនាក់ទំនងនៃសហគ្រាសពហុជាតិ**.....................................................៤២
កថាខណ្ឌទី ១: ទំនាក់ទំនងផ្ទៃក្នុង.....................................................................៤២
កថាខណ្ឌទី ២: ទំនាក់ទំនងជាមួយតតិយជន.....................................................៤២
**ជំពូកទី ៣: ការរំលាយសហគ្រាសពហុជាតិ**.....................................................៤២
**ផ្នែកទី ១:មូលហេតុនៃការរំលាយ**.....................................................................៤២
កថាខណ្ឌទី ១: កិច្ចសន្យា.....................................................................................៤៣
កថាខណ្ឌទី ២: តុលាការ.....................................................................................៤៣
**ផ្នែកទី ២: ការជម្រះបញ្ជី**.....................................................................................៤៤
កថាខណ្ឌទី ១: អ្នកជម្រះបញ្ជី.............................................................................៤៤
កថាខណ្ឌទី ២: ដំណាក់កាលជម្រះបញ្ជី.....................................................................៤៥
កថាខណ្ឌទី ៣: ដំណាក់កាលនៃការរំលាយសហគ្រាសពហុជាតិនៅកម្ពុជា.................៤៦

# ភាគទី ៣: សហគ្រាសពាណិជ្ជកម្ម

**ជំពូកទី ១: ក្រុមហ៊ុនសហកម្មសិទ្ធិ**.....................................................................៤៩
**ផ្នែកទី ១: ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**.....................................................................៤៩
កថាខណ្ឌទី ១: ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ.............................................៤៩
កថាខណ្ឌទី ២: ដំណើរការក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ.............................................៥០
ក- ទំនាក់ទនងរវាងសហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករទូទៅ.............៥១
ខ- ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងតតិយជន............................៥៤
គ- ការផ្ទេរសិទ្ធិជាសហកម្មសិទ្ធិករទូទៅ.................................................៥៥
កថាខណ្ឌទី ៣: ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ................៥៦


រក្សាសិទ្ធិគ្រប់យ៉ាង©
អ៊ីវ ប៉ូលី

**ផ្នែកទី ២: ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត**.......................................................៥៨

**ជំពូកទី ២: ក្រុមហ៊ុនមូលធន**.......................................................................................៦២

**ផ្នែកទី ១: ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត**..........................................៦៣

កថាខណ្ឌទី ១: ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត.......................៦៤

ក- នីតិវិធីនៃការបង្កើតក្រុមហ៊ុន..........................................................៦៤

ខ-សិទ្ធិរបស់ក្រុមហ៊ុន.....................................................................៦៥

កថាខណ្ឌទី ២: ដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត......................៦៦

ក- ការចុះបញ្ជីពាណិជ្ជកម្ម..................................................................៦៧

ខ- សៀវភៅបញ្ជី និងកំណត់ហេតុ.......................................................៦៧

គ- ការប្រកាសប្រតិវេទន៍...................................................................៦៨

ឃ- អភិបាលក្រុមហ៊ុន និងម្ចាស់ហ៊ុន......................................................៦៩

១- អភិបាលក្រុមហ៊ុន...........................................................៦៩

២- ម្ចាស់ហ៊ុន.........................................................................៧៥

ង- ភាគហ៊ុន ភាគលាភ និងមូលបត្រ......................................................៨០

១-ភាគហ៊ុន និងភាគលាភ.......................................................៨០

២- មូលបត្រ.........................................................................៨៤

ច- អ្នកថែរក្សាទ្រព្យសម្បត្តិ និងរបាយការណ៍ហិរញ្ញវត្ថុ.............................៩១

១- អ្នកថែរក្សាទ្រព្យសម្បត្តិ.......................................................៩១

២- របាយការណ៍ហិរញ្ញវត្ថុ.......................................................៩៣

កថាខណ្ឌទី ៣: ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងការរំលាយក្រុមហ៊ុន.......................៩៥

ក- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន..........................................................៩៥

ខ- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា.........................................................៩៧

គ- ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជី...........................................១០០

**ផ្នែកទី ២: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត**..........................................១០៣

**ជំពូកទី ៣: ក្រុមហ៊ុនពាណិជ្ជកម្មបរទេស**......................................................១០៦
**ផ្នែកទី ១: សាខាក្រុមហ៊ុន**......................................................១០៧
**ផ្នែកទី ២: ការិយាល័យតំណាងពាណិជ្ជកម្ម**......................................................១០៧
**ផ្នែកទី ៣: បុត្រសម្ព័ន្ធ**......................................................១០៨
**សេចក្តីសន្និដ្ឋាន**......................................................១១០
**ឧបសម្ព័ន្ធ**
**បញ្ជីឯកសារយោង**

# នីតិក្រុមហ៊ុន

## សេចក្តីផ្តើម

### ១.ប្រវត្តិនៃកំណើតនីតិក្រុមហ៊ុន

បើពិនិត្យជារួមទៅលើប្រវត្តិនៃការកកើតវិធាន ដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម យើងឃើញថា វាមាន ដើមកំណើត ប្រហែលជានៅឆ្នាំ ២០០០ មុន គ.ស ប៉ុន្តែនេះ គឺគ្រាន់តែជាសេចក្តីសន្និដ្ឋានប៉ុណ្ណោះ។ ដើមកំណើតពិតប្រាកដនៃនីតិពាណិជ្ជកម្ម គឺប្រហែលជានៅសតវត្សទី ១១ ព្រោះមានចារទុកនៅតាមទីប្រជុំមួយចំនួននៃប្រទេស អ៊ីតាលី អាល្លឺម៉ង់ និងបារាំង ដែលជាទឹកដីដើមកំណើតនៃជនជាតិរ៉ូម៉ាំង។ ការកកើតទីផ្សារសម្រាប់មុខរបរពាណិជ្ជកម្មនេះ បានជំរុញឱ្យអ្នកចូលរួមទាំងឡាយ បង្កើតចេញនូវរបបនៃកិច្ចសន្យាសម្រាប់មុខរបររបស់ខ្លួន និងរូបិយាណត្តិ។ យោងតាមឯកសារចងក្រងមួយចំនួន គេសង្កេតឃើញថា កាលពីបុព្វកាល គេបានបង្កើតនូវវិធានមួយចំនួនដែលពាក់ព័ន្ធទៅនឹងការបង្កើតក្រុមហ៊ុន និងរបៀបធ្វើពាណិជ្ជកម្ម ដោយប្រភពឯកសារប្រវត្តិសាស្ត្របានបញ្ជាក់ថា ការអនុញ្ញាតឱ្យអ្នកមានដើមទុនរួបរួមទុនគ្នា គឺជាពាណិជ្ជករ និងរួមគ្នាទទួលខុសត្រូវ ក្នុងការបង់ខាត និងការចែកប្រាក់ចំណេញ។ រហូតដល់ឆ្នាំ ១៨០៧ ក្រមពាណិជ្ជកម្មត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងប្រទេសបារាំង ដែលនៅក្នុងនោះមានចែកជា ០៤ ផ្នែក គឺ ពាណិជ្ជកម្មទូទៅ ពាណិជ្ជកម្មសមុទ្រ អសាធនភាព ក្ស័យធន និងតុលាការពាណិជ្ជកម្ម។

បើយើងមើលទៅលើប្រវត្តិសាស្ត្រនៃប្រជាជាតិអាស៊ីវិញ ឯកសារដែលទាក់ទងនឹងវិធានពាណិជ្ជកម្មច្រើនមានចងក្រងដោយជនជាតិឥណ្ឌា និងជនជាតិចិន។ ដោយឡែកសម្រាប់ប្រទេសកម្ពុជាវិញ រហូតមកដល់ឆ្នាំ ១៩២០ ប្រទេសកម្ពុជាឥតមានច្បាប់ពិសេស សម្រាប់គ្រប់គ្រងវិស័យពាណិជ្ជកម្មនោះទេ។ យោងតាមឯកសារបរទេសមួយចំនួន ប្រទេសកម្ពុជាបានចងកម្រងមួយ ដែលចម្រុះដោយច្បាប់សឹងគ្រប់វិស័យសម្រាប់គ្រប់គ្រងជីវភាពក្នុងសង្គមរួមទាំងកិច្ចការឯកជន។ កម្រង ច្បាប់នោះមានឈ្មោះថា **ក្រមកម្ពុជា** ដែលចងក្រង

ឡើងដោយលោក **អាដេមាឡឺក្លែរ** ច្បាប់ទាំងនោះបានមក ដោយអ្នកនិពន្ធសញ្ជាតិបារាំងរូបនេះបានសាកសួរ រាជវង្សានុវង្សនៃព្រះមហាក្សត្រនៅសម័យនោះ ដែលនៅចងចាំច្បាប់ទម្លាប់ កាលពីបុរាណកាល មានន័យថា ច្បាប់នោះមិនមែនត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិដូចសព្វថ្ងៃនេះទេ។ មុនប្រទេសកម្ពុជាទទួលបាន ឯករាជ្យនាថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ ច្បាប់សំខាន់ ដែលត្រូវយកទៅអនុវត្តក្នុងវិស័យពាណិជ្ជកម្មមានជា ចម្បងគឺ ក្រមរដ្ឋប្បវេណី អនុម័តឆ្នាំ ១៩២០ ពីមាត្រា ១២៨៧ ដល់មាត្រា ១២៩៤ និងក្រមពាណិជ្ជកម្មដែល ប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៥០ ដោយបទបញ្ញត្តិទាំងនេះត្រូវ បន្តអនុវត្តរហូតដល់ឆ្នាំ ១៩៧៥ ទើបផុតរលត់ទាំស្រុង។ ប្រទេសកម្ពុជា លែងមានច្បាប់ ពាណិជ្ជកម្ម ចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៨៨ រហូតមកដល់សព្វថ្ងៃនេះ នីតិវិធីខ្មែរមានកង្វះខាតជាច្រើន និង ស្ទើរគ្រប់វិស័យច្បាប់ដែលនៅក្នុងនោះមាន ច្បាប់រដ្ឋប្បវេណី ច្បាប់កិច្ចសន្យា និងច្បាប់ពាណិជ្ជកម្មផងដែរ ប៉ុន្តែ នាពេលបច្ចុប្បន្ននេះ ក្រមរដ្ឋប្បវេណី និង វិធានដែលពាក់ព័ន្ធជាមួយវិស័យពាណិជ្ជកម្ម បានរីកចម្រើន និងកំពុងតែវិវត្តន៍ជាលំដាប់ទៅតាមស្ថានភាព រីកចំរើននៃសេដ្ឋកិច្ចកម្ពុជា។

## ២. ប្រភពនៃនីតិក្រុមហ៊ុន

### ក. ប្រភពជាតិ

#### ១-រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ ១៩៩៣ បានសម្តែងទុកជាគោលការណ៍ទូទៅនូវសេរីភាពពាណិជ្ជកម្ម និងការជួយជ្រោម-ជ្រែងពីរដ្ឋក្នុងការអភិវឌ្ឍសេដ្ឋកិច្ចលើគ្រប់វិស័យ ជាពិសេសវិស័យសិប្បកម្ម និងវិស័យឧស្សាហកម្ម។ អនុលោមតាមរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរទាំងប្រុសទាំងស្រីមានសិទ្ធិជ្រើសរើសមុខរបរដែលសមស្របនឹង សមត្ថភាពរបស់ខ្លួន។ ដើម្បីធានាសកម្មភាពពាណិជ្ជកម្ម ប្រកបដោយសុវត្ថិភាពទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវ រូបសាស្ត្រ ច្បាប់ចាំបាច់ត្រូវទទួលស្គាល់ និងចេញវិធានការពារសិទ្ធិជាម្ចាស់នៃកម្មសិទ្ធិ។ ពោលគឺរាល់កម្មសិទ្ធិ ឯកជនគ្រប់ប្រភេទ ដែលស្របច្បាប់ត្រូវស្ថិតក្រោមការគាំពារនៃច្បាប់ និងកម្មសិទ្ធិឯកជន គឺជាលក្ខណៈគ្រឹះ ឬ ចំណុចផ្តើមនៃវិស័យពាណិជ្ជកម្ម។ មួយវិញទៀត ជនណាក៏ដោយ ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី មានសិទ្ធិ ជាម្ចាស់កម្មសិទ្ធិ ហើយកម្មសិទ្ធិឯកជន ត្រូវបានទទួលស្គាល់ និងទទួលការគាំពារពីច្បាប់ ដោយគ្មានជនណាម្នាក់

អាចដកហូតកម្មសិទ្ធិនេះ លើកលែងតែ ធ្វើឡើងដើម្បីប្រយោជន៍សាធារណៈ និងទទួលបានសំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ដែលជាប្រភពដ៏សំខាន់នៃនីតិក្រុមហ៊ុន។

**២-ច្បាប់**

ក្រៅពីរដ្ឋធម្មនុញ្ញ មានច្បាប់ចែងអំពីវិធានចម្បងផ្សេងៗទៀត ដែលចែងពីវិធាននានាទាក់ទងនឹងនីតិវិធីពាណិជ្ជកម្មដូចជា :

ទី១-ច្បាប់ស្តីអំពីវិនិយោគទុន នៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ ១៩៩៤

ទី២-ច្បាប់ស្តីអំពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មអនុម័តនៅថ្ងៃទី ០៣ ខែ ឧសាភា ឆ្នាំ ១៩៩៥

ទី៣-ច្បាប់ស្តីពីសភាពាណិជ្ជកម្មអនុម័តនៅថ្ងៃទី១៦ ខែ ឧសាភា ឆ្នាំ ១៩៩៥

ទី៤-ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីអំពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មអនុម័តនៅថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ទី៥-ច្បាប់ស្តីអំពីម៉ាក ពាណិជ្ជនាម និងអំពីនៃការប្រកួតប្រជែងមិនស្មោះត្រង់អនុម័តថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១

ទី៦-ច្បាប់ស្តីអំពីវិសោធនកម្ម នៃច្បាប់ស្តីអំពីវិនិយោគទុន នៃព្រះរាជាណាចក្រកម្ពុជាអនុម័តថ្ងៃទី ១៣ កុម្ភៈ ២០០៣

ទី៧-ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៩ មិថុនា ២០០៥

ទី៨-ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ០៦ មេសា ២០០៧

ទី៩-ច្បាប់ស្តីពីធនក្ស័យ ០៨ ធ្នូ ២០០៧

ក្រៅពីនេះមានសេចក្តីព្រាងច្បាប់ផ្សេងៗទៀតដែលសភាមិនទាន់អនុម័តនៅឡើយដូចជា :

- សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម
- សេចក្តីព្រាងច្បាប់ស្តីពីអ៊ី-ពាណិជ្ជកម្ម
- សេចក្តីព្រៀងច្បាប់ស្តីពី តុលាការពាណិជ្ជកម្ម

**៣-បទបញ្ជា**

បទបញ្ជាដែលចេញដោយអង្គការនីតិប្រតិបត្តិ គឺជាប្រភពដ៏សំខាន់នៃវិស័យនីតិក្រុមហ៊ុនផងដែរ។ ដោយហេតុថា បទដ្ឋានទាំងនេះមាននាទីចង្អុលបង្ហាញ និងបំភ្លឺបទបញ្ញតិនៃច្បាប់ដើម្បីធានាការអនុវត្តច្បាប់

ប្រកបដោយប្រសិទ្ធភាព និងអនុលោមតាមស្មារតីរបស់ស្ថាប័ននីតិបញ្ញត្តិ។ បទបញ្ជាទាំងនោះចេញដោយរដ្ឋាភិបាល និងក្រសួងពាណិជ្ជកម្ម ដូចជាសារាចរណែនាំស្តីពីការចុះបញ្ជីពាណិជ្ជកម្មក្នុងក្រសួងពាណិជ្ជកម្ម ០៣ ធ្នូ ១៩៩៧ ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចុះថ្ងៃទី ១២ តុលា ១៩៩៧។ លើសពីនេះទៅទៀតមានប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ដែលកំណត់អំពីរបៀបនៃការអនុវត្តបញ្ញត្តិនៃច្បាប់ ឬបង្ហាញបន្ថែម ឬពង្រីកអត្ថន័យនៃខ្លឹមសារអត្ថបទច្បាប់ មានដូចជា ប្រកាសស្តីពីការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ប្រកាសអន្តរក្រសួងស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម ជាអាទិ៍។

### ៤-ទម្លាប់

ទំលាប់គឺជាការអនុវត្តជាប្រចាំនូវវិជ្ជាជីវៈអ្វីមួយ ឬនៅក្នុងទីកន្លែងណាមួយ។ ដោយសារតែមានការអនុវត្តជាច្រើនលើក ច្រើនសារ លើវិធានដដែល១ វិធាននេះបានប្រែក្លាយជាវិធានគតិយុត្ត ដែលត្រូវយកទៅអនុវត្តក្នុងករណីដែលភាគីនៃកិច្ចសន្យាពាណិជ្ជកម្ម ដែលមិនបានចែងផ្សេងនៅក្នុងកិច្ចសន្យាផ្ទុយពីនេះ។ ទម្លាប់ទាំងនេះមានលក្ខណៈទូទៅចំពោះតែតំបន់ណាមួយ ឬពិសេសសម្រាប់តែវិជ្ជាជីវៈណាមួយប៉ុណ្ណោះ។ មួយវិញទៀតទម្លាប់អាចកើតមាននៅក្នុងការព្រមព្រៀង(ពេលទិញឈើមូល នៅពេលមានវិការៈ ដែលអ្នកទិញមើលមិនឃើញ អ្នកលក់ទទួលខុសត្រូវ តែតាមទម្លាប់អនុវត្តកន្លងមក ទោះបីឈើនោះស្អុយក្នុង ក៏ជាបន្ទុករបស់អ្នកទិញដដែល) ឬទម្លាប់តាមច្បាប់(ជាទម្លាប់ដែលនៅពេលមានវិវាទ តុលាការទទួលស្គាល់ ហើយអ្នកដែលបានដឹង ឬបានឮ ក៏ទទួលយកអនុវត្តផងដែរ)។

### ៥-យុត្តិសាស្ត្រ

យុត្តិសាស្ត្រ គឺសំដៅវាល់សេចក្តីសំរេចរបស់តុលាការដែលមានតួនាទីដូចគ្នាទាំងក្នុង នីតិរដ្ឋប្បវេណី និងនីតិពាណិកម្ម។ យុត្តិសាស្ត្របានមកដោយសារការបកស្រាយច្បាប់បំពេញបន្ថែមលើកង្វះខាតច្បាប់ហើយ រហូតដល់អភិវឌ្ឍ បទបញ្ញត្តិ ច្បាប់ឱ្យអនុលោមតាមសេចក្តីត្រូវការបច្ចុប្បន្ន។ សេចក្តីសម្រេច និងយុត្តិវិធីនានារបស់តុលាការ គឺជាយុត្តិសាស្ត្រ ដែលមានតួនាទីសំខាន់នៅក្នុងនីតិពាណិជ្ជកម្ម ដោយសារ វាជាបំណកស្រាយច្បាប់សម្រាប់បំពេញបន្ថែមនូវចន្លោះ ដែលខ្វះខាត និងធ្វើឱ្យច្បាប់វិវត្តន៍មកបំពេញសេចក្តីត្រូវការ ជាមូលដ្ឋាននៃការអនុវត្តពាណិជ្ជកិច្ច ពីសំណាក់ពាណិជ្ជករ និងអ្នកធ្វើប្រតិបត្តិការពាណិជ្ជកម្ម។

ឧទាហរណ៍ ៖ មុនពេលមានច្បាប់ស្តីពីនៃការប្រកួតប្រជែងមិនស្មោះត្រង់ ទ្រឹស្តីនៃការប្រកួតប្រជែងមិនស្មោះត្រង់នេះ ត្រូវបានតុលាការតាក់តែងដោយមានមូលដ្ឋានផ្អែកលើគោលការណ៍ផ្សេងៗនៃនីតិរដ្ឋប្បវេណី ឬនីតិពាណិជ្ជកម្ម។ ដូច្នេះតុលាការបានយកទ្រឹស្តីនេះទៅអនុវត្តចំពោះវិវាទពាណិជ្ជកម្ម ដែលទាក់ទងទៅនឹងការប្រកួតប្រជែងនេះ។ ដរាបណាតុលាការមិនទាន់ធ្វើការសើរើយុត្តិសាស្ត្ររបស់ខ្លួនទេ យុត្តិសាស្ត្រ ដែលតុលាការយកទៅអនុវត្តមានតំលៃដូចជាច្បាប់ផងដែរ។

**៦-លទ្ធិ**

លទ្ធិ គឺជាការចងក្រងរាល់ទ្រឹស្តីនានា ដែលពាក់ពន្ធ័នឹងវិស័យច្បាប់ ដែលមាននាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាមូលដ្ឋានពិចារណាដល់តុលាការ ក្នុងការវិនិច្ឆ័យសេចក្តី ក៏ដូចជាស្ថាប័ននីតិបញ្ញត្តិ។ ចំពោះភារកិច្ចនីតិកម្ម (ភារៈកិច្ចតាក់តែងច្បាប់) ឱ្យបានប្រកបដោយភាពពេញលេញ និងចៀសវាងគុណវិបត្តិនានា ដែលអាចមានខ្វះការពិនិត្យគ្រប់ជ្រុងជ្រោយ។ តែនៅប្រទេសកម្ពុជា លទ្ធិមិនទាន់មានការរីកចំរើនទេ ដោយមានមូលហេតុផ្សេងៗពាក់ពន្ធ័នឹងទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គម និងកាលានុវត្តភាពនៃវិស័យពាណិជ្ជកម្ម ដែលតាមរយៈនេះលទ្ធិត្រូវបានក្លាយជាភាពមិនចាប់អារម្មណ៍នៅក្នុងប្រទេសកម្ពុជា។

**៧-ប្រភពអន្តរជាតិ**

ការចូលជាសមាជិកអស៊ានបានផ្តល់ដល់កម្ពុជានូវកាលានុវត្តភាព(ឱកាស) ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ដូច្នេះ កម្ពុជាក្លាយជាភាគីកិច្ចព្រមព្រៀងនានាដែលមាននៅក្នុងក្របខ័ណ្ឌរបស់អាស៊ាន ដូចជាកិច្ចព្រមព្រៀងលើគំរោងអនុគ្រោះពន្ធគយរួម កិច្ចព្រមព្រៀងអនុញ្ញាតឱ្យរួចពន្ធគយ ជាដើម។

កម្រងកិច្ចព្រមព្រៀងចុងក្រោយជាលទ្ធផលនៃកិច្ចប្រជុំនៅ **យ៉ូរូហ្គាយ** (Uruguay) ស្តីពីការចរចាពាណិជ្ជកម្មទ្វេភាគី ដែលសំរេចនៅខែធ្នូ ១៩៩៣។ នៅពេលកម្ពុជាចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក កម្រងអត្ថបទនេះ នឹងមានសារៈសំខាន់បំផុតសំរាប់គ្រប់គ្រងការងារស្តីពីកិច្ចព្រមព្រៀងពាណិជ្ជ-កម្មពិភពលោក។ ពេលបច្ចុប្បន្នក្រសួងពាណិជ្ជកម្មបានប្រកាសឱ្យប្រើប្រាស់កំរងឯកសារនេះ ដើម្បីពង្រឹងសមត្ថភាពក្រុមការងារ អង្គការពាណិជ្ជកម្មពិភពលោក និងផ្នែកឯកជនឱ្យយល់ច្បាស់ពីសិទ្ធិ និងកាតព្វកិច្ចរបស់

អង្គការនេះ។ នាពេលអនាគតកិច្ចព្រមព្រៀងទាំងនេះនឹងផ្ដល់ប្រយោជន៍ដល់កម្ពុជា ដែលតាមរយៈនេះកម្ពុជាត្រូវត្រៀមខ្លួនអនុម័តនូវច្បាប់ជាច្រើន ហើយគេសង្កេតឃើញថាការរៀបចំរបស់កម្ពុជាសំរាប់ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកមានដំណើរការបានយ៉ាងល្អ ដោយកម្ពុជាអាចទទួលអត្ថប្រយោជន៍ជាច្រើន ដូចជា ជំនួយបច្ចេកទេសសំរាប់វិស័យចាំបាច់នានា ជាពិសេសក្របខ័ណ្ឌច្បាប់ និងការវាយតំលៃអំពីគោលនយោបាយពាណិជ្ជកម្ម។ ក្រៅពីនេះមាន កត្តិការសញ្ញាស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ ចុះថ្ងៃទី ១៦ ធ្នូ ១៩៦៦ ជាដើម ដែលជាផ្នែកមួយសម្រាប់សម្របសម្រួលរចនាសម្ព័ន្ធ ឬខ្សែចង្វាក់វិស័យពាណិជ្ជកម្ម។

## ៣.លក្ខណៈពិសេសនៃនីតិក្រុមហ៊ុន

### ក_អត្ថន័យ

នីតិក្រុមហ៊ុន គឺជានីតិដែលអនុវត្តចំពោះពាណិជ្ជករនៅក្នុងពេលអនុវត្តវិជ្ជាជីវៈរបស់ខ្លួន (វិធានដែលទាក់ទងនឹងសមត្ថភាពពាណិជ្ជកម្ម មូលនីធិពាណិជ្ជកម្ម ក្រុមហ៊ុនជាដើម) និងចំពោះសកម្មភាពពាណិជ្ជកិច្ច (ពាណិជ្ជកិច្ច គឺជាកិច្ចសន្យាពាណិជ្ជកម្ម) ដូច្នេះ នីតិនេះត្រូវបានចូលរួមផ្សំឡើងដោយកំរងវិធានគតិយុត្តទាំងឡាយដែលត្រូវអនុវត្ត ជាពិសេសចំពោះពាណិជ្ជករ និងសហគ្រាសពាណិជ្ជកម្ម ក៏ដូចជាកិច្ច និងប្រតិបត្តិការពាណិជ្ជកម្មផងដែរ។

នីតិក្រុមហ៊ុន គឺជាកំរងវិធានទាំងឡាយស្ដីពីសកម្មភាពពាណិជ្ជកម្ម (ផលិតកម្ម និងការដោះដូរ) ដែលត្រូវបំពេញដោយឯកត្តបុគ្គល និងសហគ្រាស។ នីតិក្រុមហ៊ុន ក៏ជាផ្នែកមួយនៃនីតិពាណិជ្ជកម្មដែរ បានន័យថាជាវិធាននៃនីតិ ដែលត្រូវយកទៅអនុវត្តចំពោះទំនាក់ទំនងរវាងបុគ្គលឯកជន។ តែពាណិជ្ជកម្មជានីតិអញ្ញត្តិកម្មផ្ទុយពីនីតិរដ្ឋប្បវេណីជានីតិរួម បានសេចក្ដីថានីតិរដ្ឋប្បវេណីដែលជានីតិរួម និងត្រូវយកទៅអនុវត្តនៅក្នុងវិស័យពាណិជ្ជកម្ម តែក្នុងករណីដែលនីតិពាណិជ្ជកម្មមិនបានសម្ដែងនូវវិធានពិសេសប៉ុណ្ណោះ។ ប្រសិនបើមានវិវាទរវាង វិធានរដ្ឋប្បវេណី(នីតិរួម) និងនីតិពាណិជ្ជកម្ម(នីតិអញ្ញត្តិកម្ម) គោលការណ៍ដែលត្រូវយកទៅអនុវត្តគឺជាអញ្ញត្តិកម្ម ត្រូវមានឧត្តមភាពលើនីតិរួម។

### ខ_ចរិតនៃនីតិក្រុមហ៊ុន

គោលដៅចម្បងនៃនីតិក្រុមហ៊ុន គឺត្រូវឆ្លើយតបទៅនឹងរាល់ការចាំបាច់ទាំងឡាយទៅក្នុងវិស័យពាណិជ្ជកម្ម និងផ្អែកលើចក្ខុវិស័យនេះ នីតិក្រុមហ៊ុនតូវស្វែងរកដំណោះស្រាយនានា ដែលផ្សេងពីដំណោះ-ស្រាយមានស្រាប់នៅក្នុងនីតិរដ្ឋប្បវេណីនឹងត្រូវប្រើប្រាស់វិស័យបច្ចេកទេសពិសេសផ្សេងៗទៀត។ គេអាចសរុបចរិកពិសេសនៃនីតិក្រុមហ៊ុននេះជា ៤ ឬ ៥ ស្ថានគឺ :

**១.ភាពរហ័សហួន និងភាពងាយស្រួល**

នីតិក្រុមហ៊ុនផ្តល់ឧត្តមភាព និងភាពឆាប់រហ័សនៃប្រតិបត្តិការពាណិជ្ជកម្ម។ តបតាមអត្ថន័យនេះ នីតិក្រុមហ៊ុនមានសភាពកាន់តែទន់ភ្លន់ និងកាន់តែមិនសូវមានទំរង់បែបបទ ហួសហេតុដែលត្រូវបំពេញ។ ដូច្នេះនីតិនេះពុំសូវមានចរិកការពារគូរភាគីពាណិជ្ជកម្មដែរ ហើយតាំងពីបុរាណកាលរៀងមក នីតិក្រុមហ៊ុន ជានីតិអ្នកខ្លាំងឬរបស់គេហបតី។ ភស្តុតាងនៅក្នុងវិស័យក្រុមហ៊ុនអាចយកមកបង្ហាញបានតាមគ្រប់មធ្យោបាយ ដែលអនុលោមតាមគោលការណ៍នៃសេរីភាពខាងបន្ទាល់ (នៃភស្តុតាង) នីតិវិធីផ្អែកយុត្តាធិការ ក៏ងាយស្រួលនឹងអនុវត្ត ហើយអាជ្ញាយុកាលក៏មានរយៈពេលខ្លី។ ផ្ទុយទៅវិញនីតិក្រុមហ៊ុន គឺមានលក្ខណៈពិសេសជាងនីតិរដ្ឋប្បវេណី ឱ្យតំលៃជាអទិភាពដល់សុវត្ថិភាពនៃទំនាក់ទំនងគតិយុត្ត ដែលតំរូវឱ្យបំពេញនៅទំរង់បែបបទជាច្រើន និងគោលការណ៍ខាងបន្ទាល់ក្នុងវិស័យនេះគឺ ត្រូវបង្ហាញភស្តុតាងគ្រប់មធ្យោបាយ។

**២.ទំរង់បែបបទនិយម**

ទំរង់បែបបទនេះ ត្រូវបានបង្កើតឡើងទៅក្នុង វិស័យពាណិជ្ជកម្មក្នុងគោលបំណងការពារអ្នកប្រើប្រាស់ និងស្វែងរកនូវភាពជាក់លាក់ដ៏ច្បាស់លាស់មួយ (តាក់តែងជាលាយលក្ខណ៍អក្សរ) និងត្រូវប្រកបពាណិជ្ជកិច្ចដោយពាណិជ្ជករដោយជ្រើសរើសទម្រង់ក្រុមហ៊ុនពាណិជ្ជកម្មណាមួយ ក្នុងចំណោមក្រុមហ៊ុន ០៣ ប្រភេទ គឺសហគ្រាសសាធារណៈ សហគ្រាសពហុជាតិ និងសហគ្រាសពាណិជ្ជកម្ម ដែលតាមរយៈនេះ ពាណិជ្ជករត្រូវធ្វើសកម្មភាពពាណិជ្ជកិច្ចរបស់ខ្លួន ក្រោមរូបភាពជា សហគ្រាស ឬក្រុមហ៊ុន និងគ្រប់គ្រងទៅតាមច្បាប់ជាធរមាន។

**៣.ការផ្សព្វផ្សាយជាសាធារណៈ**

សេចក្តីត្រូវការនូវព័ត៌មានពីសំណាក់កូនហ៊ុន ពីតតិយជន ដែលមានម្ចាស់បំណុលជាច្រើន ពីកម្មករនិយោជិត ជាបច្ច័យនាំឱ្យការផ្សព្វផ្សាយពីស្ថានភាព និងសកម្មភាពពាណិជ្ជកម្មត្រូវតែងធ្វើឡើងជាចាំបាច់ដោយ

ខានមិនបាន។ ការចុះឈ្មោះក្រុមហ៊ុនចូលក្នុងបញ្ជីពាណិជ្ជកម្ម ការផ្សព្វផ្សាយតាមសារព័ត៌មាន ការផ្សព្វផ្សាយតាមការតម្កល់ទុកក្នុងក្រសួងពាណិជ្ជកម្ម សុទ្ធជាមធ្យោបាយបង្ហាញពីការប្រកួតប្រជែងនៅក្នុងវិស័យពាណិជ្ជកម្ម និងកម្មវត្ថុនៃការប្រកបរបរដល់សាធារណៈជន ដែលលាតត្រដាងពីតម្លាភាព និងភាពស្មោះត្រង់ ក្នុងការប្រកួតប្រជែង។

**៤.ឥណទាន**

រាល់បណ្តាពាណិជ្ជករទាំងអស់តែងតែប្រើឥណទាន ដោយភ្ជាប់មកជាមួយនូវបច្ចេកទេសពិសេសជាច្រើនទៀត(ផលប័ត្រពាណិជ្ជកម្ម ឬការបញ្ចាំ ឬហ៊ីប៉ូតែក)។ នីតិក្រុមហ៊ុនត្រូវតែអនុគ្រោះការប្រើប្រាស់ឥណទានដែលជាមូលដ្ឋាននៃគ្រប់សកម្មភាពពាណិជ្ជកម្មទាំងអស់ ផ្អែកលើសេចក្តីទុកចិត្ត និងការជឿជាក់។

ដោយហេតុថា ឥណទានអាចអនុវត្តទៅបានលុះណាម្ចាស់បំណុលមានការជឿជាក់ថានឹងអាចទទួលសំណងវិញគ្រប់ចំនួន ទើបការជម្រះអកម្មទ្រព្យតាមនីតិវិធីក្ស័យធនចាំបាច់ត្រូវតាក់តែងឡើងដោយច្បាប់។ ស្ថាប័នដែលប្រតិបត្តិការឥណទានអាចធ្វើឡើងក្នុងរូបភាព ជាធនាគារពាណិជ្ជកម្ម ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬក្រុមហ៊ុនធានារ៉ាប់រង ជាអាទិ៍។

## ៤.ស្ថាប័នគតិយុត្តិនៃនីតិក្រុមហ៊ុន

### ក.ស្ថាប័នខាងរដ្ឋបាល និងវិជ្ជាជីវៈក្រុមហ៊ុន

សភាពាណិជ្ជកម្មត្រូវបានបង្កើតឡើងដោយ ច្បាប់ស្តីពីសភាពាណិជ្ជកម្មដែលប្រកាសឱ្យប្រើនៅថ្ងៃទី២០ ឧសភា ១៩៩៥ សភាពាណិជ្ជកម្ម គឺជាគ្រឹះស្ថានសាធារណៈនៅក្រោមអាណាព្យាបាលនៃក្រសួងពាណិជ្ជកម្មដែលធ្វើសកម្មភាពជាផលប្រយោជន៍ខាងវិស័យពាណិជ្ជកម្ម-ឧស្សាហកម្ម និងសេវាកម្មក្នុងលំនៅរបស់ខ្លួន។ សភាពាណិជ្ជកម្ម មានសមាជិកជ្រើសតាំងតាមការបោះឆ្នោត និងសមាជិកទីប្រឹក្សា។ សមាជិកជ្រើសតាំងតាមការបោះឆ្នោតត្រូវបានកំនត់ដោយ អនុក្រឹត្យបង្កើតសភាពាណិជ្ជកម្មនីមួយៗ ហើយចំនួនសមាជិកទីប្រឹក្សាត្រូវកំនត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។ ចំនួននៃសមាជិកសភាពាណិជ្ជកម្មមានរយៈពេល ៦ឆ្នាំ ព្រមទាំងរៀងរាល់ ៣ឆ្នាំ ម្តងសភាពាណិជ្ជកម្មត្រូវរៀបចំការបោះឆ្នោតជ្រើសរើសសមាជិក ជ្រើសតាំងចំនួនពាក់កណ្តាលដោយសមាជិកសភាពាណិជ្ជកម្ម មានភារៈកិច្ច :

- ធ្វើទំនាក់ទំនងជាមួយនឹងប្រភពសេដ្ឋកិច្ចក្នុងប្រទេស និងក្រៅប្រទេសដើម្បីស្រង់យកព័ត៌មានដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងការអភិវឌ្ឍសហគ្រាសជាតិ
- បង្កើនប្រសិទ្ធិភាពសហគ្រាសទាំងឡាយដើម្បីផលប្រយោជន៍ខាងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម កសិកម្ម សេវកម្ម និងសេដ្ឋកិច្ចទូទៅ
- ផ្តល់ជូនរាជរដ្ឋាភិបាល និងអាជ្ញាធរខេត្ត-ក្រុង នូវយោបល់ និងព័ត៌មានទាំងឡាយស្តីពីបញ្ហាឧស្សាហកម្ម សិប្បកម្ម កសិកម្ម សេវកម្ម និងសេដ្ឋកិច្ចទូទៅ
- ដើរតួជាតំណាងសហគមន៍ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម កសិកម្ម សេវកម្ម និងសេដ្ឋកិច្ចទូទៅសំរាប់សំរបសំរួលកិច្ចការផ្សេងៗជាមួយរដ្ឋអំណាច ឬអាជ្ញាធរមូលដ្ឋាន
- ដើរតួជាអជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ច្បាប់ស្តីពីវិនិយោគទុននៃព្រះរាជាណាចក្រកម្ពុជាដែលអនុម័តថ្ងៃទី ០៤ សីហា ១៩៩៤ បានក្លាយជាឧបករណ៍ជាចាំបាច់នៃយន្តការឯកជនភាវូនីយកម្មនៃសហគ្រាសសាធារណៈ។ ច្បាប់នេះក្លាយជាក្របខ័ណ្ឌទទួលយកនូវរាល់បណ្តាវិនិយោគិនដែលអនុវត្តលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដោយវិនិយោគិនទាំងជាតិខ្មែរ និងបរទេស។ ចំពោះវិនិយោគិនបរទេស ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ជាច្រកចូលតែមួយគត់ដើម្បីសំរួលដល់ដំណើរការវិនិយោគរបស់ខ្លួន។ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជាមានសមត្ថកិច្ចទទួលបន្ទុកការងារនីតិសម្បទាអភិវឌ្ឍ និងវិនិយោគ។ស្ថាប័ននេះជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសំរេចការងារនីតិសម្បទាអភិវឌ្ឍ និងការវិនិយោគនានា។ ក្រុមប្រឹក្សានេះស្ថិតក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រី ហើយត្រូវបើកសម័យប្រជុំពេញអង្គមួយដងក្នុងមួយខែ ជាការប្រជុំសាមញ្ញ និងការប្រជុំវិសាមញ្ញអាចធ្វើឡើងតាមស្ថានភាពចាំបាច់។

**ខ-ស្ថាប័នយុត្តាធិការ**

រហូតមកទល់សព្វថ្ងៃនេះ ប្រទេសកម្ពុជាមិនទាន់បង្កើតតុលាការពាណិជ្ជកម្មនៅឡើយទេ។ រាល់បណ្តាវិវាទពាណិជ្ជកម្មត្រូវធ្លាក់ក្នុងសមត្ថកិច្ចរបស់តុលាការខេត្ត-ក្រុង។ កាលដែលប្រទេសកម្ពុជា ចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក WTO បន្ទាប់ពីបានចូលជាសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ គឺជាសញ្ញាណនៃភាពជាចាំបាច់ ខានមិនបាននៃតុលាការពាណិជ្ជកម្មនៅកម្ពុជា។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលកម្ពុជា

បច្ចុប្បន្នកំពុងបង្កើតការដ្ឋានថ្មីមួយស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ដែលមានទិសដៅចម្បងពង្រឹងសុវត្ថិភាពគតិយុត្តលើគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាសន្តិសុខដល់ការវិនិយោគទុន ដល់សកម្មភាពពាណិជ្ជកម្ម និងបង្កើតបរិយាកាសសុវត្ថិភាពក្នុងប្រទេសដល់ការធ្វើសមាហរណកម្មរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ តុលាការពាណិជ្ជកម្ម បានចាត់ទុកចូលទៅក្នុងពង្រាង ច្បាប់មួយរបស់រាជរដ្ឋាភិបាលផងដែរ ដែលនឹងត្រូវជំនុំជំរះនូវវិវាទទាំងឡាយក្នុងវិស័យពាណិជ្ជកម្ម ដែលកើតមាននៅក្នុងទឹកដីកម្ពុជាទាំងមូល ដែលតុលាការនេះ គ្រោងនឹងត្រូវដឹកនាំដោយចៅក្រមវិជ្ជាជីវៈ រួមជាមួយនឹងចៅក្រមប្រឹក្សាផងដែរ។

ដើម្បីឆ្លើយតបជាមួយនឹងកម្មវត្ថុនៃការសិក្សាទៅលើនីតិក្រុមហ៊ុននេះ ខ្ញុំបាទបានធ្វើការបែងចែកនីតិក្រុមហ៊ុននេះ ជា ០៣ ភាគ ដោយសង្ឃឹមថាអាចចូលរួមចំណែកជាគំនិត និងការគ្រប់គ្រងមជ្ឈត្តដ្ឋានការងារនៃនីតិក្រុមហ៊ុន ក្នុងគោលដៅធានាឱ្យបាននូវគោលការណ៍អន្តរនិស្សរភាពនៃអត្ថបទច្បាប់ និងការអនុវត្ត គឺ :

**ភាគទី ១: សហគ្រាសសាធារណៈ**

**ភាគទី ២: សហគ្រាសពហុជាតិ**

**ភាគទី ៣: សហគ្រាសពាណិជ្ជកម្ម**

# ភាគទី ១: សហគ្រាសសាធារណៈ

រដ្ឋបានធ្វើអន្តរាគមន៍ក្នុងសេដ្ឋកិច្ចជាយូរលង់មកហើយ ដូចជាការគ្រប់គ្រងអាជីវកម្មរ៉ែ បោះពុម្ព ឬសកម្មភាពឧស្សាហកម្មផ្សេងៗទៀត និងរដ្ឋបានពង្រាតរហូតមកដល់វិស័យធនាគារ កំពង់ផែ ក្រុមហ៊ុនប្រេង ក្រុមហ៊ុនអាកាសចរណ៍ និងក្រុមហ៊ុននាវាសមុទ្រ ជាអាទិ៍។ ក្រោយសង្គ្រាមលោកលើកទី ២ រដ្ឋបានធ្វើជាតូបនីយកម្មលើវិស័យខ្លះដូចជា ឧស្សាហកម្មរ៉ែ រោងចក្រធ្វើរថយន្ត ធនាគារកណ្ដាល ក្រុមហ៊ុនធានារ៉ាប់រង រោងចក្រអគ្គិសនី និងការផលិតឧស្ម័ន និងធ្យូងថ្ម ជាដើម។

នៅក្នុងក្របខណ្ឌសហគ្រាសសាធារណៈ ត្រូវការអន្តរាគមន៍របស់រដ្ឋ ដែលជាគោលការណ៍អន្តរា-និស្សរភាព សម្រាប់ជាច្រក ឬមធ្យោបាយសម្រាប់រដ្ឋធ្វើអន្តាគមន៍នៅលើវិស័យសេដ្ឋកិច្ច ដែលជាដង្ហើមចេញចូលរបស់រដ្ឋ នៅក្នុងការគ្រប់គ្រងស្ថេរភាពសេដ្ឋកិច្ច ការអភិវឌ្ឍន៍ និងស្ថានភាពផ្សេងៗ ដែលពាក់ព័ន្ធ ដែលតាមរយៈយើងនឹងធ្វើការសិក្សាទៅលើ សញ្ញាណទូទៅនៃសហគ្រាសសាធារណៈ និងប្រភេទនៃសហគ្រាសសាធារណៈ។

## ជំពូកទី ១: សញ្ញាណទូទៅនៃសហគ្រាសសាធារណៈ

ការបង្កើតសហគ្រាសសាធារណៈ គឺជាចំណែកមួយនៃប្រតិបត្តិការរបស់រដ្ឋនៅក្នុងក្របខណ្ឌសេដ្ឋកិច្ចជាតិ ដើម្បីរួមចំណែកការពារ និងថែរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងមីក្រូសេដ្ឋកិច្ច ក្នុងគោលដៅឱ្យមានចីរភាពនៃការអភិវឌ្ឍន៍។

នៅក្នុងក្របខណ្ឌនៃសញ្ញាណទូទៅនៃសហគ្រាសសាធារណៈ យើងធ្វើការសិក្សាទៅលើអត្ថន័យនៃសហគ្រាសសាធារណៈ សិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ និងការត្រួតពិនិត្យសហគ្រាសសាធារណៈ។

### ផ្នែកទី ១: អត្ថន័យនៃសហគ្រាសសាធារណៈ

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ដែលសហ-គ្រាសសាធារណៈមានបេសកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ នៅក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។ សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ដោយក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈ ដែលគេហៅកាត់ថា ក្រុមប្រឹក្សាភិបាល ជាអង្គការដឹកនាំខ្ពស់បំផុត នៅក្នុងសហគ្រាសាធារណៈ ហើយបំពេញមុខងារ ប្រកបដោយស្វ័យភាពបរិបូរណ៍ ហើយចំនួនសមា

ជិកនៃក្រុមប្រឹក្សាភិបាល មិនត្រូវលើសពី ០៧ នាក់ឡើយ។ មួយវិញទៀតការគ្រប់គ្រងលើគ្រប់ផ្នែករបស់សហគ្រាសសាធារណៈ ត្រូវអនុលោមតាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយសហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមរបបនៃនីតិរូម ចំពោះពន្ធ និងអាករ។ សហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួង ឬអាជ្ញាធរសាធារណៈណាមួយ អាស្រ័យលើសកម្មភាពរបស់សហគ្រាសនោះ។ សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោម :

-ការត្រួតពិនិត្យរបស់រដ្ឋ ដូចដែល មានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-ការត្រួតពិនិត្យហិរញ្ញវត្ថុ និងអធិការកិច្ចរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ

ចំណែកឯ បុគ្គលដែលធ្វើការនៅក្នុងសហគ្រាសសាធារណៈនេះត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកដែលសម្រេចដោយក្រុមប្រឹក្សា។

### កថាខណ្ឌទី ១: របបគតិយុត្តនៃសហគ្រាសសាធារណៈ

#### ក- គោលការណ៍គ្រប់គ្រងពាណិជ្ជកម្ម

បើសហគ្រាសសាធារណៈ គ្រប់គ្រងអាជីវកម្មដូចឯកជន សហគ្រាសសាធារណៈនេះត្រូវស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្ម។ ប៉ុន្តែបើសហគ្រាសនេះមានកិច្ចការចម្បង បម្រើសេវាសាធារណៈ ដោយមិនគិតពីការខាត ឬចំណេញ សហគ្រាសនេះត្រូវស្ថិតនៅក្រោម នីតិរូម។ និយាយជារួម គ្រឹះស្ថានសាធារណៈ ឧស្សាហកម្ម និងពាណិជ្ជកម្មមានលក្ខណៈដូចពាណិជ្ជករដែរ ប៉ុន្តែ គ្មានលក្ខណៈគ្រប់គ្រាន់ដូចគ្នានោះទេ ដោយសារ សហគ្រាសនេះគឺជាអង្គភាពមួយដែលគេបំបែកចេញពីរដ្ឋបាល។

#### ខ- គោលការណ៍ឯកទេសភាព

ជាការកំណត់លើសកម្មភាពរបស់សហគ្រាសសាធារណៈណា ដែលមានលក្ខណៈជាគ្រឹះស្ថានសាធារណៈ (គ្រឹះស្ថានសាធារណៈរដ្ឋបាល និងគ្រឹះស្ថានសាធារណៈមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម) ត្រូវតែគោរពជាដាច់ខាត។ ប៉ុន្តែបច្ចុប្បន្ន ការអនុវត្តនូវមានលក្ខណៈខ្វះ ចន្លោះ ដោយសារគំនិតពាណិជ្ជកម្ម និងការរកចំណេញ បានទាញគ្រឹះស្ថានទាំងនេះឱ្យពង្រីកសកម្មភាពរបស់ខ្លួន ទៅដល់វិស័យផ្សេងៗទៀត។ ឧទាហរណ៍ :

ក្រុមហ៊ុនរថភ្លើងមួយ មានភាគហ៊ុន ៨០% នៅក្នុងក្រុមហ៊ុនដឹក- ជញ្ជូនតាមផ្លូវអាកាស និង ៦០% នៅក្នុងក្រុមហ៊ុនពាណិជ្ជអន្តរជាតិ។

ការពង្រីកអាជីវកម្មបែបនេះ ជាកិច្ចមួយរំលោភគោលការណ៍ឯកភាពដើម ដែលគ្រឹះស្ថានសាធារណៈត្រូវគោរព និងត្រូវរិះរកមធ្យោបាយដើម្បីដោះស្រាយ។ នៅក្នុងគំនិតនេះ ជាគោលការណ៍ ការយកលុយកាក់របស់សហគ្រាសសាធារណៈទៅចូលហ៊ុនក្នុងក្រុមហ៊ុនឯកជន ឬក្រុមហ៊ុនចំរុះ ត្រូវមានការអនុញ្ញាតពីសភា។

### គ- គោលការណ៍នៃការគ្រប់គ្រងបុគ្គលិក

**+ការបែងចែកបុគ្គលិក ភ្នាក់ងារសាធារណៈ និងភ្នាក់ងារឯកជនៈ** ទី ១ ថ្នាក់ដឹកនាំជាភ្នាក់ងារសាធារណៈ នៅក្នុងនេះសមាជិកក្រុមប្រឹក្សាភិបាល រួមជាមួយប្រធានគណនេយ្យ(ករណីច្បាប់តម្រូវឱ្យមានគណនេយ្យករសាធារណៈ) ប៉ុន្តែភ្នាក់ងារសាធារណៈនេះ មិនមានលក្ខណៈសម្បត្តិជាមន្ត្រីរាជការនោះទេ ព្រោះលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ មិន អាចយកមកអនុវត្តចំពោះគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្មនោះទេ និងទី ២ ចំពោះមន្ត្រីរាជការ ដែលបានផ្តាច់តំណែងរបស់ខ្លួនមួយរយៈដើម្បីចូលទៅធ្វើការនៅក្នុងសហគ្រាសសាធារណៈ នៅតែរក្សាលក្ខន្តិកៈរបស់ខ្លួនដដែល ហើយមន្ត្រីទាំងនេះ មិនត្រូវចាត់ទុកជាភ្នាក់ងារឯកជននោះឡើយ។

**+សិទ្ធិ និងកាតព្វកិច្ច** : នៅក្នុងជីវភាពការងាររបស់ខ្លួន បុគ្គលិកសហគ្រាសសាធារណៈត្រូវមានសិទ្ធិដូចជា : ទី ១ *ការរៀបចំគណៈកម្មាធិការផ្ទៃក្នុងសហគ្រាស* សម្រាប់មើលការចាត់ចែងការងារទូទៅនៅក្នុងសហគ្រាសឱ្យបានសមស្របតាមច្បាប់ទម្លាប់ និងកុំឱ្យមានការរំលោភបំពាន។ គណៈកម្មាធិការនេះ ខុសពីសហជីព ដែលតំណាងតែក្រុម ឬនិន្នាការតែមួយ ដោយមានសមាជិកជាច្រើន មកពីមជ្ឈដ្ឋាននានា សម្រាប់មើលការខុសត្រូវលើរបៀបចាត់ចែងការងារនៅក្នុងសហគ្រាសទាំងមូល ជាពិសេសការងារបច្ចេកទេស និងការងារសង្គមកិច្ច និងទី ២ *ការរៀបចំកូដកម្ម* ដូចជានៅក្រុមហ៊ុនឯកជនដែរ ពីព្រោះ មានសេរីភាពពេញលេញដូនដែលមានចែងនៅក្នុងច្បាប់ ប៉ុន្តែដោយសារសហគ្រាសសាធារណៈ មានតួនាទីបម្រើសេវាសធារណៈនោះ គេបានបន្ថយសេរីភាពនេះ កុំឱ្យមានភាពទូលំទូលាយពេក ដូចជាគេបានហាមមិនឱ្យមានកូដកម្មលួចឆ្មក់ និងកូដកម្មបណ្តាក់គ្នា ពីព្រោះវានាំឱ្យមានការរំខានដល់សារធារណៈជន។ ឧទាហរណ៍ : កូដកម្មរបស់ក្រុមហ៊ុនដឹកជញ្ជូន

របស់រដ្ឋ ក្រុមហ៊ុនរថភ្លើង ជាដើម បានបង្កការលំបាកខ្លាំងណាស់ដល់សាធារណៈជន ដូននេះ គេកំណត់ឱ្យមានការបម្រើសេវាអប្បបរមាក្នុងពេលមានកូដកម្មម្ដង១ ដូចជា កូដកម្មរបស់បុគ្គលិកទទួលខុសត្រូវគ្រប់គ្រងពិនិត្យដែនអាកាស ។

**+លាភការ** : ជាធម្មតា ការកំណត់លាភការ ជាភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងក្រសួងអា-ណាព្យាបាល ប៉ុន្តែក្រោយ១មក គឺធ្វើឡើងដោយថ្នាក់ដឹកនាំសហគ្រាស និងមានការចូលរួមពីសហជីព ហេតុនេះហើយ បានជានាពេលបច្ចុប្បន្ននេះ សហគ្រាសសធារណៈច្រើនធ្វើកិច្ចព្រមព្រៀងជាប្រចាំឆ្នាំ ជាមួយសហជីព ។

**+ការចូលរួមចែកចំណែកសម្រាប់បុគ្គលិក** : បុគ្គលិកដែលធ្វើការក្នុងសហគ្រាសនីមួយ១ត្រូវមានសិទ្ធិក្នុងការទទួលផលខ្លះ ក្នុងករណីដែលសហគ្រាសរកស៊ីបានចំណេញ ។ បុគ្គលិកនៅក្នុងសហគ្រាសត្រូវ-ទទួលផលចំណេញខ្លះ ទៅតាមទំហំប្រាក់ចំណេញ ដែលសហគ្រាសរកបាននៅក្នុងមួយឆ្នាំ១ ។ ផលនេះគេមិនយកមកចែកឱ្យបុគ្គលិកភ្លាម១នោះទេ គឺគិតជាភាគហ៊ុន ហើយភាគហ៊ុននេះត្រូវរក្សាទុកនៅក្នុងក្រុមហ៊ុន យ៉ាងតិច ០៥-០៦ឆ្នាំ មុនយកមកចែកគ្នា ។

**+ទ្រព្យសម្បត្តិសហគ្រាសសាធារណៈ** : បេតិកភណ្ឌសហគ្រាសសាធារណៈ មានច្រើនសន្ទឹកជាហេតុនាំឱ្យមានចោទជាបញ្ហាគតិយុត្តសាំញ៉ាំច្រើន : ទី ១ *ប្រភពទ្រព្យសម្បត្តិ* : ទ្រព្យសម្បត្តិសាធារណៈមានប្រភពពីរ គឺទ្រព្យសម្បត្តិដែលរដ្ឋបានផ្ទេរមកឱ្យ និងទ្រព្យសម្បត្តិដែលសហគ្រាសបានទិញ ឬសង់ដោយខ្លួនឯងក្នុងពេលបង្កើតដំបូង ឬនៅពេលក្រោយ១មកទៀត ទី ២ *កម្មសិទ្ធិលើទ្រព្យសម្បត្តិ* : ទ្រព្យស្បត្តិដែលរដ្ឋបានផ្ទេរមកឱ្យសហគ្រាស ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរដ្ឋ ដូចជា រដ្ឋបានប្រគល់ផ្លូវដែកឱ្យក្រុមហ៊ុនអាជីវកម្មក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងសម្បទាន ដល់ពេលចប់កិច្ចសន្យា ឬកាលកំណត់ ត្រូវប្រគល់កមកឱ្យរដ្ឋវិញ ។ ចំណែកទ្រព្យសម្បត្តិសហគ្រាសបានទិញ ឬកសាងក្រោយពេលបង្កើតដំបូង ត្រូវទុកជាទ្រព្យសម្បត្តិផ្ទាល់របស់សហគ្រាស និងទី ៣ *សម្បត្តិជាតិ ឬសម្បត្តិផ្ទាល់របស់សហគ្រាស* : បេតិកភណ្ឌសហគ្រាសសាធារណៈ ត្រូវទុកជាសម្បត្តិជាតិសុទ្ធសាធ និងគេបានបែងចែកឱ្យដាច់ពីគ្នា រវាងទុនរបស់សហគ្រាស និងទ្រព្យសម្បត្តិដទៃទៀតដែលជាកម្មសិទ្ធិឯកជនរបស់សហគ្រាស ហើយមានលក្ខខណ្ឌពីរ ដើម្បីក្លាយជាទ្រព្យសម្បត្តិជាតិគឺ ម្ចាស់ទ្រព្យ

ជាបុគ្គលសាធារណៈ (ទោះជាមានលក្ខណៈជាក្រុមហ៊ុនចំរុះក៏ដោយ) និងទ្រព្យនេះត្រូវយកទៅប្រើប្រាស់ដើម្បីបម្រើប្រយោជន៍ទូទៅ ឬសាធារណៈ ដូចជាស្ថានីយ៍អយស្ម័យាន ឬកំពង់ផែ ជាអាទិ៍។

**+សកម្មភាព ឬ កិច្ចរបស់សហគ្រាសសាធារណ** : សហគ្រាសសាធារណៈដែលគ្រប់គ្រងសេវាសាធារណៈអាចធ្វើកិច្ចការនានា ដែលមានលក្ខណៈរដ្ឋបាល ដោយប្រើសិទ្ធិអំណាចសាធារណៈរបស់ខ្លួន។ ឧទាហរណ៍ : ក្រុមហ៊ុនរងភ្លើង អាចចេញបញ្ជាបង្ខំឱ្យអ្នកមានសត្វពាហនៈ ធ្វើរបងដើម្បីកុំឱ្យសត្វទាំងនេះឆ្លង-កាត់ ឬកិច្ចសន្យាសហគ្រាសសាធារណៈជាមួយអតិថិជន គឺជាកិច្ចសន្យាឯកជន នៅពេលមានវិវាទត្រូវយកទៅដោះស្រាយ ដោយតុលាការនៃនីតិរូម។ ចំណែកកិច្ចសន្យាដែលធ្វើជាមួយគ្រឹះស្ថានសាធារណៈ ជាគោលការណ៍ត្រូវមានលក្ខណៈជាកិច្ចសន្យារដ្ឋបាល។

## កថាខណ្ឌទី ២: ទំនាក់ទំនងរវាងសហគ្រាសសាធារណៈ និងរដ្ឋ

នៅក្នុងបរិបទនេះ មានគំនិតពីរផ្ទុយឡើងផ្ទុយគ្នា : គេចង់ឱ្យសហគ្រាសមានស្វ័យភាពគ្រប់គ្រាន់ដើម្បីធ្វើការ ដូចសហគ្រាសឯកជនដែរ។ មួយវិញទៀតគេចង់ឱ្យសហគ្រាសាធារណៈ បំពេញមុខងារ ដូចអង្គភាពរដ្ឋបាលធម្មតា និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។ បច្ចុប្បន្ននេះ ការគ្រប់គ្រងសហគ្រាសសាធារណៈ ស្ថិតនៅក្រោមការគ្រប់ក្រងរបស់រដ្ឋដដែល ប៉ុន្តែនិន្នាការសកលភាវូបនីយកម្ម បានជំរុញឱ្យមានការផ្តល់សេរីភាពខ្លះដល់សហគ្រាស ដើម្បីធ្វើការប្រកួតប្រជែង។

### ក- ការត្រួតពិនិត្យរបស់រដ្ឋ

សហគ្រាសសាធារណៈជាច្រើន ជាទូទៅរកស៊ីមិនសូវបានចំណេញនោះទេដោយតម្រូវឱ្យរដ្ឋជួយឧបត្ថម្ភដែលជាហេតុនាំឱ្យរដ្ឋត្រូវតែត្រួតពិនិត្យមើល។

**+ជំនួយហិរញ្ញវត្ថុរបស់រដ្ឋ** : សហគ្រាសសាធារណៈជាច្រើន តែងតែជួបបញ្ហា ហើយបញ្ហាធំបំផុត គឺបំណុល នេះបណ្តាលមកពីការគ្រប់គ្រងមិនល្អ ដូចជាការចំណាយច្រើនទៅលើសោធនិវត្តន៍ និងកិច្ចការដែលរដ្ឋបង្ខំឱ្យធ្វើខ្លះ។ មួយវិញទៀត រដ្ឋបានកំណត់ថ្លៃឱ្យអនុវត្ត ហើយតម្លៃនេះមានកម្រិតទាប មិនរួចសោហ៊ុយ។ ដើម្បីដោះស្រាយឱនភាពហិរញ្ញវត្ថុសហគ្រាសសាធារណៈ ភាគច្រើនរដ្ឋត្រូវខ្ចីលុយបរទេស ឬរដ្ឋឧបត្ថម្ភដោយខ្លួនឯងផ្ទាល់ ប្រសិនបើមានលទ្ធភាព។

**+ការត្រួតពិនិត្យច្រើនជាន់** : រចនាសម្ព័ន្ធគ្រឹះស្ថានសាធារណៈមានភាពសាំញ៉ាំច្រើន ដោយក្នុងនោះ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌ ០៤ ស្ថាន គឺ : ទី ១ *ការត្រួតពិនិត្យក្នុងក្របខ័ណ្ឌអាណាព្យាបាលបច្ចេកទេស* : ដោយមានក្រសួងបច្ចេកទេស ដែលជាក្រសួងអាណាព្យាបាល ហើយជាគោលការណ៍ ក្រសួងនេះមានតែមួយទេ សម្រាប់សហគ្រាសសាធារណៈនីមួយៗ។ ឧទាហរណ៍ : ក្រុមហ៊ុនរថភ្លើង កំពង់ផែស្វយ័តនានាស្ថិតនៅក្រោមអាណាព្យាបាលក្រសួងដឹកជញ្ជូន ចំណែកក្រុមហ៊ុនអគ្គីសនីត្រូវស្ថិតនៅក្រោមអាណាព្យាបាលក្រសួងឧស្សាហកម្ម។ ដើម្បីធ្វើការត្រួតពិនិត្យ បានធ្វើការចាត់តំណាងរបស់ខ្លួនដែលមានមុខងារ ជាស្នងការរបស់រដ្ឋាភិបាល ដោយមន្ត្រីរូបនេះ ត្រូវមកធ្វើជាមួយថ្នាក់ដឹកនាំសហគ្រាស និងធ្វើការនៅក្នុងក្របខ័ណ្ឌក្រុម-ប្រឹក្សាភិបាល ដោយកិច្ចការអាណាព្យាបាលមានដូចជា : បញ្ហាថវិកាសហគ្រាស លាភការបុគ្គល របបសោធ-និវត្តន៍ ការចូលហ៊ុន និងការទិញ-លក់អចលនវត្ថុ។ ស្នងការរបស់រដ្ឋាភិបាលមានអំណាច ក្នុងការជំទាស់សេចក្តី-សម្រេចរបស់ក្រុមប្រឹក្សាភិបាល ពីបញ្ហាការកម្រិតតម្លៃ ឬប្រាក់ខែបុគ្គលិក ជាអាទិ៍ ដែលការត្រួនពិនិត្យនេះជាទម្ងន់មួយ ដែលសង្កត់លើកិច្ចការសហគ្រាសមិនឱ្យដើរលឿន ដោយរដ្ឋត្រូវទទួលខុសត្រូវពីរឿងនេះ។ ទី ២ *អាណាព្យាបាលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* : ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាអ្នកដឹកនាំ ហើយសេចក្តីសម្រេចសំខាន់ៗដែលទាក់ទងនឹងថវិកាសហគ្រាស តុល្យការ ការយកលុយកាក់ទៅទិញហ៊ុនខាងក្រៅ ប្រាក់ខែបុគ្គលិកត្រូវមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រី ហើយក្រសួងចាត់តាំងអភិបាលម្នាក់ ឱ្យឃ្លាំមើលជាអចិន្ត្រៃយ៍នៃសកម្មភាពរបស់សហគ្រាស ដែលការពិនិត្យនេះមិនមែនធ្វើតែសហគ្រាសសាធារណៈប៉ុណ្ណោះនោះទេ សូម្បីក្រុមហ៊ុនចំរុះ ក៏ត្រូវត្រួតពិនិត្យមើលផងដែរ។ ទី ៣ *ការត្រួតពិនិត្យរបស់តុលាការគណនី* : ជាស្ថាប័នត្រួតពិនត្យសហ-គ្រាសសាធារណៈ ដែលខ្លួនមានតួនាទីត្រួតពិនិត្យមើលគណនីរបស់សហគ្រាសសាធារណៈទាំងអស់ និងតាមឃ្លាំមើលការវិវត្តន៍នៃសហគ្រាសសាធារណៈ ដោយឱ្យធ្វើរបាយការណ៍ ០២ ឆ្នាំ ម្តង ហើយរបាយការណ៍នេះ ត្រូវផ្សព្វផ្សាយជាសាធារណៈ។ ទី ៤ *ការត្រួតពិនិត្យរបស់សភា* : មានភារកិច្ចត្រួតពិនិត្យសហគ្រាសសាធារណៈដែលជាទ្រព្យសម្បត្តិរដ្ឋ ដើម្បីឱ្យដឹងថា ការគ្រប់គ្រងសហគ្រាសនេះ ធ្វើឡើងដើម្បីប្រយោជន៍ទូទៅ។

**ខ- ចលនាសេរីភាវូបនីយកម្ម**

សហគ្រាសសាធារណៈជាច្រើនរកស៊ីមិនសូវចំណេញនោះទេ ដូច្នេះ រដ្ឋត្រូវបំពេញឱនភាពទាំងនេះ

និងស្ថានភាពនេះរដ្ឋមានកាតព្វកិច្ចធ្វើការកំណែទម្រង់ដើម្បីធ្វើការស្តារសហគ្រាសឱ្យមានដំណើរការល្អជាងមុន តាមរយៈការផ្តល់ស្វ័យភាពហិរញ្ញវត្ថុ និងស្វ័យភាពរដ្ឋបាល ។

ទី ១ *ស្វ័យភាពហិរញ្ញវត្ថុ* : រដ្ឋមិនត្រូវលូកដៃចូលនៅក្នុងការកំណត់តម្លៃរបស់សហគ្រាស ត្រូវទុកឱ្យសហគ្រាសចាត់ចែងដោយខ្លួនឯង ទៅតាមសោហ៊ុយដែលខ្លួនបានចំណាយដើម្បីផលិតកម្ម និងរដ្ឋត្រូវទុកឱ្យសហគ្រាសនីមួយៗ ទទួលខុសត្រូវដោយខ្លួនឯងផ្នែកហិរញ្ញវត្ថុ ដោយបន្ទុករបស់សហគ្រាសសាធារណៈត្រូវនាំគ្នាជួយកាត់បន្ថយ ព្រោះ បើរដ្ឋនៅទេបញ្ហាមិនចេះចប់ នោះការចំណាយ ក៏ចេះតែកើនឡើងផងដែរ ។

ទី ២ *ស្វ័យភាពរដ្ឋបាល* :រដ្ឋ ត្រូវបន្ធូរដង្ហៀបរបស់ខ្លួនលើសហគ្រាសសាធារណៈ ដោយចាត់វិធានការណ៍ ០២ យ៉ាង :**សម្រាលការត្រួតពិនិត្យ** រដ្ឋគួរពិនិត្យមើល ក្រោយពេលអនុវត្តការងារវិញ និងគួរជៀសវាងការត្រួតពិនិត្យមើលកិច្ចការមុនពេលអនុវត្ត បើចាំបាច់ផ្តោតជាសំខាន់ទៅលើលទ្ធផលការងារវិញ ។ **រៀបចំឡើងវិញរចនាសម្ព័ន្ធត្រួតពិនិត្យ** មានរូបមន្តពីរ គឺ បញ្ចូលអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុឱ្យនៅតែមួយ ដោយរូបមន្តនេះមានគុណសម្បត្តិធ្វើឱ្យការ- ត្រួតិនិត្យមានតែមួយ មិនសាំញ៉ាំ និងស្រួលរកអ្នកទទួលខុសត្រូវ ប៉ុន្តែអង្គភាពនេះត្រូវជួបបញ្ហាធំៗពីរ :ទី ១ អង្គភាពនេះមានអំណាចខ្លាំង ត្រួតលើក្រសួងជាច្រើននាំឱ្យមានប្រតិកម្មតបតមកវិញ ឬកិច្ចការច្រើនហួសហេតុ មិនអាចធ្វើបាន ជាហេតុនាំឱ្យអ្នកដឹកនាំអង្គភាពទទួលនូវបរាជ័យ ដោយសារ មានបញ្ហាខាងលើមានរូបមន្តមួយ ដែលមានលក្ខណៈប្រាកដនិយម គឺបង្កើតនៅក្នុងផ្ទៃក្នុងក្រសួងអាណាព្យាបាលនីមួយៗ នូវនាយកដ្ឋានពិសេសមួយដែលមានមុខងារត្រួតពិនិត្យលើសហគ្រាសសាធារណៈ ។

## ផ្នែកទី ២: សិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសាធារណៈ

បន្ទាប់ពីយល់អំពីអត្ថន័យនៃសហគ្រាសសាធារណៈ វាបង្កើតនាំឱ្យសហគ្រាសសាធារណៈនោះមានសិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ។

នៅក្នុងក្របខណ្ឌ័នេះ យើងធ្វើវិចារណកិច្ចគតិយុត្តទៅលើ ភារកិច្ច និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ។

### កថាខណ្ឌទី ១: ភារកិច្ច និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានអាសនៈមួយកន្លែងសម្រាប់តំណាងនិយោជិតនៃសហគ្រាសសាធារណៈ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងចេញពីនិយោជិត និងដោយនិយោជិតរបស់សហគ្រាស។ ក្រុមប្រឹក្សាភិបាល អាចផ្ទេរឱ្យប្រធានអគ្គនាយក ឬអគ្គនាយក នូវអំណាចចំបាច់សម្រាប់ដំណើរការសហគ្រាសប្រចាំថ្ងៃ តែការផ្ទេរអំណាចនេះ មិនមែនជាការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ។ មុខងារនៃប្រធានអគ្គនាយក អគ្គនាយក ឬសមាជិកក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈមានវិសមិតភាពជាមួយមុខងារនៃសមាជិករាជរដ្ឋាភិបាល ឬសមាជិកសភា។

ក្រុមប្រឹក្សាភិបាលមានតួនាទី កំណត់ទិសដៅ និងត្រួតពិនិត្យការគ្រប់គ្រងសហគ្រាស ព្រមទាំងធានាសនិទានភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគ្រាស ហើយដើម្បីបំពេញមុខងារនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ច ជាអាទិ៍ :

-សម្រេចគម្រោងអភិវឌ្ឍន៍សហគ្រាស

-វាយតម្លៃក្នុងចន្លោះពេលមួយទៀងទាត់នូវលទ្ធផលសម្រេចបាន និងលើកវិធានការកែតម្រូវសម្រាប់អនុវត្ត

-សម្រេចគម្រោងថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគព្រមទាំងសេមាហិរញ្ញប្បទាន

-អនុម័តតុល្យការ និងគណនីគ្រប់គ្រង

-កំណត់រចនាសម្ព័ន្ធរបស់សហគ្រាស លក្ខន្តិកៈបុគ្គលិក និងរបបបៀវត្ស

-អនុម័តការដេញថ្លៃសាធារណៈ។

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិច មួយដងក្នុងរៀងរាល់ ០៣ ខែ ដើម្បីពិភាក្សា និងសម្រេចនូវបញ្ហាដែលមានចុះនៅក្នុងរបៀបវារៈ។ របៀបវារៈនេះ នឹងត្រូវបានជូនដំណឹងជាមុន យ៉ាងតិច ១០ ថ្ងៃ ដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរមានអាណាព្យាបាល ដោយក្រុមប្រឹក្សាភិបាល ត្រូវចាត់ចែងធ្វើកំណត់ហេតុនានា ឱ្យហើយ នៅក្នុងរយៈពេល ១០ ថ្ងៃបន្ទាប់ពីការប្រជុំ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហគ្រាសាធារណៈណាមួយ ក្រុមប្រឹក្សាភិបាលអាចចាត់ទុកជាបានការ លុះត្រាតែសមាជិកភាគច្រើនចូលរួម ហើយក្រុមប្រឹក្សាត្រូវសម្រេចដោយសម្លេងភាគច្រើននៃសមជិក

វត្តមាន និងនៅក្នុងករណីមានសម្លេងស្មើគ្នានោះ សម្លេងរបស់ប្រធានក្រុមប្រឹក្សាមានឧត្តមានុភាព។ ក្រុមប្រឹក្សាភិបាល ត្រូវសម្រេចយ៉ាងយូរបំផុតនៅថ្ងៃទី ៣០ ខែ កញ្ញា រៀងរាល់ឆ្នាំ នូវគម្រោងថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ ព្រមទាំងសេមាហិរញ្ញប្បទាន។ ឯកសារទាំងនេះ ត្រូវមានការទទួលយល់ព្រមពីក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល បន្ទាប់ពីការផ្តល់យោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលអតិបរមា ២ ខែ គិតចាប់ពីថ្ងៃដែលឯកសាមកដល់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ហើយក្រុមប្រឹក្សាភិបាល ត្រូវសម្រេចលើរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំ តុល្យការនិងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធនានា យ៉ាងយូរបំផុត ០៣ ខែ បន្ទាប់ពីជម្រះបញ្ជី។

## កថាខណ្ឌទី ២: ភារកិច្ចរបស់សហគ្រាសសាធារណៈ

សហគ្រាសសាធារណៈត្រូវផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនូវឯសារដែលពាក់ព័ន្ធទៅនឹង :

-កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល

-ថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ

-របាយការណ៍ស្តីពីសកម្មភាព តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ

-របាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា។

ឯកសារនីមួយៗ ដែលបានធ្វើរួចរាល់តាមកាលកំណត់ ត្រូវបញ្ជូនទៅកន្លែងទទួលក្នុងរយៈពេល មិនលើសពី ១៥ ថ្ងៃ។ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល មានរយៈពេល ០១ ខែ សម្រាប់ជំទាស់នៅក្នុងករណីចាំបាច់។ ក្រុមប្រឹក្សាភិបាលត្រូវបានផ្តល់ព័ត៌មានអំពីខ្លឹមសារនៃការជំទាស់ នៅពេលប្រជុំបន្ទាប់ដើម្បីចាត់វិធានការ។ នៅក្នុងករណីដែល ក្រុមប្រឹក្សាភិបាលមិនបានទទួលការជំទាស់របស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនោះ ក្រុមប្រឹក្សាភិបាលត្រូវបង្ហាញហេតុផល ហើយត្រូវជូនដំណឹងទៅក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលវិញ ជាបន្ទាន់។ គណនីទាំងឡាយរបស់សហគ្រាសសាធារណៈត្រូវាបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីអ្នកជំនាញគណនេយ្យ តាមលក្ខខណ្ឌ និងបែបបទដែលកំណត់ដោយអនុក្រឹត្យ។ លទ្ធកម្ម ដោយសហគ្រាសសាធារណៈ ដាច់ខាតត្រូវធ្វើឡើងដោយអនុលោមតាមការកំណត់

របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វិធានការនៃការដេញថ្លៃ ការអនុវត្ត និងការត្រួតពិនិត្យ ការដេញថ្លៃ ត្រូវបានកំណត់ដោយអនុក្រឹត្យ ។

**ផ្នែកទី ៣: ការត្រួតពិនិត្យសហគ្រាសសាធារណ:**

អត្ថន័យ សិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ គឺជាលំនាំ បង្កើតឱ្យមាននីតិបុគ្គលិលក្ខណៈចំពោះសហគ្រាសសាធារណៈ ដែលតម្រូវឱ្យមានការត្រួតពិនិត្យសហគ្រាសសាធារណៈ ។

ការត្រួតពិនិត្យសហគ្រាសាធារណៈ ត្រូវធ្វើឡើងទៅតាមលក្ខន្តិកៈទូទៅនៃសហគ្រាសាធារណៈ ដែលជាគោលការណ៍ ការត្រួតពិនិត្យសហគ្រាសាធារណៈ ត្រូវធ្វើឡើងដោយក្រសួងអាណាព្យាបាល ដែលជាស្ថាប័នរដ្ឋសម្រាប់គ្រប់គ្រងសេវាសាធារណៈ លើកលែងតែ សេវាសាធារណៈមួយចំនួន ដែលអនុញ្ញាតដោយច្បាប់ ត្រូវស្ថិតនៅក្រោមស្ថាប័នឯកជន ។

**កថាខណ្ឌទី ១: ស្ថាប័នរដ្ឋដែលគ្រប់គ្រងសេវាសាធារណ:**

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ត្រូវធ្វើការត្រួតពិនិត្យសេដ្ឋកិច្ចដល់សហគ្រាសតាមរយៈតំណាង របស់ខ្លួនដែលនៅក្នុងក្រុមប្រឹក្សា។ ការត្រួតពិនិត្យសេដ្ឋកិច្ច ត្រូវបានធ្វើឡើងដើម្បីធានាឱ្យសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលមានលក្ខណៈអនុលោមតាមទិសដៅរបស់រដ្ឋាភិបាល ឬតាមការណែនាំរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ មួយវិញទៀត ត្រូវបានដាក់ឱ្យនៅអមសហគ្រាសសាធារណៈនីមួយៗ នូវមន្ត្រីត្រួតពិនិត្យរដ្ឋ ដែលទទួលបន្ទុកខាងការងារត្រួតពិនិត្យ ជាអាទិ៍ :

-ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលមានចែងនៅក្នុងច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន

-ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

-ការតាមដានការប្រព្រឹត្តទៅ និងករអភិវឌ្ឍន៍របស់សហគ្រាស

-ប្រក្រតីភាពនៃសកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំង និងបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ តាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបាន និងកំពុងបំពេញការងារសាធារណៈ យ៉ាងតិច ០៥ ឆ្នាំ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញភារកិច្ចតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវរាយការណ៍ជូនក្រសួងឱ្យបានទៀងទាត់អំពីការបំពេញភារកិច្ចរបស់ខ្លួន។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវចូលរួមនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល មានសិទ្ធិផ្តល់យោបល់ពិគ្រោះ និងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងមហាសន្និបាតជាទៀងទាត់។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវផ្តល់យោបល់ទៅលើបញ្ហាដែលមានចុះក្នុងរបៀបវារៈ នៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងការអនុវត្តភារកិច្ចនេះ មន្ត្រីត្រួតពិនិត្យរដ្ឋអាចស្នើសុំព័ត៌មាន ឬស្វែងយល់ទៅនឹងកន្លែងអំពីឯកសារ ឬបញ្ជីទាំងអស់ដែលមាននៅក្នុងសហគ្រាស។ មន្ត្រីត្រួតពិនិត្យរដ្ឋ អាចធ្វើការជំទាស់និងចាត់វិធានការទាំងឡាយដែលខ្លួនយល់ឃើញថា ផ្ទុយនឹងច្បាប់ ឬការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់សហគ្រាស ឬរបស់រដ្ឋ ឬពមសមស្របនឹងគោលការណ៍របស់សហគ្រាស។ ការជំទាស់របស់មន្ត្រីត្រួតពិនិត្យ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាលនៅពេលប្រជុំ ឬយ៉ាងយូរបំផុតនៅក្នុងរយៈពេល ៣ថ្ងៃ " គិតតែថ្ងៃធ្វើការ" ក្រោយពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសនៃសហគ្រាស អំពីការជំទាស់របស់ខ្លួនលើការអនុវត្តសេចក្តីសម្រេច ក្នុងរយៈពេល ០៤ ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ បើសិនជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យបាល ឬអាជ្ញាធរអាណាព្យាបាល មិនបានបញ្ជាក់អំពីការជំទាស់នេះ ដោយចញ្ចបញ្ជាឱ្យលុបចោល ឬកែប្រែសេចក្តីសម្រេចទេនោះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកជាបានការ។

## កថាខណ្ឌទី ២: ស្ថាប័នឯកជនដែលគ្រប់គ្រងសេវាធាណៈ

រដ្ឋអាចប្រគល់ការគ្រប់គ្រងលើសេវាសាធារណៈណាមួយ ទៅឱ្យឯកជន( ជារូបវន្តបុគ្គល ឬនីតិបុគ្គល) ដោយឱ្យធ្វើការគ្រប់គ្រងជាប្រចាំថ្ងៃ ឬដឹកនាំការងារនានាទៅតាមកិច្ចសន្យារដ្ឋបាល។

### ក- បរិបទទូទៅនៃការប្រគល់សេវាសាធារណៈ

ការប្រគល់ការគ្រប់គ្រងសេវាសាធារណៈខ្លះទៅឱ្យឯកជគ្រប់គ្រង បានធ្វើឡើងនាពេលបច្ចុប្បន្ននេះ ខណៈពេលឱកាសនៃការពុករលួយមាននៅក្នុងមជ្ឈត្តដ្ឋានមន្ត្រីរាជការ និងអ្នកនយោបាយ :

តើការប្រកួតប្រជែងនេះ មានបែបផែនយ៉ាងណា?

ទី ១- ផ្សព្វផ្សាយជាសាធារណៈ

ទី ២- ការគ្រប់គ្រងសេវាសាធារណៈត្រូវមានរយៈពេលមួយជាកំណត់

ទី ៣- នៅក្នុងកិច្ចសន្យាសម្បទាន ត្រូវបន្ថែមតម្លៃខ្លះ ទៅតាមស្ថានភាពជាក់ស្តែង

### ខ- សម្បទានលើសេវាសាធារណៈ

កិច្ចសន្យារដ្ឋបាលមានពីរប្រភេទ : កិច្ចសន្យាលទ្ធកម្ម( ភាគីមានភារកិច្ចផ្តល់ទំនិញ ឬសេវាអ្វីមួយទៅឱ្យរដ្ឋបាលដោយយកកម្រៃ) កិច្ចសន្យាសម្បទាន( ភាគីឯកជនយកកម្រៃពីអតិថិជន ដែលប្រើសេវានោះ) ។

កិច្ចសន្យាសម្បទានមានលក្ខណៈ ០៥ យ៉ាង គួរឱ្យកត់សំគាល់ :

**+លក្ខណៈសេវាសាធារណៈ**

**+សម្បទានិកជាអ្នកទទួលខុសត្រូវ** :

**+សម្បទានិកយកចំណូលពីអតិថិជន** :

**+រដ្ឋនៅតែមានសិទ្ធិត្រួតពិនិត្យសេវាសាធារណៈ**

**+អំណាចរបស់សម្បទានិក** :

-*ការចុះកិច្ចសន្យាសម្បទាន* : កិច្ចសន្យានេះមានលក្ខណៈជាការព្រមព្រៀងរវាងរដ្ឋ និងភាគីឯកជន ដោយមានទំនុកចិត្តទៅលើគ្នាទៅវិញទៅមក ដើម្បីឱ្យសម្បទានិកធ្វើការជំនួសខ្លួន ក្នុងការបំរើសេវាសាធារណៈ ដោយសម្បទានិក ត្រូវការឱ្យភាគីម្ខាងទៀត(រដ្ឋ) ជួយជ្រោមជ្រែងខ្លួន នៅពេលមានវិវាទ ឬបញ្ហាអ្វីមួយកើតឡើង ដោយសារមានស្ថានភាពនេះ ទើបគេសន្និដ្ឋានថា កិច្ចសន្យាសម្បទាន ជាកិច្ចសន្យាមួយពិសេសក្នុងចំណោមកិច្ចសន្យារដ្ឋបាលទាំងឡាយ ។ មួយវិញទៀត **ចរិករបស់កិច្ចសន្យាសម្បទាន** មានលក្ខណៈជាកិច្ចសន្យារដ្ឋបាល ដែលតុលាកាមានសមត្ថកិច្ចគឺតុលាការរដ្ឋបាល ។

-*ខ្លឹមសារនៃកិច្ចសន្យាសម្បទាន* : សៀវភៅបន្ទុក ជាឯកសារដែលរដ្ឋបានរៀបចំឡើង ដើម្បីកំណត់នូវចំណុចជាច្រើន ដែលទាក់ទងនឹងសេវាដែលត្រូវបម្រើ ដោយសៀវភៅបន្ទុកមានច្រើនយោងតាមលក្ខណៈនៃសេវានីមួយៗ ដូចជាការដឹកជញ្ជូនសាធារណៈ ការចែកចាយទឹក-ភ្លើង ឧស្ម័ន ជាអាទិ៍ ។

បើគិតតាមផ្លូវគតិយុត្ត វាមានតម្លៃខុសគ្នា : មុនពេលចុះកិច្ចសន្យា ( ឯកសារនេះមានអានុភាពតែទៅលើភ្នាក់-ងាររដ្ឋបាលទេ ព្រោះខ្លួនត្រូវគោរពខ្លឹមសារ និងនីតិវិធីដែលមានកំណត់នៅក្នុងឯកសារ) និងក្រោយពេលចុះ-កិច្ចសន្យា( ឯកសារនេះត្រូវទុកជាចំណែកមួយនៃកិច្ចសន្យា ដែលរដ្ឋ និងសម្បទានិកត្រូវគោរពទាំងអស់គ្នា) ។ កិច្ចសន្យាសម្បទាន ជាកិច្ចសន្យាអញ្ញមញ្ញ ពោលភាគីមានកាតព្វកិច្ចទៅវិញទៅមក។ រដ្ឋផ្តល់ឱ្យសម្បទានិក នូវសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដោយអាចមានសិទ្ធិយកអាករពីអតិថិជន និងបង់ជូនរដ្ឋនូវទឹកប្រាក់ដែល មានកំណត់នៅក្នុងកិច្ចសន្យា។

-*ការអនុវត្តកិច្ចសន្យាសម្បទាន* : សម្បទានិក មានសិទ្ធិយកអាករពីប្រជាជន ការ-ធ្វើអាជីវកម្មផ្តាច់ ឬការដកហូតទ្រព្យសម្បត្តិឯកជន ដើម្បីមូលហេតុសាធារណៈ បើសិនមានកាចាំបាច់។ ចំណែករដ្ឋមានសិទ្ធិត្រួតពិនិត្យកិច្ចសន្យា ដោយមិនទុកឱ្យសម្បទានិកធ្វើតាមទំនើងចិត្តនោះឡើយ។ សមតា-ហិញ្ញវត្ថុនៃកិច្ចសន្យា : ជាធម្មតា សម្បទានិក មានលក្ខណៈសម្បត្តិជាពាណិជ្ជករ បៈសហគ្រិនឯកជន ដែលចូល គ្រប់គ្រងសេវាសាធារណៈណាមួយ ដោយសុខចិត្តទទួលខុសត្រូវលើការខាត ឬចំណេញ។ នៅក្នុងវិស័យសេវា-សាធារណៈ គោលការណ៍សំខាន់គឺអ្នកប្រើប្រាស់ទទួលបាននូវសេវាប្រើប្រាស់ជានិរន្តន៍ ហេតុនេះសម្បទានិកអាច ជួបប្រទះបញ្ហានៅក្នុងការគ្រប់គ្រងសេវា ហើយបញ្ហានេះជះឥទ្ធិពលដល់អ្នកប្រើប្រាស់ ដែសមតាហិរញ្ញវត្ថុអាច ជួបប្រទះ ដោយសារតែកត្តា ពីរ : ទី ១ រាជសក្តិ សំដៅលើអំណាចសាធារណៈ ដែលបង្កឱ្យការចំណាយរបស់ សម្បទានិកកើនឡើង ទី ២ ការមិនអាចគិតទុកជាមុន ដូចជា ព្រឹត្តការណ៍ដែលកើតឡើងភ្លាម១ ដោយគ្មាន អ្នក ដឹងមុន ជាពិសេសនៅពេលចុះកិច្ចសន្យា ( សង្គ្រាម ការបញ្ចុះតម្លៃរូបិយវត្ថុ ការឡើងថ្លៃវត្ថុធាតុដើម) និង ព្រឹត្តការណ៍ដែលកើតឡើងក្រៅឆន្ទៈគូភាគី។ ការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា នៅក្នុងកិច្ចសន្យាគេតែង តែដាក់នៅ **ខចែងមួយថា សម្បទានិកគ្រប់គ្រង រដ្ឋត្រួតពិនិត្យ** ។ តើការត្រួតពិនិត្យនេះ មានលក្ខណៈដូចម្តេច?

ទី ១ ភាពហ្មត់ចត់ : ភាគីត្រូវពិនិត្យ តាមដានកិច្ចសន្យាសម្បទាន ជាពិសេស ត្រូវពិនិត្យមើល សម្បទានិក បាន គោរពតាមសៀវភៅបន្ទុក ឬយ៉ាងណា ប៉ុន្តែរដ្ឋមិនអាចជ្រៀតជ្រែកចូលធ្វើការជំនួសបានទេ។

ទី ២ ការដាក់ទណ្ឌកម្ម : ទណ្ឌកម្មមាន ០៣ ប្រភេទ ( ពិន័យ ឬផ្អាកសកម្មភាពសម្បទានិកជាបណ្តោះអាសន្ន និង បញ្ឈប់កិច្ចសន្យាសម្បទាន) ។

-*ការបញ្ចប់កិច្ចសន្យាសម្បទាន* : មាន ០២ ប្រភេទ គឺ

ទី ១ កិច្ចសន្យារលត់តាមពេលវេលាដែលបានកំណត់ : ជាធម្មតាកិច្ចសន្យាសម្បទានមានរយៈពេលវែង សម្រាប់ឱ្យសម្បទានិកមានលទ្ធភាពអាចស្វែងរកចំណូល និងនៅពេលដល់កាលកំណត់ កិច្ចសន្យានេះត្រូវបញ្ចប់លើកលែងតែមានការបន្តដោយតុល្យភាព។ បន្ទាប់មកអចលនទ្រព្យត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ គឺស្ថាប័នសាធារណៈ ចំណែកចលនវត្ថុ សម្បទានិកអាចយកទៅតាមខ្លួន ឬលក់ទៅស្ថាប័នសាធារណៈតាមការព្រមព្រៀង។

ទី ២ ការលោះមកវិញនូវសម្បទានកម្ម : ស្ថាប័នសាធារណៈអាចទិញនូវសម្បទានកម្ម ពោលគឺសម្រេចចិត្តយកសេវាសាធារណៈមកគ្រប់គ្រងដោយខ្លួនឯងវិញ ហើយការសម្រេចនេះអាចធ្វើឡើងដោយឯកតោភាគី ដោយមិនចាំបាច់សួរទៅតុលាការនោះទេ ព្រោះកិច្ចសន្យាសម្បទាន ជាប្រភេទមួយនៃកិច្ចសន្យារដ្ឋបាល និងតែងតែមានចែងអំពី "**ខហួសប្រមាណ**"។

## ជំពូកទី ២: ប្រភេទនៃសហគ្រាសសាធារណៈ

សហគ្រាសសាធារណៈ មានទម្រង់ជា គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះ។

### ផ្នែកទី ១: គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

គ្រឹស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ចគឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ ហើយគ្រឹះស្ថាននេះ ផលិតផលទំនិញ ឬធ្វើសេវាសម្រាប់ទីផ្សារ។ គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ដោយអនុក្រឹត្យនេះកំណត់ ជាអាទិ៍ : ភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ និងវិធាននៃការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន។

គ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានដឹកនាំដោយប្រធានអគ្គនាយកមួយរូបជាប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកផង ដែលបំពេញមុខងារក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល។ តួនាទីរបស់ក្រុមប្រឹក្សាភិបាល និងអគ្គនាយកអាចញែកចេញដាច់ពីគ្នា ដោយនៅក្នុងករណីនេះ

ទីចាត់ការប្រតិបត្តិនៃគ្រឹះស្ថាន ត្រូវបានដឹកនាំដោយអគ្គនាយក។ ប្រធានអគ្គនាយក ឬអគ្គនាយកត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនៃគ្រឹះស្ថានសាធារណៈនោះ ហើយសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ក្រសួង ឬអាជ្ញាធរដែលជាសមាជិកអាចជាតំណាង និងត្រូវបានជ្រើសរើសតាមលក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦។

**ផ្នែកទី ២: ក្រុមហ៊ុនរដ្ឋ**

ក្រុមហ៊ុនរដ្ឋគឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ។ ក្រុមហ៊ុនរដ្ឋត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរមក្ខារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ដោយអនុក្រឹត្យនេះ នឹងកំណត់ ជាអាទិ៍ កម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្ត ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល។ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យបាលបច្ចេកទេស ទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយ :

-រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុន ដោយមានការព្រមព្រៀងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចាត់ចែងឈ្មោះ នៅក្នុងបញ្ជីពាណិជ្ជកម្ម

-បំពេញបែបបទទាំងអស់តាមគោលការណ៏ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។

លក្ខន្តិកៈរបស់ក្រុមហ៊ុនរដ្ឋ កំណត់ជាអាទិ៍ ចំនួនទឹកប្រាក់ ប្រភេទនៃភាគទុន ការរៀបចំរដ្ឋបាល ហិរញ្ញវត្ថុ និងវិធាននៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន។ បដិបញ្ញត្តិលើគោលការណ៏ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម អំណាចនៃមហាសន្និបាតរបស់ក្រុមហ៊ុនរដ្ឋ ត្រូវបានប្រគល់ឱ្យក្រុមប្រឹក្សា។ ភាគទុនដំបូង ព្រមទាំងការកែប្រែ ជាក្រោយនៃដើមទុនរបស់រដ្ឋ ត្រូវបានធ្វើឱ្យសម្រេចដោយអនុលោមតាម បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុជាធរមាន។ ប្រធានអគ្គនាយក ឬអគ្គនាយកក្រុមហ៊ុនរដ្ឋត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ដោយសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ក្រសួង ឬអាជ្ញាធរ

ដែលសមាជិកនោះជាតំណាង និងត្រូវបានជ្រើសរើសក្នុងលក្ខខណ្ឌដែលមានកំណត់នៅក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦។

**ផ្នែកទី ៣: ក្រុមហ៊ុនចម្រុះ**

ភាគកម្មសាធារណៈ គឺជាចំណែកនៃដើមទុនរបស់ក្រុមហ៊ុនចម្រុះ ដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬដោយក្រុមហ៊ុនរដ្ឋ។ ក្រុមហ៊ុនចម្រុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើង តាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដើមទុនត្រូវបានកាន់កាប់រួមគ្នា ដោយនីតិបុគ្គល ឬរូបវន្តបុគ្គល ឬបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ។ កាលណាភាគកម្មសាធារណៈលើសពី ៥១% នៃដើមទុន ឬសិទ្ធិបោះឆ្នោត ក្រុមហុនចម្រុះ ត្រូវបានចាត់ទុកជាគ្រឹះស្ថានសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រ៉ាប់រងខាងផ្នែករដ្ឋបាលលើភាគកម្មសាធារណៈ ហើយប្រតិបត្តិការហិរញ្ញវត្ថុអំពីភាគកម្មសាធារណៈ ត្រូវបានធ្វើឱ្យសម្រេចដោយអនុលោមតាមបញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុ ជាធរមាន។ បដិបញ្ញត្តិលើគោលការណ៍ និងបែបទទាំងឡាយនៃក្រុមហ៊ុននីតិពាណិជ្ជកម្ម រដ្ឋ គ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនរដ្ឋ ត្រូវបានលើកលែងការតម្កល់ភាគហ៊ុនធានាសម្រាប់តំណាងនៅក្នុងក្រុមប្រឹក្សាភិបាលសហគ្រាស ដែលខ្លួនបានចូលរួម។

តំណាងរបស់រដ្ឋ ឬតំណាងរបស់គ្រឹះស្ថានសាធារណៈ នៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តំណាងរបស់ក្រសួងរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននោះ ក្រោយពីមានយោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈ ឬរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះត្រូវបានជ្រើសរើសដោយផ្អែកលើគុណសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ឬពីក្នុងចំណោមមន្ត្រីរាជការ បម្រើការងារយ៉ាងតិច ០៥ ឆ្នាំ ឬចូលនិវត្តន៍ តែមានអាយុមិនលើសពី ៦៥ ឆ្នាំ ឬក្នុងចំណោមឥស្សរជនខ្មែរដែលមានសមត្ថភាពខាងសេដ្ឋកិច្ច ឬខាងនីតិសាស្ត្រ ឬខាងវិទ្យាសាស្ត្រ ដោយតំណាងទាំងនោះ អាចឱ្យរួចផុតពីការបង់ប្រាក់ធានាសម្រាប់មុខ

តំណែងនៅក្នុងក្រុមប្រឹក្សាភិបាល តែមិនត្រូវមានភាគហ៊ុននៅក្នុងសហគ្រាសឡើយ។ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់តំណាងទាំងនោះ នៅក្នុងការបំពេញភារកិច្ច នៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវធ្លាក់ទៅលើរដ្ឋ លើគ្រឹះស្ថានសាធារណៈ ឬលើក្រុមហ៊ុនរដ្ឋ តែតំណាងត្រូវទទួលខុសត្រូវដោយខ្លួនឯងខាងផ្នែកព្រហ្មទណ្ឌ។ មួយវិញទៀត មិនអនុញ្ញាតឱ្យមន្ត្រីសាធារណៈដែលធ្លាប់ធ្វើជាតំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈរបស់រដ្ឋ ឬរបស់ក្រុមហ៊ុនចម្រុះ ចូលធ្វើការនៅក្នុងមុខតំណែងណាមួយ ក្នុងសហគ្រាសដែលខ្លួនធ្លាប់ពាក់ព័ន្ធនៅមុនកាលផុតរយៈពេល ០៣ ឆ្នាំ គិតចាប់ពីថ្ងៃឈប់ធ្វើការរបស់តំណាងនោះ លើកលែងតែមានការអនុញ្ញាតពិសេស ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះទៅទៀត ត្រូវមានអាណត្តិ-គាហកៈមួយរូប តំណាងរដ្ឋនៅក្នុងមហាសន្និបាតក្រុមហ៊ុនចម្រុះ ប៉ុន្តែ អាណត្តិគាហកៈពិសេស មានវិសមិតភាពជាមួយតំណែងជាអគ្គនាយកនៃសហគ្រាសនោះ។ អាណត្តិគាហកៈពិសេស មានភារកិច្ចការពារផលប្រយោជន៍រដ្ឋនៅក្នុងមហាសន្និបាតសាមញ្ញ និងវិសាមញ្ញ ហើយមានសិទ្ធិបោះឆ្នោត ក្នុងនាមភាគីរដ្ឋ។ អាណត្តិគាហកៈពិសេស ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការ ដែលបាន និងកំពុងបម្រើការងារយ៉ាងតិច ០៥ ឆ្នាំ និងអាណត្តិគាហកៈពិសេស ត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយអាណត្តិគាហកៈពិសេស ត្រូវសុំមតិណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលចូលរួមមហាសន្និបាតរបស់ក្រុមហ៊ុនចម្រុះ។

និយាយជារួម នៅពេលយើងធ្វើការសិក្សាអំពីសហគ្រាសសាធារណៈ គេធ្វើការពិចារណាអំពី សញ្ញាណទូទៅនៃសហគ្រាសសាធារណៈ និងប្រភេទនៃសហគ្រាសសាធារណៈ។ នៅក្នុងក្របខណ្ឌនៃសញ្ញាណទូទៅនៃសហគ្រាសសាធារណៈ ចំណុចជាសារវន្ត ដែលត្រូវធ្វើការធ្វើវិចារណកិច្ចគតិយុត្តនោះគឺ អត្ថន័យនៃសហគ្រាសសាធារណៈ សិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ និងការត្រួតពិនិត្យសហគ្រាសសាធារណៈ ដោយនៅក្នុងបរិបទនៃអត្ថន័យសហគ្រាសសាធារណៈ ត្រូវបានពន្យល់ថាជា សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ដែលសហគ្រាសសាធារណៈមានបេសកម្មបង្កលក្ខណៈ ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ នៅក្នុងការបង្កើន តម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។ សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ដោយក្រុមប្រឹក្សាភិបាលសហគ្រាស

សាធារណៈ ដែលគេហៅកាត់ថា ក្រុមប្រឹក្សាភិបាល ជាអង្គការដឹកនាំ ខ្ពស់បំផុត នៅក្នុងសហគ្រាសសាធារណៈ ហើយបំពេញមុខងារ ប្រកបដោយស្វ័យភាពបរិបូរណ៍ ហើយចំនួនសមា ជិកនៃក្រុមប្រឹក្សាភិបាល មិនត្រូវលើស ពី ០៧ នាក់ឡើយ។ រីឯសិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ គឺធ្វើការបរិយាយអំពីភារកិច្ច និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលតាមរយៈនេះ សហគ្រាសសាធារណៈ មានភារកិច្ចធ្វើ កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល ថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ របាយ-ការណ៍ស្តីពីសកម្មភាពតុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ របាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា។ មួយវិញទៀត ការត្រួតពិនិត្យសហគ្រាសសាធារណៈ ផ្តោតជាសំខាន់ទៅលើ ស្ថាប័នរដ្ឋដែលគ្រប់គ្រងសេវាសាធារណៈ និងស្ថាប័នឯកជនដែលគ្រប់សេវាសាធារណៈ ដែលនៅក្នុងក្របខណ្ឌនេះ ស្ថាប័នរដ្ឋដែលគ្រប់គ្រងសេវានេះ ត្រូវធ្វើការមួយចំនួន ដូចជា ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលមានចែងនៅក្នុងច្បាប់ និងបទបញ្ញត្តិទាំងឡាយ ជាធរមាន , ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល, ការតាមដានការប្រព្រឹត្តទៅ និងករអភិវឌ្ឍន៍របស់សហគ្រាស,ប្រក្រតីភាពនៃសកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស ហើយស្ថាប័នឯកជនដែលគ្រប់គ្រងសេវានេះ អាចធ្វើទៅលើសេវាមួយចំនួនដូចជា :បរិបទទូទៅនៃការប្រគល់សេវាសាធារណៈ( ទី ១- ផ្សព្វផ្សាយជាសាធារណៈ ទី ២- ការគ្រប់គ្រងសេវាសាធារណៈត្រូវមានរយៈពេលមួយជាកំណត់ និងទី ៣- នៅក្នុងកិច្ចសន្យាសម្បទាន ត្រូវបន្ថែមតម្លៃខ្លះ ទៅតាមស្ថានភាពជាក់ស្តែង) និងសម្បទានលើសេវាសាធារណៈត្រូវមានស្ថានភាពជា( លក្ខណៈសេវាសាធារណៈ សម្បទានិកជាអ្នកទទួលខុសត្រូវ សម្បទានិកយកចំណូលពីអតិថិជន រដ្ឋនៅតែមានសិទ្ធិត្រួតពិនិត្យសេវាសាធារណៈ និងអំណាចរបស់សម្បទានិកត្រូវបានកម្រិត ដោយខហួសប្រមាណ) ។

លើសពីនេះទៅទៀត ប្រភេទនៃសហគ្រាសសាធាណៈត្រូវបានបែងចែកជា ០៣ ផ្នែក គឺគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះ។ ចាប់ផ្តើមពីចំណុចនេះ គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច គឺជាគ្រឹស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ចគឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ ហើយគ្រឹះស្ថាននេះ ផលិតផលទំនិញ ឬធ្វើសេវាសម្រាប់ទីផ្សារ។ គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ និងក្រសួង អាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ដោយអនុក្រឹត្យនេះកំណត់ ជាអាទិ៍ : ភារកិច្ច ដើមទុន ក្រសួង អាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ និងវិធាននៃការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន។ រីឯក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុន ទាំងអស់ជារបស់រដ្ឋ។ ក្រុមហ៊ុនរដ្ឋត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ដោយអនុក្រឹត្យនេះ នឹងកំណត់ ជាអាទិ៍ កម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្ត ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែល ត្រូវអនុវត្ត និងសមាសភាពក្រុមប្រឹក្សាភិបាល។ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យបាលបច្ចេកទេស ទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយ រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុនដោយមានការ ព្រមព្រៀងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាត់ចែងឈ្មោះ នៅក្នុងបញ្ជីពាណិជ្ជកម្ម និងបំពេញបែបបទ ទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។ ដោយឡែកក្រុមហ៊ុនចម្រុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើង តាម គោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដើមទុនត្រូវបានកាន់កាប់រួមគ្នា ដោយនីតិបុគ្គល ឬរូបវន្តបុគ្គល ឬបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ។ កាលណាភាគកម្មសាធារណៈលើសពី ៥១% នៃដើមទុន ឬសិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះ ត្រូវបានចាត់ទុកជា គ្រឹះស្ថានសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រ៉ាប់រងខាងផ្នែករដ្ឋបាលលើភាគកម្មសាធារណៈ ហើយ ប្រតិបត្តិការហិរញ្ញវត្ថុអំពីភាគកម្មសាធារណៈ ត្រូវបានធ្វើឱ្យសម្រេចដោយអនុលោមតាមបញ្ញត្តិដែលមានចែង នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុ ជាធរមាន។ បដិបញ្ញត្តិលើគោលការណ៍ និងបែបបទ ទាំងឡាយនៃក្រុមហ៊ុននីតិពាណិជ្ជកម្ម រដ្ឋ គ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនរដ្ឋ ត្រូវបានលើកលែងការតម្កល់ ភាគហ៊ុនធានាសម្រាប់តំណាងនៅក្នុងក្រុមប្រឹក្សាភិបាលសហគ្រាស ដែលខ្លួនបានចូលរួម។/

# ភាគទី ២: សហគ្រាសពហុជាតិ

នៅពេលធ្វើការសិក្សាអំពីសហគ្រាសពហុជាតិ យើងត្រូវធ្វើការប្រមើលមើលអំពីបញ្ហាពាក់ព័ន្ធ ដែលជាមូលដ្ឋាននៃគំនិតក្នុងការពិចារណា ដែលជាប្រភពនៃមូលហេតុគតិយុត្ត។

នៅក្នុងក្របខណ្ឌនេះ សហគ្រាសពហុជាតិត្រូវសិក្សាទៅលើវដ្តនៃដំណើរការរបស់ខ្លួន ដែលស្តែងចេញតាមរយៈ ការបង្កើតសហគ្រាសពហុជាតិ ដំណើរការសហគ្រាសពហុជាតិ និងការរំលាយសហគ្រាសពហុជាតិ។

## ជំពូកទី ១: ការបង្កើតសហគ្រាសពហុជាតិ

នៅពេលធ្វើការចាប់ផ្តើមបង្កើតក្រុមហ៊ុន បញ្ហាដែលពាក់ព័ន្ធមួយចំនួន ដែលជាមូលដ្ឋាននៃដំណើរការ ឬការបង្កើត នាំឱ្យកកើតនូវគំនិតស្តីពីការបង្កើតក្រុមហ៊ុន ឬសហគ្រាសពហុជាតិ ដែលមានលក្ខណៈពិសេសជាងក្រុមហ៊ុនធម្មតា ដែលគប្បីធ្វើការពិចារណា។

សកម្មភាពនៃការបង្កើតនេះ ត្រូវធ្វើការសិក្សាទៅលើសារធាតុនៃសហគ្រាសពហុជាតិ និងសណ្ឋាននៃសហគ្រាសពហុជាតិ។

### ផ្នែកទី ១: សារធាតុនៃសហគ្រាសពហុជាតិ

ការកកើតឡើងនូវសហគ្រាសពហុជាតិ គឺជាការពិចារណាអំពីហេតុផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ក្រុមហ៊ុននោះ ដើម្បីធ្វើការពិចារណា ថាតើមានចំណុចណាខ្លះ ដែលជាមូលដ្ឋាននៃសកលភាពនៃការកកើត។

នៅពេលធ្វើការសិក្សាទៅលើក្របខណ្ឌនៃសារធាតុនៃសហគ្រាសពហុជាតិ យើងត្រូវធ្វើការពិចារណាទៅលើអត្ថន័យ លក្ខណៈសំគាល់សហគ្រាសពហុជាតិ និងរចានសម្ព័ន្ធនៃសហគ្រាសពហុជាតិ។

#### កថាខណ្ឌទី ១: អត្ថន័យ

សហគ្រាសពហុជាតិមានលក្ខណៈខុសប្លែកគ្នាបន្តិចបន្តួចទៅតាមប្រភពផ្សេងៗ។ ក្រុមហ៊ុន Microsoft បានឱ្យអត្ថន័យនៃសហគ្រាសពហុជាតិថា ជាសហគ្រាសដែលមានសាខាជាអ្នកផលិត-លក់ និងផ្តល់សេវានៅក្នុងប្រទេសមួយ ឬច្រើន។ សហគ្រាសពហុជាតិធ្វើការកែច្នៃ និងបង្កើតទំនិញថ្មីៗ នៅក្នុងប្រទេសដើមកំណើតរបស់ខ្លួនរួចធ្វើការផលិតនៅបរទេស។ ប៉ុន្តែយោងតាមអត្ថន័យរបស់រាជរដ្ឋាភិបាលនៃបណ្តារដ្ឋសមាជិកអង្គការសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍន៍(OECD)សហគ្រាសពហុជាតិ ជាបណ្តាក្រុមហ៊ុនដែលនៅក្នុងនោះ

មានក្រុមហ៊ុនផ្សេងៗ ដែលអាចជាកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិរបស់រដ្ឋ ឬជាកម្មសិទ្ធិរួមគ្នារវាងរដ្ឋ និងឯកជន។ ក្រុមហ៊ុនទាំងនេះមាននៅតាមបណ្ដាប្រទេសផ្សេងៗគ្នា និងមានទំនាក់ទំនងជាមួយក្រុមហ៊ុនមួយ ឬច្រើន ដែលមានឥទ្ធិពលទៅលើក្រុមហ៊ុនមួយទៀត។

ទោះបីការឱ្យអត្ថន័យចំពោះសហគ្រាសពហុជាតិ មានភាពខុសគ្នាបន្តិចបន្តួច យើងឃើញថា សហគ្រាសពហុជាតិមានលក្ខៈសំគាល់ ជារួមគឺ :

-លក្ខណៈនៃភាពជាម្ចាស់ : ភាពជាម្ចាស់ត្រូវបានគេទទួលស្គាល់ថា ជាលក្ខខណ្ឌដែលបង្កើតឱ្យមានសហគ្រាសពហុជាតិ។ ក្រុមហ៊ុនមួយ ក្លាយទៅជាសហគ្រាសពហុជាតិ នៅពេលដែលទីស្នាក់ការធំ ឬក្រុមហ៊ុនដើម ជារបស់ប្រទេស ០២ ឬច្រើន។ ឧទាហរណ៏ : ក្រុមហ៊ុន Shell និង Uniliver ដែលត្រូវគ្រប់គ្រងដោយ ប្រទេស អង់គ្លេស និង ប្រទេសអាឡឺមង់ ជាអាទិ៏។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពជាក់ស្ដែង មានសហគ្រាសពហុជាតិតែមួយចំនួនប៉ុណ្ណោះ ដែលជាក្រុមហ៊ុនរបស់ប្រទេស ០២ ឬច្រើន មានន័យថា ភាពជាម្ចាស់មិនមានលក្ខណៈចម្បងនោះទេ។

-ភាពចម្រុះជាតិសាសន៏នៃអ្នកគ្រប់គ្រង : មតិខ្លះបានលើកឡើងពីភាពចម្រុះជាតិសាសន៏ នៃអ្នកគ្រប់គ្រងសំខាន់ៗ ដែលជាផ្នែកសារវ័ន្តបង្កើតឱ្យមានក្រមហ៊ុននេះ។

-វិធីសាស្ត្រនៃមុខជំនួយ : សហគ្រាសពហុជាតិអាចជា ក្រុមហ៊ុនដែលផ្ដោតខ្លាំងទៅលើប្រទេសកំណើត ឬប្រទេសស្នាក់អាស្រ័យ ឬមានទីតាំងពាសពេញពិភពលោក ដោយក្រុមហ៊ុនទាំងនេះ ទី ១ ភ្ជាប់ខ្លួននៅក្នុងផលិតកម្មបរទេសតាមរយៈបណ្ដាញរបស់ខ្លួន ដែលមានទីតាំងនៅបណ្ដាប្រទេសផ្សេងៗ ទី ២ ធ្វើការពិនិត្យដោយផ្ទាល់ទៅលើគោលការណ៏នៃបណ្ដាញរបស់ខ្លួន និងទី ៣ អនុវត្តវិធីសាស្ត្រធ្វើជំនួយ តាមរយៈផលិតកម្ម ទីផ្សារហិរញ្ញវត្ថុ និងការជ្រើសរើសបុគ្គលិកដែលមានលក្ខណៈជឿនលឿន។

**កថាខណ្ឌទី ២: លក្ខណៈសំគាល់សហគ្រាសហុជាតិ**

លក្ខណៈសំគាល់សហគ្រាសពហុជាតិ ត្រូវត្រួតពិនិត្យទៅលើលក្ខណៈ ០៤ យ៉ាង :

-ប្រព័ន្ធនៃការគ្រប់គ្រង : សំដៅទៅលើចំនួនប្រទេសដែលសហគ្រាសពហុជាតិដំណើរការនៃមុខជំនួញព្រមទាំងភាពជាកម្មសិទ្ធិនៃកម្មវត្ថុពាណិជ្ជកម្ម។ ចំពោះសហគ្រាសពហុជាតិភាគច្រើន ម្ចាស់កម្មសិទ្ធិជាប្រទេស

ដែលមានទីស្នាក់ការកណ្តាល និងអាចមានដាក់ភាគហ៊ុននៅតាមបណ្តាប្រទេសផ្សេងៗ។ ឧទាហរណ៍ ក្រុមហ៊ុន (British American Tobacco) ដែលមានទីស្នាក់ការនៅទីក្រុង London នៃប្រទេសអង់គ្លេស និងមានសាខាជាង ១៨០ ប្រទេស ជុំវិញពិភពលោក ដែលនៅក្នុងនោះមាននៅព្រះរាជាណាចក្រកម្ពុជា ផងដែរ។

-ការមើលឃើញជារួម : ជាការមើលឃើញជាទូទៅចំពោះសហគ្រាសពហុជាតិទៅលើភាគរយនៃចំណូល ឬប្រាក់ចំណេញប្រចាំឆ្នាំ និងកម្មសិទ្ធិផ្សេងៗ ព្រមទាំងនិយោជិតដែលមានសញ្ជាតិបទេសជាដើម។ ឧទាហរណ៍ : ក្រុមហ៊ុន Nestlé មាន ៩៨% នៃមុខជំនួញរបស់ខ្លួន ស្ថិតនៅបរទេស Hoffman La Roche មាន ៩៦% ក្រុមហ៊ុន Michelin មាន ៧៨% ក្រុមហ៊ុន Sony មាន ៦៦% និងក្រុមហ៊ុន Gillette មាន ៦៥% ជាអាទិ៍។

-អត្តចរិកក្រុមហ៊ុន : សំដៅលើភាពចម្រុះជាតិសាសន៍នៃអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងរង្វង់ក្រុមហ៊ុនអន្តរជាតិ ហើយសហគ្រាសពហុជាតិរបស់សហគមន៍អឺរ៉ុប ភាគច្រើនមានថ្នាក់ដឹកនាំសញ្ជាតិបរទេស រីឯសហរដ្ឋអាមេរិក ជាប្រទេសដែលមានលក្ខណៈលើកលែង ព្រោះថ្នាក់ដឹកនាំជាន់ខ្ពស់ភាគច្រើន មានសញ្ជាតិអាមេរិកតែម្តង។

-ការសម្របសម្រួល : សំដៅទៅលើក្រុមហ៊ុនមួយ ដែលរបៀបនៃការគ្រប់គ្រងជំនួញរបស់ខ្លួន មាន ០២ របៀប គឺ Multiple-domestic និង Global ។ Multiple-domestic គឺជាប្រភេទក្រុមហ៊ុនដែលសម្របខ្លួនទៅតាមទីផ្សារផ្សេងៗគ្នា ដែលបង្ហាយយ៉ាងជាក់លាក់ពីបណ្តុំសាខា ជាច្រើនរបស់ក្រុមហ៊ុននោះ។ រីឯ ក្រុមហ៊ុន Global គឺជាក្រុមហ៊ុនបង្កើតជាផលិតផលស្តង់ដារ សម្រាប់គ្រប់គ្រងប្រទេស ដែលចាត់ទុករាល់បណ្តាប្រទេសលើពិភពលោក ជាទីផ្សារតែមួយ និងមិនសម្របផលិតផលរបស់ខ្លួន ទៅតាមសារធាតុផ្សេងៗគ្នានៃប្រទេសនោះឡើយ។

**កថាខណ្ឌទី ៣: រចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ**

រចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ ពុំដូចគ្នាឡើយ ដែលវាប្រែប្រួលពីសហគ្រាសពហុជាតិមួយ ទៅជាសហគ្រាសពហុជាតិមួយទៀត ហើយគេធ្វើការពិចារណាទៅលើរចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ ទៅលើលក្ខណៈ ០៤ យ៉ាង :

-ប្រភេទនៃទីផ្សារ ដែលសហគ្រាសពហុជាតិបណ្តាក់ទុន

-ការប្រកួតប្រជែងលើទីផ្សារ ដែលត្រូវជ្រើសរើស

-ប្រភេទផលិតផល ឬទំនិញ ឬសេវា ដែលត្រូវបានបណ្តាក់ទុនដោយសហគ្រាសពហុជាតិ

-តម្រូវការ ដែលឈានទៅដល់ផលិតផលទំនិញ ឬសេវា

សហគ្រាសពហុជាតិខ្នាតធំ ភាគច្រើនកំពុងដកខ្លួនចេញពីរចនាសម្ព័ន្ធក្រុមហ៊ុន ដែលមានភាពមជ្ឈការ ឬវិមជ្ឈការពេក ហើយងាកទៅរកការបន្ទុបន្ថយ ដែលឆ្លើយតបទៅនឹងទីផ្សារ ដែលមានលក្ខណៈប្រកួតប្រជែងខ្លាំង នាំឱ្យក្រុមហ៊ុនភាគច្រើន ឈានទៅរកការហ្វឹកហ្វឺនចំពោះបុគ្គលិក និងគ្រប់គ្រងទៅលើមុខតំណែងសំខាន់ទៅតាមជំនាញរៀង១ខ្លួន ដូចជាផ្នែកទីផ្សារ ផ្នែកហិរញ្ញវត្ថុ ផ្នែកផលិតកម្ម ឬបច្ចេកវិទ្យា ជាអាទិ៍។ មុនពេលជ្រើសរើន នូវរចនាសម្ព័ន្ធណាមួយ សហគ្រាសពហុជាតិចោទសួរខ្លួនឯងថា តើក្រុមហ៊ុនត្រូវជ្រើសរើសគោលការណ៍តាមបែប មជ្ឈការ ឬវិមជ្ឈការ។ ដំណោះស្រាយសម្រាប់សំណួរនេះ គឺជ្រើសរើសគោលការណ៍តាមបែបមជ្ឈការចំពោះរាល់បញ្ហាទាក់ទងនឹងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងវិមជ្ឈការចំពោះបញ្ហា ឬកិច្ចការ ដែលមានភាពដាច់ដោយឡែក ដោយមិនប៉ះពាល់ដល់ផ្នែកផ្សេង១។ ក្នុងការជ្រើសរីសរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ក៏ត្រូវទទួលឥទ្ធិពលពីបរិស្ថានច្បាប់នៅក្នុងបណ្តានៃប្រទេសបណ្តាក់ទុន និងចំពោះប្រទេសមួយចំនួនតម្រូវឱ្យក្រុមហ៊ុនបង្កើតនូវ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាដើម ដែលជាកត្តាផ្នែកច្បាប់ក្នុងស្រុក ក៏ជះឥទ្ធិពលលើការជ្រើសរើសនូវរចនាសម្ព័ន្ធសហគ្រាសពហុជាតិ ផងដែរ។

### ផ្នែកទី ២: សណ្ឋាននៃសហគ្រាសពហុជាតិ

នៅក្នុងបែបទនៃដំណើរការនៃសហគ្រាសពហុជាតិ ទាមទារឱ្យមានបែបទ និងសណ្ឋានផ្សេង១ ដែលជាសណ្ឋាននៃសហគ្រាសពហុជាតិ។

នៅក្នុងក្របខណ្ឌនេះ សណ្ឋាននៃសហគ្រាសពហុជាតិ ខ្ញុំធ្វើការពិចារណាទៅលើ ជម្រើសនៃសហគ្រាសពហុជាតិ មូលហេតុនៃការបណ្តាក់ទុននៅបរទេស រូបភាពនៃការបណ្តាក់ទុនរបស់សហគ្រាសពហុជាតិ សញ្ជាតិនៃសហគ្រាសពហុជាតិ និងការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា។

#### កថាខណ្ឌទី ១: ជម្រើសនៃសហគ្រាសពហុជាតិ

នៅក្នុងប្រតិបត្តិការនៃកិច្ចការសហគ្រាសពហុជាតិ បង្កើតឱ្យមានច្រើនសណ្ឋាននៃការជ្រើសរើស ហើយ

រាល់សណ្ឋានទីមួយៗ នឹងផ្តល់នូវអត្ថប្រយោជន៍ និងកាតព្វកិច្ចព្រមទាំងការទទួលខុសត្រូវផ្សេងគ្នា ដោយសហគ្រាសពហុជាតិមានសណ្ឋានដូចតទៅ ៖

-ក្រុមហ៊ុនពាណិជ្ជកម្មតែម្នាក់ឯង Sole Trader or sole proprietershtip

-ក្រុមហ៊ុនសហកម្មសិទ្ធិ Partnerships

-ក្រុមហ៊ុនសាជីវកម្ម Incorporate

-ក្រុមហ៊ុនពាណិជ្ជកម្មទទួលភារៈគ្រប់គ្រង Trading Trusts

-ក្រុមហ៊ុនឯកភាពទទួលភារៈគ្រប់គ្រង Unit Trusts

-ក្រុមហ៊ុន Franchise

-ក្រុមហ៊ុនផ្សេងៗ ដែលជាទម្រង់ក្រុមហ៊ុនក្នុងស្រុក ... ជាអាទិ៍

ដោយយល់ឃើញពីសារៈប្រយោជន៍ផ្សេងៗនៃប្រភេទនីមួយៗ សហគ្រាសពហុជាតិអាចធ្វើប្រតិបត្តិការទៅតាមចំណូលចិត្ត និងលទ្ធភាពរបស់ខ្លួន។ ទោះបីជា សហគ្រាសពហុជាតិមានការបែប្រួលពីសណ្ឋាននីមួយៗក៏ដោយ រូបភាពរួមនៃក្រុមហ៊ុនពុំខុសគ្នាឡើយ លើកលែងតែមានការប្រែប្រួលទំហំនៃក្រុមហ៊ុន។ រូបភាពទូទៅនៃសហគ្រាសពហុជាតិ គឺការគ្រប់គ្រងតាមឋានានុក្រម ចំពោះក្រុមហ៊ុនរបស់ខ្លួន នៅតាមបណ្តាប្រទេសនានាលើពិភពលោក ដែលការគ្រប់គ្រងមានការបែងចែកទៅតាមតំបន់ដែលជាទីតាំងកណ្តាលនៃប្លុកប្រទេសមួយចំនួន ដែលនេះធ្វើឱ្យមានប្រសិទ្ធភាពនៅក្នុងដំណើរការក្រុមហ៊ុន។

| | សហគ្រាសឯកបុគ្គល | ក្រុមហ៊ុនសហកម្មសិទ្ធិ | ក្រុមហ៊ុនមូលធន | ក្រុមហ៊ុនចម្រុះ | ក្រុមហ៊ុនទទួលការគ្រប់គ្រង | ក្រុមហ៊ុនឯកភាពទទួលការគ្រប់គ្រង | ក្រុមហ៊ុនទទួលសិទ្ធិប្រើយីហោ |
|---|---|---|---|---|---|---|---|
| ១.ការបង្កើត | ពុំមានការព្រមព្រៀង | មានការព្រមព្រៀង | តាមច្បាប់ | តាមការព្រមព្រៀង | លិខិតប្រគល់សិទ្ធិ | លិខិតប្រគល់សិទ្ធិ | |
| ២.អ្នកចូលរួម | មួយ | ពីរ ឬច្រើន | មួយ ឬច្រើន | ពីរ ឬច្រើន | អាណត្តិទាយក អ្នកតំណាង ១ ឬច្រើន អត្ថគាហក ១ ឬច្រើន | អាណត្តិទាយក អ្នកតំណាង ១ ឬច្រើន អត្ថគាហក ១ ឬច្រើន | ពីរ ឬច្រើន |
| ៣.ការប្រើប្រាស់ | តាមច្បាប់ | ឈ្មោះនៃក្រុមហ៊ុនសហកម្មសិទ្ធិ | តាមច្បាប់ | ពុំចាំបាច់ | ជម្រើសរបស់អត្ថគាហកៈ | ជម្រើសរបស់អាណត្តិទាយក | ឈ្មោះក្រុមហ៊ុនដើម ដែលជាម្ចាស់ផ្លាកយីហោ |
| ៤.ដើមទុន | ម្ចាស់ក្រុមហ៊ុន | សហកម្មសិទ្ធករ និងម្ចាស់កម្មសិទ្ធិករអកម្ម | ម្ចាស់ភាគហ៊ុន | ភាគនៃការព្រមព្រៀង | អាណត្តិទាយក | អត្ថគាហកៈ | ក្រុមហ៊ុនទទួលសិទ្ធិប្រើប្រាស់យីហោ |
| ៥.កម្មសិទ្ធិលើទ្រព្យ | កម្មសិទ្ធិម្ចាស់ក្រុមហ៊ុន | កម្មសិទ្ធិរួមជាមួយសហកម្មសិទ្ធិករ | កម្មសិទ្ធិរបស់ក្រុមហ៊ុន | កម្មសិទ្ធិដោយឡែក | ការកាន់កាប់ដោយអ្នកតំណាង | អត្ថគាហកៈរួមគ្នា | កម្មសិទ្ធិរបស់ក្រុមហ៊ុនប្រើប្រាស់យីហោ |
| ៦.ការគ្រប់គ្រង | ផ្ទាល់ខ្លួន | ការព្រមព្រៀង | នាយកគ្រប់គ្រង | ព្រមព្រៀម | អ្នកតំណាង | ស្ថាបនិក | គ្រប់គ្រងដោយក្រុមហ៊ុនទទួលសិទ្ធិ |
| ៧.ការទទួលខុសត្រូវ | ម្ចាស់ក្រុមហ៊ុនទាំងស្រុង | សហកម្មសិទ្ធិករទាំងអស់ | ទទួលខុសត្រូវចំពោះបំណុល | សមាជិកក្រុមហ៊ុនទទួលខុសត្រូវ | ទទួលខុសត្រូវដោយអ្នកតំណាង | អត្ថគាហកៈ | ក្រុមហ៊ុនទទួលសិទ្ធិប្រើប្រាស់យីហោ |
| ៨.ការរំលាយក្រុមហ៊ុន | ក្ស័យធន | មរណភាពនៃសហកម្មសិទ្ធិករណាម្នាក់ | តាមច្បាប់ | តាមច្បាប់ | លិខិតប្រគល់កម្មសិទ្ធិ | លិខិតប្រគល់កម្មសិទ្ធិ | ការព្រមព្រៀង |

ឧទាហរណ៍:តារាងខាងក្រោមបង្ហាញរូបភាពនៃក្រុមហ៊ុនMaklelingLtd.




តាមរយៈតារាងក្រុមហ៊ុន Makleling Ltd. គឺជាសហគ្រាសពហុជាតិ ដែលមានសញ្ជាតិអាមេរិចកាំង និងមានទីស្នាក់កណ្តាលនៅរដ្ឋ Ohio នៃសហរដ្ឋអាមេរិក ដោយក្រុមហ៊ុនMakleling Ltd. មានទីស្នាក់ការតំបន់របស់ខ្លួន ០៣ គឺ Makleling-Singapore, Makleling-Malayia, Makleling-Australia ដែលទីស្នាក់ការទាំងបីគឺជាខ្សែផ្ទាល់នៃក្រុមហ៊ុនដើម និងជាក្រុមហ៊ុនដែលត្រួតពិនិត្យបន្តទៅតាមបណ្តាក្រុមហ៊ុន Makleling Ltd. នៅក្នុងប្រទេសដទៃ ទៅតាមតំបន់របស់ខ្លួន ប៉ុន្តែ អ្នកគ្រប់គ្រង គឺ Ohio សហរដ្ឋអាមេរិក ។

## កថាខណ្ឌទី ២: មូលហេតុនៃការបណ្តាក់ទុននៅបរទេស

សហគ្រាសពហុជាតិ ធ្វើការជ្រើសរើសការបណ្តាក់ទុននៅបរទេសចំពោះប្រទេសមួយចំនួន ដែលក្រុមហ៊ុនសិក្សា ឃើញថានឹងផ្តល់ប្រាក់ចំណេញដល់ក្រុមហ៊ុនច្រើនជាងគេ ប្រៀបនឹងបណ្តាប្រទេសផ្សេងទៀត ដែលការងារ ងាកទៅរកការបណ្តាក់ទុននៅបទេសគឺជាផ្លែការនៃគំរោងអ្នកគ្រប់គ្រងផ្សេងៗនៅក្នុងក្រុមហ៊ុន :

-ឈានទៅដល់កម្រិតនៃការជោគជ័យនៃទីផ្សារ

-ការប្រកួតប្រជែងនៃទីផ្សារ ដែលជាដៃគូរប្រកួតប្រជែង

-កាត់បន្ថយចំណាយ ដោយសហគ្រាសពហុជាតិកាត់បន្ថយទៅតាមតម្លៃពលកម្ម និងពន្ធដារ

-ទប់ស្កាត់ការនាំចូលនៅក្នុងប្រទេសដើមកំណើត តាមរយៈការបង្កើតសាខា ព្រមទាំងទប់ស្កាត់ការរីកដុះដាលទីផ្សារ ចំពោះទំនិញ គូប្រកួតប្រជែងលើទំនិញនាំចេញរបស់ខ្លួន ទៅកាន់ប្រទេសទទួលទំនិញនាំចូល។

**កថាខណ្ឌទី ៣:រូបភាពនៃការបណ្តាក់ទុនរបស់សហគ្រាសពហុជាតិ**

ការបណ្តាក់ទុននៃសហគ្រាសពហុជាតិនៅបរទេស អាចកើតឡើងក្នុងរូបភាព ០៣ យ៉ាងគឺ :

-ការិយាល័យតំណាងពាណិជ្ជកម្ម

-សាខាសហគ្រាសពាណិជ្ជកម្ម

-បុត្រសម្ព័ន្ធ

**កថាខណ្ឌទី ៤: សញ្ជាតិសហគ្រាសពហុជាតិ**

ការកំណត់សញ្ជាតិសហគ្រាសពហុជាតិពុំមានលក្ខណៈខុសគ្នា ទៅតាមប្រទេសនីមួយៗនោះឡើយ ដោយសារ សហគ្រាសពហុជាតិនៅតាមបណ្តាប្រទេសផ្សេងៗនោះ គឺជាការពង្រីកខ្លួនរបស់ក្រុមហ៊ុនដើម។ ទោះបីជាយ៉ាងណាក៏ដោយ ករណីលើកលែងកើតមានចំពោះក្រុមហ៊ុន ដែលជាក្រុមហ៊ុនសហកម្មសិទ្ធិ និងពាក់ព័ន្ធចំណែកភាគហ៊ុននឹងក្រុមហ៊ុនដើម និងភាគហ៊ុននៅក្នុងស្រុក ដែលនៅក្នុងករណីនេះ សញ្ជាតិមានការឱ្យអត្ថន័យទៅតាមច្បាប់នៃ បណ្តាប្រទេសទាំងនោះ។ ការកំណត់សញ្ជាតិនៃសហគ្រាសពហុជាតិ ដែលជាក្រុមហ៊ុនសហ-កម្មសិទ្ធិ និងយោងតាម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រុមហ៊ុននឹងទទួលបានបុគ្គលភាពគតិយុត្តសញ្ជាតិខ្មែរក្នុងករណី :

-ក្រុមហ៊ុនសហកម្មសិទ្ធិនោះ មានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅកម្ពុជា

-អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ត្រូវជាកម្មសិទ្ធិកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។

**កថាខណ្ឌទី ៥:ការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា**

រាល់ការបណ្តាក់ទុន ត្រូវដាក់ពាក្យសុំការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ រាល់ពាក្យស្នើសុំត្រូវមានចុះហត្ថលេខា និងបញ្ជូនដោយម្ចាស់វិនិយោគទុននោះ ឬអ្នកតំណាង ដែលត្រូវបានផ្ទេរសិទ្ធិដោយមាន

លិខិតជាលាយលក្ខណ៍អក្សរ។ ក្រោយពីទទួលបាននូវពាក្យសុំ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាធ្វើការពិនិត្យ សារឡើងវិញ ដោយលក្ខខណ្ឌនៃការដាក់ពាក្យសុំតម្រូវឱ្យមាន ៖

-ពាក្យស្នើសុំពេញលេញ ដែលផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងចុះហត្ថលេខាដោយម្ចាស់វិនិយោគទុន ឬអ្នកតំណាងស្របច្បាប់

-លិខិតបញ្ជាក់អំពីគោលបំណង នៃការបណ្តាក់ទុនដែលភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេបនៃម្ចាស់វិនិយោគទុន គំរោងការនៃការបណ្តាក់ទុន គោលបំណង និងសំណូមពរពិសេសស្នើដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់គំរោងការ។

-លក្ខន្តិកៈក្រុមហ៊ុន

-ការសិក្សាលំអិតពីគំរោងការនៃការបណ្តាក់ទុន ក្នុងព្រះរាជាណាចក្រកម្ពុជា

-ក្នុងករណីមានការប្រែប្រួល ម្ចាស់វិនិយោគទុនត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងរយៈ ២៥ ថ្ងៃនៃថ្ងៃធ្វើការ

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងធ្វើការសម្រេចចិត្តទទួល ឬមិនទទួលយក លិខិតស្នើក្នុងរយៈពេល ២៨ ថ្ងៃ ក្រោយពេលលិខិតស្នើសុំ ត្រូវបានបញ្ជូនត្រឹមត្រូវ និងចប់សព្វគ្រប់

-ដើម្បីជាការទាក់ទាញ និងជំរុញឱ្យមានភាពងាយស្រួលនៅក្នុងការចុះបញ្ជី រដ្ឋាភិបាលបានបង្កើតឱ្យមានការចុះបញ្ជីតាមប្រព័ន្ធ Internet ជាអាទិ៍។

## ជំពូកទី ២: ដំណើរការសហគ្រាសពហុជាតិ

ដំណើរការសហគ្រាសពហុជាតិ គឺជាជំហានទី ២នៃវដ្តរបស់សហគ្រាស ដើម្បីទទួលបាននូវគោលបំណងដែលជាគំនិតនៃការបង្កើតឱ្យមានទម្រង់ក្រុមហ៊ុននេះ។

នៅពេលធ្វើការសិក្សាអំពីដំណើរការសហគ្រាសពហុជាតិ យើងធ្វើការសិក្សាអំពីសញ្ញាណទូទៅនៃសហគ្រាសពហុជាតិ និងទំនាក់ទំនងនៃសហគ្រាសពហុជាតិ។

### ផ្នែកទី ១: សញ្ញាណទូទៅនៃសហគ្រាសពហុជាតិ




-ម្ចាស់ភាគហ៊ុន : ជាម្ចាស់កម្មសិទ្ធិនៃក្រុមហ៊ុន ដែលម្ចាស់ភាគហ៊ុនទាំងអស់ចូលរួមគ្នា ដើម្បីធ្វើជាដើមទុនរបស់ក្រុមហ៊ុន។ ម្ចាស់ភាគហ៊ុន ផងនោះដែរទទួលបានប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈ ការបែងចែកទៅតាមចំណែករៀងៗខ្លួន ដែលមានភាពខុសគ្នាទៅតាមទំហំភាគហ៊ុនរបស់ខ្លួន រីឯប្រាក់ចំណេញ ផ្អែកលើការដែលក្រុមហ៊ុនចំណេញប្រចាំឆ្នាំ។

-នាយកគ្រប់គ្រង : ជាអ្នកគ្រប់គ្រងកិច្ចការប្រចាំថ្ងៃរបស់ក្រុមហ៊ុន។ នាយកគ្រប់គ្រងទទួលបាន ជាប្រាក់កម្រៃទៅតាមកិច្ចសន្យាការងារ ដែលពួកគេទទួលបាននូវអំណាចតាមរយៈលក្ខន្តិកៈក្រុមហ៊ុន។

-ឥណទាយក : ជាអ្នកផ្តល់ប្រាក់កម្ចីដល់ក្រុមហ៊ុន ហើយឥណទាយកមានសិទ្ធិចំពោះក្រុមហ៊ុន ទៅតាមការព្រមព្រៀងក្នុងកិច្ចសន្យាកម្ចី។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេពុំមានសិទ្ធិ ក្នុងការចាត់ចែងក្រុមហ៊ុនឡើយ។ ឥណទាយកទទួលបានប្រាក់សំណង និងជាប្រចាំពីក្រុមហ៊ុន ដោយមិនផ្អែកលើការចំណេញរបស់ក្រុមហ៊ុនឡើយ។

-រដ្ឋាភិបាល : រដ្ឋាភិបាលពុំមែនជាភាគីនៃសហគ្រាសពហុជាតិឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ទម្រង់ និងការដឹកនាំរបស់រដ្ឋាភិបាល តែងតែជះឥទ្ធិពលលើដំណើរការទាំងមូល របស់ក្រុមហ៊ុន។ ក្នុងករណីនេះ

អាចឃើញមានភាពខុសគ្នាខ្លះៗ ពីសហគ្រាសពហុជាតិក្នុងប្រទេសមួយ ទៅប្រទេសមួយ។ ជាក់ស្តែងយុទ្ធសាស្ត្រទីផ្សារនៃក្រុមហ៊ុនថ្នាំជក់អង់គ្លេស អាមេរិចកាំង មានភាពប្រែប្រួលទៅតាមបណ្តាប្រទេសផ្សេងៗគ្នា នៅក្នុងទីផ្សារបើកចំហរ ដែលមានប្រទេស Singapore Malaysia and US ជាអាទិ៍។

-សារធារណជន : សាធារណៈជនពុំបានទទួលសិទ្ធិណាមួយនៅក្នុងក្រុមហ៊ុនឡើយ ប៉ុន្តែសាធារណជនដែលជាអតិថិជនរបស់ក្រុមហ៊ុន គឺជាអំណាចសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។

-និយោជិត : និយោជិតពុំមានកាតព្វកិច្ចក្នុងការសម្រេចកិច្ចការរបស់ក្រុមហ៊ុននោះទេ លុះណាតែពួកគេ គឺជាម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនមានភារកិច្ច និងទទួលខុសត្រូវរាល់ទង្វើរបស់និយោជិតរបស់ខ្លួន។

**កថាខណ្ឌទី ១ : ភាគហ៊ុន**

ភាគហ៊ុនគឺជាដើមទុនស្របច្បាប់ ដែលរួមផ្សំជាមួយដើមទុនរបស់ក្រុមហ៊ុនតាមរយៈប្រព័ន្ធ Common Law ភាគហ៊ុនគឺជាបណ្តុំនៃសិទ្ធិ និងកាតព្វកិច្ច នៅក្នុងទំនាក់ទំនងនៃក្រុមហ៊ុន ដែលជាពាណិជ្ជកិច្ច។ ម្ចាស់ហ៊ុនគឺជាអ្នកកាន់កាប់ភាគហ៊ុន ដែលអ្នកទាំងនោះអាចកាន់កាប់ភាគហ៊ុន មួយឬច្រើនរបស់ក្រុមហ៊ុននោះ អាស្រ័យទៅតាមកិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុន Shareholder Agreement ។

ផ្តើមចេញពីចំណុចនេះ ការសិក្សាអំពីភាគហ៊ុន យើងធ្វើការសិក្សាអំពី សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់ហ៊ុន និងបណ្តឹងដែលទាក់ទងនឹងភាគហ៊ុន ដែលជាប្រភពនៃការកកើតគំនិតនៃដំណើរការសហគ្រាសពហុជាតិ ដែលជាការបង្កើត ឬដំណើរការសហគ្រាសពហុជាតិ។

ក-សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់ហ៊ុន

+សិទ្ធិសំខាន់ៗរបស់អ្នកកាន់កាប់ភាគហ៊ុនមានដូចជា :

-សិទ្ធិទទួលបានចំណែកក្រុមហ៊ុន : ម្ចាស់ភាគហ៊ុនទទួលបានចំណែកនៃប្រាក់ចំណេញ ស្របទៅតាមចំនួននៃភាគហ៊ុន ដែលមាននៅក្នុងក្រុមហ៊ុន។ ម្ចាស់ភាគហ៊ុនមានសិទ្ធិទទួលបានចំណែកនៃការបែងចែកកម្មសិទ្ធិ លើតម្រូវការរបស់ក្រុមហ៊ុនស្របតាមភាគហ៊ុនរបស់ខ្លួន។

-សិទ្ធិទទួលព័ត៌មានពីក្រុមហ៊ុន : ម្ចាស់ភាគហ៊ុនមានសិទ្ធិទទួលបាននូវសេចក្តីប្រកាសផ្សេងៗរបស់ក្រុមហ៊ុន ក៏ដូចជាឯកសារអំពីកំណត់ត្រាប្រចាំឆ្នាំរបស់ក្រុមហ៊ុន ឬជាព័ត៌មានលំអិតណាមួយ ដែលម្ចាស់ភាគហ៊ុនមានសិទ្ធិក្នុងការចូលរួមប្រជុំ លើការសម្រេចផ្សេងៗ របស់ក្រុមហ៊ុនផងដែរ ។

-សិទ្ធិហាមឃាត់ជំនួយហិរញ្ញវត្ថុពិសេស : ដោយមាននូវអំណះអំណាងគ្រប់គ្រាន់តាមតម្រូវការរបស់ក្រុមហ៊ុន ម្ចាស់សិទ្ធិមានសិទ្ធិប្តឹងទៅតុលាការ មិនឱ្យមានការផ្តល់ជំនួយហិរញ្ញវត្ថុ ពិសេសទៅឱ្យម្ចាស់ហ៊ុនដទៃផ្សេងទៀត តាមរយៈបណ្តឹងជំនួស ។

-សិទ្ធិនៅក្នុងការលក់ភាគហ៊ុន : រាល់ភាគហ៊ុនអាចត្រូវបានលក់ ក្នុងន័យជាសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់ហ៊ុន ទោះជាភាគហ៊ុននោះ ត្រូវបានរឹតត្បិតក្នុងការផ្ទេរ ឬលក់ក៏ដោយ និងម្ចាស់ហ៊ុនមានសិទ្ធិរក្សាទុកនូវកំនើននៃដើមទុន ។

+កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុន :

-ការទទួលខុសត្រូវរបស់អ្នកកាន់កាប់ភាគហ៊ុនមានភាពខុសគ្នា ទៅតាមក្រុមហ៊ុននីមួយៗ តាមការចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន និងអាចជាការមិនទទួលខុសត្រូវចំពោះកិច្ចការផ្សេងៗ ក្រៅពីនាមជាអ្នកកាន់កាប់ភាគហ៊ុន ( ម្ចាស់ភាគហ៊ុនអកម្ម-Sleeping Shareholder) រហូតដល់ការទទួលខុសត្រូវមិនមានកំណត់ ។

-ប្រសិនបើអ្នកកាន់កាប់ក្រុមហ៊ុនមានមុខងារជានាយកគ្រប់គ្រង ម្ចាស់ភាគហ៊ុននោះត្រូវទទួលខុសត្រូវ រាល់អំពើដែលប៉ះពាល់ដល់កាតព្វកិច្ចរបស់នាយកគ្រប់គ្រងក្រុមហ៊ុន ។

-ការទទួលខុសត្រូវរាល់ទង្វើ ដែលផ្ទុយពីលក្ខន្តិកៈ បះកិច្ចសន្យាដែលមានចែងឱ្យទទួលខុសត្រូវចំពោះបំណុលរបស់ក្រុមហ៊ុន ។

ខ-បណ្តឹង

បណ្តឹងមានបីប្រភេទ គឺ :

-បណ្តឹងបុគ្គលៈ អាចត្រូវបានរៀបចំឡើងនៅក្នុងករណីមានការប្រព្រឹត្តកំហុសចំពោះសិទ្ធិរបស់ម្ចាស់ភាគហ៊ុន ។ ឧទាហរណ៍ : សម្លេងឆ្នោតរបស់ម្ចាស់ភាគហ៊ុនក្នុងអង្គប្រជុំ លើសេចក្តីសម្រេចណាមួយ ត្រូវបានគេ

បោះបង់ចោល។ ម្យ៉ាងទៀតបណ្តឹងបុគ្គលអាចកើតមានឡើង ពេលពុំធ្វើការបែងចែកប្រាក់ចំណេញ ជូនម្ចាស់ភាគហ៊ុន នៅពេលដែលក្រុមហ៊ុនប្រកាសថា បានចំណេញក្នុងរយៈពេលណាមួយ។

-បណ្តឹងតំណាង : អ្នកកាន់កាប់ភាគហ៊ុនម្នាក់ អាចប្តឹងជំនួសសមាជិកភាគហ៊ុនផ្សេងទៀត ដែលប្រព្រឹត្តកំហុស ឬនាយកក្រុមហ៊ុន។ ឧទាហរណ៍ : នៅធនាគារ Kuwait Bank ត្រូវបានម្ចាស់ភាគហ៊ុនម្នាក់ ដាក់ពាក្យបណ្តឹង តំណាងឱ្យម្ចាស់ភាគហ៊ុនដទៃទៀត។

-បណ្តឹងជំនួស : គឺជាបណ្តឹងដែលម្ចាស់ភាគហ៊ុន ប្តឹងជំនួសក្រុមហ៊ុនទាំងមូល ពីកំហុសនាយកគ្រប់គ្រង ដែលនៅក្នុងករណីនេះ ម្ចាស់ភាគហ៊ុនមិនដើរតួនាទី ជាដើមចោទនោះទេ។

ឧទាហរណ៍ : នៅក្នុងការកេងប្រវ័ញ្ចក្រុមហ៊ុន នាយកក្រុមហ៊ុនត្រូវបានប្តឹង តាមរយៈបណ្តឹងជំនួស ដែលក្រុមហ៊ុនគឺជាដើមចោទ និងនាយកក្រុមហ៊ុនជាចុងចម្លើយ។

## កថាខណ្ឌទី ២ : ការបង់ពន្ធនៃសហគ្រាសពហុជាតិ

នៅពេលដែលដំណើរការក្រុមហ៊ុន ឬសហគ្រាសពហុជាតិ ទាមទារឱ្យមានការបង់ពន្ធ ដែលធ្វើឡើងដោយសហគ្រាសពហុជាតិ នៅក្នុងក្របខណ្ឌគតិយុត្ត។

ក្របខណ្ឌនៃការបង់ពន្ធនៃសហគ្រាសពហុជាតិ យើងនឹងធ្វើការសិក្សាអំពីគោលការណ៍នៃការបង់ពន្ធ និងការបង់ពន្ធរបស់សហគ្រាសពហុជាតិនៅកម្ពុជា។

ក-គោលការណ៍នៃការបង់ពន្ធ :

សហគ្រាសពហុជាតិ តម្រូវឱ្យបង់ពន្ធទៅកាន់ប្រទេសផ្សេងៗ មួយចំនួនក្រៅពីប្រទេសដែលក្រុមហ៊ុននោះតាំងនៅ។ គោលការណ៍នៃការបង់ពន្ធ មានភាពប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយ និងដោយសារភាពខុសគ្នានៃគោលការណ៍នៃការបង់ពន្ធ ធ្វើឱ្យមានការជ្រើសរើសយ៉ាងល្អិតល្អន់ អំពីការបង្កើតសាខានានា តាមបណ្តាប្រទេសទាំងនោះ ពោលគឺប្រាល់ថ្លៃពន្ធនៅក្នុងប្រទេសមួយ ក៏ជាកត្តានៃការសម្រេចចិត្តរបស់សហគ្រាសពហុជាតិដើម ក្នុងកាជ្រើសរើសប្រទេសនោះ ដើម្បីធ្វើការបណ្តាក់ទុន។ កត្តាទាំងនេះបណ្តាលឱ្យមានការប្រកួត-ប្រជែង នៅតាមបណ្តាប្រទេសនានា ដើម្បីទាក់ទាញការបណ្តាក់ទុននៃសហគ្រាសពុហជាតិ។ គោលការណ៍បង់ពន្ធច្រើនប្រទេសនេះ ជួនកាលបណ្តាលបង្កើតឱ្យមានឱកាសឱ្យសហគ្រាសពហុជាតិរួចផុតពីការបង់ពន្ធ រឺឯ

សហគ្រាសពហុជាតិមួយចំនួនត្រូវបង់ពន្ធទ្វេរដងលើប្រាក់ចំណូលតែមួយ។ ការបង់ពន្ធមានពីរប្រភេទ ដែលជាជម្រើសទៅតាមរដ្ឋាភិបាលនៃប្រទេសនីមួយៗ គឺ :ការបង់ពន្ធលើជំនួញក្នុងប្រទេស និងការបង់ពន្ធលើជំនួយក្នុងប្រទេស និងក្រៅប្រទេស។ ការបង់ពន្ធលើជំនួញក្នុងប្រទេស សំដៅលើការបង់ពន្ធចំពោះការបណ្តាក់ទុនទាំងឡាយ ដែលបានពីសាខានៅក្រៅប្រទេស ត្រូវរួចផុតពីការបង់ពន្ធ។ ប្រភេទនៃការបង់ពន្ធ របៀបនេះ មាននៅក្នុង ៣០ប្រទេសជាង លើពិភពលោក ដែលនៅក្នុងនោះ មានប្រទេសសំខាន់មួយចំនួនដូចជា បារាំង អ៊ីតាលី និង ហូឡង់ ជាអាទិ៍។ ចំណែកឯការបង់ពន្ធលើជំនួញនៅក្នុងប្រទេស និងក្រៅប្រទេស សំដៅលើការបង់ពន្ធចំពោះការបណ្តាក់ទុនទាំងក្នុង និងក្រៅប្រទេស។ ប្រភេទនៃការបង់ពន្ធរបៀបនេះ ត្រូវបានយកទៅប្រើប្រាស់ដោយទ្រេសមួយចំនួន និងមានសហរដ្ឋអាមេរិក ជាអាទិ៍។ ទោះបីជាយ៉ាងណាក៏ដោយ នៅបណ្តាប្រទេសដែលអនុវត្តការបង់ពន្ធលើជំនួញក្នុងស្រុក ក៏បានប្រើប្រាស់នូវប្រព័ន្ធបង់ពន្ធលើជំនួញក្នុង និងក្រៅប្រទេសផងដែរ ដែលធ្វើឱ្យសហគ្រាសពហុជាតិ ក្នុងបណ្តាប្រទេសទាំងនោះរងការបង់ពន្ធទ្វេរ។ រាល់បណ្តាសហគ្រាសពហុជាតិតែងតែព្យាយាមកាត់បន្ថយការបង់ពន្ធរបស់ពួកគេ ដែលជាទូទៅ ប្រាក់ចំណូលរបស់សហគ្រាសពហុជាតិ មានការកើនឡើងនៅបណ្តាប្រទេសដែលទាមទារពន្ធទាប បើប្រៀបធៀបប្រទេសដែលទាមទារពន្ធខ្ពស់។

ខ-ការបង់ពន្ធនៃសហគ្រាសពហុជាតិនៅកម្ពុជា

១-ប្រភេទ និងតម្លៃពន្ធ

របបនៃការបង់ពន្ធ នៅកម្ពុជាមាន ពីរប្រភេទ គឺ :

-របបមៅការ : សម្រាប់ការបណ្តាក់ទុនចំពោះទំនិញ**ក្រោម ១២៥ លានរៀល** និងការបណ្តាក់ទុនលើសសេវាក្រោម ៣០លានរៀល។

-របបពិត : សម្រាប់ការបណ្តាក់ទុនលើទំនិញ**លើសពី ១២៥ លានរៀល** និងការបណ្តាក់ទុនលើសេវាលើសពី ៣០ លានរៀល។ រាល់សហគ្រាសពហុជាតិទាំងអស់ ត្រូវបង់ពន្ធតាមរបបពិត ដោយសាររាល់ជំនួញដែលមានតម្លៃលើសពី ១២៥ លានរៀល និងលើសពី ៣០ លានរៀលចំពោះសេវា។ ពន្ធដែលត្រូវបង់នៅក្នុងរបបពិតរួមមាន :

∞ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ/ប្រាក់រំដោះពន្ធជាមុនលើប្រាក់ចំណេញ :ក្នុងករណីទទួលបានប្រាក់ចំណូលច្រើនជាងប្រាក់ចំណាយ នៅក្រុមហ៊ុនត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ដែលមានអត្រាពន្ធស្មើនឹង ៩% នៃប្រាក់ចំណេញ។ ក្នុងករណីក្រុមហ៊ុនទទួលបានប្រាក់ចំណូល តិចជាងប្រាក់ចំណាយក្នុងរយៈពេលណាមួយនោះ ក្រុមហ៊ុនពុំមានកាតព្វកិច្ចបង់ពន្ធសម្រាប់រយៈកាលនោះទេ។ ប៉ុន្តែក្រុមហ៊ុនតម្រូវឱ្យបង់ពន្ធជាមុន សម្រាប់បន្ទាប់ដែលហៅថាប្រាក់រំដោះពន្ធ ជាមុនលើប្រាក់ចំណេញ ដែលមានអត្រាពន្ធស្មើនឹង ១% តាមរយៈរូបមន្ត គឺ : ប្រាក់រំដោះពន្ធជាមុនលើប្រាក់ចំណេញ = (តម្លៃលក់ - អាករលើតម្លៃបន្ថែម) × ១% ហើយក្រុមហ៊ុនត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ឬប្រាក់រំដោះពន្ធជាមុនលើប្រាក់ចំណេញជាប្រចាំខែ ឱ្យបានមុនថ្ងៃទី ១៥ នៃខែនីមួយៗ។

∞ប្រាក់អាករពិសេសលើទំនិញ និងសេវាជំនួញ : ជាករណីពិសេសចំពោះប្រាក់អាករលើទំនិញ និងសេវាជំនួញដែលពុំដាក់កាតព្វកិច្ចជាទូទៅ ប៉ុន្តែចំពោះតែក្រុមហ៊ុនបណ្តាក់ទុនលើទំនិញ និងសេវាមួយចំនួន ដូចជា:

Table of Chart

ក្រុមហ៊ុនត្រូវបងប្រាក់អាករពិសេសជាប្រចាំខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្តបន្ទាប់។

∞អាករលើតម្លៃបន្ថែម : រាល់ការបណ្តាក់ទុនលើទំនិញ និងសេវា ក្រុមហ៊ុនមានកាតព្វកិច្ចលើអាករនៃតម្លៃបន្ថែមដែលត្រូវបានគេស្គាល់ថា VAT ដែល

+អត្រាពន្ធស្មើនឹង ១០%នៃតម្លៃទំនិញ ឬសេវា

+រាល់វិក្កយបត្រពន្ធ ត្រូវមាននូវលេខអត្តសញ្ញាណកម្ម

+គ្មាន VAT សម្រាប់ទំនិញនាំចេញ

+ក្រុមហ៊ុនត្រូបបង់ VAT ជាប្រចាំខែ ត្រឹមថ្ងៃទី ២០

∞អាករសម្រាប់បំភ្លឺសេវាសាធារណៈ : មានលក្ខណៈប្រហាក់ប្រហែល និងប្រាក់អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ ពុំដាក់កាតព្វកិច្ចចំពោះក្រុមហ៊ុនជាទូទៅឡើយ ហើយវាគឺជាកាតព្វកិច្ចនៃការបង់អាករនេះតម្រូវតែរាល់ទំនិញខូចគុណភាពដែលពុំអាចធ្វើអាជីវកម្មបាន។ អត្រាពន្ធគឺ ៣% ដែលត្រូវបានគណនាតាម

រូបមន្ត អាករសម្រាប់បំភ្លឺសាធារណៈ = (តម្លៃលក់ទំនិញ — VAT លើទំនិញលក់ចេញ) ក្រុមហ៊ុនត្រូវបង់អាករសម្រាប់បំភ្លឺសាធារណៈប្រចាំខែយ៉ាងយឺតត្រឹមថ្ងៃទី ២០។

○ពន្ធកាត់ទុកទូទៅ : រាល់ក្រុមហ៊ុនទាំងឡាយ ដែលពុំបានចុះឈ្មោះ បង់អាករពីតម្លៃបន្ថែម ឬ VAT ត្រូវមានកាតព្វកិច្ចបង់ពន្ធកាត់ទុក ឬឱ្យ WHT ។ ពន្ធកាត់ទុក តែងជាកាតព្វកិច្ចនៃក្រុមហ៊ុនផ្គត់ផ្គង់តូចៗ សម្រាប់សហគ្រាសពហុជាតិ ដែលសហគ្រាសពហុជាតិត្រូវទទួលខុសត្រូវ ប្រសិនបើក្រុមហ៊ុនដែលផ្គត់ផ្គង់នោះ ពុំបានបង់ WHT ទេនោះ មានន័យថារាល់ការបង្ហាប់តម្លៃនៃក្រុមហ៊ុនផ្គត់ផ្គង់របស់សហគ្រាសពហុជាតិ ក្នុងការផលិតឧបករណ៍ផ្សេងៗ សហគ្រាសពហុជាតិត្រូវស្វែងយល់ថា តើក្រុមហ៊ុនផ្គត់ផ្គង់នោះមានបង់ពន្ធកាត់ទុកទូទៅ ឬទេ។ ក្នុងករណីសហគ្រាសពហុជាតិ នៅតែទទួលក្រុមហ៊ុនផ្គត់ផ្គង់ ដើម្បីផ្តល់សេវា ឬទំនិញដល់ខ្លួន ដែលពុំចុះឈ្មោះកាត់ទុក នោះសហគ្រាសពហុជាតិ ត្រូវទទួលបង់ពន្ធ WHT ជំនួស ដែលអត្រាពន្ធនៅក្នុងស្រុកគឺ ១០%នៃថ្លៃទំនិញ(សម្រាប់ថ្លៃជួលចលនវត្ថុ ឬអចលនវត្ថុ) និង ១៥% នៃថ្លៃសេវា (សម្រាប់ការផ្គត់ផ្គង់សេវា) ហើយអត្រាពន្ធកាត់ទុកទូទៅសម្រាប់ក្រុមហ៊ុនក្រៅស្រុក គឺ ១៤% លើរាល់ទំនិញ ឬសេវា ដោយតម្រូវឱ្យក្រុមហ៊ុនត្រូវបង់ WHT ជាប្រចាំខែយ៉ាងយឺតត្រឹមថ្ងៃទី ១៥។

○ពន្ធលើប្រាក់បៀវត្ស : គឺជាពន្ធដែលនិយោជិតនៃក្រុមហ៊ុនត្រូវបង់ជូនរដ្ឋតាមរយៈនិយោជក ដែលមានបែងចែកដូចខាងក្រោម :

+បើប្រាក់បៀវត្សប្រចាំខែមានចំនួនមិនលើសពី ៥00,000 រៀល អត្រាពន្ធស្មើនឹង 0%

+បើប្រាក់បៀវត្សប្រចាំខែមានចំនួនលើសពី ៥000,000 រៀល និងតិចជាង ឬស្មើ ១,២៥0,000 រៀល នោះអត្រាពន្ធស្មើនឹង ៥% នៃប្រាក់បៀវត្ស

+បើប្រាក់បៀវត្សប្រចាំខែមានចំនួនលើសពី ១,២៥0,000 រៀល និងតិចជាង ឬស្មើ ៨,៥00,000 រៀល នោះអត្រាពន្ធស្មើនឹង ១០% នៃប្រាក់បៀវត្ស

+បើប្រាក់បៀវត្សប្រចាំខែមានចំនួនលើសពី ៨,៥00,000 រៀល និងតិចជាង ឬស្មើ ១២,៥00,000 រៀល នោះអត្រាពន្ធស្មើនឹង ១៥% នៃប្រាក់បៀវត្ស

+បើប្រាក់បៀវត្សប្រចាំខែមានចំនួនលើសពី ១២,៥០០,០០០ រៀល នោះអត្រាពន្ធស្មើនឹង ១៥% នៃប្រាក់បៀវត្ស។

ក្រុមហ៊ុនដែលនិយោជកត្រូវមានកាតព្វកិច្ចប្រមូលពន្ធលើនិយោជិតរបស់ខ្លួន និងត្រូវបង់ជាប្រចាំខែ។ ឧទាហរណ៍ : ការគណនាពន្ធលើប្រាក់បៀវត្ស :

អ្នកទទួលប្រាក់បៀវត្សម្នាក់មានកូន ០៣ នាក់ ស្ថិតនៅក្នុងបន្ទុក និងប្រពន្ធជាមេផ្ទះ ហើយបានទទួលប្រាក់បៀវត្សប្រចាំខែ គឺ ៨,០០០,០០០ (ប្រាំបីលាន) រៀល។

នៅក្នុងការគណនា គឺ រកប្រាក់ដែលគាត់ត្រូវបង់ពន្ធ :

បើត្រឹម ៥០០០,០០០ × 0%

ពី ៥០០,០០១ ដល់ ១,២៥០,០០០ : ៧៥០,០០០ × ៥% = ៣៧,៥០០ រៀល

ពី ១,២៥០,០០១ ដល់ ៨,៥០០,០០០ : ៧,២៥០,០០០ × ១០% = ៧២៥,០០០ រៀល

៧៦២,៥០០ រៀល

ដូច្នេះ លោកត្រូវបង់ពន្ធដែលមានតម្លៃ ៧៦២,៥០០ រៀល

៰ពន្ធលើអត្ថប្រយោជន៍ : គឺជាពន្ធលើអត្ថប្រយោជន៍ជាសាច់ប្រាក់ក្តី ននិងជាសំភារៈប្រើប្រាស់ផ្សេងៗក្តី ដែលក្រុមហ៊ុនផ្តល់ជូននិយោជិតជាតិ និងអន្តរជាតិមួយចំនួនទៅតាមឋានន្តរសក្តិក្នុងរយៈពេលដែលស្ថិតនៅក្នុងកិច្ចសន្យា ហើយដែលជាកាតព្វកិច្ចរបស់និយោជិត បង់ពន្ធជូនរដ្ឋតាមរយៈនិយោជក។ អត្ថប្រយោជន៍បន្ថែមមានដូចជា : និវេសនដ្ឋាន អាហារ អ្នកបម្រើ ថ្លៃអគ្គីសនី និងផ្គត់ផ្គង់ទឹកប្រើប្រាស់ ថ្លៃមធ្យោបាយធ្វើដំណើរ ថ្លៃទូរស័ព្ទ និងថ្លៃសេវាកាប់រង ជាអាទិ៍។ អត្រាន្ធលើអត្ថប្រយោជន៍បន្ថែមស្មេនឹង ២០% នៃតម្លៃនៃប្រភេទអត្ថប្រយោជន៍តាមទីផ្សារ ដែលធ្វើការគណនាតាមរូបមន្តអត្រាពន្ធលើអត្ថប្រយោជន៍ បន្ថែម ចែកនឹង 0.៨។ ក្រុមហ៊ុនមានភារកិច្ចត្រូវប្រមូលពន្ធលើអត្ថប្រយោជន៍បន្ថែម ជារៀលរាល់ខែ និងបង់ពន្ធ ជូនរដ្ឋយ៉ាងយូរត្រឹមថ្ងៃទី ១៥ នៃខែនីមួយៗ។

ឧទាហរណ៍ : ពីការគណនាពន្ធលើអត្ថប្រយោជន៍បន្ថែម :

អ្នកទទួលប្រាក់បៀវត្សម្នាក់មានកូន ០៣ នាក់ស្ថិតនៅក្នុងបន្ទុក និងមានប្រពន្ធជាមេផ្ទះ ហើយបានទទួលប្រាក់បៀវត្សប្រចាំខែ ចំនួន ៨,០០០,០០០ រៀល និងមានផ្ទះមួយជាអត្ថប្រយោជន៍ពីការងារ ដោយមានឈ្នួលផ្ទះប្រចាំខែ ថ្លៃ ១,៣០០,០០០ រៀល។

បៀបក្នុងការគណនាប្រាក់ ដែលគេត្រូវបង់ពន្ធលើអត្រាពន្ធលើអត្ថប្រយោជន៍បន្ថែម គឺ :

១,៣០០,០០ × ២០% /០.៨ = ៣២៥,០០០រៀល

ដូច្នេះលោកត្រូវបង់ពន្ធលើអត្ថប្រយោជន៍បន្ថែម គឺ មានតម្លៃ ៣២៥,០០០ រៀល

∞ពន្ធលើប៉ាតង់ : ពន្ធប៉ាតង់ត្រូវផ្អែកជាមូលដ្ឋានលើផលរបរប្រចាំឆ្នាំ ដែលចំពោះអាជីវកម្មចាស់ ផលរបរដែលធ្វើជាមូលដ្ឋានសម្រាប់កំណត់ប្រាក់ពន្ធប៉ាតង់ គឺជាផលរបរនៃឆ្នាំកន្លងមក និងចំពោះអាជីវកម្មថ្មី ផលរបរដែលធ្វើជាមូលដ្ឋានសម្រាប់កំណត់ប្រាក់ពន្ធប៉ាតង់ គឺជាផលរបរដែលអង្គភាពពន្ធ គិតជាបណ្តោះអាសន្នប្រចាំឆ្នាំ។

២-ដំណាក់កាលនៃការបង់ពន្ធ

ក្រុមហ៊ុនត្រូវធ្វើការបំពេញលិខិតប្រកាសពន្ធដែលផ្តល់ជូនដោយនាយកដ្ឋានពន្ធដានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះរាល់ពន្ធដែលទាក់ទង រួចបញ្ជូនទៅមន្ត្រីពន្ធដារ ប្រចាំនៅនាយកដ្ឋានពន្ធដា ទទួលត្រួតពិនិត្យ និងកែប្រែ បើមានកំហុសផ្សេងៗ រួចចុះហត្ថលេខាទទួលស្គាល់ថា ការបំពេញលើសេចក្តីប្រកាសពន្ធ មានភាពត្រឹមត្រូវ។ បន្ទាប់ពីទទួលបានការចុះហត្ថលេខារបស់មន្ត្រីពន្ធដារលើលិខិតប្រកាសពន្ធរួចមក ក្រុមហ៊ុនត្រូវបង់តម្លៃនៃប្រាក់ពន្ធទាំងអស់នៅធនាគារជាតិនៃកម្ពុជា ដែលនឹងត្រូវទទួលដោយមន្ត្រីពន្ធដារជាបន្ត រួចមកក្រុម-ហ៊ុន ត្រូវរក្សាទុកនូវវិក្ក័យបត្រ ដែលបញ្ជាក់អំពីការបង់ពន្ធ រួមជាមួយឯកសារផ្សេងៗ ដែលនឹងត្រូវបានចុះត្រួតពិនិត្យជាប្រចាំ ដោយសវនកម្មពន្ធដារ។ សវនកម្មពន្ធដារ រួមមាន ការិយាល័យពន្ធបណ្ឌិត ក្រសួងមន្ទីរពាក់ព័ន្ធ ការិយាល័យទទួលពិនិត្យព័ត៌មាន។

**កថាខណ្ឌទី ៣ : ការខកខានមិនបានបង់ពន្ធ**

កាតព្វកិច្ចបង់ពន្ធ គឺជាកាតពកិច្ចរបស់សហគ្រាស ឬក្រុមហ៊ុន ដើម្បីទទួលបាននូវភាពស្របច្បាប់នៃពាណិជ្ជកិច្ចរបស់ខ្លួន ហើយនៅពេលមិនបង់ពន្ធ ត្រូវមានមូលហេតុ និងសំអាងគ្រប់គ្រាន់ ដើម្បីជៀសវាង ការ

ចាត់វិធានការណ៍ តាមផ្លូវច្បាប់ ដែលជាលផលវិបាកគតិយុត្តនៃដំណើរការសហគ្រាស។

នៅពេលមានការពិចារណា អំពីការខកខានមិនបង់ពន្ធ យើងត្រូវធ្វើការវិនិច្ឆ័យអំពីមូលហេតុ និងការពិន័យ ដើម្បីជាទណ្ឌកម្មចំពោះអ្នកមិនបានបំពេញកាតព្វកិច្ចឱ្យបានល្អ តាមផ្លូវច្បាប់។

ក-មូលហេតុ

ផ្អែកទៅតាមប្រភេទនៃពន្ធនីមួយៗ ដែលមានការចែងពីពេលផុតកំណត់នៃការបង់ពន្ធខុសៗគ្នា ដូចជាប្រាក់ដែលផុតកំណត់ថ្ងៃទី១៥ នៃខែនីមួយៗ រីឯអាករលើតម្លៃបន្ថែមផុតកំណត់នៅថ្ងៃទី២០ នៃខែនីមួយៗ។ មូលហេតុមួយក្នុងចំណោមមូលហេតុដទៃផ្សេងៗទៀត ក្នុងការចែងពីពេលផុតកំណត់ផ្សេងៗពីគ្នានៅក្នុងការបង់ពន្ធ គឺជាការសម្រួលដល់នាយកដ្ឋានពន្ធដារ និងក្រុមហ៊ុនទាំងឡាយនៅក្នុងការរៀបចំដំណើរការបង់ពន្ធ ឱ្យមានប្រសិទ្ធិភាព និងដើម្បីជំរុញឱ្យមានការកំណត់នៃការបង់ពន្ធឱ្យមានប្រសិទ្ធិភាព រាល់សកម្មភាពខាងក្រោមនឹងទទួលការផាកពិន័យ ៖

-មិនបានដាក់លិខិតប្រកាសនៅការិយាល័យរបបពិត ទោះបីគ្មានប្រាក់បង់ពន្ធក៏ដោយ

-មិនបង់ ឬបង់យឺតយ៉ាវនូវប្រាក់ពន្ធដែលបានប្រកាស

-ធ្វើការប្រកាសក្លែងបន្លំ

ខ-ការពិន័យ

យោងតាមមាត្រា ១៣១នៃបទបញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ក្រុមហ៊ុនត្រូវបង់ប្រាក់ពន្ធបន្ថែមស្មើនឹង ១០%នៃចំនួនប្រាក់ពន្ធដែលបង់ខាត + ការប្រាក់ ២% នៃចំនួនប្រាក់ពន្ធ ដែលបង់ខ្វះ សម្រាប់ខែនីមួយៗ នៅក្នុងករណីដែលធ្ងន់ធ្ងរ តម្លៃពន្ធត្រូវបន្ថែមស្មើនឹង ២៥%នៃចំនួនប្រាក់ពន្ធ ដែលបង់ពន្ធ + ការប្រាក់ ២% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ។ យោងតាមមាត្រា ១១៨ នៃបទបញ្ញត្តិខាងលើ ការប្រាក់មិនត្រូវអនុញ្ញាតក្នុងរយៈពេលកំណត់ពន្ធឡើងវិញ ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ និងយោងតាមមាត្រានៃបទបញ្ញត្តិខាងលើ ប្រសិនបើបុគ្គលពុំបានបង់ពន្ធក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីបានទទួលលិខិតជូនដំណឹង រំលឹកការទារបំណុលពន្ធ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ២៥% នៃទឹកប្រាក់ពន្ធបង់យឺត + ការប្រាក់ ២% នៃប្រាក់ពន្ធដែលបង់យឺតយ៉ាវសម្រាប់ខែនីមួយៗ។ ក្នុងករណីការកំណត់ពន្ធដារ

ជាឯកតោភាគី សម្រាប់ការមិនដាក់លិខិតប្រកាសប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ៤០%នៃចំនួនប្រាក់ពន្ធដែលបានកំណត់ + ការប្រាក់ ២%នៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែនីមួយៗ។ ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ១ នៃខែបន្ទាប់ពីខែដែលត្រូវបង់ពន្ធ ហើយចំពោះពន្ធលើប្រាក់ចំណេញ ការប្រាក់យឺតយ៉ាវ ត្រូវគិតចាប់ពីថ្ងៃទី ១នៃខែបន្ទាប់ពីខែផុតកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ។ ពន្ធបន្ថែម ចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវស្មើនឹង ១០០%នៃប្រាក់ពន្ធ ដែលត្រូវបង់។

### ផ្នែកទី ២: ទំនាក់ទំនងនៃសហគ្រាសពហុជាតិ

នៅពេលដែលសហគ្រាសពហុជាតិមានដំណើរការ និងត្រូវបានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនរួចរាល់ហើយ ទាមទារឱ្យមានទំនាក់ទំនាក់ទំនងផ្ទៃក្នុង និងទំនាក់ទំនងជាមួយតតិយជន។

#### កថាខណ្ឌទី ១: ទំនាក់ទំនងផ្ទៃក្នុង

នៅក្នុងទំនាក់ទំនងផ្ទៃក្នុងនៃសហគ្រាសពហុជាតិ គឺត្រូវមានបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈក្រុមហ៊ុន ដែលកំណត់អំពីទម្រង់ក្រុមហ៊ុន មហាសន្និបាត ដើមទុន កម្មវត្ថុនៃការធ្វើអាជីវកម្ម រចនាសម្ព័ន្ធគ្រប់គ្រង និងខចែងតម្រូវមួយចំនួនទៀតដែលមានកំណត់នៅក្នុងច្បាប់។ ជាទូទៅនៅពេលសហគ្រាសពហុជាតិចាប់ផ្តើមដំណើរការត្រូវកំណត់អំពីទម្រង់នៃក្រុមហ៊ុនរបស់ខ្លួន ថាតើជ្រើសរើសយកទម្រង់មួយណា ដើម្បីឱ្យខ្លួនមានបុគ្គលភាពគតិយុត្តសម្រាប់ប្រតិបត្តិការពាណិជ្ជកិច្ចរបស់ខ្លួន នៅក្នុងដែនដីរដ្ឋបាលណាមួយ។ មួយវិញទៀត រចនាសម្ព័ន្ធក្រុមហ៊ុនត្រូវកំណត់ជាទូទៅ មាន ០៤ ស្រទាប់គឺ ម្ចាស់ភាគហ៊ុន អភិបាលក្រុមហ៊ុន បុគ្គលិកជាន់ខ្ពស់ និងកម្មករនិយោជិត ដែលជាសរសៃឈាមនៃដំណើរការក្រុមហ៊ុន។

#### កថាខណ្ឌទី ២: ទំនាក់ទំនងជាមួយតតិយជន

នៅក្នុងក្របខណ្ឌនៃទំនាក់ទំនងជាមួយតតិយជនរបស់សហគ្រាសពហុជាតិ ត្រូវកំណត់ទៅតាមប្រភេទនៃទម្រង់ក្រុមហ៊ុន ដែលមានច្បាប់ស្តីពីសហគ្រាសពហុជាតិជាអ្នកគ្រប់គ្រងនៃព្រះរាជាណាចក្រកម្ពុជា មានន័យថា ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនពាណិជ្ជកម្មបរទេស។

## ជំពូកទី ៣: ការរំលាយសហគ្រាសពហុជាតិ

ការរំលាយក្រុមហ៊ុន គឺជាការបញ្ចប់នូវភាពជានីតិបុគ្គល ព្រមទាំងរាល់មុខជំនួញ និងកិច្ចការរវាងក្រុមហ៊ុន ដែលមានម្ចាស់ហ៊ុន ឥណទាយក នាយកគ្រប់គ្រង និងនិយោជិតក្រុមហ៊ុន។

ផ្តើមចេញពីចំណុចនេះ ការរំលាយក្រុមហ៊ុនកើតឡើងដោយសារតែមានមូលហេតុ ដែលគេហៅថា មូលហេតុនៃការរំលាយ និងមធ្យោបាយមួយទៀត គឺការជម្រះបញ្ជី។

## ផ្នែកទី ១ : មូលហេតុនៃការរំលាយ

នៅពេលចង់បញ្ចប់ដំណើរការនៃនីតិបុគ្គលភាពគតិយុត្តរបស់សហគ្រាសពហុជាតិ តម្រូវឱ្យធ្វើឡើងតាមរយៈមូលហេតុនៃការរំលាយ ដើម្បីជាការបញ្ចប់នូវដំណើរការក្រុមហ៊ុន។

មូលហេតុ ០២ យ៉ាង ដែលជាការរំលាយក្រុមហ៊ុន គឺ កិច្ចសន្យា និងតាមផ្លូវតុលាការ។

### កថាខណ្ឌទី ១: កិច្ចសន្យា

ម្ចាស់ភាគហ៊ុនទាំងអស់អាចធ្វើការតែងតាំង អ្នកជម្រះបញ្ជីម្នាក់ដើម្បីធ្វើការរំលាយក្រុមហ៊ុន ហើយនៅក្នុងករណីខ្លះ នាយកគ្រប់គ្រងក្រុមហ៊ុន ក៏មានសិទ្ធិតែងតាំងអ្នកជម្រះបញ្ជី តាមការផ្តល់អំណាចដោយធម្មនុញ្ញក្រុមហ៊ុន ឬតាមគំនិតផ្តួចផ្តើមរបស់ម្ចាស់ភាគហ៊ុន ឬនាយកក្រុមហ៊ុន បណ្តាលមកពីមូលហេតុពីរយ៉ាង:

-ការបណ្តាក់ទុនរបស់ក្រុមហ៊ុន លើកលែងជាតម្រូវការរបស់ម្ចាស់ហ៊ុនទាំងអស់

-ក្រុមហ៊ុនក្ស័យធន

### កថាខណ្ឌទី ២: តុលាការ

ដើម្បីជំរុញកាសងបំណុលបន្ទាន់មួយចំនួន ឥណទាយកមានសិទ្ធដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីសំណូមពរឱ្យមានអន្តរាគមន៍។ ក្នុងករណីដែលកូនបំណុល (សហគ្រាសពហុជាតិ) បដិសេធមិនសង តុលាការនឹងចាត់វិធានការបន្ត ដើម្បីជាការជំរុញផ្នែកច្បាប់។

ប្រសិនបើឥណទាយករកឃើញថា កូនបំណុលមានកម្មសិទ្ធិមួចំនួន ដែលអាចលក់សងបំណុលបាន តុលាការអាចចេញដីកាសម្រេច ឬសាលក្រមឱ្យកូនបំណុលទាំងនោះលក់សងបំណុលឥណទាយក។ ទោះបីជាយ៉ាងណាក៏ដោយ ជម្រើសនេះបានប្រែក្លាយទៅជាការចំណាយពេឡវេលា និងថវិកាច្រើន និងជួនកាលត្រូវ

អសារបង់ផងដែរ។ ប្រសិនបើឥណទាយករកឃើញថា ក្រុមហ៊ុនពុំមានលទ្ធភាពសងសំណងរបស់ខ្លួន ដោយក្រុមហ៊ុនជួបនូវកង្វះថវិកា នោះឥណទាយកអាចប្តឹងទៅតុលាការ ដើម្បីចាត់តាំងអ្នកជម្រះបញ្ជីក្រុមហ៊ុន។

ដំណាក់កាលផ្សេងៗដែលឈានទៅដល់ការចាត់តាំងអ្នកជម្រះបញ្ជីក្រុមហ៊ុនគឺ :

-បន្ទាប់ពីដាក់ពាក្យបណ្តឹងទាមទារបំណុល ប្រសិនបើបំណុលនោះត្រូវបានតវ៉ា( ទោះបីទាំងស្រុង ឬមួយផ្នែកក្តី) ឥណទាយកត្រូវដោះស្រាយនូវទំនាស់ តាមរយៈការសម្រុះសម្រួល ឬការចរចាគ្នាជាមួយនឹងក្រុមហ៊ុន ឬតាមរយៈការសម្របសម្រួលរបស់តុលាការ។

-ប្រសិនបើកូនបំនុលពុំមានលទ្ធភាពសងបំណុលជូនឥណទាយកតាមការកំណត់នោះទេ ឥណទាយកមានសិទិ្ធប្តឹងទៅតុលាការ ដើម្បីចាត់តាំងអ្នកជម្រះបញ្ជី។

-បន្ទាប់ពីទទួលបានបណ្តឹងរបស់ឥណទាយក ដែលធ្វើតាមដំណាក់កាល ដោយច្បាប់ដែលមានដូចជាការផ្តល់ដំណឹងជាសារធារណៈពីការដកពាក្យបណ្តឹង តុលាការត្រូវចេញដីកាសម្រេចចិត្តតាំងអ្នកជម្រះបញ្ជី រួចបញ្ជូនទៅក្រុមហ៊ុន ដែលនៅក្នុងករណីនេះអ្នកជម្រះបញ្ជីដើរតួនាទីជា Official Assigner ។

-ការរំលាយក្រុមហ៊ុន ត្រូវធ្វើឡើងក្នុងពេលនៃការតែងតាំងអ្នកជម្រះបញ្ជីក្រុមហ៊ុន ដោយក្រោយពីការចាត់តាំងអ្នកជម្រះបញ្ជីរួចរាល់ហើយនោះ :

+អ្នកជម្រះបញ្ជីមានសិទ្ធិនៅក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើកម្មសិទ្ធិទាំងឡាយរបស់ក្រុមហ៊ុន

+នាយកគ្រប់គ្រងលែងមានអំណាច និងតួនាទីដឹកនាំក្រុមហ៊ុន លើកលែងតែមានការចែងចំពោះកិច្ចការមួយចំនួន នៅក្នុងធម្មនុញ្ញរបស់ក្រុមហ៊ុន។

+គ្មានការផ្ទេរនូវរាល់ភាគហ៊ុន របស់ក្រុមហ៊ុន បើពុំមានការចេញដីកាសម្រេចរបស់តុលាការ។

+ពុំមានគោលការណ៍ផ្លាស់ប្តូរណាមួយចំពោះសិទ្ធិ និងការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុន។

+ពុំមានការកែប្រែធម្មនុញ្ញរបស់ក្រុមហ៊ុន

នៅក្នុងករណីដែលមានការរំលាយក្រុមហ៊ុន ក្រុមហ៊ុនស្ថិតនៅជានីតិបុគ្គល ប៉ុន្តែនេះ ដើម្បីជាការរំលាយនូវកាតព្វកិច្ច និងទទួលខុសត្រូវរបស់ក្រុមហ៊ុន ហើយចែករំលែកនូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅឱ្យម្ចាស់ភាគហ៊ុនវិញ។ នៅក្នុងករណីនេះ ក្រុមហ៊ុននៅតែជាម្ចាស់ទ្រព្យនៃកម្មសិទ្ធិក្រុមហ៊ុន ក៏ប៉ុន្តែទាំងនាយកគ្រប់គ្រងដំណើរការរកស៊ីរបស់ក្រុមហ៊ុន ពុំមានសិទ្ធិចំពោះទ្រព្យទាំងនោះឡើយ ក្នុងពេលជាមួយគ្នានេះផងដែរ ដំណើរការរបស់ក្រុមហ៊ុនត្រូវបញ្ឈប់ រីឯនិយោជិតរបស់ក្រុមហ៊ុនក៏ត្រូវបញ្ឈប់ ស្របពេលជាមួយនឹងការរំលាយក្រុមហ៊ុននេះផងដែរ។

**ផ្នែកទី ២: ការជម្រះបញ្ជី**

នៅពេលដែលមានមូលហេតុនាំឱ្យបញ្ចប់សកម្មភាពរបស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវចាប់ផ្តើមនីតិវិធីជម្រះបញ្ជី ដើម្បីទូទាត់បំណុល ឬទ្រព្យអកម្ម និងស្ថានភាពហិរញ្ញវត្ថុផ្សេងៗ ដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុន។

នៅពេលនិយាយអំពីការជម្រះបញ្ជី គេត្រូវលើកឡើងពីអ្នកជម្រះបញ្ជី និងដំណាក់កាលនៃការជម្រះបញ្ជី ដើម្បីជាមូលដ្ឋាននៃការបិទបញ្ជីក្រុមហ៊ុន និងសន្មតថាក្រុមហ៊ុនត្រូវបានបញ្ចប់ដំណើរការរបស់ខ្លួន ដែលមានន័យថាក្រុមហ៊ុនលែងមានបុគ្គលភាពគតិយុត្តតទៅទៀតហើយ ដោយសារតែឆ្លងកាត់នូវនីតិវិធីជម្រះបញ្ជីនាំឱ្យស្ថានភាពរបស់ក្រុមហ៊ុន ស្មើនឹងមនុស្សស្លាប់។

**កថាខណ្ឌទី ១: អ្នកជម្រះបញ្ជី**

អ្នកជម្រះបញ្ជី ត្រូវបានតែងតាំង ដែលមានការផ្តល់អំណាច ដោយច្បាប់នៅក្នុងករណី ដែលក្រុមហ៊ុនស្ថិតនៅក្នុងដំណាក់កាលនៃការរំលាយក្រុមហ៊ុន ដើម្បីធានាការសងបំណុលរបស់ឥណទាយក ព្រមទាំងអ្នក-ពាក់ព័ន្ធផ្សេងៗ។ បុគ្គលិកលក្ខណៈរបស់អ្នកជម្រះបញ្ជី ពុំមានលក្ខណៈពិសេសនោះឡើយ ហើយបុគ្គលម្នាក់មិនអាចក្លាយជាអ្នកជម្រះបញ្ជីបានឡើយ នៅក្នុងករណី :

-ក្រុមហ៊ុន

-អនីតិជន និងអសមត្ថជន

-ឥណទាយករបស់ក្រុមហ៊ុន

-បុគ្គលដែលក្នុងអំឡុងពេល ០២ ឆ្នាំ ចុងក្រោយ ធ្លាប់ជាម្ចាស់ក្រុមហ៊ុន នាយកគ្រប់គ្រង អ្នកគ្រប់គ្រងទ្រព្យបណ្តោះអាសន្នរបស់ក្រុមហ៊ុនដែលត្រូវរំលាយ ឬក្រុមហ៊ុនដែលពាក់ព័ន្ធ

-ជនដែលធ្លាប់ឆ្លងកាត់នីតិវិធីក្ស័យធន

-ជនដែលស្ថិតនៅក្រោមបម្រាមរបស់តុលាការ មិនអាចឱ្យធ្វើការជម្រះបញ្ជីឡើយ ឬអ្នកគ្រប់គ្រងទ្រព្យបណ្តោះអាសន្ន

-ជនដែលច្បាប់ហាមឃាត់មិនឱ្យធ្វើការគ្រប់គ្រងលើក្រុមហ៊ុន

### កថាខណ្ឌទី ២: ដំណាក់កាលជម្រះបញ្ជី

បន្ទាប់ពីបានធ្វើការតែងតាំងជាអ្នកជម្រះបញ្ជី អ្នកជម្រះបញ្ជីត្រូវចេញជាសេចក្តីជូនដំណឹងជាសាធារណៈពីការតែងតាំង ព្រមទាំងកាលបរិច្ឆេទនៃការតែងតាំងរួម ជាមួយនឹងអាស័យដ្ឋានពិតប្រាកដ និងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនង ដើម្បីទទួលរងចម្ងល់ដែលទាក់ទង ដោយមានចម្លងជូនអ្នកកាន់កាប់បញ្ជីផងដែរ ហើយរាល់ឯកសារដែលពាក់ព័ន្ធនឹងក្រុមហ៊ុនត្រូវបញ្ជាក់ពីការរំលាយក្រុមហ៊ុន។ ទន្ទឹមនឹងនេះ អ្នកជម្រះបញ្ជីត្រូវរៀបចំបញ្ជីនៃរាល់ឥណទាយកទាំងអស់ ហើយអ្នកជម្រះបញ្ជីត្រូវជូនដំណឹង និរបាយការណ៍ទាក់ទងពីការរំលាយក្រុមហ៊ុន ជាមួយព័ត៌មានលំអិតពីការរំលាយជូនទៅដល់ឥណទាយក និងម្ចាស់ភាគហ៊ុនទាំងអស់ ព្រមទាំងបញ្ជាក់អំពីសិទ្ធិរបស់ខ្លួន ពីព្រោះការប្រជុំឥណទាយកទាំងអស់ អាចធ្វើបាននៅក្នុងករណីចាំបាច់ និងរាល់ឯកសារត្រូវចម្លងជូនអ្នកកាន់កាប់បញ្ជី។ នៅរាល់ដំណាក់កាលជាក់លាក់ណាមួយ អ្នកជម្រះបញ្ជីត្រូវបញ្ជូនរបាយ-ការណ៍លើការវិវឌ្ឍន៍នៃដំណាក់កាលផ្សេងៗនៃការរំលាយក្រុមហ៊ុនទៅឥណទាយក ម្ចាស់ភាគហ៊ុន ដោយមានការចម្លង ជូនអ្នកកាន់កាប់បញ្ជី។ ក្រោយពីការបញ្ចប់ការរំលាយក្រុមហ៊ុន អ្នកជម្រះបញ្ជីត្រូវបញ្ជូនរបាយការណ៍លំអិត ទៅកាន់ឥណទាយក និងម្ចាស់ភាគហ៊ុន ព្រមទាំងអ្នកកាន់កាប់បញ្ជីផងដែរ។ អ្នកជម្រះបញ្ជីត្រូវបញ្ជាក់អំពីរាល់កម្មសិទ្ធិក្រុមហ៊ុន ដែលត្រូវបានចាត់ចែងរួចរាល់ ហើយក្រុមហ៊ុនអាចត្រូវបានដកចេញពីបញ្ជីបាន។ អ្នកចុះបញ្ជី ក៏ត្រូវបញ្ជាក់ជូនចំពោះឥណទាយក និងម្ចាស់ភាគហ៊ុនពីសិទ្ធិរបស់ពួកគេ ក្នុងការហាមឃាត់មិនឱ្យដកក្រុមហ៊ុនចេញពីបញ្ជីនៃការរំលាយក្រុមហ៊ុន។

### កថាខណ្ឌទី ៣: ដំណាក់កាលនៃការរំលាយសហគ្រាសពហុជាតិនៅកម្ពុជា

ក្រោយពីមានការព្រមព្រៀងពីការរំលាយក្រុមហ៊ុន ពីរាល់ភាគីដែលពាក់ព័ន្ធរួចរាល់តាម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ត្រូវធ្វើសេចក្តីជូនដំណឹង ទៅមន្ត្រីចុះបញ្ជីពីការរំលាយក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម តាមទម្រង់បែបបទដែលត្រូវបានកំណត់ដោយការតែងតាំងអ្នកជម្រះបញ្ជីផងដែរ។ ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសពីសណងរំលាយជាទម្រង់លំអិត ទៅឱ្យក្រសួងពាណិជ្ជកម្ម។ ក្រោយពីបានទទួលនូសេចក្តីប្រកាសនេះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុនរបស់ក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់អំពីបំណងរំលាយក្រុមហ៊ុន ដែលក្រុមហ៊ុនត្រូវធ្វើការបញ្ឈប់អាជីវកម្មរបស់ខ្លួន ភ្លាមៗ លើកលែងតែ ចំពោះការចាំបាច់សម្រាប់ការជម្រះបញ្ជី។ ទោះបីជាយ៉ាងណាក៏ដោយ សុពលភាពនៃនីតិបុគ្គលភាពរបស់ក្រុមហ៊ុននៅតែបន្ត រហូតដល់ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្រស្តីពីការរំលាយជាស្ថាពរនៃក្រុមហ៊ុននោះ។ ក្រោយពីចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកក្រុមហ៊ុនរបស់ក្រសួងពាណិជ្ជកម្ម ត្រូវ :

-បញ្ជូនសេចក្តីជូនដំណឹងស្តីពីបំណងរំលាយទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុនជាបន្ទាន់

-ត្រូវធ្វើការចុះផ្សាយជាបន្ទាន់ពីការរំលាយក្រុមហ៊ុន ក្នុងរយៈពេល ០២ សប្តាហ៍ បន្តបន្ទាប់នៅតាមទំព័រសារព័ត៌មាននានាជាភាសាខ្មែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបោះពុម្ព ឬផ្សព្វផ្សាយផ្សេងៗទៀត។ សេចក្តីជូនដំណឹង ដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងនៅក្នុងបទបញ្ញត្តិនៃបទដ្ឋាននានារបស់ក្រសួងពាណិជ្ជកម្ម។ អ្នកជម្រះបញ្ជីមានសិទ្ធិនៅក្នុងការកាន់កាប់ និងចាត់ចែងរបស់ក្រុមហ៊ុន និងត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនរហូតដល់រយៈពេល ១០ ឆ្នាំ ចាប់ពីពេល ដែលបានជម្រះបញ្ជីរួច ហើយអ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវបញ្ជី និងកំណត់ហេតុផ្សេងៗទៀត សម្រាប់រយៈពេលច្រើនជាង ១០ ឆ្នាំ ប្រសិនបើឯកសារទាំងអស់តម្រូវឱ្យទុកជាភស្តុតាង និងរាល់ឯកសារត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។ ក្រោយពីការជម្រះបញ្ជីត្រូវបានបញ្ចប់ សហគ្រាសពហុជាតិត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន រួចបញ្ជូនទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម និងមន្ត្រីដែលត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុន ហើយចាប់ពីថ្ងៃដែលបានចុះនៅក្នុងវិញ្ញានបត្របញ្ជាក់អំពីការរំលាយក្រុមហ៊ុនត្រូវបញ្ចប់ ហើយត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន និងការរំលាយក្រុមហ៊ុនត្រូវចប់ជាស្ថាពរ ។

និយាយជារួម នៅពេលយើងធ្វើការសិក្សានិងស្រាវជ្រាវស្តីពីសហគ្រាសពហុជាតិ ចំណុចជាសារវ័ន្ត ដែលយើងគប្បីធ្វើការពិចារណាគឺ វដ្តជីវិតនៃសហគ្រាសពហុជាតិ ដែលបង្កើតជាខ្សែចង្វាក់នៃវិវឌ្ឍនាការរបស់ក្រុមហ៊ុន គឺការបង្កើតសហគ្រាសពហុជាតិ ដំណើរការសហគ្រាសពហុជាតិ និងការរំលាយសហគ្រាសពហុជាតិ។ នៅក្នុងការបង្កើតសហគ្រាសពហុជាតិ យើងធ្វើការពិចារណាទៅលើ សារធាតុនៃសហគ្រាសពហុជាតិ និងសណ្ឋាននៃសហគ្រាសពហុជាតិ ដែលតាមរយៈនេះ សារធាតុនៃសហគ្រាសពហុជាតិ យើងធ្វើវិចារណកិច្ចគតិយុត្តទៅលើអត្ថន័យ លក្ខណៈសំគាល់នៃសហគ្រាសពហុជាតិ និងរចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ។ នៅពេលយើងលើកពីអត្ថន័យនៃសហគ្រាសពហុជាតិត្រូវបានពន្យល់ថា ជាសហគ្រាសដែលមានសាខាជាអ្នកផលិត-លក់ និងផ្តល់សេវានៅក្នុងប្រទេសមួយ ឬច្រើន។ សហគ្រាសពហុជាតិធ្វើការកែច្នៃ និងបង្កើតទំនិញថ្មីៗ នៅក្នុងប្រទេសដើមកំណើតរបស់ខ្លួនរួចធ្វើការផលិតនៅបរទេស។ ប៉ុន្តែយោងតាមអត្ថន័យរបស់រាជរដ្ឋាភិបាលនៃបណ្តារដ្ឋសមាជិកអង្គការសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍(OECD)សហគ្រាសពហុជាតិ ជាបណ្តាក្រុមហ៊ុនដែលនៅក្នុងនោះមានក្រុមហ៊ុនផ្សេងៗ ដែលអាចជាកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិរបស់រដ្ឋ ឬជាកម្មសិទ្ធិរួមគ្នារវាងរដ្ឋ និងឯកជន។ ក្រុមហ៊ុនទាំងនេះមាននៅតាមបណ្តាប្រទេសផ្សេងៗគ្នា និងមានទំនាក់ទំនងជាមួយក្រុមហ៊ុនមួយ ឬច្រើន ដែលមានឥទ្ធិពលទៅលើក្រុមហ៊ុនមួយទៀត។ រីឯលក្ខណៈសំគាល់នៃសហគ្រាសពហុជាតិ គេពិចារណាទៅលើលក្ខណៈ ០៤ យ៉ាង :**ប្រព័ន្ធនៃការគ្រប់គ្រង**(សំដៅទៅលើចំនួនប្រទេសដែលសហគ្រាសពហុជាតិដំណើរការនៃមុខជំនួញ ព្រមទាំងភាពជាកម្មសិទ្ធិនៃកម្មវត្ថុពាណិជ្ជកម្ម។ ចំពោះសហគ្រាសពហុជាតិ ភាគច្រើន ម្ចាស់កម្មសិទ្ធិជាប្រទេស ដែលមានទីស្នាក់ការកណ្តាល និងអាចមានដាក់ភាគហ៊ុននៅតាមបណ្តាប្រទេសផ្សេងៗ។ **កាមើលឃើញជារួម** (ជាការមើលឃើញជាទូទៅចំពោះសហគ្រាសពហុជាតិទៅលើភាគរយនៃចំណូល ឬប្រាក់ចំណេញប្រចាំឆ្នាំ និងកម្មសិទ្ធិផ្សេងៗ ព្រមទាំងនិយោជិតដែលមានសញ្ជាតិបទេសជាដើម។ **អត្តចរិកក្រុមហ៊ុន** (ភាពចម្រុះជាតិសាសន៍នៃអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងរង្វង់ក្រុមហ៊ុនអន្តរជាតិ និងសហគ្រាសពហុជាតិរបស់សហគមន៍អឺរ៉ុប ភាគច្រើនមានថ្នាក់ដឹកនាំសញ្ជាតិបរទេស រីឯសហរដ្ឋអាមេរិក ជាប្រទេសដែលមានលក្ខណៈលើកលែងព្រោះថ្នាក់ដឹកនាំជាន់ខ្ពស់ភាគច្រើន មានសញ្ជាតិអាមេរិក តែម្តង។ **ការសម្របសម្រួល** (ក្រុមហ៊ុនមួយ ដែលរបៀបនៃការគ្រប់គ្រងជំនួញរបស់ខ្លួន មាន ០២ របៀប គឺ Multiple-domestic និង Global។ Multiple-

domestic គឺជាប្រភេទក្រុមហ៊ុនដែលសម្របខ្លួន ទៅតាមទីផ្សារផ្សេងៗគ្នា ដែលបង្ហាញយ៉ាងជាក់លាក់ពីបណ្តុំសាខា ជាច្រើនរបស់ក្រុមហ៊ុននោះ។ រីឯក្រុមហ៊ុន Global គឺជាក្រុមហ៊ុនបង្កើតជាផលិតផលស្តង់ដារ សម្រាប់គ្រប់គ្រងប្រទេស ដែលចាត់ទុករាល់បណ្តាប្រទេស លើពិភពលោក ជាទីផ្សារតែមួយ និងមិនសម្របផលិតផលរបស់ខ្លួន ទៅតាមសារធាតុផ្សេងៗគ្នានៃប្រទេស នោះឡើយ។ ដោយឡែក រចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ គឺផ្តោតទៅលើលក្ខណៈ ០៤ យ៉ាង (ប្រភេទនៃទីផ្សារ ដែលសហគ្រាសពហុជាតិបណ្តាក់ទុន ការប្រកួតប្រជែងលើទីផ្សារ ដែលត្រូវជ្រើសរើស ប្រភេទផលិតផល ឬទំនិញ ឬសេវា ដែលត្រូវបានបណ្តាក់ទុនដោយសហគ្រាសពហុជាតិ និងតម្រូវការ ដែលឈានទៅដល់ផលិតផលទំនិញ ឬសេវា)។

លើសពីនេះទៅទៀត សណ្ឋាននៃសហគ្រាសពហុជាតិ ត្រូវលើកឡើងពី ជម្រើសនៃសហគ្រាសពហុជាតិ មូលហេតុនៃការបណ្តាក់ទុននៅបរទេស រូបភាពនៃការបណ្តាក់ទុនរបស់សហគ្រាសពហុជាតិ សញ្ជាតិនៃសហ-គ្រាស និងការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា។ ជម្រើសនៃសហគ្រាសពហុជាតិ ផ្តោតទៅលើក្រុមហ៊ុនពាណិជ្ជកម្មតែម្នាក់ឯង, ក្រុមហ៊ុនសហកម្មសិទ្ធិ, ក្រុមហ៊ុនសាជីវកម្ម, ក្រុមហ៊ុនពាណិជ្ជកម្មទទួលភារៈគ្រប់គ្រង ក្រុមហ៊ុនឯកភាពទទួលភារៈគ្រប់គ្រង និងក្រុមហ៊ុន Franchise។ ចំណែកឯ មូលហេតុនៃការបណ្តាក់ទុននៅបរទេសគឺឈានទៅដល់កម្រិតនៃការជោគជ័យនៃទីផ្សារ ,ការប្រកួតប្រជែងនៃទីផ្សារ ដែលជាដៃគូរប្រកួតប្រជែង ,កាត់បន្ថយចំណាយ ដោយសហគ្រាសពហុជាតិកាត់បន្ថយទៅតាមតម្លៃពលកម្ម និងពន្ធដារ, ទប់ស្កាត់ការនាំចូលនៅក្នុងប្រទេសដើមកំណើត តាមរយៈការបង្កើតសាខា ព្រមទាំងទប់ស្កាត់ការរីក ដុះដាលទីផ្សារ ចំពោះទំនិញ គូប្រកួតប្រជែងលើទំនិញនាំចេញរបស់ខ្លួន ទៅកាន់ប្រទេសទទួលទំនិញនាំចូល។ មួយវិញទៀត រូបភាពនៃការបណ្តាក់ទុនរបស់សហគ្រាសពហុជាតិ ធ្វើឡើងតាមរយៈ(ការិយាល័យតំណាងពាណិជ្ជកម្ម ,សាខាសហគ្រាសពាណិជ្ជកម្ម និងបុត្រសម្ព័ន្ធ)។ រីឯសញ្ជាតិនៃសហគ្រាសពហុជាតិ អាស្រ័យលើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដោយក្រុមហ៊ុននឹងទទួលបានបុគ្គលភាពគតិយុត្តសញ្ជាតិខ្មែរក្នុងករណី(ក្រុមហ៊ុនសហកម្មសិទ្ធិនោះមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅកម្ពុជា និងអត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ត្រូវជាកម្មសិទ្ធិកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ)។ យ៉ាងណាក៏ដោយ ដំណើការរបស់សហគ្រាស

ពហុជាតិ ត្រូវបង្ហាញតាមរយៈសញ្ញាណទូទៅនៃសហគ្រាសពហុជាតិ និងទំនាក់ទំនងនៃសហគ្រាសពហុជាតិ ដែលតាមរយៈនេះ សញ្ញាណទូទៅនៃសហគ្រាសពហុជាតិ លើកឡើងពី ភាគហ៊ុន ការបង់ពន្ធ និងការមិនបានបង់ពន្ធ ដែលនាំឱ្យមានពិន័យនៅពេលមិនគោរពកាតព្វកិច្ច ដែលតម្រូវដោយច្បាប់ ដើម្បីទទួលបាននូវភាពស្របច្បាប់នៃសកម្មភាពពាណិជ្ជកិច្ចរបស់ខ្លួន នៅក្នុងដែនដីរដ្ឋបាលជាក់លាក់ណាមួយ។ មួយវិញទៀត នៅពេលចង់បញ្ចប់ដំណើរការរបស់ក្រុមហ៊ុន អាចធ្វើឡើងតាមមធ្យោបាយរំលាយសហគ្រាសបហុជាតិ ដែលការរំលាយនេះធ្វើឡើងតាមរយៈមូលហេតុនៃការរំលាយ និងការជម្រះបញ្ជី។/

# ភាគទី ៣: សហគ្រាសពាណិជ្ជកម្ម

បណ្តាសហគ្រាសទាំងឡាយ ដែលបានបង្កើតឡើងទៅតាមច្បាប់ជាតិក្តី ឬច្បាប់អន្តរជាតិក្តី តែងតែមានទម្រង់ជាក់លាក់របស់ខ្លួន ដើម្បីកំណត់ពីនីតិបុគ្គលិកលក្ខណៈរបស់ខ្លួន នៅក្នុងការស្វែងយល់ពីអត្ថន័យតាមផ្លូវច្បាប់ ដែលតាមរយៈនេះសហគ្រាសពាណិជ្ជកម្ម ក៏ជាផ្នែកមួយនៃប្រតិបត្តិការទាំងនេះផងដែរ។

នៅក្នុងក្របខណ្ឌនៃសហគ្រាសពាណិជ្ជកម្ម គេបែងចែកជា ០៣ ប្រភេទ ទី ១ ក្រុមហ៊ុនសហកម្មសិទ្ធិ ទី ២ ក្រុមហ៊ុន មូលធន និងទី ៣ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស។

## ជំពូកទី ១: ក្រុមហ៊ុនសហកម្មសិទ្ធិ

នៅក្នុងក្របខណ្ឌនៃក្រុមហ៊ុនសហកម្មសិទ្ធិ គឺជារចនាសម្ព័ន្ធចាត់តាំងនៃនីតិបុគ្គល ដែលធ្វើពាណិជ្ជកិច្ចក្រោមការទទួលខុសត្រូវពីសមាជិកភាគហ៊ុន ដែលជាម្ចាស់កម្មសិទ្ធិ ឬសហកម្មសិទ្ធិទូទៅ។

នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គេធ្វើការបែងចែកជា ០២ ប្រភេទ គឺទី ១ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងទី ២ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។

### ផ្នែកទី ១: ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងក្នុងនាមក្រុមហ៊ុនសហកម្មិទ្ធិទូទៅ គឺជាការលើកឡើងពីរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន នៅក្នុងការដឹកនាំ រៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមហ៊ុន ក្នុគោលដៅឱ្យមានប្រសិទ្ធភាពនៅក្នុការសម្រេចបេសកម្ម និងទស្សនៈវិស័យរបស់ខ្លួន តាមរយៈយុទ្ធសាស្ត្រ និងជំហាននានា។

នៅក្នុងការបង្ហាញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាការលើកឡើងពី ការបង្កើតក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅ ដំណើរការក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលជាចរន្ត ឬវដ្តដំណើរនៃជីវិតរបស់នីតិបុគ្គលក្រុមហ៊ុនពាណិជ្ជកម្ម។

#### កថាខណ្ឌទី ១: ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួម ក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ។ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិទូទៅ

ទាំងអស់ ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ។ នៅក្នុងករណីដែលកិច្ចសន្យានោះមិនច្បាស់លាស់ តុលាការត្រូវពិចារណាវាលវិធានដូចខាងក្រោម ដើម្បីថា តើភាគីទាំងអស់មានគោលបំណងរួមក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិនោះ ឬទេ :

-ក្នុងករណីដែលបុគ្គលពីរនាក់ ឬច្រើននាក់ កាន់កាប់ទ្រព្យសម្បត្តិរួមគ្នា ថាតើ បុគ្គលទាំងនោះ ចែកប្រាក់ចំណេញ ដែលបានមកពីទ្រព្យទាំងនោះ ឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ កើតឡើងដោយទ្រព្យសម្បត្តិរួម ឬទេ។

-ក្នុងករណីដែលបុគ្គល ពីរនាក់ ឬច្រើននាក់ ចែករំលែកប្រាក់ចំណូលដែលបានមកពីការធ្វើពាណិជ្ជកិច្ច ថាតើបុគ្គលទាំងនោះមានសិទ្ធិចូលរួមក្នុងទ្រព្យសម្បត្តិណាមួយ ដែលបង្កើតប្រាក់ចំណូលនោះទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះកើតឡើងដោយទ្រព្យសម្បត្តិរួមនោះឬទេ។

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបានបង្កើតឡើង ភាគីនៃកិច្ចសន្យាត្រូវជាប់កាតព្វកិច្ចចាប់ពីពេលដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងចប់សព្វគ្រប់ លើកលែងតែ កិច្ចសន្យាមានចែងផ្សេងពីនេះ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីសហកម្មសិទ្ធិករទូទៅម្នាក់ៗ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈចាប់ពីពេលដែលបានចុះបញ្ជី ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ហើយមានសិទ្ធិដូចតទៅ :ទី ១ ជាម្ចាស់លើចលនទ្រព្យ និងអចលនទ្រព្យក្នុងនាមក្រុមហ៊ុន ទី ២ ធ្វើពាណិជ្ជកិច្ចក្នុងនាមក្រុមហ៊ុន ទី ៣ ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន និងទី ៤ ប្តឹង ឬត្រូវគេប្តឹងក្នុងនាមក្រុមហ៊ុន។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរ លុះត្រាតែ : ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយអត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ឡើងទៅ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។ នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ហើយនៅខាងក្រោយ ឬខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា "**ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ**" ដោយក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅពេលធ្វើ

ពាណិជ្ជកិច្ច ហើយសហកម្មសិទ្ធករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយ នៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។

## កថាខណ្ឌទី ២: ដំណើរការក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបានបង្កើតស្របតាមច្បាប់តម្រូវរួចរាល់ហើយនោះ ក្រុមហ៊ុនមានតួនាទីដំណើរការសម្រាប់ភាពរីកចម្រើននៃមុខជំនួយរបស់ខ្លួន នៅក្នុងគោលដៅវិស័យពាណិជ្ជកម្ម ដែលតាមរយៈនេះ គឺបង្ហាញពីទំនាក់ទំនងរវាងសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិទូទៅ ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងតតិយជន និងការថ្លោះសិទ្ធិជាសហកម្មសិទ្ធិករទូទៅ

### ក-ទំនាក់ទំនងរវាងសហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករទូទៅ

សហកម្មសិទ្ធិករទូទៅម្នាក់ៗ អាច : បង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាសាច់ប្រាក់ ជាវត្ថុ ជាសេវា ពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬជាការសន្យាថានឹងផ្តល់សេវានាពេលអនាគត ឬដាក់ភាគទុនជាសេវាដែលជាចំណេះដឹង ឬសកម្មភាពផ្សេងៗ ប៉ុន្តែមិនត្រូវរាប់បញ្ចូលនូវការប្រើប្រាស់ឥទ្ធិពលដែលទទួលបានពីមុខងារជាមន្ត្រីសាធារណៈ នោះឡើយ។ សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាកូនបំណុលនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ចំពោះរាល់អ្វីៗដែលខ្លួនបានសន្យាចូលរួមទៅក្នុងក្រុមហ៊ុន។

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ទ្រព្យសម្បត្តិ ជាភាគទុន សហកម្មសិទ្ធិករទូទៅនោះ ត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ-ទូទៅ។ នៅពេលសហកម្មសិទ្ធិករទូទៅបានយល់ព្រមបង់ភាគទុននូវចំនួនទឹកប្រាក់ណាមួយ ហើយខកខានមិនបានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលខុសត្រូវចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀត ដែលត្រូវទាមទារពីសហកម្មសិទ្ធិករទូទៅនោះ។ នៅពេលសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមដាក់ភាគទុន ជាចំណេះដឹង ជាសេវា ឬជាសកម្មភាព សហកម្មសិទ្ធករទូទៅនោះ ត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ។ កិច្ចសន្យាជាលាយលក្ខណ៍អក្សរ

សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ប្រសិនបើភាគទុនរបស់សហកម្មសិទ្ធិករទូទៅ ជាចំណេះដឹង ជាសេវា ឬជាសកម្មភាព។ ដើមទុនរបស់ក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅ រួមមានភាគទុនជាសាច់ប្រាក់ និងជាវត្ថុ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬភាគទុនជាសកម្មភាពនោះទេ។ ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ។

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវមានសិទ្ធិទទួលប្រាក់ចំណេញ និងត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុន ហើយខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីសិទ្ធិទទួលប្រាក់ចំណេញត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព។ ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីការជាប់កាតព្វកិច្ចក្នុងការរួមចំណែកការខាតបង់ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាពចំពោះតតិយជនឡើយ។ សមាមាត្រនៃផល-ប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗនៅក្នុងទ្រព្យសម្បត្តិប្រាក់ចំណេញ និងការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យា។ ប្រសិនបើកិច្ចសន្យាចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬការខាតបង់ ពេលនោះសមាមាត្រ ដែលបានបង្កើតឡើងក្នុងករណីនេះ ត្រូវបានសន្មតជាមុន ដើម្បីអនុវត្តទៅលើតែករណីទាំងបីនោះ។ សហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយ ដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវកម្មណាមួយនៅក្នុងពាណិជ្ជកិច្ច ឬពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត ហើយសហកម្មសិទ្ធិករទូទៅទាំងឡាយមិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ និងគ្មានសហកម្មសិទ្ធិករទូទៅណាម្នាក់ ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នូវរាល់ការខូចខាតដែលបង្កឡើងដោយកំហុសឆ្គងរបស់សហកម្មសិទ្ធិករទូទៅនោះ។ មួយវិញទៀត សហកម្មសិទ្ធិករទូទៅក្នុងនាមខ្លួនឯងផ្ទាល់ និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមគ្នា ជាម្ចាស់បំណុលនៃកូនបំណុលតែមួយ បំណុលទាំងពីរនឹង

ត្រូវសង ហើយកូនបំណុលត្រូវសងទៅសហកម្មសិទ្ធិករទូទៅ ប៉ុន្តែមិនសងទៅក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ ក្នុងករណីនេះ ចំនួននៃប្រាក់សំណងដែលសហកម្មសិទ្ធិករទូទៅទទួលត្រូវបែងចែកទៅតាមសមាមាត្រទៅនឹងបំណុលផ្ទាល់ខ្លួន និងបំណុលចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះ ប្រើប្រាស់ក្នុងប្រយោជន៍របស់ក្រុមហ៊ុន។ រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅបានក្នុងលក្ខណៈជាការប្រើប្រាស់ផ្ទាល់ខ្លួន លុះត្រាតែសហកម្មសិទ្ធិករទូទៅ នោះមានការយល់ព្រមជាឯកច្ឆន្ទពីគ្រប់សហកម្មសិទ្ធិករទូទៅផ្សេងទៀត។ រាល់សហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងករណីមិនប៉ះពាល់ដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ដែលប្រើ ប្រាស់ទ្រព្យសម្បត្តិនោះ។ គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចក្លាយជាសហកម្មសិទ្ធិករទូទៅ ដោយគ្មានការយល់ព្រមជាឯកច្ឆន្ទ ពីគ្រប់សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានឡើយ។ សហកម្មសិទ្ធិករទូទៅម្នាក់ អាចប្រគល់សិទ្ធិឱ្យទៅបុគ្គលផ្សេង ដើម្បីទទួលប្រាក់កាសជំនួសខ្លួនបាន ដោយមិនចាំបាច់មានការយល់ព្រមពីសហកម្មសិទ្ធិករទូទៅដទៃទៀតឡើយ។ ការប្រគល់សិទ្ធិបែបនេះមិនធ្វើឱ្យអ្នកទទួលសិទ្ធិនោះក្លាយទៅជាសហកម្មសិទ្ធិករទូទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ សហកម្មសិទ្ធិករទូទៅម្នាក់ អាចផ្ទេរអត្ថ-ប្រយោជន៍របស់ខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់។

ភាគទុនជាទ្រព្យ ឬបាក់ចំណេញរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចត្រូវបានប្រើប្រាស់ជាទ្រព្យធានានូវកាតព្វកិច្ចផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករទូទៅនោះ។ ទ្រព្យធានានោះត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។ សហកម្មសិទ្ធិករទូទៅទាំងឡាយអាចធ្វើសេចក្តីសម្រេចអំពីសិទ្ធិរបស់ខ្លួននៅក្នុងការគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬបុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅ ឱ្យគ្រប់គ្រងកិច្ចការ

ជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះបាន និងអ្នកគ្រប់គ្រងអាចអនុវត្តរាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចរបស់ខ្លួនដរាបណា អ្នកគ្រប់គ្រងនោះមិនប្រព្រឹត្តអំពើក្លែងបន្លំ។ ការប្រព្រឹត្តរបស់អ្នកគ្រប់គ្រងត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែងដោយសំឡេងភាគច្រើនដោយប្រៀបនៃវត្តមានរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ នៅពេលដែលបុគ្គលច្រើនរូបត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងក្រុមហ៊ុន អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ៗ អាចអនុវត្តសកម្មភាពដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ សកម្មភាព ដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងទៅនឹងសកម្មភាពរួមរបស់ក្រុមហ៊ុន សហកម្មសិទ្ធិទូទៅក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀតដែរ។ រាល់សហកម្មសិទ្ធិករទូទៅមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ហើយការអនុវត្តសិទ្ធិនោះមិនត្រូវបានបង្អាក់ដោយសារកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។ លើកលែងតែ មានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោត តាមសំឡេងភាគច្រើនដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅ ដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ ប៉ុន្តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ។ សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលព័ត៌មានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជី និងកំណត់ហេតុ ទោះបីជាសហកម្មសិទ្ធិករទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រង ក៏ដោយ។ នៅក្នុងការអនុវត្តសិទ្ធិនេះ សហកម្មសិទ្ធិករ-ទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ ក្រុមហ៊ុនដោយគ្មានហេតុផលត្រឹមត្រូវ ឬមិនត្រូវធ្វើឱ្យរាំងស្ទះដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀតក្នុងការ អនុវត្តសិទ្ធិដូចគ្នាឡើយ។

### ខ-ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងតតិយជន

សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាភ្នាក់ងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ និងសហកម្មសិទ្ធិករទូទៅទាំងនោះត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុននូវរាល់អំពើ ដែលខ្លួនបានអនុវត្តក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវបានចាត់ទុកជាគ្មានប្រសិទ្ធភាព។ សហកម្មសិទ្ធិករទូទៅម្នាក់ ដែលបានចុះកិច្ចសន្យាជាមួយតតិយជន ត្រូវបានជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលណា ដែលកាតព្វកិច្ចនោះស្ថិតក្នុងវង្វង់អាជីវកម្មរបស់ក្រុមហ៊ុន ឬនៅពេលណាដែលកម្មវត្ថុនៃកិច្ចសន្យានោះជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នា នូវកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ និងតតិយជនត្រូវទាមទារការអនុវត្តកាតព្វកិច្ចបំណុល ឬទ្រព្យសម្បត្តិពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅសិន មុននឹងទាមទារពីសហកម្មសិទ្ធិករទូទៅ។ បុគ្គលណាដែលចូលជាសហកម្មសិទ្ធិករទូទៅ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកើតរួចហើយ ត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់ ដែលកើតឡើងដោយសារក្រុមហ៊ុន មុនពេលដែលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ ដូចដែលខ្លួនជាសហកម្មសិទ្ធិករទូទៅនៅពេលបំណុលនោះកើតឡើងដែរ។ ប៉ុន្តែបំណុលទាំងឡាយណា ដែលបានកើតឡើងមុនពេលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ បំណុលនោះ អាចត្រូវបានចេញសងដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន តែប៉ុណ្ណោះ ហើយមិនត្រូវបានចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលនោះឡើយ លើកលែងតែ បុគ្គលនោះមានការព្រមព្រៀងផ្សេងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ។

ការជូនដំណឹងទៅសហកម្មសិទ្ធិករទូទៅណាម្នាក់ ឬការដឹងឮរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់ ដែលពាក់ព័ន្ធទៅនឹងការងាររបស់ក្រុមហ៊ុន ត្រូវចាត់ទុកថាជាសេចក្តីជូនដំណឹង និងការដឹងឮដល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នោះដែរ លើកលែងតែមានការក្លែងបន្លំ ដែលប្រព្រឹត្តឡើងដោយការឃុបឃិតពីសហកម្មសិទ្ធិករទូទៅនោះចំពោះក្រុមហ៊ុន។ បុគ្គលណាម្នាក់ដែលធ្វើឱ្យបុគ្គលផ្សេងទៀតជឿទុកចិត្តដោយផ្ទាល់ ឬដោយប្រយោលថាខ្លួនជាសហកម្មសិទ្ធិករទូទៅ ប៉ុន្តែការពិតបុគ្គលនោះមិនមែនជាសហកម្មសិទ្ធិករទូទៅទេ ត្រូវទទួល-ខុសត្រូវចំពោះតតិយជនដែលធ្វើ ពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ដូចសហកម្មសិទ្ធិករទូទៅពិតៗដែរ ។ ក្នុង

ករណីមានបុគ្គលក្លែងបន្លំ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនទទួលខុសត្រូវចំពោះតតិយជនណាឡើយ លើកលែងតែ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះមិនបានចាត់វិធានការដើម្បីការពារតតិយជននោះ ក្រោយពេលដែលក្រុមហ៊ុនបានដឹងថាមានការក្លែងបន្លំហើយ ។ សហកម្មសិទ្ធិករទូទៅណាម្នាក់ ដែលមិនបានប្រកាសចេញមុខដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលស្គាល់ថាជាសហកម្មសិទ្ធិករទូទៅកំបាំងមុខ ។ សហកម្មសិទ្ធិករទូទៅនោះ ត្រូវទទួលខុសត្រូវចំពោះតតិយជនទាំងឡាយនូវរាល់កាតព្វកិច្ចដូចសហកម្មសិទ្ធិករទូទៅទាំងឡាយដែលបានប្រកាសចេញមុខដែរ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចបោះចេញឬបែងចែកមូលបត្រឬប័ណ្ណដែលអាចលក់ដូរបានទៅឱ្យសាធារណជនឡើយ ។ កិច្ចសន្យាដែលចូលជាធរមានទៅក្នុងការបោះចេញមូលបត្រ ឬប័ណ្ណដែលធ្វើឡើងផ្ទុយពីមាត្រានេះត្រូវ ចាត់ទុកជាមោឃៈ ហើយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវសងនូវការខូចខាតទាំងឡាយដែលបង្កឡើងពីមោឃភាពនៃកិច្ចសន្យាមូលបត្រ ឬប័ណ្ណទៅឱ្យតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ។

**គ-ការផ្ទេរសិទ្ធិជាសហកម្មសិទ្ធិករទូទៅ**

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលដែលបុគ្គល :

-បានផ្ទេរផលប្រយោជន៍របស់ខ្លួន

-បានទទួលមរណភាព

-ត្រូវបានដាក់ក្រោមការពិនិត្យអង្កេតពេលក្ស័យធន

-បានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញ

-ត្រូវបានបណ្តេញចេញពីក្រុមហ៊ុន

-ទទួលសាលក្រមតុលាការអនុញ្ញាតឱ្យដកខ្លួនចេញ ឬបញ្ជាឱ្យរឹបអូសអត្ថប្រយោជន៍របស់បុគ្គលនោះ

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ បង្កឱ្យមានការរំលាយជាស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ លើកលែងតែកិច្ចសន្យាចែងផ្សេងពីនេះ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចបន្តសកម្មភាពទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃការតម្កល់

ទុក និងការចុះបញ្ជី ដើម្បីបង្ហាញអំពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ ប្រសិនបើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរកិច្ចសន្យានោះត្រូវធ្វើការកែប្រែឱ្យស្របតាមនោះដែរ ។ បុគ្គលណាមួយដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រៅពីដោយសារការផ្ទេរ ឬ ដោយសារការរឹបអូសអត្ថប្រយោជន៏របស់ខ្លួនបុគ្គលនោះអាចទទួលនូវតម្លៃណាមួយនៃអត្ថប្រយោជន៏របស់ខ្លួន អំពីការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនេះបាន។ សហកម្មសិទ្ធិករទូទៅដទៃទៀត ត្រូវបង់ការចំណាយជាចាំបាច់ដល់ បុគ្គលនោះនូវតម្លៃណាមួយដែលអាចធ្វើទៅបានដោយឆាប់រហ័សជាមួយ និងការប្រាក់ចាប់ពីថ្ងៃដែលបុគ្គលនោះ អស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ។ តម្លៃនៃអត្ថប្រយោជន៏ត្រូវបានកំណត់ ដូចដែលមានចែងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬកិច្ចសន្យាក្នុងចំណោមសហកម្មសិទ្ធិករទូទៅទាំងឡាយ។ បើមិនដូច្នោះទេ តម្លៃនោះត្រូវកំណត់ដោយអ្នកឯកទេសដែលបានជ្រើសតាំងដោយសហកម្មសិទ្ធិករទូទៅទាំងឡាយ ឬដោយតុលាការ។ សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលមិនកំណត់ ឬកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលចែងអំពីការបម្រុងទុកនូវសិទ្ធិដកខ្លួន សហកម្មសិទ្ធិករទូទៅនោះ អាចដកខ្លួនចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន តាមការជូនដំណឹងអំពីការដកខ្លួនដោយសុទ្ធចិត្ត។ សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលកំណត់អាចដកខ្លួនចេញបាន តែក្នុងករណីមានការយល់ព្រមពី មតិភាគច្រើនដាច់ខាតរបស់ សហកម្មសិទ្ធិករទូទៅទាំងឡាយ បើមិនដូច្នោះទេលុះត្រាតែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចែងផ្សេងពីនេះ។ សហកម្មសិទ្ធិករទូទៅទាំងឡាយអាចបណ្តេញចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវសហកម្មសិទ្ធិករទូទៅ ដែលខក ខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ឬដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដោយប្រៀប។ ក្នុងករណីដែលមានការជំទាស់សហកម្មសិទ្ធិករទូទៅ ទាំងឡាយអាចស្នើសុំការអនុញ្ញាតពីតុលាការ ដើម្បីដកសហកម្មសិទ្ធិករទូទៅនោះចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ តុលាការអាចអនុញ្ញាតនូវការស្នើសុំនោះបាន លុះត្រាតែតុលាការពិចារណាឃើញថាការសុំដកចេញនោះសមស្រប ហើយចេញដីកាផ្អែកទៅតាមកំហុសរបស់សហកម្មសិទ្ធិករទូទៅ។

## កថាខណ្ឌទី ៧: ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយមូលហេតុដូចខាងក្រោម :

១-មូលហេតុដែលមានចែងក្នុងកិច្ចសន្យា

-គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់

-គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត

-តាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ

២-តុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់

នៅពេលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយ ក្រុមហ៊ុននោះអាចធ្វើការជម្រះបញ្ជីបាន ហើយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានបង្កើតឡើងដោយមានកាលកំណត់មួយនៃកិច្ចសន្យា អាចពន្យារបន្តសកម្មភាពរបស់ខ្លួនបានដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់។ ការទទួលដាក់រួមនូវអត្ថប្រយោជន៍ទាំងអស់ទៅក្នុងដៃសហកម្មសិទ្ធិករទូទៅតែម្នាក់ មិនមែនជាមូលហេតុនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ដរាបណាមានបុគ្គលណាមួយផ្សេងទៀតក្លាយជាសហកម្មសិទ្ធិករទូទៅ ក្នុងអំឡុង ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃដែលអត្ថប្រយោជន៍នោះដាក់បញ្ចូលគ្នា។ សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណា ដែលជាវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដែលបានធ្វើពុំទាន់ចប់សព្វគ្រប់។ ប៉ុន្តែរាល់កិច្ចការ ដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅដែលមិនបានដឹងជាមុនអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ។

ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនប៉ះពាល់ទៅនឹងសិទ្ធិតតិយជន ដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ និងមិនប៉ះពាល់ទៅនឹងបុគ្គលណាមួយ ដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ

ឬមិនប៉ះពាល់ទៅនឹង ភ្នាក់ងារណាម្នាក់ ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។ នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បន្តរហូតដល់ចប់នូវការជម្រះបញ្ជីរបស់ក្រុមហ៊ុននោះ។ សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជីផង។ សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុន ក្នុងរយៈពេល ៤ (បួន) សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះ មានការិយាល័យរបស់ខ្លួននៅទីនោះ ឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀត ដូចមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹងដែល បានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។ នៅពេលធ្វើការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ សិទ្ធិក្នុងការកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវប្រគល់ឱ្យអ្នកជម្រះបញ្ជី។ អ្នកជម្រះបញ្ជីត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកចាត់ចែងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងអ្នកជម្រះបញ្ជីត្រូវបានផ្តល់សិទ្ធិពេញលេញក្នុងការចាត់ចែងទាំងមូល។ អ្នកជម្រះបញ្ជីមានសិទ្ធិទាមទារ ពីសហកម្មសិទ្ធិករទូទៅទាំងអស់នូវឯកសារនានា និងការបកស្រាយដែលពាក់ព័ន្ធដល់សិទ្ធិនិង កាតព្វកិច្ចនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិទៅសងបំណុលបៀវត្សបុគ្គលិក បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀតទៅតាមសិទ្ធិបុរិមាជាមុន រួចទើបធ្វើការបែងចែកភាគទុន។ អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិ ដែលនៅសេសសល់ឱ្យទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេង នៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិរបស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឱ្យតតិយជននោះវិញ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះតម្រូវឱ្យទុកជាភស្តុតាង។

ការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ចប់ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះ នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក និង ការតម្កល់ទុកឯកសារនេះគឺជាការលុបចោលនូវ នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។

## ផ្នែកទី ២: ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ដែល មានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រង និងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិត ម្នាក់ ឬច្រើននាក់ ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ ។ បុគ្គលម្នាក់អាចជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផង នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ បុគ្គលម្នាក់ដែលជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផង ក្នុងពេលតែមួយ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមានសិទ្ធិ និងកាតព្វកិច្ចជាសហកម្មសិទ្ធិករទូទៅ ។ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។ ក្នុងករណីកិច្ចសន្យា ធ្វើជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ និងសហកម្មសិទ្ធិករមានកម្រិតយ៉ាងតិចម្នាក់ ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ។ រយៈពេលនៃកិច្ចសន្យារបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនត្រូវលើសកំណត់ ៩៩(កៅសិបប្រាំបួន)ឆ្នាំឡើយ ប៉ុន្តែអាចពន្យារពេលបន្តបាន។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវបានបង្កើតតាមកាលបរិច្ឆេទ ដែលបានចុះបញ្ជីពាណិជ្ជកម្ម ស្របទៅតាមច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ក្នុងករណីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនបានចុះបញ្ជីពាណិជ្ជកម្មទេ ក្រុមហ៊ុននោះត្រូវបានចាត់ទុកថា ជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ ក្នុងករណីនេះ ក្រុមហ៊ុនប្រភេទនេះមិនមាននីតិបុគ្គលិកលក្ខណៈនោះទេ។ នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវបញ្ចូលឈ្មោះរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ និងនៅខាងក្រោយ ឬក្រោមនាមករណ៍នោះ ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ហើយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវប្រើឈ្មោះនោះក្នុងខណៈដែលខ្លួនធ្វើអាជីវកម្ម។ សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាទុកនូវកំណត់ហេតុដែលមានឈ្មោះ អាសយដ្ឋានរបស់សហកម្មសិទ្ធិ-ករ មានកម្រិតម្នាក់ៗ និងព័ត៌មានដែលទាក់ទងទៅនឹងការបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមាន

កម្រិតនោះ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាកំណត់ហេតុទុកនៅទីស្នាក់ការចុះបញ្ជី របស់ក្រុមហ៊ុនសហកម្មសិទ្ធិមាន កម្រិតនោះ។ សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជី ការតម្កល់ទុក និងការផ្សព្វផ្សាយដែលតម្រូវឱ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះអនុវត្ត។ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិត អាចជាទឹកប្រាក់ ឬជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ និងសហកម្មសិទ្ធិករ មានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា។ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ អាចជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលកំពុងបន្តនាពេលបច្ចុប្បន្ន ឬជាការសន្យាថានឹងផ្តល់សេវានាពេលអនាគត។ សហកម្ម-សិទ្ធិករមានកម្រិតម្នាក់ៗ មានសិទ្ធិទទួលចំណែកនៃប្រាក់ចំណេញរបស់ខ្លួន ។ ប៉ុន្តែប្រសិនបើការទទួលប្រាក់ចំណេញនោះ នៅតែធ្វើឱ្យមានឱនភាពដល់ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតដែលបានទទួលចំណែកនៃប្រាក់ចំណេញនោះ ត្រូវបង្វិលចំនួនទឹកប្រាក់ចាំបាច់ណាមួយនៃប្រាក់ចំណេញ ចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ ដើម្បីទប់ទល់ទៅនឹងឱនភាពភាគទុនរបស់ខ្លួន។ សហកម្មសិទ្ធិករមានកម្រិតទទួលខុសត្រូវទៅលើតែចំនួនទឹកប្រាក់ ឬតម្លៃនៃទ្រព្យសម្បត្តិដែលខ្លួនបានព្រមព្រៀងដាក់ជាភាគទុនប៉ុណ្ណោះ។ សហកម្មសិទ្ធិករមានកម្រិត ដែលមានឈ្មោះនៅក្នុងនាមករណ៍ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវទទួលខុសត្រូវ ចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដូចជាសហកម្មសិទ្ធិករទូទៅដែរ លើកលែងតែស្ថានភាពរបស់សហកម្មសិទ្ធិករមានកម្រិតនោះត្រូវបានបញ្ជាក់ច្បាស់លាស់។ សហកម្មសិទ្ធិករទូទៅមានសិទ្ធិនិងកាតព្វកិច្ចដូចជាសហកម្មសិទ្ធិករនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ សហកម្មសិទ្ធិករទូទៅ ត្រូវរាយការណ៍ពីការគ្រប់គ្រងដល់សហកម្មសិទ្ធិករមានកម្រិតទាំងឡាយ។ សហកម្មសិទ្ធិករទូទៅមាន កាតព្វកិច្ចទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិសហកម្មសិទ្ធិករមានកម្រិតដទៃទៀតដែលមាននៅក្នុងដើមទុនរបស់ក្រុមហ៊ុន។ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអាចជៀសវាងកាតព្វកិច្ចនេះបានទេ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវបំណុលទាំងឡាយរបស់ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតចំពោះតតិយជន និងសហកម្មសិទ្ធិករមានកម្រិតអាចទទួលប្រាក់បៀវត្សពី ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន។ នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតកើតឡើងនៅក្នុងករណី ណាក៏ដោយ សហកម្មសិទ្ធិករមានកម្រិតមិនអាចដកចំណែកណាមួយនៃភាគទុន

របស់ខ្លួនបានទេ លើកលែងតែមាន ការយល់ព្រមពីមតិភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ និង ក្រោយពីការដកនោះ ទ្រព្យសម្បត្តិដែល នៅសល់ក្នុងក្រុមហ៊ុនមានគ្រប់គ្រាន់ដើម្បីដោះបំណុលរបស់ក្រុមហ៊ុន សហកម្មសិទ្ធិមានកម្រិតនោះបាន។ សហកម្មសិទ្ធិករមានកម្រិតម្នាក់ អាចធ្វើការផ្ទេរអត្ថប្រយោជន៍របស់ខ្លួន បាន នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករ ដទៃទៀតឡើយ។ ក្នុងទំនាក់ទំនងទៅនឹងតតិយជន សហកម្មសិទ្ធិករមានកម្រិតដែលបានផ្ទេរអត្ថប្រយោជន៍ របស់ខ្លួនរួចមកហើយនោះ នៅតែជាប់ កាតព្វកិច្ចដែលកើតមានឡើងនៅពេលដែលខ្លួននៅជាសហកម្មសិទ្ធិករ មានកម្រិត។ សហកម្មសិទ្ធិករមានកម្រិត មិនអាចចូលរួមនៅក្នុងការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុន សហកម្មសិទ្ធិមានកម្រិតបានទេ និងសហកម្មសិទ្ធិករ មានកម្រិតអាចធ្វើការពិនិត្យរបាយការណ៍ និងការរីក ចំរើនរបស់ក្រុមហ៊ុន និងអាចផ្តល់ជាគំនិតក្នុងការគ្រប់គ្រង ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបានគ្រប់ ដំណាក់កាល។ សហកម្មសិទ្ធិករមានកម្រិតមិនអនុញ្ញាតឱ្យចរចា ក្នុងកិច្ចការពាណិជ្ជកម្មណាមួយក្នុងនាមនៃ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារ ហើយក្រុមហ៊ុនសហកម្មសិទ្ធិនោះ ឬមិន អនុញ្ញាតឱ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្ម ណាមួយរបស់ក្រុមហ៊ុន នោះឡើយ។ សហកម្មសិទ្ធិ-ករមានកម្រិតដែលប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលខុសត្រូវរាល់កាតព្វកិច្ចរបស់ក្រុមហ៊ុន ដែលកើតឡើង ដោយសារការប្រព្រឹត្តទាំងនោះ និងសហកម្មសិទ្ធិករមានកម្រិត អាចអនុញ្ញាតឱ្យទទួល ខុសត្រូវដូចសហកម្ម-សិទ្ធិករទូទៅដែរ ចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ប្រសិនបើសកម្មភាពទាំងឡាយដែលបាន រៀបរាប់រួចហើយ ឬសារៈសំខាន់នៃសកម្មភាពទាំងនោះស្របតាមដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ហើយ មានភស្តុតាងបញ្ជាក់ថា សហកម្មសិទ្ធិករមានកម្រិតធ្វើសកម្មភាពក្នុងនាមសហកម្មសិទ្ធិករទូទៅ ពិតប្រាកដមែន និងនៅពេលសហកម្មសិទ្ធិករទូទៅមិនអាចបំពេញការងារពាណិជ្ជកម្មតទៅមុខទៀតបានទេ សហកម្មសិទ្ធិករ មានកម្រិតអាចបំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃដែលជាតម្រូវការក្នុងដំណើរការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិ មានកម្រិតនោះ។ ក្នុងករណីដែលសហកម្មសិទ្ធិករទូទៅទាំងឡាយ មិនត្រូវបានជំនួសក្នុងរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះនឹងត្រូវបានរំលាយ។ តតិយជនដែលជាម្ចាស់ បំណុលអាចប្តឹងទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនិងពីសហកម្មសិទ្ធិករទូទៅបានដូចគ្នា ដូច

ក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ។ នៅពេលណាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនគ្រប់គ្រាន់ទេ សហកម្មសិទ្ធិករទូទៅទាំងឡាយត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នា ចំពោះតតិយជននូវបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។សហកម្មសិទ្ធិករមានកម្រិតត្រូវទទួលខុសត្រូវនូវបំណុលត្រឹមតែ ចំនួនភាគទុន ដែលខ្លួនបានព្រមព្រៀងដាក់ជាមួយគ្នា ដោយមិនគិតការផ្ទេរអត្ថ-ប្រយោជន៍ណាមួយរបស់ខ្លួនឡើយ។ ក្នុងករណីបំណុលកើនលើសពីដើមទុន ឬក្នុងករណីក្ស័យធននៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតសហកម្មសិទ្ធិករ មានកម្រិតម្នាក់ៗដែលជាម្ចាស់បំណុល មិនអាចទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេរហូតដល់ ម្ចាស់បំណុលដទៃទៀតនៃក្រុមហ៊ុនមានកម្រិតនេះ ត្រូវបានដោះស្រាយចប់សព្វគ្រប់ ហើយវិធាននៃការគ្រប់គ្រង ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវអនុវត្តចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែរ។

និយាយជារួម ក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវសិក្សាក្រោមទម្រង់ជាក់លាក់ ០២ គឺក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវសិក្សាទៅលើ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដំណើរការក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលនៅក្នុងក្របខណ្ឌនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺផ្តោតទៅលើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរ លុះត្រាតែ : ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយអត្ថ-ប្រយោជន៍ នៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ឡើងទៅ ត្រូវបានកាន់កាប់ដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។ នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ហើយនៅខាងក្រោយ ឬខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ" ដោយក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅពេលធ្វើពាណិជ្ជកិច្ច ហើយសហកម្មសិទ្ធករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហក្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវ

រក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយ នៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។

រីឯដំណើរការនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គេធ្វើការពិចារណាទៅលើទំនាក់ទំនងរវាងសហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករទូទៅ ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ និងតតិយជន និងការផ្ទេរសិទ្ធិជាសហកម្មសិទ្ធិករទូទៅ។ នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ទ្រព្យសម្បត្តិ ជាភាគទុន សហកម្មសិទ្ធិករទូទៅនោះ ត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ នៅពេលសហកម្មសិទ្ធិករទូទៅបានយល់ព្រមបង់ភាគទុននូវចំនួនទឹកប្រាក់ណាមួយ ហើយខកខានមិន បានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលខុសត្រូវចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀត ដែលត្រូវទាមទារពីសហកម្មសិទ្ធិករទូទៅនោះ។ នៅពេលសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមដាក់ភាគទុន ជាចំណេះដឹង ជាសេវា ឬជាសកម្មភាព សហកម្មសិទ្ធករទូទៅនោះ ត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ។ កិច្ចសន្យាជាលាយលក្ខណ៍អក្សរ សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ប្រសិនបើ ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ ជាចំណេះដឹង ជាសេវា ឬជាសកម្មភាព។ ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រួមមានភាគទុនជាសាច់ប្រាក់ និងជាវត្ថុ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬភាគទុនជាសកម្មភាពនោះទេ។ ដើមទុនរបស់ក្រុមហ៊ុន សហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ។

ម្យ៉ាងវិញទៀត ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ យើងធ្វើការសិក្សាទៅលើ : មូលហេតុដែលមានចែងក្នុងកិច្ចសន្យា (គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់, គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត, តាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ) និងតុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់។ អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិ ដែល

នៅសេសសល់ឱ្យ ទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេង នៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិ របស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឱ្យតតិយជននោះវិញ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច ។

លើសពីនេះទៅទៀត ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនាមករណ៍របស់ក្រុមហ៊ុន សហកម្មសិទ្ធិមានកម្រិត ត្រូវបញ្ចូលឈ្មោះរបស់សហកម្មសិទ្ធិករ ទូទៅម្នាក់ ឬច្រើននាក់ និងនៅខាងក្រោយ ឬក្រោមនាមករណ៍នោះ ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ហើយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវប្រើឈ្មោះនោះក្នុងខណៈដែលខ្លួនធ្វើអាជីវកម្ម ។សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាទុកនូវកំណត់ហេតុដែលមានឈ្មោះ អាសយដ្ឋានរបស់សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ និងព័ត៌មានដែលទាក់ទងទៅនឹងការបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាកំណត់ហេតុទុកនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ។ សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីការតម្កល់ទុក និងការផ្សព្វផ្សាយដែលតម្រូវឱ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះអនុវត្ត ផងដែរ ។

## ជំពូកទី ២: ក្រុមហ៊ុនមូលធន

ច្បាប់អនុញ្ញាតឱ្យបង្កើតក្រុមហ៊ុនមូលធន ដែលមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដើម្បីប្រកបពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចបង្កើតឡើងក្រោមច្បាប់នេះ ក្នុងគោលបំណងធ្វើអាជីវកម្មធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនឥណទានបានឡើយ ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតគឺជាទម្រង់ទ្រាយមួយនៃ ក្រុមហ៊ុនមូលធនហើយត្រូវមានលក្ខណៈសម្គាល់ដូចជា :

-ក្រុមហ៊ុនអាចមានសមាជិកភាគហ៊ុនពី ០២(ពីរ)នាក់ រហូតដល់៣០ (សាមសិប)នាក់ ។ ប៉ុន្តែបុគ្គលម្នាក់ក៏ អាចបង្កើតក្រុមហ៊ុនបានដែរ ដែលមានឈ្មោះថាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។

សហគ្រាស ឯកបុគ្គលទទួលខុសត្រូវមានកម្រិត មានលក្ខខណ្ឌដូចគ្នាទៅនឹងលក្ខខណ្ឌទាំងឡាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែលក្ខខណ្ឌស្តីពីទំនាក់ទំនងរវាងសមាជិកភាគហ៊ុន។

-ក្រុមហ៊ុននោះមិនអាចអនុញ្ញាតឱ្យលក់ភាគហ៊ុន ឬមូលបត្រដទៃទៀត ជាសាធារណៈបានឡើយ។ ប៉ុន្តែ អាចអនុញ្ញាតឱ្យធ្វើអនុប្បទានទៅសមាជិកភាគហ៊ុនសមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន និងក្នុងករណីធ្វើអនុប្បទានទៅឱ្យតតិយជនត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃទៀតតាមសំឡេងភាគច្រើន។

-ក្រុមហ៊ុននោះអាចមានការរឹតត្បិតមួយ ឬច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់។

-ក្រុមហ៊ុនត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចាប់ពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទជាក់លាក់ ដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។ ក្រុមហ៊ុនមហាជន ទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈបាន។

ក្រុមហ៊ុនពាណិជ្ជកម្មមួយអាចធ្វើសម្ព័ន្ធភាពជាមួយក្រុមហ៊ុនណាមួយទៀតបាន ប្រសិនបើក្រុមហ៊ុន មួយក្នុងចំណោមក្រុមហ៊ុននោះ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនផ្សេងឬក្រុមហ៊ុនទាំងពីរជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនតែមួយដូចគ្នា ឬក្រុមហ៊ុននីមួយៗត្រូវគ្រប់គ្រងដោយបុគ្គលតែមួយរូបដូចគ្នា។ ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មពីរធ្វើសម្ព័ន្ធភាព ជាមួយក្រុមហ៊ុនមួយដូចគ្នានៅក្នុងពេលតែមួយក្រុមហ៊ុនទាំងនោះត្រូវចាត់ទុកថាជាក្រុមហ៊ុនដែលមាន ទំនាក់ទំនងធ្វើសម្ព័ន្ធភាពជាមួយគ្នា។ ស្ថាបនិកឬអភិបាលម្នាក់ៗ ជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តនូវការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងការផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់។

## ផ្នែកទី ១: ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

នៅពេលធ្វើការពិភាក្សា អំពីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺយើងធ្វើការសិក្សាអំពីការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

### កថាខណ្ឌទី ១: ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

នីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬច្រើន ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទេឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់នូវពាក្យថា"ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬសរសេរអក្សរកាត់ដាក់ខាងចុង ឬខាងក្រោម។ នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់នូវពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ឬសរសេរអក្សរកាត់ដាក់ខាងចុង ឬខាងក្រោម។

ដែលតាមរយៈនេះ ត្រូវធ្វើឡើងតាមនីតិវិធីនៃការបង្កើត និងនាំឱ្យកកើតសិទ្ធិ បន្ទាប់ពីក្លាយជានីតិបុគ្គលដែលមានបុគ្គលភាពគតិយុត្ត សម្រាប់ដំណើរការនូវប្រតិបត្តិការពាណិជ្ជកិច្ចរបស់ខ្លួន។

## ក- នីតិវិធីនៃការបង្កើតក្រុមហ៊ុន

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យនូវនាមករណ៍ ដែលបានស្នើសុំដោយក្រុមហ៊ុននោះ ហើយអាចបដិសេធនូវនាមករណ៍ណា ដែលប្រហាក់ប្រហែលគ្នា ធ្វើឱ្យមានការភាន់ច្រឡំទៅនឹងនាមករណ៍របស់ក្រុមហ៊ុនផ្សេងទៀត ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនរួចហើយ ឬនាមករណ៍មួយដែលផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈដែលមានឈ្មោះអាស្រូវ ឬដែលមិនសមរម្យ។ សេចក្តីសម្រេចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដែលពាក់ព័ន្ធទៅនឹងនាមករណ៍របស់ក្រុមហ៊ុន គឺជាសេចក្តីសម្រេចចុងក្រោយ ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងនូវលក្ខខណ្ឌដូច ខាងក្រោម :

-នាមករណ៍របស់ក្រុមហ៊ុន

-ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា

-កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុននោះធ្វើពាណិជ្ជកិច្ច

-កម្មវត្ថុអាជីវកម្ម របស់ក្រុមហ៊ុនអាចមានមួយ ឬច្រើនប្រភេទ ដែលមិនផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់

-ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ

-ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឱ្យបោះចេញដោយក្រុមហ៊ុននោះ

-ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឱ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយប្រភេទហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវចែងចំនួនភាគហ៊ុនអតិបរមា និងតម្លៃចារឹកលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃប័ណ្ណភាគហ៊ុននោះ។

-ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាសេរី លក្ខន្តិកៈក្រុមហ៊ុននោះ ត្រូវអនុញ្ញាតឱ្យអភិបាលកំណត់ចំនួនភាគហ៊ុន នៃសេរីនីមួយៗ ដើម្បីកំណត់ប្លង់បែងចែកសេរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និង លក្ខខណ្ឌដែលភ្ជាប់ទៅនឹងសេរីនីមួយៗនោះ

-ក្នុងករណីការបោះចេញ ការផ្ទេរ ឬការកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធភាព និងមានរបាយការណ៍ពីការកម្រិតនោះ

-ឈ្មោះនិងអាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ

-ចំនួនអភិបាល ឬចំនួនអប្បបរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ

លើសពីនេះទៅទៀត លក្ខន្តិកៈត្រូវរួមបញ្ចូលផងដែរ នូវរាល់ចំណុចផ្សេងទៀតតាមការចាំបាច់ និងលក្ខន្តិកៈអាចធ្វើឡើងតាមរូបភាពជាលិខិតរវាងឯកជន ឬជាលិខិតសារការី។ គ្រប់ទំព័រនៃលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវចុះហត្ថលេខា ឬហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ។ ស្ថាបនិកក្រុមហ៊ុន ត្រូវស្នើសុំទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការតម្កល់ លក្ខន្តិកៈនោះជាមួយឯកសារសុំចុះបញ្ជីពាណិជ្ជកម្មផ្សេងទៀត។ ក្រោយពីការយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុន និងក្រោយពីបានទទួលសោហ៊ុយនៃការតម្កល់នោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវចេញនូវលិខិតបញ្ជាក់មួយជាសម្គាល់ និងក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ចាប់ពីកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម។

## ខ-សិទ្ធិរបស់ក្រុមហ៊ុន

ក្រុមហ៊ុនដែលបានបង្កើតឡើងតាមច្បាប់នេះមានសមត្ថភាព សិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលដែរ។ ក្រុមហ៊ុន អាចប្រកបពាណិជ្ជកិច្ចទូទាំងព្រះរាជាណាចក្រកម្ពុជាបាន និង ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចរបស់ខ្លួន ធ្វើកិច្ចការរបស់ខ្លួន និងអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងដែនសមត្ថកិច្ចនៃ ប្រទេសណាមួយ ក្រៅពីព្រះរាជា-

ណាចក្រកម្ពុជាបាន លុះត្រាតែច្បាប់នៃប្រទេសនោះបានអនុញ្ញាត។ ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរ លុះត្រាតែ :

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១ % (ហាសិបមួយមួយភាគរយ) ត្រូវបានកាន់កាប់ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ក្រុមហ៊ុនមួយអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន។ មិនចាំបាច់ មានបទបញ្ជាផ្ទៃក្នុងមួយ ដែលធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់អំពីសិទ្ធិពិសេសណាមួយទៅលើក្រុមហ៊ុន និងអភិបាលក្រុមហ៊ុន។ ក្រុមហ៊ុនមិនត្រូវប្រកបពាណិជ្ជកិច្ចណាមួយ ឬអនុវត្តសិទ្ធិណាមួយ ដែលលក្ខន្តិកៈរបស់ខ្លួនបាន ហាមឃាត់ ឬមិនត្រូវអនុវត្តសិទ្ធិណាមួយ ដែលផ្ទុយពីលក្ខន្តិកៈរបស់ខ្លួនឡើយ។ ប្រការដែលក្រុមហ៊ុនបានប្រព្រឹត្តរំលោភលើលក្ខន្តិកៈរបស់ខ្លួន មិននាំឱ្យមានមោឃភាពដល់ការប្រព្រឹត្តនោះឡើយ វិធាននេះអនុវត្តចំពោះគ្រប់ការប្រព្រឹត្តរួមមានការផ្ទេរទ្រព្យសម្បត្តិទៅឱ្យក្រុមហ៊ុនឬការផ្ទេរទ្រព្យសម្បត្តិពីក្រុមហ៊ុន។ ប្រការដែលមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មតម្កល់ទុកឯកសាររបស់ក្រុមហ៊ុន ឬប្រការដែលឯកសារសម្រាប់ធ្វើអធិការកិច្ច ដែលថតចម្លងទុកនៅក្នុងការិយាល័យក្រុមហ៊ុនមិនត្រូវបានចាត់ទុកថា ធ្វើឱ្យប៉ះពាល់ទៅលើបុគ្គលណាមួយឬជាការជូនដំណឹងដល់បុគ្គលណាមួយឡើយ។ ក្រុមហ៊ុន ឬបុគ្គលម្នាក់ដែលធានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោមជាលេស ដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជនដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះ ឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបានឡើយ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ ឬបានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួន ឬដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះ :

-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម

-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុតដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ

-ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន នៃក្រសួងពាណិជ្ជកម្មមិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ

-បុគ្គលដែលជាអភិបាល បុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំង ឬមិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្ត និងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន

-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬភ្នាក់ងារណាម្នាក់របស់ក្រុមហ៊ុនមិនមានសុពលភាព ឬមិនយកជាការបានឡើយ

-ប្រាក់ខ្ចី និងការធានា ឬការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ

## កថាខណ្ឌទី ២: ដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

នៅពេលដែលបង្កើតបាននូវក្រុមហ៊ុនដែលមានលក្ខណៈពេញច្បាប់ តម្រូវឱ្យមានមានភារកិច្ច ឬកាតព្វកិច្ចមួយយចំនួន ដែលត្រូវអនុវត្តនៅក្នុងការបំពេញសកម្មភាពរបស់ខ្លួន។

នៅក្នុងដំណើរការរបស់ក្រុមហ៊ុន ត្រូវប្រតិបត្តិនូវការងារមួយចំនួន ដូចជា ការចុះបញ្ជីពាណិជ្ជកម្ម សៀវភៅបញ្ជី កំណត់ហេតុ ការប្រកាសប្រតិវេទន៍ អភិបាលក្រុមហ៊ុន ម្ចាស់ភាគហ៊ុន ភាគហ៊ុន ភាគលាភ មូលបត្រ អ្នកថែរក្សាទ្រព្យ និងរបាយការណ៍ហិរញ្ញវត្ថុ។

### ក- ការចុះបញ្ជីពាណិជ្ជកម្ម

នៅគ្រប់ពេលវេលា ក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបានបញ្ជាក់នៅ ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវផ្តល់ឱ្យទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវ សេចក្តីជូនដំណឹងអំពីទីតាំង ទីស្នាក់ការចុះបញ្ជីជាមួយគ្នា និងលក្ខន្តិកៈដែលស្តីពីទីតាំង ឬពីការផ្លាស់ប្តូរទីតាំងស្នាក់ ការចុះបញ្ជីនោះ។ លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរទីតាំងរបស់ទីស្នាក់ការចុះបញ្ជីត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់ គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរនោះ។ ក្រុមហ៊ុនត្រូវរៀបចំនិងរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ខ្លួននូវ :

-លក្ខន្តិកៈ និងគ្រប់ការកែប្រែទាំងអស់

-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចទាំងឡាយរបស់ម្ចាស់ហ៊ុន

-ឯកសារនៃសេចក្តីជូនដំណឹងតម្រូវឱ្យផ្ញើ ឬតម្កល់ទុកជាឯកសារ

-បញ្ជីមូលបត្រ

## ខ- សៀវភៅបញ្ជី និងកំណត់ហេតុ

ម្ចាស់ហ៊ុន និងម្ចាស់បំណុលរបស់ក្រុមហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់ របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអាចពិនិត្យគ្រប់ឯកសារដូចដែលបានចែង នៅក្នុងអំឡុងពេលម៉ោងធ្វើ អាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើសម្រង់បានដោយមិនគិតកម្រៃ។ ប្រសិនបើក្រុមហ៊ុនជាក្រុមហ៊ុនមហាជន ទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាចធ្វើសម្រង់លើគ្រប់ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្របរាល់បញ្ជីឈ្មោះម្ចាស់ហ៊ុន មិនត្រូវបានប្រើដោយបុគ្គលណាម្នាក់ឡើយ លើកលែងតែបុគ្គលនោះមានការពាក់ព័ន្ធជាមួយ :

-ការខិតខំប្រឹងប្រែងដើម្បីរកសំឡេងគាំទ្រក្នុងការបោះឆ្នោតពីម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន

-ការផ្តល់សំណើទិញភាគហ៊ុនរបស់ក្រុមហ៊ុន

-អ្វីផ្សេងៗទៀត ដែលទាក់ទងទៅនឹងការងាររបស់ក្រុមហ៊ុន ដោយក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងឡាយ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអភិបាលឱ្យបានសព្វគ្រប់ និងកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល ត្រូវរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅកន្លែងដទៃទៀត ដែលអភិបាលយល់ឃើញថាសមស្រប ហើយឯកសារទាំងនោះ ត្រូវបាន បើកចំហ ដើម្បីឱ្យអភិបាលធ្វើការពិនិត្យបានគ្រប់ពេល។ ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវបញ្ជីគណនេយ្យ ឱ្យបានគ្រប់គ្រាន់សម្រាប់រយៈពេល ១០(ដប់)ឆ្នាំ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ។ ប្រសិនបើបញ្ជីគណនេយ្យត្រូវរក្សា ទុកនៅក្រៅព្រះ-រាជណាចក្រកម្ពុជា ឯកសារច្បាប់ចម្លងនៃបញ្ជីគណនេយ្យនោះ ក៏ត្រូវរក្សាទុកនៅទីស្នាក់ការចុះបញ្ជីផងដែរ។ ក្រុមហ៊ុន និងភ្នាក់ងាររបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកសៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្នឱ្យបានទ្បេងទាត់ និងការពារឱ្យបានត្រឹមត្រូវ។ លិខិតស្នាម ឬកិច្ចសន្យា ដែលបាន

ធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬអ្នកគ្រប់គ្រងម្នាក់ ឬភ្នាក់ងារម្នាក់ របស់ក្រុមហ៊ុនមានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ ។

### គ- ការប្រកាសប្រតិវេទន៍

ប្រតិវេទន៍នេះត្រូវមាននិទ្ទេសទាក់ទងនឹងបុគ្គល (នាមរបស់ពាណិជ្ជករ ឬរបស់សមាជិកក្រុមហ៊ុន សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៅក្នុងរឿងពាណិជ្ជកម្ម សញ្ជាតិ ស្ថានភាពគ្រួសារ...) និងគ្រឹះស្ថាន (ពាណិជ្ជនាម រហ័សនាម អាស័យដ្ឋាន ផ្លាកសញ្ញាក្រុមហ៊ុន កម្មវត្ថុរបស់ក្រុមហ៊ុន ពាណិជ្ជកម្ម ពោលគឺព័តិមានដែលទាក់ទងនឹងមូលនីធិពាណិជ្ជកម្ម) ។

ប្រតិវេទន៍ធ្វើឡើងដោយ ៣ ច្បាប់ (ចំពោះក្រុមហ៊ុន) ដែលត្រូវយកទៅដាក់ដោយអ្នកស្នើសុំ ឬ អាណត្តិគាហក ដែលមានលិខិតប្រគល់សិទ្ធិអំណាច ហើយលិខិតនេះត្រូវតំកល់ទុកនៅកន្លែងទទួលពាក្យសុំចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

បើប្រតិវេទន៍យកទៅដាក់ដោយផ្ទាល់ ដោយអ្នកស្នើរសុំ មន្ត្រីចុះឈ្មោះពាណិជ្ជកម្ម និងធ្វើការផ្ទៀងផ្ទាត់ក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន អំពីបែបបទទាំងឡាយតាមបញ្ញត្តិច្បាប់ដូចជា ត្រូវចុះនៅលើផ្នែកខាងលើនៃប្រតិវេទន៍នៅនីតិវិធីដូចតទៅ ÷

-ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការកំនត់ និងទីកន្លែង

-លេខរៀងប្រតិវេទន៍តាមលំដាប់ជាបន្តបន្ទាប់

-អត្តលេខសំគាល់តាមប្រភេទនៃសកម្មភាពរបស់ពាណិជ្ជកម្មដែលត្រូវចុះបញ្ជីវិភាគ (តារាងធ្វើវិភាគលើស្ថានភាពក្រុមហ៊ុនដើមទុន) ។

ចំពោះអ្នកធ្វើប្រតិវេទន៍ដែលមិនបានផ្តល់ព័តិមានគ្រប់គ្រាន់ដល់ការចុះបញ្ជី និងត្រូវបានអនុញ្ញាតពិសេសចំនួន ១៥ថ្ងៃ បន្ថែមទៀត។ បន្ទាប់ពីបានពិនិត្យប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងឯកសារតំកល់រួចរាល់ ហើយមន្ត្រី ចុះបញ្ជី នឹងផ្តល់នូវវិញ្ញាបនបត្រចុះបញ្ជីដែលហៅថាសំរង់ ដែលមានចុះអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម។វិញ្ញាណបនបត្រនេះ ត្រូវបិតនៅក្នុងលក្ខណៈបណ្តោះអាសន្នក្នុងរយះពេល ១ ខែ គត់ គិតចាប់តាំងពីថ្ងៃដែលបានផ្តល់ជូន ក្នុងថេរវេលានេះ ប្រសិនបើរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំ មន្ត្រីចុះបញ្ជី

ពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មអាចជំទាស់បាននូវការចុះបញ្ជីនេះ និងលុបចោលអត្តលេខសំគាល់ដែលមានចុះក្នុងបញ្ជីហើយ។ ច្បាប់ពុំបានកំនត់ច្បាស់លាស់ នូវរយៈពេលនៃការចេញវិញ្ញាបនបត្របណ្តោះអាសន្ននោះទេ។ ការបើនិទ្ទេសដែលមាននៅក្នុងប្រតិវេទន៍ ត្រូវបានកត់ត្រាទុកក្នុងបញ្ជីវិភាគ មន្ត្រីចុះបញ្ជីត្រូវប្រគល់ជូនអ្នកដែលយកមកតំកល់នៅប្រតិវេទន៍មួយច្បាប់ដែល មានហត្ថលេខាត្រឹមត្រូវសំរាប់ប្រើប្រាស់ជាវិញ្ញាណបនបត្រចុះឈ្មោះប៉ុណ្ណោះ។ លើសពីនេះទៅទៀត នៅក្នុងលិខិតប្រតិវេទន៍នោះ គេរៀបរាប់ចំណុចសំខាន់ៗ មួយចំនួនដូចជា នាមករណ៍ អាស័យដ្ឋានស្នាក់ការចុះបញ្ជី សមាសភាពម្ចាស់ភាគហ៊ុន និងការកែប្រែ សមាសភាពក្រុម-ប្រឹក្សាភិបាល និងការប្រែប្រួល កម្មវត្ថុ លេខកូដចុះបញ្ជី សញ្ជាតិ ទ្រង់ទ្រាយក្រុមហ៊ុន និងសាខា គោលការណ៍របស់ក្រសួងពាណិជ្ជកម្ម គោលការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគោលការណ៍ផ្សេងៗទៀត។

## ឃ- អភិបាលក្រុមហ៊ុន និងម្ចាស់ហ៊ុន

### ១-អភិបាលក្រុមហ៊ុន

នៅពេលតម្កល់ទុកឯកសារ និងលក្ខន្តិកៈការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ស្ថាបនិកទាំងឡាយត្រូវផ្តល់ទៅមន្ត្រី ទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងរបស់អភិបាលទៅតាម បែបបទដែលបានកំណត់ដោយក្រសួងពាណិជ្ជកម្ម។ ក្រោយពីចេញវិញ្ញាបនបត្របញ្ជាក់ពីការបង្កើតក្រុមហ៊ុន ស្ថាបនិកម្នាក់ ឬអភិបាលម្នាក់អាចកោះប្រជុំក្រុមប្រឹក្សាភិបាលបានដោយផ្តល់ការជូនដំណឹងយ៉ាងតិច០៥(ប្រាំ)ថ្ងៃ តាមរយៈលិខិតទៅ គ្រប់អភិបាល ។ លិខិតជូនដំណឹងនោះ មានបញ្ជាក់ពីពេលវេលា និងទីកន្លែងប្រជុំផង។អភិបាលដំបូងត្រូវកាន់ តំណែង ចាប់ពីកាលបរិច្ឆេទនៃការបង្កើតក្រុមហ៊ុនរហូតដល់មានមហាសន្និបាតម្ចាស់ហ៊ុនលើកទីមួយ។ ក្រុមប្រឹក្សាភិបាលដំបូងទាំងឡាយ ត្រូវចាត់ចែងមហាសន្និបាតលើកទី ១ របស់ម្ចាស់ហ៊ុនក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីក្រុមហ៊ុនបានបង្កើតឡើង។ លិខិតជូនដំណឹងពីមហាសន្និបាតនោះ ត្រូវចែកយ៉ាងហោចណាស់ ២០ (ម្ភៃ)ថ្ងៃ មុនទៅបុគ្គល ដែលមានសិទ្ធិចូលរួមមហាសន្និបាតនោះ។ លិខិតជូនដំណឹងត្រូវបញ្ជាក់អំពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈនៃមហាសន្និបាតនោះ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬច្រើននាក់។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលយ៉ាងតិច ០៣(បី) នាក់។ ម្ចាស់ហ៊ុនត្រូវបោះឆ្នោត ជ្រើសរើសអភិបាល តាមរយៈសេចក្តីសម្រេច

សាមញ្ញ នៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ ក្រុមប្រឹក្សាភិបាល ត្រូវចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន។ លក្ខន្តិកៈក្រុមហ៊ុនត្រូវចែងពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍ :

-តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ។

-កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ។

-កម្រិតប្រាក់បៀវត្ស ឬប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ និងដាក់ជូនទៅម្ចាស់ហ៊ុនដើម្បីសុំសេចក្តីសម្រេច។

-ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាម ដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយនោះ។

-ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬលុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន។

-ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ។

-ស្នើសុំម្ចាស់ហ៊ុន ដើម្បីលក់ទ្រព្យសម្បត្តិ ក្រុមហ៊ុនទាំងអស់ ឬមួយភាគ។

-ស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន។

-ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុន ប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ។

-ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

- ខ្ចីប្រាក់។

- បោះចេញ បោះចេញសាជាថ្មី ឬលក់មូលបត្ររបស់ក្រុមហ៊ុន។

-ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន។

-ធ្វើអ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន។

-រៀបចំការបិទបញ្ជី គណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន។

រាល់រូបវន្តបុគ្គល ដែលមានសមត្ថភាពមានអាយុលើសពី ១៨ (ដប់ប្រាំបី)ឆ្នាំ អាចបម្រើការងារជាអភិបាល ឬជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបាន ។ អភិបាលមិនចាំបាច់ជាម្ចាស់ហ៊ុនទេ ឬមិនចាំបាច់តម្រូវឱ្យមានលក្ខណសម្បត្តិណាផ្សេងទៀតទេ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឱ្យមានលក្ខខណ្ឌតម្រូវ។ ក្នុងករណីលក្ខន្តិកៈក្រុមហ៊ុនមិនចែងអំពីអាណត្តិទេ អភិបាលម្នាក់ៗត្រូវមានអាណត្តិ ០២(ពីរ)ឆ្នាំ ហើយ អាចត្រូវបោះឆ្នោតឱ្យសាជាថ្មីទៀតបាន។ អាណត្តិរបស់អភិបាល អាចត្រូវកំណត់ជាតំណាក់ៗ តែអាណត្តិរបស់អភិបាលទាំងឡាយមិនអាចបញ្ចប់ក្នុងឆ្នាំ ជាមួយគ្នាបានឡើយ។ លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចចែងបានផងដែរពីសិទ្ធរបស់អ្នកកាន់ប័ណ្ណភាគហ៊ុននៃប្រភេទនីមួយៗ ដើម្បីបោះឆ្នោតជ្រើសរើសអភិបាលមួយ ឬច្រើន ដែលអភិបាលនោះបម្រើអាណត្តិ និងមានសិទ្ធិចាត់ចែងការងារផ្សេងៗ ដែលបានចែងក្នុងលក្ខន្តិកៈ។ អាណត្តិនៃមុខតំណែង និងសិទ្ធិនៃការបោះឆ្នោតរបស់អភិបាលប្រភេទមួយអាចច្រើនជាង ឬតិចជាងអភិបាលប្រភេទមួយផ្សេងទៀតបាន។ អភិបាលអាចត្រូវដកហូតចេញពីមុខតំណែងបាន ដោយសំឡេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិ បោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ។ អភិបាលអាចលាលែងពីមុខតំណែងនៅពេលណាក៏បានដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុន។ ការលាលែងពីមុខតំណែងនេះ ត្រូវមានសុពល ភាពភ្លាម ឬមានប្រសិទ្ធភាពចាប់ពីពេលដែលបានចែងនៅក្នុងលិខិត ជូនដំណឹងនោះ។ អភិបាលម្នាក់ ដែលជាអភិបាលនៅសល់ចុងក្រោយក្នុងក្រុមហ៊ុន ហើយអភិបាលនោះធ្វើការ លាលែងមុនពេលអភិបាលផ្សេងត្រូវបានតែងតាំង ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបានបង្កឡើងដល់ ក្រុមហ៊ុនដោយសារការលាលែងរបស់ខ្លួន។ បន្ទាប់ពីអាណត្តិរបស់ខ្លួនបានផុតកំណត់ អភិបាលត្រូវបន្តបម្រើការងារ របស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសតាំងជំនួសជាថ្មី។ ក្រុមប្រឹក្សាភិបាល ត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ពីក្នុងចំណោមសមាជិករបស់ខ្លួន។ ប្រធានក្រុមប្រឹក្សាភិបាលអាចត្រូវដកហូតពីមុខតំណែងដោយសំឡេងភាគច្រើន ដាច់ខាតរបស់អភិបាលទាំងឡាយ ប៉ុន្តែមិនត្រូវបានដកហូតពីឋានៈអភិបាលឡើយ។ ប្រធានក្រុមប្រឹក្សាភិបាលមានសិទ្ធិអញ្ជើញអភិបាលប្រជុំ។ មួយភាគបីនៃសមាជិកក្រុមប្រឹក្សាភិបាល ដែលបម្រើការងារក៏អាចអញ្ជើញក្រុមប្រឹក្សាភិបាលប្រជុំបានដែរ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងនៅក្នុងព្រះរាជា ណាចក្រកម្ពុជា លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ។ ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំយ៉ាងតិច មួយដង

ក្នុងរយៈពេលរាល់បីខែ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលយកជាបានការ លុះត្រាតែមានសំឡេងភាគច្រើនដោយប្រៀបរបស់សមាជិក ឬតំណាងដែលមានវត្តមាន។ ក្រុមប្រឹក្សាភិបាលអាចជួបប្រជុំនៅកន្លែងណាមួយទៅតាមលិខិតជូនដំណឹង។ លិខិតជូនដំណឹងត្រូវបញ្ជាក់ផងដែរពីកាលបរិច្ឆេទ និងរបៀបវារៈពិស្តារ និងអភិបាលអាចអនុគ្រោះដល់ការខ្វះខាតពីការមិនបានទទួលលិខិតជូនដំណឹងពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ ប៉ុន្តែនៅពេលចូលរួមប្រជុំ អភិបាលនោះអាចធ្វើការជំទាស់ទៅនឹងពាណិជ្ជកិច្ចណាមួយបាន ដោយសំអាងថាការប្រជុំ នោះមិនបានកោះហៅត្រឹមត្រូវតាមច្បាប់កំណត់។ អភិបាលអាចធ្វើសកម្មភាពបានតាមរយៈការទាក់ទងគ្នាជាលិខិត លើកលែងតែលក្ខន្តិកៈចែងផ្សេង។ រាល់អភិបាលត្រូវទទួលសំណុំរឿងនៃសេចក្តីសម្រេចដែលត្រូវស្នើសុំការពិនិត្យ និងការសម្រេចគាំទ្រ ឬមិនគាំទ្រ ព្រមទាំងសន្លឹកឆ្នោតសម្រាប់បោះ "ព្រម" ឬ "មិនព្រម" ចំពោះប្រធានបទនោះ ។ ក្នុងករណីដែលអភិបាលទាំងអស់ បោះឆ្នោតអនុម័តលើប្រធានបទមួយប្រធានបទនោះត្រូវចាត់ទុកថាមានការ អនុម័តដោយក្រុមប្រឹក្សាភិបាល។ ការឆ្លើយតបជាលិខិតត្រូវចូលជាផ្នែកមួយនៃកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាល លេខាធិការរបស់ក្រុមហ៊ុន ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរពីការប្រាស្រ័យទាក់ទងគ្នាជាលិខិតនោះ និងត្រូវចែករបាយការណ៍នេះទៅអភិបាលទាំងអស់។ ដើម្បីសម្រួលការងាររបស់ខ្លួនក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងៗបាន តាមការចាំបាច់។ គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល អាចត្រូវបង្កើតឡើងដោយ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនីមួយៗត្រូវមានអភិបាលមួយរូប ឬច្រើនរូបដែល ត្រូវតែងតាំងដោយសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការ ត្រូវអនុវត្តកិច្ចប្រជុំរបស់ខ្លួនតាមវិធីដូចគ្នានឹងក្រុមប្រឹក្សាភិបាលដែរ។ គណៈកម្មាធិការនីមួយៗ ត្រូវមានសិទ្ធិដែលបានផ្តល់ឱ្យដោយឯកសារជាលាយលក្ខណ៍អក្សរ ដែលបានបង្កើតគណៈកម្មាធិការនោះ ប៉ុន្តែគណៈកម្មាធិការមួយមិនអាចត្រូវបានគេផ្ទេរអំណាចណាមួយដើម្បីធ្វើសកម្មភាពដូចតទៅនេះទេ :

-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន។

-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលណាមួយផ្សេង ។

-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមួយភាគ ឬទាំងអស់។

-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន។

-ប្រកាសភាគលាភ។

-បោះចេញនូវប័ណ្ណភាគហ៊ុននៅក្នុងក្រុមហ៊ុន។

ចំនួនភាគច្រើននៃអភិបាលទាំងអស់ ដែលមានវត្តមាននៅក្នុងពេល ប្រជុំបង្កើតបានជាកូរ៉ុមរបស់ក្រុមប្រឹក្សាភិបាល ឬរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលនោះ ប៉ុន្តែលក្ខន្តិកៈរបស់ក្រុមហ៊ុនអាចតម្រូវឱ្យកូរ៉ុមមានចំនួនច្រើនជាងនេះបាន និងអភិបាលម្នាក់ ត្រូវមានសំឡេងឆ្នោតតែមួយ ដោយអភិបាលអាចធ្វើជាអាណត្តិគាហកៈឱ្យអភិបាលមួយរូប ផ្សេងទៀតបាន នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយ មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដែលបានចុះ ហត្ថលេខាដោយអភិបាលដែលខ្លួនធ្វើតំណាងឱ្យ។ លេខាធិការត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុនៃកិច្ចប្រជុំ ទាំងអស់របស់ក្រុមប្រឹក្សាភិបាល ហើយត្រូវផ្ញើឯកសារថតចម្លងនៃកំណត់ហេតុនេះ ទៅឱ្យអភិបាលទាំងអស់។ ក្រុមហ៊ុនអាចចេញសងការចំណាយដល់អភិបាលបច្ចុប្បន្ន ឬអភិបាលពីមុនអ្នកគ្រប់គ្រង ឬបុគ្គលិករបស់ក្រុមហ៊ុន ក្នុងការបំពេញភារកិច្ចដែលបានអនុវត្តដោយស្មោះត្រង់ និងសមហេតុសមផល។ ការចេញសងត្រូវធ្វើឡើង នៅពេល ដែលអភិបាល អ្នកគ្រប់គ្រង ឬបុគ្គលិកបានសំអាងក្នុងឆន្ទៈល្អនៅលើកំណត់ហេតុ ឬសៀវភៅបញ្ជី ដែលមានភាព ត្រឹមត្រូវរបស់ក្រុមហ៊ុន ឬនៅលើព័ត៌មានមានមតិយោបល់ របាយការណ៍ផ្សេងៗ ឬរបាយការណ៍ ដែលបង្ហាញដោយអ្នក គ្រប់គ្រងណាម្នាក់របស់ក្រុមហ៊ុននោះ ឬជនណាម្នាក់ផ្សេងអំពីបុគ្គលទាំងនោះ។ ការចេញសងត្រូវបានអនុវត្តចំពោះ តែការចំណាយ ឬការខូចខាតសមហេតុសមផលដែលទទួលរងដោយអភិបាល អ្នកគ្រប់គ្រង ឬបុគ្គលិកនៅពេល បម្រើការងារឱ្យក្រុមហ៊ុនប៉ុណ្ណោះ។ អភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុន ត្រូវបង្ហាញនូវទំហំផលប្រយោជន៍របស់ខ្លួន ជាលាយលក្ខណ៍អក្សរទៅឱ្យក្រុមហ៊ុន ឬស្នើឱ្យមានសេចក្តីប្រកាស ដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងករណី :

-ដែលខ្លួនជាភាគីនៃកិច្ចសន្យា ឬជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន។

-ដែលខ្លួនមានអត្ថប្រយោជន៍ជាមួយបុគ្គលណាម្នាក់ ដែលជាភាគីក្នុងកិច្ចសន្យាឬភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន។

ក្នុងករណីជាអភិបាល ការបង្ហាញត្រូវធ្វើឡើង :

-នៅពេលប្រជុំកិច្ចសន្យាដែលបានស្នើឡើងត្រូវពិចារណាជាលើកទីមួយ។

-នៅពេលប្រជុំលើកិច្ចសន្យា អភិបាលនោះមិនបានបង្ហាញថាមានការពាក់ព័ន្ធផលប្រយោជន៍ទេប៉ុន្តែក្រោយមកគាត់បានបញ្ជាក់ថាមានការពាក់ព័ន្ធ។

-នៅក្រោយពេលកិច្ចសន្យាត្រូវបានធ្វើឡើង ហើយក្រោយមកអភិបាលនោះ បានបង្ហាញប្រាប់ថាមានការពាក់ព័ន្ធដល់ផលប្រយោជន៍របស់ខ្លួ ន។

-ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន ហើយក្រោយមកបុគ្គលនោះបានក្លាយជាអភិបាល។

ក្នុងករណីជាអ្នកគ្រប់គ្រងក្រុមហ៊ុន ការបង្ហាញត្រូវធ្វើឡើង :

-ក្រោយពីអ្នកគ្រប់គ្រងនោះ ដឹងភ្លាមថាកិច្ចសន្យា ឬកិច្ចសន្យាដែលបានដាក់ស្នើសុំនោះត្រូវសម្រេច ឬត្រូវបានសម្រេចរួចហើយ នៅក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល។

-ប្រសិនបើអ្នកគ្រប់គ្រងនោះ បានបកស្រាយបង្ហាញមុនពេលដែលកិច្ចសន្យានោះបានធ្វើរួចរាល់។

-ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន និងក្រោយមកបុគ្គលនោះបានក្លាយជាអ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ ។

អភិបាលដែលមានពាក់ព័ន្ធពីផលប្រយោជន៍ មិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងការធ្វើសេចក្តី សម្រេចណាមួយ ក្នុងការអនុម័តកិច្ចសន្យាមួយទេ លើកលែងតែកិច្ចសន្យានោះជា :

-ការសម្របសម្រួលតាមរយៈការធានាសម្រាប់ទឹកប្រាក់ ដើម្បីឱ្យទៅអ្នកខ្ចី ឬកាតព្វកិច្ចទាំងឡាយ ដែលបានធានាអនុវត្តដោយអភិបាលនោះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុន ឬដល់សាខាមួយរបស់ក្រុមហ៊ុន។

-កិច្ចសន្យាដែលទាក់ទងជាចម្បងទៅនឹងទឹកប្រាក់បំណាច់របស់ខ្លួន ដែលជាអភិបាល អ្នកគ្រប់គ្រងបុគ្គលិកភ្នាក់ងារ របស់ក្រុមហ៊ុន ឬសាខាមួយរបស់ក្រុមហ៊ុន។

-កិច្ចសន្យាមួយធ្វើឡើងជាការរ៉ាប់រងសងការខូចខាត ឬជាការធានា។

- កិច្ចសន្យាមួយធ្វើឡើងជាមួយសាខាណាមួយ។

លក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនអាចមានចែង :

-ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមានសិទ្ធិចាត់ចែងការិយាល័យរបស់ក្រុមហ៊ុន តែងតាំងអ្នកគ្រប់គ្រងក្រុមហ៊ុន កំណត់តួនាទីភារកិច្ចនិងសិទ្ធិរបស់អ្នកទាំងនោះឱ្យបានច្បាស់លាស់ ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន។

-អភិបាលអាចត្រូវបានតែងតាំងឱ្យគ្រប់គ្រងការិយាល័យណាមួយរបស់ក្រុមហ៊ុន។

-បុគ្គលម្នាក់អាចរៀបចំគ្រប់គ្រងការិយាល័យមួយ ឬច្រើនរបស់ក្រុមហ៊ុនបាន។

បុគ្គលម្នាក់ៗដែលបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្នុងនាម ឬតំណាងឱ្យក្រុមហ៊ុនមុនពេលក្រុមហ៊ុននោះមានអត្ថិភាព ឬបុគ្គលនោះត្រូវជាប់កាតព្វកិច្ចដោយផ្ទាល់នៅក្នុងកិច្ចសន្យានោះ និងមានសិទ្ធិក្នុងការទទួលផលប្រយោជន៍នោះដែរ។ ក្រោយពីកិច្ចសន្យាមួយ បានបង្កើតឡើងក្នុងពេលវេលាមួយសមស្របក្រុមហ៊ុន អាចទទួលយកបាននូវកិច្ចសន្យាជាលាយលក្ខណ៍អក្សរនោះ ដែលបានធ្វើឡើងមុនពេលក្រុមហ៊ុនមានអត្ថិភាព និងមុនការ ទទួលយល់ព្រមនៅក្នុងក្រុមហ៊ុន។ ការទទួលនេះផ្អែកលើសកម្មភាព ឬការប្រព្រឹត្តដែលផ្តោតទៅលើគោលបំណងដ៏ សំខាន់នៃកិច្ចសន្យា ដែលបានជាប់កាតព្វកិច្ចរួចមកហើយនោះ ។ ក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចដោយកិច្ចសន្យា ហើយមានសិទ្ធិក្នុងការទទួលផលប្រយោជន៍ដូចពេលដែលក្រុមហ៊ុនមានអត្ថិភាព ចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា និងដូចពេលដែលក្រុមហ៊ុននោះជាចំណែកមួយនៃកិច្ចសន្យា។ បុគ្គលម្នាក់ដែលប្តឹងទាមទារថាបានអនុវត្តក្នុងនាម ឬតំណាងឱ្យក្រុមហ៊ុនមានកាតព្វកិច្ច ឬមានសិទ្ធិទទួលផលប្រយោជន៍នៅក្នុងកិច្ចសន្យាបាន លុះត្រាតែមានដីកាសម្រេចរបស់តុលាការ។ អភិបាលដែលបោះឆ្នោតឱ្យ ឬយល់ព្រមក្នុងការធ្វើសេចក្តីសម្រេចលើការអនុញ្ញាតឱ្យចេញ ប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូល ដែលមិនមែនជាសាច់ប្រាក់ទេត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នា ចំពោះក្រុមហ៊ុនទៅតាមចំនួនតម្លៃសមមូលដែលបានទទួលដែលតិចជាងតម្លៃត្រឹមត្រូវជាសាច់ប្រាក់ ដែលក្រុមហ៊ុនបានទទួលប្រសិនបើប័ណ្ណភាគហ៊ុនដែល បានបោះចេញនោះសម្រាប់លក់យកជាប្រាក់នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច។ អភិបាលមិនទទួលខុសត្រូវទេ ប្រសិនបើអភិបាលនោះបង្ហាញថាមិនបានដឹងថាភាគហ៊ុនដែលបោះ ចេញសម្រាប់តម្លៃសមមូល ដែលតិចជាងសាច់ប្រាក់

ដែលក្រុមហ៊ុនអាចនឹងទទួលប្រសិនបើប័ណ្ណភាគហ៊ុននោះ ដែលបានបោះចេញសម្រាប់លក់យកជាប្រាក់។ សកម្មភាពក្នុងការអនុវត្តនូវការទទួលខុសត្រូវបំណុល ដែលតម្រូវដោយច្បាប់នេះមិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ)ឆ្នាំបានទេ ចាប់ពីកាលបរិច្ឆេទនៃ សេចក្តីសម្រេច របស់អភិបាលនោះ។ អភិបាលដែលបានបោះឆ្នោតឱ្យ ឬ យល់ព្រមចំពោះសេចក្តីសម្រេចដែលអនុញ្ញាតឱ្យមានការ ទិញមកវិញនូវភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានលក់កន្លងមក ឬធ្វើការបន្ថយដើមទុនតាមវិធីណាមួយ ឬធ្វើការចែកភាគលាភ ដែលផ្ទុយពីបទប្បញ្ញត្តិនៃជំពូកនេះត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវរាល់ចំនួនដែល បានបែងចែក ឬបានបង់ហើយ ដើម្បីស្តារក្រុមហ៊ុនឡើងវិញ។ សកម្មភាពដើម្បីអនុវត្តការទទួលខុសត្រូវដែលតម្រូវដោយមាត្រានេះ មិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ) ឆ្នាំ បានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ។ អភិបាលម្នាក់ ដែលមានវត្តមាននៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកថាបានយល់ព្រមនូវរាល់សេចក្តីសម្រេចដែលបានអនុម័ត ឬសកម្មភាពដែល បានធ្វើឡើងនៅក្នុងមហាសន្និបាតលើកលែងតែ :

-អភិបាលនោះមានការជំទាស់ ដែលស្នើដាក់ចូលក្នុងកំណត់ហេតុអង្គប្រជុំនៃមហាសន្និបាតនោះ។

-អភិបាលនោះ ផ្ញើគំនិតជំទាស់ជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅលេខាធិការរបស់មហាសន្និបាត មុនពេលបិទមហាសន្និបាតនោះ។

អភិបាលដែលអវត្តមាននៅក្នុងមហាសន្និបាត នៅពេលសេចក្តីសម្រេចដែលត្រូវអនុម័ត ឬសកម្មភាពដែលបានធ្វើឡើង រួចមកហើយគឺចាត់ទុកថាបានយល់ព្រម លើកលែងតែក្នុងរយៈពេលដប់ប្រាំ (១៥)ថ្ងៃក្រោយពីបានដឹង សេចក្តីសម្រេចនោះ អភិបាលនោះបាន :

-បង្ហាញមូលហេតុនៃការជំទាស់របស់គាត់ ដែលបានបញ្ចូលទៅក្នុងកំណត់ហេតុនៃមហាសន្និបាត។

-ផ្ញើគំនិតជំទាស់របស់ខ្លួនតាមរយៈលិខិតអនុសិដ្ឋ ឬយកទៅប្រគល់ផ្ទាល់នៅឯការិយាល័យរបស់ក្រុមហ៊ុន។

### ២- ម្ចាស់ហ៊ុន

មហាសន្និបាតម្ចាស់ហ៊ុន ត្រូវធ្វើឡើងនៅទីកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។ មហាសន្និបាតម្ចាស់

ហ៊ុនអាចធ្វើឡើង នៅក្រៅព្រះរាជាណាចក្រកម្ពុជាបានប្រសិនបើមានការយល់ព្រមពីម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទាំងអស់។ អភិបាលទាំងឡាយរបស់ក្រុមហ៊ុន ត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំមិនឱ្យលើសពី ១២ (ដប់ពីរ)ខែ ក្រោយពីក្រុមហ៊ុននោះបានបង្កើតឡើងជាផ្លូវការ។ អភិបាលទាំងឡាយរបស់ក្រុមហ៊ុនត្រូវកោះប្រជុំមហាសន្និបាត វិសាមញ្ញរបស់ម្ចាស់ហ៊ុននៅពេលណាមួយក៏បានតាមការចាំបាច់។ ម្ចាស់ហ៊ុនទាំងឡាយ អាចធ្វើសំណូមពរទៅអភិបាលឱ្យកោះប្រជុំមហាសន្និបាត ម្ចាស់ហ៊ុនតាមគោលបំណងដែលបានបញ្ជាក់នៅក្នុងសំណើនោះ។ លិខិតស្នើសុំនោះត្រូវធ្វើឡើងដោយម្ចាស់មូលបត្រ ដែលកាន់កាប់ប័ណ្ណភាគហ៊ុនមិនតិចជាង៥១(ហាសិបមួយ)ភាគរយនៃប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានបោះចេញហើយដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាត។ លិខិតស្នើសុំនោះ អាចធ្វើតាមបែបបទផ្សេងៗ ដែលបានចុះហត្ថលេខាដោយម្ចាស់ហ៊ុនម្នាក់ ឬច្រើននាក់។ លិខិតសំណើនៅក្នុងកិច្ចប្រជុំ ត្រូវបញ្ជាក់នូវពាណិជ្ជកិច្ចដែលត្រូវធ្វើ ហើយត្រូវផ្ញើទៅអភិបាល ម្នាក់ៗ និងទៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន។ នៅពេលទទួលសំណើ អភិបាលទាំងឡាយត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីពិភាក្សាកិច្ចការពាណិជ្ជកម្មដែលបានចែងនៅក្នុងលិខិតស្នើសុំនោះ។ ប្រសិនបើអភិបាល ទាំងឡាយ មិនបានកោះប្រជុំក្នុងអំឡុងពេល ២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំនោះទេ ម្ចាស់ហ៊ុន ណាមួយដែលបានចុះហត្ថលេខាលើលិខិតស្នើសុំនោះ អាចកោះប្រជុំមហាសន្និបាតបាន និងលុះត្រាតែម្ចាស់ហ៊ុន ទាំងឡាយបានធ្វើសេចក្តីសម្រេចនៅឯមហាសន្និបាតដែលម្ចាស់ហ៊ុនបានកោះប្រជុំ។ ក្នុងករណីនេះក្រុមហ៊ុនត្រូវចេញ សងម្ចាស់ហ៊ុនវិញនូវការចំណាយ លើកលែងតែម្ចាស់ហ៊ុនទាំងឡាយដែលបានសម្រេចផ្សេងពីនេះ ដែលបានធ្វើឡើងដោយម្ចាស់ហ៊ុនដ៏សមហេតុសមផលក្នុងការស្នើសុំការកោះប្រជុំ និងការរៀបចំមហាសន្និបាតនោះ។ ក្នុងករណីមិនអាចកោះប្រជុំ ឬមិនអាចប្រព្រឹត្តទៅបានចំពោះកិច្ចប្រជុំមហាសន្និបាតម្ចាស់ហ៊ុនទៅតាមបែបបទ ដែល បានចែងក្នុងលក្ខន្តិកៈ ឬច្បាប់នេះ ឬដោយមូលហេតុណាមួយផ្សេងទៀត អភិបាល ម្ចាស់ហ៊ុនដែលមានសិទ្ធបោះ ឆ្នោតក្នុងអង្គប្រជុំ ឬមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចស្នើសុំតុលាការឱ្យចាត់ចែង មហាសន្និបាតបាន ទៅតាមវិធីណាមួយ ដែលតុលាការពិចារណាឃើញថាសមស្រប។ តុលាការអាចកំណត់កូរ៉ុម ផ្សេងពីកូរ៉ុមដែលបានតម្រូវដោយលក្ខន្តិកៈ ឬច្បាប់នេះចំពោះកិច្ចប្រជុំដែលបានកោះប្រជុំ ដែលបានរៀបចំ និងដែល បានប្រព្រឹត្តទៅដោយផ្អែកតាមមាត្រានេះ។ ម្ចាស់ហ៊ុន

ដែលមានសិទ្ធិទទួលលិខិតជូនដំណឹងពីមហាសន្និបាតម្ចាស់ហ៊ុន គឺជាអ្នកកាន់កាប់ប័ណ្ណភាគហ៊ុនតាមប្រភេទ ឬ ស៊េរី ដែលមានឈ្មោះក្នុងបញ្ជីមូលបត្រ នៅពេលបិទអាជីវកម្ម តាមកាលបរិច្ឆេទដែលកំណត់ទុកជាមុន។ អភិបាលសម្រេចកាលបរិច្ឆេទដែលកំណត់ទុកមុនមិនច្រើនជាង ៥០ ( ហាសិប ) ថ្ងៃ ឬតិចជាង ២០( ម្ភៃ ) ថ្ងៃ មុនថ្ងៃ ធ្វើមហាសន្និបាតឡើយ។ ប្រសិនបើអភិបាលមិនបានសម្រេចកាលបរិច្ឆេទកំណត់ទុកជាមុនទេ កាលបរិច្ឆេទកំណត់ទុកត្រូវធ្វើឡើង :

-នៅពេលបិទអាជីវកម្ម មុនថ្ងៃជូនដំណឹងពីមហាសន្និបាត

-នៅថ្ងៃមហាសន្និបាតត្រូវបានរៀបចំឡើង ប្រសិនបើគ្មានការជូនដំណឹងមុនទេ។ ចំពោះកាលបរិច្ឆេទកំណត់ទុកមុនដើម្បីកំណត់ថា តើម្ចាស់ហ៊ុនមានសិទ្ធិផ្សេងទៀតឬទេ ក្រៅពីសិទ្ធិក្នុងការទទួលលិខិតជូនដំណឹងពីមហា-សន្និបាត និងសិទ្ធិក្នុងការបោះឆ្នោត។ សិទ្ធិនោះត្រូវកំណត់នៅថ្ងៃបិទអាជីវកម្ម ហើយដែលអភិបាលបានអនុម័តលើសេចក្តី សម្រេចដែលពាក់ព័ន្ធដល់សិទ្ធិនោះ។

ប្រសិនបើអភិបាលបានកំណត់កាលបរិច្ឆេទកំណត់ទុកជាមុន អភិបាលត្រូវបោះផ្សាយលិខិតជូនដំណឹងពីកាលបរិច្ឆេទ កំណត់ទុកនោះនៅក្នុងសារព័ត៌មាន ដែលធ្វើចរាចរជាទូទៅដល់ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន។ អភិបាលត្រូវផ្តល់ ផងដែរ នូវលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ្រប់ទីផ្សារភាគហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែល នៅទីនោះប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនមានចុះក្នុងបញ្ជីសម្រាប់លក់ដូរ។ លិខិតជូនដំណឹងនេះត្រូវផ្តល់ក្នុងអំឡុងពេល ០៧ ( ប្រាំពីរ ) ថ្ងៃ បន្ទាប់ពីអភិបាលបានបង្កើតកាលបរិច្ឆេទកំណត់ទុកនោះ។ លិខិតជូនដំណឹងពីកាលបរិច្ឆេទកំណត់ ទុកមិនតម្រូវឱ្យមានទេ ប្រសិនបើគ្រប់អ្នកកាន់កាប់ប័ណ្ណភាគ-ហ៊ុនតាមប្រភេទ ឬស៊េរីដែលមានឈ្មោះក្នុងបញ្ជី មូលបត្រ នៅពេលបិទអាជីវកម្មនាថ្ងៃអភិបាលបង្កើតកាល-បរិច្ឆេទកំណត់ទុក បានធ្វើលិខិត ជំរាបក្រុមហ៊ុនបញ្ជាក់ពី ការអនុគ្រោះរបស់ខ្លួនក្នុងការទទួលលិខិតជូនដំណឹងពីកាលបរិច្ឆេទកំណត់ទុក។ ក្រុមហ៊ុនត្រូវរៀបចំបញ្ជីឈ្មោះម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលលិខិតជូនដំណឹងពីការប្រជុំ។ បញ្ជីឈ្មោះនោះ ត្រូវចាត់ថែងតាមលំដាប់អក្សរ និងបញ្ជាក់ចំនួនភាគហ៊ុនដែលបានកាន់កាប់ដោយម្ចាស់ហ៊ុនម្នាក់ៗ។ ប្រសិនបើអភិបាល ទាំងឡាយបានកំណត់កាលបរិច្ឆេទ បញ្ជីត្រូវរៀបចំយ៉ាងយូរ ១០ ( ដប់ ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនោះ។ ប្រសិនបើអភិបាលមិនបានកំណត់កាលបរិច្ឆេទ បញ្ជីត្រូវរៀបចំ :

-នៅពេលបិទអាជីវកម្មនាថ្ងៃបន្ទាប់ ដែលលិខិតជូនដំណឹងត្រូវបានផ្តល់ឱ្យជាបន្ទាន់

-នៅពេលដែលគ្មានការជូនដំណឹង បញ្ជីត្រូវរៀបចំនៅថ្ងៃបើកមហាសន្និបាត

បុគ្គលដែលមានឈ្មោះក្នុងបញ្ជីឈ្មោះម្ចាស់ហ៊ុន មានសិទ្ធិបោះឆ្នោតសម្តែងនៅត្រង់ប្រអប់ ដែលមានឈ្មោះរបស់ខ្លួន ក្នុងអង្គប្រជុំដែលជាប់ទាក់ទងទៅនឹងបញ្ជីឈ្មោះនោះ។ ប្រសិនបើបុគ្គលដែលមានឈ្មោះក្នុងបញ្ជីឈ្មោះម្ចាស់ហ៊ុន ដែលបានផ្ទេរកម្មសិទ្ធិភាគហ៊ុនណាមួយ ក្រោយពីកាលបរិច្ឆេទកំណត់ទុក បុគ្គលទទួលកម្មសិទ្ធិនោះ ត្រូវមានសិទ្ធិ បោះឆ្នោតនៅក្នុងអង្គប្រជុំបាន ក្រោយពីបានបំពេញលក្ខខណ្ឌពីរ :

-មានភាគហ៊ុនដែលមានបិដ្ឋិលេខត្រឹមត្រូវ ឬបង្ហាញភស្តុតាងដែលបញ្ជាក់ថាខ្លួនជាម្ចាស់ភាគហ៊ុន

-ទាមទារបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជី ឱ្យបានមុនការប្រជុំយ៉ាងយូរ១០(ដប់)ថ្ងៃ ឬដូចមានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន

ម្ចាស់ហ៊ុនម្នាក់ៗអាចពិនិត្យបញ្ជីឈ្មោះរបស់ម្ចាស់ហ៊ុនទាំងឡាយបាន :

-នៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងដែលរក្សាទុកបញ្ជីមូលបត្រនោះ នៅក្នុងម៉ោងធ្វើការធម្មតា

-នៅពេលប្រជុំមហាសន្និបាតម្ចាស់ហ៊ុន បញ្ជីឈ្មោះត្រូវបានរៀបចំ

លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ លើរាល់ការប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ត្រូវផ្តល់ទៅឱ្យម្ចាស់-ហ៊ុនទាំងអស់ អភិបាលទាំងអស់ និងសវនករផង ក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃ ទៅ ៥០(ហាសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃមហា សន្និបាតនោះ។ លិខិតជូនដំណឹងពីការប្រជុំមហាសន្និបាត ម្ចាស់ហ៊ុនត្រូវបញ្ជាក់ពីកាលបរិច្ឆេទ របៀបវារៈនិងទីកន្លែង នៃមហាសន្និបាតនោះ។ នៅពេលដែលមានពាណិជ្ជកិច្ចសំខាន់ត្រូវលើកយកមកពិភាក្សានៅក្នុងអង្គប្រជុំ :

-ឯកសារពិស្តារដែលចែងអំពីខ្លឹមសារនៃពាណិជ្ជកិច្ច ដើម្បីឱ្យម្ចាស់ហ៊ុនធ្វើការវិនិច្ឆ័យដោយសមហេតុផល និង

-អត្ថបទស្តីពីសេចក្តីសម្រេចពិសេសត្រូវដាក់ស្នើសុំការពិនិត្យនៅក្នុងកិច្ចប្រជុំនោះ។

ការខកខានក្នុងការទទួលលិខិត ជូនដំណឹងគឺមិនដកសិទ្ធិម្ចាស់ហ៊ុនក្នុងការបោះឆ្នោតនៅឯមហាសន្និបាត នោះ

ឡើយ។ ប្រសិនបើកិច្ចប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ត្រូវលើកវារៈប្រជុំទៅពេលក្រោយមានរយៈពេលតិចជាង ៣០ (សាមសិប) ថ្ងៃគឺមិនចាំបាច់ផ្តល់លិខិតជូន ដំណឹងអំពីកិច្ចប្រជុំដែលបានលើកវារៈប្រជុំ នោះឡើយ។

ម្យ៉ាងទៀតអាច ធ្វើការជូនដំណឹងដោយ ការប្រកាសនៅ ឯអង្គប្រជុំ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ។ ម្ចាស់ហ៊ុន និងបុគ្គលដែលមានសិទ្ធិចូលរួមមហាសន្និបាត អាចអនុគ្រោះដល់ការខ្វះខាតពីការមិនបានទទួលលិខិតជូន ដំណឹងពីមហាសន្និបាតម្ចាស់ហ៊ុននេះបាន។ ប៉ុន្តែម្ចាស់ហ៊ុន ឬបុគ្គលនោះ នៅពេលចូលរួមប្រជុំអាចធ្វើការជំទាស់ទៅ នឹងពាណិជ្ជកិច្ច ដោយសំអាងថា មហាសន្និបាតនោះមិនបានកោះប្រជុំត្រឹមត្រូវ តាមច្បាប់កំណត់។ ម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតប្រចាំឆ្នាំអាច :

-ស្នើសុំឱ្យក្រុមហ៊ុនពិនិត្យនូវសេចក្តីជូនដំណឹងពីប្រធានបទមួយ ដែលខ្លួនស្នើសុំ ដើម្បីលើកឡើងនៅក្នុងអង្គប្រជុំ

-ពិភាក្សាវែកញែក ពីប្រធានបទមួយ ដែលសមស្របទៅនឹងសំណូមពររបស់ខ្លួន

កូរ៉ុមនៃម្ចាស់ហ៊ុនសម្រាប់មហាសន្និបាត គឺវត្តមាននៃអ្នកកាន់កាប់ភាគហ៊ុនភាគច្រើន ដែលមានសិទ្ធិបោះឆ្នោត មានវត្តមានដោយផ្ទាល់ ឬដោយតំណាងជាអាណត្តិគាហកៈ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ប្រសិនបើកូរ៉ុមមានគ្រប់ចំនួននៅពេលបើកមហាសន្និបាត ម្ចាស់ហ៊ុនទាំងឡាយ ដែលមានវត្តមាន អាចពិភាក្សានៅ ក្នុងអង្គប្រជុំបាន។ ប្រសិនបើកូរ៉ុមមិនមានគ្រប់ចំនួនក្នុងពេលបើកមហាសន្និបាតទេ ម្ចាស់ហ៊ុន ដែលមានវត្តមានអាច លើកការប្រជុំនោះទៅពេលក្រោយ និងទីកន្លែងកំណត់មួយ ប៉ុន្តែមហា-សន្និបាតដែលបានលើកវារៈប្រជុំនោះមិនត្រូវ បានអនុញ្ញាតឱ្យពិភាក្សាលើកិច្ចការជំនួញណាមួយបានឡើយ។

រាល់សមាជិកហ៊ុនជាម្ចាស់ប័ណ្ណភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ឬអាណត្តិគាហកៈរបស់ខ្លួន មានសិទ្ធិចូលរួម និង បោះឆ្នោត នៅក្នុងកិច្ចប្រជុំទៅតាមសិទ្ធិបោះឆ្នោត ដែលមានសម្រាប់ភាគហ៊ុនរបស់ខ្លួន។ ក្នុងករណីបុគ្គលពីរនាក់ ឬច្រើននាក់កាន់កាប់ភាគហ៊ុនរួមគ្នា ហើយបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងនោះ មានវត្តមានក្នុងមហា-សន្និបាតម្ចាស់ ហ៊ុន អ្នកនោះអាចបោះឆ្នោតបាន ទោះជាអវត្តមានអ្នកឯទៀតក៏ដោយ។ ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់ក្នុងចំណោមគាហកៈទាំងនោះ មានវត្តមានដោយផ្ទាល់ ឬដោយអាណត្តិគាហកៈរបស់ខ្លួន ពួកគេអាចបោះឆ្នោត សម្រាប់មួយសំឡេងលើភាគហ៊ុនដែលបានកាន់កាប់រួមគ្នានោះ។ រាល់ម្ចាស់ហ៊ុនអាចផ្តល់

សិទ្ធិ ឱ្យរូបវន្តបុគ្គលណាមួយផ្សេងដើម្បីធ្វើជាតំណាង និងដើម្បីបោះឆ្នោតក្នុងនាមជាអាណត្តិ គាហកៈ ជំនួសខ្លួនបាននៅក្នុងកិច្ចប្រជុំ។ ការប្រគល់សិទ្ធិត្រូវធ្វើជាលាយលក្ខណ៍អក្សរ មានចុះហត្ថលេខាដោយ ម្ចាស់ហ៊ុន ហើយត្រូវមានកាលបរិច្ឆេទ។ ឯកសារប្រគល់សិទ្ធិ មិនត្រូវមានសុពលភាពលើសពី ០១ (មួយ)ឆ្នាំឡើយ បន្ទាប់ពីកាលបរិច្ឆេទនៃហត្ថលេខាលើលិខិតប្រគល់សិទ្ធិនោះ ឬសម្រាប់រយៈពេលខ្លីជាងនេះ ដែលឯកសារប្រគល់សិទ្ធិនោះបានបញ្ជាក់។ ម្ចាស់ហ៊ុនមួយចំនួន អាចព្រមព្រៀងក្នុងចំណោមពួកគេជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ចេញ សំឡេងឆ្នោតនៃភាគហ៊ុនតាមវិធីណាមួយ។ ការបោះឆ្នោតជ្រើសរើសអភិបាល និងសេចក្តីសម្រេចលើប្រធានបទផ្សេងៗ ដែលបានផ្តល់សំឡេងឆ្នោត ដោយម្ចាស់ ហ៊ុន ត្រូវធ្វើតាមសន្លឹកឆ្នោតសម្ងាត់ លុះត្រាតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់ម្ចាស់ហ៊ុនទាំងអស់ ដែលមានសិទ្ធិបោះឆ្នោត មាន សុពលភាពដូចគ្នានឹងសេចក្តីសម្រេច ដែលបានអនុម័តនៅឯមហាសន្និបាតម្ចាស់ហ៊ុនដែរ។ សេចក្តីសម្រេចជាលាយ លក្ខណ៍អក្សរ ទាក់ទងនឹងប្រធានបទទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងមហាសន្ន ិបាតម្ចាស់ហ៊ុនដែលបានចុះហត្ថលេខា ដោយម្ចាស់ហ៊ុនដែល មានសិទ្ធិបោះឆ្នោតទាំងអស់ គឺរួចផុតអំពីលក្ខខណ្ឌតម្រូវនៃច្បាប់នេះ ដែលទាក់ទង ទៅនឹង មហាសន្និបាតម្ចាស់ហ៊ុន។ ឯកសារនៃជាសេចក្តីសម្រេចត្រូវរក្សាទុក ដោយមានភ្ជាប់ជាមួយកំណត់ហេតុមហា សន្និបាតម្ចាស់ហ៊ុននោះ។ ម្ចាស់ហ៊ុនណាដែលមិនបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពីកិច្ចប្រជុំ ហើយមានតឹកតាងសមហេតុ សមផលផង ម្ចាស់ហ៊ុននោះមានសិទ្ធិប្តឹងសុំទៅតុលាការ ដើម្បីទាត់ចោលសេចក្តីសម្រេចណាមួយ ដែលធ្វើឡើងនៅឯកិច្ចប្រជុំនោះ។ ក្រុមហ៊ុន ម្ចាស់ហ៊ុន ឬអភិបាល អាចស្នើសុំតុលាការឱ្យដោះស្រាយការខ្វែងគំនិតគ្នា ដែលពាក់ព័ន្ធដល់ការបោះឆ្នោត ឬការតែងតាំងអភិបាល ឬសវនករនៃក្រុមហ៊ុននោះ។ កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរស្របច្បាប់មួយ រវាងម្ចាស់ហ៊ុនទាំងអស់របស់ក្រុមហ៊ុនដែលដាក់កម្រិតអំណាច ទាំងស្រុង ឬមួយផ្នែករបស់អភិបាលក្នុងការគ្រប់គ្រងអាជីវកម្ម និងកិច្ចការរបស់ក្រុមហ៊ុន គឺមានសុពលភាព។ អ្នកទទួលការផ្ទេរភាគហ៊ុន ដែលផ្អែកតាមការព្រមព្រៀងនោះជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវចាត់ទុកជាភាគីនៃកិច្ច ព្រមព្រៀងនោះ។ ម្ចាស់ហ៊ុនដែលជាភាគីនៃកិច្ចព្រមព្រៀងជាឯកច្ឆន្ទបានទទួលនូវសិទ្ធិ ភារកិច្ចទាំងអស់របស់ អភិបាលក្រុមហ៊ុន ដើម្បីគ្រប់គ្រងជំនួញ និងកិច្ចការក្រុមហ៊ុន ដែលមានទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងនោះ។ អភិបាលត្រូវ

បំពេញភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនតាមកិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន។ កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវធ្វើឡើងដោយសមាជិកហ៊ុន។ កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវរក្សាទុកក្នុងកំណត់ហេតុរបស់ក្រុមហ៊ុនដូចដែលបានចែងក្នុងមាត្រា ១០៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរនៅលើប័ណ្ណភាគហ៊ុន ។

## ង- ភាគហ៊ុន ភាគលាភ និងមូលបត្រ

នៅពេលដែលក្រុមហ៊ុនមានដំណើរការ ម្ចាស់ភាគហ៊ុន អ្នកគ្រប់គងក្រុមហ៊ុន ត្រូវកំណត់អំពីភាគហ៊ុន ភាគលាភ និងមូលបត្រសម្រាប់ជាមធ្យោបាយនៅក្នុងការគ្រប់គ្រងសកម្មភាពរបស់ក្រុមហ៊ុន។

### ១-ភាគហ៊ុន និងភាគលាភ

ភាគហ៊ុននីមួយៗត្រូវចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់ ដោយភាគហ៊ុននីមួយៗ ត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណា មួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើប័ណ្ណនោះទេ ។ សិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។ ក្នុងករណីលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុនទេ ក្រុមហ៊ុនត្រូវបោះលក់ចេញយ៉ាងតិចបំផុតមួយពាន់ភាគហ៊ុន ដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាងបួនពាន់រៀលក្នុងមួយហ៊ុនៗ។ ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុន មិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នា និងរួមបញ្ចូលនូវសិទ្ធិ :

-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន

-ក្នុងការទទួលនូវរាល់ភាគលាភ ដែលបានប្រកាសដោយក្រុមហ៊ុន

-ក្នុងការទទួលនូវទ្រព្យ ដែលនៅសេសសល់របស់ក្រុមហ៊ុន នៅពេលមានការរំលាយ

លក្ខន្តិកៈរបស់ក្រុមហ៊ុន អាចចែងឱ្យមានប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ក្នុងករណីនេះ សិទ្ធិនៃប្រភេទរបស់ប័ណ្ណភាគហ៊ុននីមួយៗអាចមានលក្ខណៈដាច់ខាត ឬលក្ខណៈធៀប។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត

និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទភាគហ៊ុននីមួយៗត្រូវកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ។ សិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១៤៤នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ត្រូវភ្ជាប់ដោយឡែក ឬទាំងស្រុងទៅនឹងភាគហ៊ុនមួយប្រភេទណាមួយ ។ សិទ្ធិទាំងនោះរួមមាន :

-ភាពដែលអាចផ្ទេរបាន ឬភាពដែលអាចផ្លាស់ប្តូរបាននៅក្នុងប្រភេទភាគហ៊ុនមួយផ្សេងទៀត ឬមូលបត្រផ្សេងទៀតនៃក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនផ្សេងទៀតអាស្រ័យទៅលើជម្រើសរបស់ក្រុមហ៊ុនមូលធន ឬអាស្រ័យទៅលើជម្រើសរបស់ម្ចាស់ហ៊ុន ឬអាស្រ័យទៅលើការកើតឡើងនៃព្រឹត្តិការណ៍ជាក់លាក់ណាមួយ

-អាទិភាពនៃការទទួលយកទ្រព្យសម្បត្តិ ដែលសល់ពីការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុនមូលធន

-ការលោះមកវិញ ការទិញឡើងវិញទៅតាមជម្រើសរបស់ក្រុមហ៊ុនមូលធន ឬទៅតាមជម្រើសរបស់អ្នកកាន់កាប់ភាគហ៊ុន

-ការរឹតត្បិតទៅលើភាពដែលអាចផ្ទេរបាន

ផ្អែកទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងរាល់សិទ្ធិដែលអាចទិញមុនគេរបស់ម្ចាស់ហ៊ុន ភាគហ៊ុន និងមូលបត្រ អាចអនុញ្ញាតឱ្យបោះចេញទៅតាមពេលវេលា និងចំពោះបុគ្គលទាំងឡាយដែលអភិបាលក្រុមហ៊ុនកំណត់ឱ្យ។ អភិបាលត្រូវកំណត់តម្លៃរបស់ប័ណ្ណភាគហ៊ុន និងតម្លៃមូលបត្រដែលត្រូវលក់ចេញ។ តម្លៃភាគហ៊ុនមិនត្រូវបោះចេញទេរហូតដល់ការបង់ថ្លៃសម្រាប់ភាគហ៊ុនត្រូវ បានបំពេញចប់សព្វគ្រប់ជាសាច់ប្រាក់ ជាវត្ថុ ឬជាសេវាពីមុនទៅក្នុងក្រុមហ៊ុន និងការបង់ភាគហ៊ុនជាវត្ថុ អាចរួមបញ្ចូល ពាណិជ្ជសញ្ញា សិទ្ធិនិពន្ធ ប្រកាសនីយបត្រតក្កកម្ម និងសិទ្ធិប្រើប្រាស់ទ្រព្យអរូបិយ ឬសិទ្ធិប្រើប្រាស់លិខិតអនុញ្ញាតពាណិជ្ជសញ្ញា។ អភិបាលទាំងឡាយកំណត់តម្លៃនៃការដាក់ភាគទុនជាវត្ថុ ឬជាសេវាកម្មពីមុននោះ និងសេចក្តីសម្រេចរបស់អភិបាលទាំងនេះចាត់ទុកជាបានការប្រសិនបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ។ ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មិនអនុញ្ញាតឱ្យមានភាគទុនជាសេវាទេ។ ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុនទាំងឡាយចំពោះបំណុលនៅក្នុងក្រុមហ៊ុន គឺមានកម្រិតត្រឹមតែលើតម្លៃជាវភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗប៉ុណ្ណោះ។ លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចអនុញ្ញាតឱ្យបោះចេញលើគ្រប់ប្រភេទនៃប័ណ្ណភាគ ហ៊ុនតាមស៊េរីមួយ ឬច្រើ ។ លក្ខន្តិកៈនេះអាចអនុញ្ញាតឱ្យអភិបាលទាំងឡាយកំណត់ចំនួនប័ណ្ណ និងកំណត់ការបែងចែកសិទ្ធិ

ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនក្នុងស៊េរីនីមួយៗ ដោយអនុលោមទៅតាមការកំណត់ដែលបានធ្វើឡើងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ។ បើពុំដូច្នេះទេ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត ឬលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុន ប្រភេទនិងស៊េរីដូចគ្នា ត្រូវតែមានលក្ខណៈដូចគ្នា។

ក្រុមហ៊ុនត្រូវរក្សាទុកគណនីដើមទុន ដែលបានចុះបញ្ជីប្រកាសដោយឡែកពីគ្នា សម្រាប់ប្រភេទនិងស៊េរីភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនបានបោះចេញ។ ក្រុមហ៊ុនត្រូវបន្ថែមទៅក្នុងគណនីដើមទុន ដែលបានប្រកាសនូវការបង់ពេញលេញណាមួយជាសាច់ប្រាក់ ជាវត្ថុ ឬជាសេវាពីមុនដែលក្រុមហ៊ុនបានទទួលចំពោះប័ណ្ណភាគហ៊ុនដែលបានបោះចេញ។ ពេលណាក្រុមហ៊ុនស្នើសុំបន្ថែមនូវចំនួនណាមួយទៅក្នុងគណនីដើមទុន ដែលបានប្រកាសលើរាល់ប្រភេទ ឬស៊េរីនៃភាគហ៊ុន ប្រសិនបើចំនួនដែលត្រូវបន្ថែមនោះ ក្រុមហ៊ុនមិនបានទទួលគ្រប់ចំនួនទេ ពេលនោះការបន្ថែមចំនួនចូលទៅក្នុងគណនីដើមទុនត្រូវតែមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ក្រុមប្រឹក្សាភិបាល។ ក្រុមហ៊ុនមិនអាចបន្ថយគណនីដើមទុនដែលបានប្រកាស ឬគណនីដើមទុនណាមួយបានឡើយ។ ក្រុមហ៊ុនអាចបន្ថយគណនីដើមទុនរបស់ខ្លួនបានសម្រាប់គោលបំណងណាមួយតាមរយៈសេចក្តីសម្រេចពិសេស។ សេចក្តីសម្រេចពិសេស ត្រូវបញ្ជាក់គណនីដើមទុនដែលនឹងត្រូវបន្ថយ។ ក្រុមហ៊ុនមិនត្រូវបន្ថយគណនីដើមទុនរបស់ខ្លួនទេ ប្រសិនបើមានមូលហេតុដូចខាងក្រោម :

-ក្រុមហ៊ុនមិនមានលទ្ធភាពសងបំណុលរបស់ខ្លួនបានទេ តាមកាលបរិច្ឆេទដែលបានកំណត់បន្ទាប់ពីការចំណាយ

-តម្លៃទ្រព្យដែលអាចប៉ាន់ស្មានបានរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល និង វិធាននេះមិនយកមកអនុវត្តទេ ប្រសិនបើក្រុមហ៊ុនកាត់បន្ថយគណនីដើមទុនរបស់ខ្លួន នូវចំនួនណាមួយដែលមិនពាក់ព័ន្ធដល់ទ្រព្យសម្បត្តិ ដែលអាចទទួលផលបាននៅពេលក្រោយ។ ម្ចាស់បំណុលរបស់ក្រុមហ៊ុន អាចធ្វើបណ្តឹងទៅតុលាការសុំឱ្យក្រុមហ៊ុនសងមកវិញនូវសាច់ប្រាក់ ឬទ្រព្យសម្បត្តិ បន្ទាប់ពីការកាត់បន្ថយគណនីដើមទុនដែលបានធ្វើឡើងផ្ទុយពីមាត្រានេះ។ បណ្តឹងទាមទារការសងបំណុលដែលបានចែងដោយមាត្រានេះ មិនត្រូវធ្វើឡើងក្រោយរយៈពេលពីរ (០២)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឡើយ។ បើសិនជាលក្ខន្តិកៈក្រុមហ៊ុនផ្តល់នូវសិទ្ធិអាចទិញបានចំពោះប្រភេទណាមួយនៃប័ណ្ណភាគហ៊ុន គ្មានប័ណ្ណភាគហ៊ុនណាផ្សេងទៀតនៃប្រភេទនោះត្រូវបោះចេញទៀតឡើយ លើកលែងតែម្ចាស់ហ៊ុនដែលមានសិទ្ធិទិញមុនគេត្រូវបានផ្តល់

សិទ្ធិដំបូងគេបង្អស់។ ម្ចាស់ហ៊ុនមានសិទ្ធិទិញបានមុននូវភាគហ៊ុន ដែលបានដាក់សំណើលក់ទៅតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនប្រភេទនោះតាមតម្លៃ និងលក្ខខណ្ឌផ្សេងៗដូចដែលប័ណ្ណភាគហ៊ុនទាំងនោះ ត្រូវបានដាក់សំណើលក់ដល់តតិយជនផងដែរ។ ក្រុមហ៊ុនអាចបោះចេញវិញ្ញាបនបត្របញ្ជាក់ពីឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬសិទ្ធិនៃការផ្លាស់ប្តូរក្នុងការទទួលមូលបត្ររបស់ក្រុមហ៊ុន។ នៅក្នុងករណីនេះវិញ្ញាបនបត្របញ្ជាក់ ឬក៏មូលបត្រទាំងឡាយត្រូវកំណត់ចេញនូវលក្ខខណ្ឌ ដែលអាចអនុវត្តបាននៅក្នុងឯកសិទ្ធិនៃការផ្លាស់ប្តូរ ជម្រើសនៃការផ្លាស់ប្តូរ ឬសិទ្ធិនៃការផ្លាស់ប្តូរ។ ឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬសិទ្ធិនៃការផ្លាស់ប្តូរក្នុងការទិញមូលបត្ររបស់ក្រុមហ៊ុនអាចធ្វើឡើងឱ្យមានភាពដែលអាចផ្ទេរបាន ឬមិនអាចផ្ទេរបាន ហើយជម្រើសនិងសិទ្ធិក្នុងការទិញអាចធ្វើដោយដាច់ពីគ្នា ឬមិនដាច់ពីគ្នាពីវាល់មូលបត្រ។

ម្ចាស់ហ៊ុនម្នាក់មានសិទ្ធិទទួលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុន។ នៅលើវិញ្ញាបនបត្រហ៊ុននីមួយៗ ដែលត្រូវបានបោះចេញដោយក្រុមហ៊ុន ត្រូវមាននាមករណ៍ក្រុមហ៊ុនឈ្មោះរបស់បុគ្គលដែលត្រូវបោះចេញឱ្យហើយចំនួន និងប្រភេទរបស់ប័ណ្ណភាគហ៊ុននិងការកំណត់នូវវាល់ស៊េរីដែលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុននោះ តំណាងយោងទៅតាមការរឹតត្បិតនៅក្នុងច្បាប់នេះ និងដោយលក្ខន្តិកៈរបស់ក្រុមហ៊ុនភាគហ៊ុនទាំងឡាយ អាចធ្វើការផ្ទេរបាន។ ក្រុមហ៊ុនអាចផ្ទេរបាននូវភាគហ៊ុននោះនឹងធ្វើការកត់បញ្ជីទៅក្នុងសៀវភៅ និងបញ្ជីរបស់ ក្រុមហ៊ុនទៅតាមសំណើរបស់ភាគីផ្ទេរ និងភាគីទទួល។ ផ្អែកទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រុមហ៊ុនអាចជាវ ឬទិញមកវិញនូវភាហ៊ុនទាំងឡាយដែលបានបោះចេញ។ ក្រុមហ៊ុនត្រូវមានប័ណ្ណភាគហ៊ុនដែលបោះចេញ យ៉ាងហោចណាស់ក៏មួយប្រភេទនៃប័ណ្ណភាគហ៊ុនដែលមានសិទ្ធិ ពេញលេញក្នុងសិទ្ធិបោះឆ្នោត និងដែលមិនស្ថិតក្រោមភាពចាំបាច់នៃការទិញមកវិញ ឬការលោះមកវិញនោះទេ។ បើសិនជាប័ណ្ណភាគហ៊ុន ត្រូវលោះយកមកវិញ ម្ចាស់ភាគហ៊ុនមានភារកិច្ចប្រគល់ប័ណ្ណភាគហ៊ុនទៅក្រុមហ៊ុនវិញ ដោយទទួលយកមកវិញនូវតម្លៃនៃការលោះនោះបើសិនជាម្ចាស់ហ៊ុនមិនព្រមប្រគល់ឱ្យវិញ ក្រុមហ៊ុនអាចកក់ នូវតម្លៃនៃភាគហ៊ុន ដែលត្រូវលោះទៅក្នុងគណនីដាច់ដោយឡែកនៅក្នុងធនាគារមួយដែលទទួលស្គាល់ដោយក្រុមហ៊ុន ហើយក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់ហ៊ុននោះ។ ក្រុមហ៊ុនត្រូវលុបចោលភ្លាមពីសៀវភៅបញ្ជីនូវប័ណ្ណ ភាគហ៊ុនដែលបាន

លោះនៅពេល ដែលលុយកក់ត្រូវបានទទួល។ ប៉ុន្តែក្រុមហ៊ុនមិនត្រូវធ្វើការទូទាត់ណាមួយ ទៅលើការទិញ ឬការលោះប័ណ្ណភាគហ៊ុនទេ ដែលបានបោះចេញ ប្រសិនបើមានហេតុផលថា :

-ក្រោយពេលទិញ ក្រុមហ៊ុនគ្មានលទ្ធភាពក្នុងការសងបំណុលឱ្យទាន់ពេលវេលាទេ។

-ក្រោយពេលទិញតម្លៃពិតប្រាកដនៃទ្រព្យរបស់ក្រុមហ៊ុននៅតិចជាងតម្លៃសរុបរបស់បំណុល។ ប័ណ្ណភាគហ៊ុនដែលបានទិញ និងបានលោះរួចមកហើយ ឬបានទទួលដោយក្រុមហ៊ុនត្រូវបានលុបចេញ ឬប្រសិនបើលក្ខន្តិកៈរបស់ក្រុមហ៊ុនកម្រិតនូវចំនួននៃប័ណ្ណភាគហ៊ុនដែលអនុញ្ញាតឱ្យបោះចេញ ក្រុមហ៊ុនអាចដាក់ប័ណ្ណភាគហ៊ុនក្នុងលក្ខណៈ អនុញ្ញាត ប៉ុន្តែពុំទាន់លក់ចេញ។ នៅពេលក្រុមហ៊ុនទិញ លោះមកវិញឬទទួលភាគហ៊ុនចូលក្រុមហ៊ុនត្រូវធ្វើការកែតម្រូវដោយភ្ជាប់ទៅនឹងគណនី ដើមទុនដែលរក្សាទុកសម្រាប់ប្រភេទ ឬស៊េរីនៃប័ណ្ណ ភាគហ៊ុនដែលបានទិញលោះមកវិញ ឬបានទទួល។ ក្នុងករណីដែលមានការរឹតត្បិតនៅក្នុងលក្ខន្តិកៈ អភិបាលអាចប្រកាសចេញនូវភាគលាភសល់ ឬប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន។ អភិបាលអាចចាត់ចែងប្រាក់បម្រុងពិសេសមួយភាគ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តពាណិជ្ជកិច្ច របស់ក្រុមហ៊ុន ដោយប្រើប្រាស់មូលនិធិណាមួយរបស់ក្រុមហ៊ុនដែលមានសម្រាប់បែងចែកភាគលាភ។ ក្រុមហ៊ុនមិនអាចប្រកាស ឬបែងចែកភាគលាភបានទេ ប្រសិនបើក្រុមហ៊ុនមានមូលហេតុសមហេតុសមផលដើម្បី ធ្វើឱ្យជឿថា :

-ក្រោយពីការបែងចែកភាគលាភនោះ ក្រុមហ៊ុនគ្មានលទ្ធភាពសងបំណុលដូចដែលបានកំណត់ឱ្យសងនោះទេ ។

-តម្លៃដែលអាចប៉ាន់ស្មានបាននៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល និងដើមទុន ប្រកាសរបស់ភាគហ៊ុនគ្រប់ប្រភេទ ។

ក្រុមហ៊ុនអាចបែងចែកភាគលាភ ដោយធ្វើការបោះចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុន។ ផ្អែកតាមការរឹតត្បិត នៅក្នុងផ្នែកនេះ ក្រុមហ៊ុនអាចបែងចែកភាគលាភជាសាច់ប្រាក់ ឬជាទ្រព្យសម្បត្តិបាន និងប្រសិនបើប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវបានបោះចេញដើម្បីទូទាត់ភាគលាភ ចំនួនភាគលាភដែលបានប្រកាសបញ្ជាក់ចំនួនសាច់ប្រាក់ត្រូវបន្ថែមទៅក្នុងគណនីដើមទុន ឬត្រូវបានរក្សាទុកសម្រាប់ប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនដែលបានបោះចេញដើម្បីទូទាត់ភាគលាភនោះ។

### ២- មូលបត្រ

មូលបត្រ មានន័យថាជាលិខិតស្នាមដែលចេញដោយក្រុមហ៊ុនហើយដែល :

-ស្ថិតក្នុងទ្រង់ទ្រាយគាហកៈ ទ្រង់ទ្រាយចុះបញ្ជី ឬទ្រង់ទ្រាយបញ្ជា

-ជាគំរូប័ណ្ណមួយលក់ជាសាធារណៈនៅលើការដោះដូរ ឬលើទីផ្សារមូលបត្រ ឬបានទទួលស្គាល់នៅក្នុងវិស័យណាមួយ ដែលនៅក្នុងវិស័យនោះ មូលបត្រត្រូវបានបោះចេញ ឬត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើឱ្យការវិនិយោគ

-ជាប្រភេទមួយ ឬស៊េរីមួយមូលបត្រ ដែលចែកនៅក្នុងប្រភេទ ឬស៊េរីនៃលិខិតស្នាម ។

-ជាភស្តុតាងបញ្ជាក់ភាគហ៊ុន ភស្តុតាងនៃការចូលរួមចំណែកឬភស្តុតាងនៃអត្ថប្រយោជន៍ផ្សេងៗក្នុងកាតព្វកិច្ចរបស់ក្រុមហ៊ុន ។

មូលបត្រគឺជាប្រភេទប័ណ្ណដែលអាចលក់ដូរបាន ដោយក្រុមហ៊ុនណាដែលតម្កល់ទុក ឬចែកចាយនូវផែនការអាជីវកម្ម សេចក្តីប្រកាសពីព័ត៌មានសំខាន់ ការប្រកាសពីការចុះបញ្ជី សារាចរណែនាំពីការដោះដូរមូលបត្រ ឬក៏ឯកសារប្រហាក់ប្រហែលដែលទាក់ទងទៅនឹងការចែកចាយ មូលបត្ររបស់ក្រុមហ៊ុនដល់សាធារណជន ត្រូវផ្ញើជាបន្ទាន់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួង ពាណិជ្ជកម្មនូវច្បាប់ចម្លងនៃឯកសារទាំងអស់នោះ។ មូលបត្រស្ថិតក្នុងទម្រង់ចុះបញ្ជី ប្រសិនបើមូលបត្រនោះ :

-បញ្ជាក់ច្បាស់លាស់នូវបុគ្គលដែលមានសិទ្ធិលើមូលបត្រនិងបញ្ជាក់ថាការផ្ទេរនោះ អាចកត់ចូលទៅក្នុងបញ្ជីមូលបត្របាន។

-មានភ្ជាប់ប្រកាសថា វាស្ថិតក្នុងបញ្ជីមូលបត្រ។

កាតព្វកិច្ចបំណុលស្ថិតក្នុងទម្រង់បញ្ជាដែលចែងថា កាតព្វកិច្ចបំណុលគឺអាចទូទាត់បានទៅតាមបំណង ឬចែងថា កាតព្វកិច្ចបំណុល ត្រូវចាត់ចែងទៅឱ្យបុគ្គលម្នាក់ដែលសម្គាល់បាន។ មូលបត្រស្ថិតក្នុងទម្រង់ "គាហកៈ" ប្រសិនបើមូលបត្រនោះ អាចទូទាត់ទៅឱ្យបុគ្គលណាម្នាក់ក៏បាន។ មូលបត្រនៅ ក្នុងទម្រង់គាហកៈមិនមានបញ្ជាក់ឈ្មោះរបស់អ្នកកាន់កាប់ទេ។ រាល់អ្នកកាន់កាប់មូលបត្រមានសិទ្ធិជ្រើសរើសមូលបត្រស្របតាមច្បាប់នេះ ឬតាមលិខិតទទួលស្គាល់ថាមិនផ្ទេរសិទ្ធិ របស់ខ្លួនក្នុងការទទួលមូលបត្រពីក្រុមហ៊ុន។ ក្រុមហ៊ុនមិនត្រូវបោះចេញនូវមូលបត្រលើសពីមួយ ដែលបានកាន់កាប់រួមគ្នាដោយបុគ្គលច្រើននាក់។ ការប្រគល់នូវមូលបត្រ

មួយទៅឱ្យបុគ្គលម្នាក់គឺជាការគ្រប់គ្រាន់ ។ មូលបត្រត្រូវចុះហត្ថលេខាផ្ទាល់ដៃដោយអភិបាលម្នាក់យ៉ាងតិច ហើយហត្ថលេខាបន្ថែមផ្សេងទៀត ដែលតម្រូវឱ្យមាននៅលើមូលបត្រ អាចត្រូវបានចុះហត្ថលេខាដោយត្រាឈ្មោះ ។ នៅលើមូលបត្រដែលបោះចេញដោយក្រុមហ៊ុនត្រូវមាន :

-នាមករណ៍របស់ក្រុមហ៊ុន ។

- ពាក្យថា"បានធ្វើអាជីវកម្មក្រោមច្បាប់សហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា" ។

-ឈ្មោះរបស់បុគ្គលដែលត្រូវចេញឱ្យ ។

-លេខ និងប្រភេទរបស់ប័ណ្ណភាគហ៊ុន និងស៊េរីរបស់ប័ណ្ណភាគហ៊ុននោះ ។

-ដាក់ការរឹតត្បិតទៅលើការផ្ទេរ ។

នៅលើមូលបត្រចេញដោយក្រុមហ៊ុន ដែលត្រូវបានផ្តល់សិទ្ធិឱ្យបោះចេញច្រើនជាងមួយប្រភេទ ឬមួយស៊េរី ត្រូវចែងឱ្យច្បាស់នូវ :

-សិទ្ធិ បុព្វសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប្រភេទស៊េរីរបស់ប័ណ្ណភាគហ៊ុននីមួយៗដែលបានបោះចេញ

-ប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនដែលបង្ហាញពីសិទ្ធិ បុព្វសិទ្ធិ ការរឹតត្បិត ឬលក្ខខណ្ឌភ្ជាប់ ។ក្រុមហ៊ុននឹងផ្តល់ឱ្យម្ចាស់ហ៊ុននូវរាល់តម្រូវការ និងដោយឥត គិតថ្លៃនូវឯកសារទាំងអស់ស្តីពីសិទ្ធិអាទិភាព ការរឹតត្បិត និងលក្ខខណ្ឌ ភ្ជាប់ទៅនឹងប្រភេទ និងស៊េរីនីមួយៗ ។ ក្រុមហ៊ុនត្រូវរក្សាទុកនូវបញ្ជីមូលបត្រ ដែលនៅក្នុងនោះមានកត់ត្រានូវមូលបត្រដែលក្រុមហ៊ុនបោះចេញដោយ បញ្ជាក់ប្រភេទ និងស៊េរីរបស់មូលបត្រទាំងនោះជាអាទិ៍ :

-ឈ្មោះដែលរៀបតាមលំដាប់អក្សរ និងអាសយដ្ឋានក្រោយបង្អស់របស់បុគ្គលម្នាក់ៗដែលជាម្ចាស់មូលបត្រ ។

-លេខមូលបត្រ ដែលកាន់កាប់ដោយម្ចាស់ហ៊ុនម្នាក់ៗ ។

-កាលបរិច្ឆេទ និងលក្ខណៈពិសេសនៃការចេញ និងការផ្ទេរមូលបត្រនីមួយៗ ។

ក្រុមហ៊ុនត្រូវទទួលស្គាល់ម្ចាស់មូលបត្រ ដែលបានទទួលការចុះបញ្ជីថាជាបុគ្គល ដែលមានសិទ្ធិបោះឆ្នោត ទទួលលិខិតជូនដំណឹង ទទួលផលប្រយោជន៍ ទទួលភាគលាភ ឬការទូទាត់សងស្របតាមមូលបត្រ និងអនុវត្តរាល់សិទ្ធិរបស់ម្ចាស់មូលបត្រនោះ ។ ក្នុងករណីដែលមានការដាក់ការរឹតត្បិតទៅលើការផ្ទេរមូលបត្រ និងមូលបត្រ ដែលត្រូវ បានផ្ទេរចេញ ឬបញ្ជូនទៅបុគ្គលម្នាក់ដែលមិនមែនជាម្ចាស់មូលបត្របុគ្គលនោះត្រូវផ្តល់

ភស្តុតាងអំពីការអនុញ្ញាត ឱ្យខ្លួនអនុវត្តសិទ្ធិ ឬបុព្វសិទ្ធិស្របតាមមូលបត្រ។ ក្រុមហ៊ុនត្រូវ ទទួលស្គាល់បុគ្គលនោះថាជាអ្នកត្រូវបានផ្តល់សិទ្ធិក្នុង ការអនុវត្តសិទ្ធិ ឬបុព្វសិទ្ធិទាំងឡាយនោះ។ ប្រសិនបើមានអនីតិជនម្នាក់ដែលស្ថិតក្រោមអាណាព្យាបាលអនុវត្តសិទ្ធិជាម្ចាស់មូលបត្ររបស់ក្រុមហ៊ុនអនីតិជន ឬតំណាងរបស់អនីតិជននោះមិនអាចបដិសេធសកម្មភាពរបស់ខ្លួនបានឡើយ។ កាលណាមូលបត្រមួយត្រូវផ្ទេរចេញ ឬបញ្ជូនទៅបុគ្គលម្នាក់ ដែលមិនមែនជាអ្នកមានឈ្មោះក្នុងបញ្ជីភាគហ៊ុន បុគ្គលនោះត្រូវមានសិទ្ធិក្លាយជា ឬចាត់ទុកជាអ្នកកាន់កាប់ដូចដែលបានចុះក្នុង បញ្ជីភាគហ៊ុនដែរ ប្រសិនបើបុគ្គលនោះបានតម្កល់ទុកនូវមូលបត្រដែលខ្លួនមានសិទ្ធិកាន់កាប់បានធ្វើជាម្ចាស់នោះ។ ឯកសារតម្កល់ទុកនោះមាន :

-ឯកសារច្បាប់ដើមរបស់សារការី ឬឯកសារដើម ឬឯកសារដែលបញ្ជាក់ពីតុលាការ ឬលិខិតស្នាមរដ្ឋបាលទាំងឡាយ ។

-លិខិតបញ្ជាក់ភស្តុតាងអំពីការផ្ទេរមូលបត្រក្នុងនាមជាអ្នកកាន់កាប់ម្នាក់ដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្មដោយតំណាងស្របច្បាប់របស់អនីតិជន បុគ្គលអសមត្ថភាព ឬបុគ្គលដែលបាត់ខ្លួន ឬដោយអ្នកជម្រះបញ្ជី ឬដោយអ្នកដែលបានទទួលទំនុកចិត្តក្នុងការគ្រប់គ្រងក្រុមហ៊ុនក្ស័យធននៅក្នុងបណ្តឹងពាក់ព័ន្ធលើមូលបត្រ :

-រាល់ការចុះហត្ថលេខាលើមូលបត្រ ឬជាបិដ្ឋិលេខក្នុងករណីចាំបាច់គឺត្រូវបានទទួលស្គាល់លើកលែងតែមានការតវ៉ា ឬការបដិសេធនីជាក់លាក់។

-ហត្ថលេខានៅលើមូលបត្រគឺត្រូវបានសន្មតថាត្រឹមត្រូវ និងមានការអនុញ្ញាត។ ប៉ុន្តែប្រសិនបើប្រសិទ្ធភាពនៃហត្ថលេខា ត្រូវបានចោទជាបញ្ហាបន្ទុកនៃការរកភស្តុងគឺស្ថិតនៅលើភាគីប្តឹងតវ៉ា។

-ប្រសិនបើហត្ថលេខាត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬត្រូវបានធ្វើឡើងរួចហើយ ការបង្ហាញមូលបត្រអាចផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់គ្រប់គ្រងលើមូលបត្រនោះ លើកលែងតែភាគីចុងចោទបង្ហាញភស្តុតាងផ្ទុយ ឬកង្វះខាតលើសុពលភាពមូលបត្រ។

-បើភាគីចុងចោទលើកឡើងនូវភស្តុតាងផ្ទុយ ឬភាពមិនពេញលក្ខណៈនៃមូលបត្រ ភាគីដើមចោទត្រូវបង្ហាញភស្តុតាងផ្ទុយ ឬភាពមិនពេញលក្ខណៈនោះទៅវិញ ។

លើកលែងតែមានការព្រមព្រៀងផ្សេង និងអនុលោមទៅតាមច្បាប់ដោយឡែក ឬបញ្ញត្តិពាក់ព័ន្ធណាផ្សេងទៀត បុគ្គលដែលច្បាប់អនុញ្ញាតឱ្យចេញលក់មូលបត្រដែលបោះចេញក្នុងទម្រង់គាហកៈ ឬដែលបានចុះឈ្មោះអ្នកទទួល ឬដែលបានធ្វើបិដ្ឋិលេខទៅឱ្យអ្នកទទួល ឬបិដ្ឋិលេខចំហ។ លក្ខខណ្ឌ នៃមូលបត្រដែលមានចែងនៅលើមូលបត្រ និងលក្ខខណ្ឌនៃមូលបត្រ ដោយយោងតាមឯកសារផ្សេងត្រូវ ឱ្យស្របគ្នា។ ក្នុងករណីដែលលក្ខខណ្ឌទាំងពីរមិនស្របគ្នា លក្ខខណ្ឌដែលមានចែងលើមូលបត្រ ត្រូវបានចាត់ទុកថា ជាបានការ។ ចំពោះអ្នកទិញដោយសុទ្ធចិត្ត ទោះជាមូលបត្រនោះមានលក្ខណៈមិនប្រក្រតីក៏ដោយ ក៏ក្រុមហ៊ុនត្រូវ តែទទួលស្គាល់សិទ្ធិជាម្ចាស់មូលបត្រដែរ។ មូលបត្រមានសុពលភាពចំពោះអ្នកទិញដោយសុទ្ធចិត្ត បើអ្នកទិញនោះ មិនបានដឹងពីភាពមិនប្រក្រតីនៃមូលបត្រនោះ។ ហត្ថលេខាដែលគ្មានការអនុញ្ញាតនៅលើមូលបត្រនៅពេលមុន ឬនៅក្នុងពេលចេញមូលបត្រ គឺគ្មានប្រសិទ្ធភាពទេ លើកលែងតែហត្ថលេខានោះមានប្រសិទ្ធភាព សម្រាប់អ្នកទិញ និងមិនចាំបាច់មានលិខិតជូនដំណឹងអំពីការខ្វះខាត ការអនុញ្ញាតនោះទេ ប្រសិនបើការចុះហត្ថលេខានោះ ត្រូវបានធ្វើឡើងដោយបុគ្គលម្នាក់ដែលបានអនុញ្ញាតដោយអ្នកចេញប័ណ្ណ ដើម្បីចុះហត្ថលេខាលើមូលបត្រ ឬមូលបត្រប្រហាក់ប្រហែល។ នៅពេលមូលបត្រមានចុះហត្ថលេខាចាំបាច់សម្រាប់បោះចេញ ឬសម្រាប់ផ្ទេរ ប៉ុន្តែពុំទាន់មានលក្ខណៈគ្រប់គ្រាន់ដោយប្រការណាមួយ :

-បុគ្គលណាក៏អាចបំពេញនូវចន្លោះទំនេរនោះបានដែរ ដោយស្របទៅតាមសិទ្ធិរបស់បុគ្គលនោះ។

-ទោះជាការបំពេញនោះមិនគ្រប់គ្រាន់ក៏ដោយក៏មូលបត្រនោះចាត់ទុកជាមានលក្ខណៈពេញលេញអាចប្រើប្រាស់បានចំពោះអ្នកទិញដែលបានទិញពេញថ្លៃដោយមិនបានដឹងអំពីភាពមិនសុក្រឹតនោះឡើយ។

-មូលបត្រដែលបានធ្វើ ចប់សព្វគ្រប់ហើយដែលមានការកែទោះបីជាកែដោយក្លែងបន្លំក៏ដោយ ក៏មូលបត្រនោះនៅតែមានតម្លៃអាចអនុវត្តបាន ប៉ុន្តែការអនុវត្តនេះ ត្រូវយោងលើលក្ខខណ្ឌដើម។

អ្នកទទួលចុះបញ្ជីលក់ភាគហ៊ុន ឬផ្ទេរភាគហ៊ុនមិនទទួលខុសត្រូវចំពោះការក្លែងបន្លំមូលបត្រទេ ប្រសិនបើ :

-សកម្មភាពក្នុងការបោះចេញមូលបត្រស្ថិតក្នុងរង្វង់ការងារដែលបានអនុញ្ញាត។

-មានមូលហេតុត្រឹមត្រូវថាមូលបត្រនោះឋិតនៅក្នុងទម្រង់បែបបទ និងចំនួនដែលបានអនុញ្ញាតឱ្យបោះចេញ។

នៅពេលប្រគល់មូលបត្រ អ្នកជាវទទួលសិទ្ធិពីមូលបត្រដូចអ្នកផ្ទេរមានដែរ ឬអ្នកដែលមានការ-អនុញ្ញាតដើម្បីផ្ទេរ លើកលែងតែអ្នកជាវជាភាគីក្លែងបន្លំ ឬប្រព្រឹត្តអំពើល្មើសដែលប៉ះពាល់ដល់មូលបត្រមិនបានបង្ហាញ អំពីសិទ្ធិ កាន់កាប់ពីម្ចាស់ពិតប្រាកដ។ បុគ្គលដែលធ្វើ ការផ្ទេរមូលបត្រ ទៅអ្នកជាវដោយសុចរិតធ្វើការធានាចំពោះតែ :

-ការផ្ទេរនោះមានសុពលភាព និងត្រឹមត្រូវតាមច្បាប់។

-មូលបត្រនោះត្រឹមត្រូវមិនក្លែងបន្លំ និងមិនមានការកែសំណៅដើមឡើយ។

-ក្នុងករណីដែលខ្លួនមិនដឹងថាមានអ្វី ដែលអាចបង្កឱ្យខូចខាតដល់សុពលភាពរបស់មូលបត្រនោះទេ។ អ្នកជើងសាផ្តល់ទៅអតិថិជនរបស់ខ្លួន ទៅអ្នកចេញមូលបត្រ និងអ្នកជាវប័ណ្ណនូវការធានាដែលបានចែងក្នុងមាត្រានេះ ហើយមានសិទ្ធិ និងបុព្វសិទ្ធិជាអ្នកជាវស្ថិតក្រោមមាត្រានេះ។ ការធានាទាំងនោះដែលសំដៅផ្តល់ប្រយោជន៍ដល់អ្ន ជើងសា ដែលធ្វើសកម្មភាពក្នុងឋានៈជាភ្នាក់ងារម្នាក់គឺបន្ថែមទៅលើការធានាដែលបានទទួលពីអតិថិជន និងការ ធានាដែលសំដៅផ្តល់ប្រយោជន៍ដល់អតិថិជន។

នៅពេលមូលបត្រមួយស្ថិតក្នុងទម្រង់ចុះបញ្ជី ដែលត្រូវផ្ទេរកម្មសិទ្ធិទៅអ្នកទិញម្នាក់ដោយពុំទាន់មានបិដ្ឋិលេខ អ្នកទិញនោះនឹងក្លាយជាអ្នកទិញពិតប្រាកដដរាបណាបិដ្ឋិលេខត្រូវបានផ្តល់ឱ្យ។ ទោះជាការផ្ទេរកម្មសិទ្ធិ បានបំពេញសព្វគ្រប់ នៅពេលបញ្ចេញមូលបត្រក៏ដោយ ក៏អ្នកទិញមានសិទ្ធិទាមទារចំពោះអ្នកផ្ទេរកម្មសិទ្ធិនោះ ឱ្យផ្តល់ជូននូវ បិដ្ឋិលេខជាចាំបាច់។ បិដ្ឋិលេខមូលបត្រនៅក្នុ ងទម្រង់ចុះបញ្ជី កើតឡើងនៅពេលដែលបុគ្គលមានសិទ្ធិចុះហត្ថលេខាលើមូលបត្រ ឬលើ ឯកសារដោយឡែកលើការផ្តល់សិទ្ធិ ឬការផ្ទេរកម្មសិទ្ធិមូលបត្រនោះ ឬចុះហត្ថលេខាផ្តល់សិទ្ធិដើម្បីចាត់ចែង ឬផ្ទេរ កម្មសិទ្ធិមូលបត្រនោះ។ បិដ្ឋិលេខមូលបត្រមានលក្ខណៈដូចតទៅ :

-បិដ្ឋិលេខអាចជាលក្ខណៈពិសេស ឬបិដ្ឋិលេខចំហ

-បិដ្ឋិលេខចំហរួមមានទាំងបដ្ឋិលេខអ្នកកាន់កាប់ផង

-បិដ្ឋិលេខពិសេសបញ្ជាក់ពីបុគ្គលដែលមូលបត្រត្រូវផ្ទេរទៅឱ្យ ឬបញ្ជាក់ពីសិទ្ធិរបស់បុគ្គលដែលមានសិទ្ធិក្នុងការផ្ទេរមូលបត្រនោះ ។ម្ចាស់មូលបត្រអាចប្តូរបិដ្ឋិលេខចំហមួយទៅជាបិដ្ឋិលេខពិសេសមួយបាន។ នៅក្នុងចំនុចនេះ បុគ្គល ដែលមានសិទ្ធិធ្វើបិដ្ឋិលេខគឺ :

-ជាបុគ្គលដែលបានបញ្ជាក់តាមរយៈមូលបត្រ ឬតាមរយៈបិដ្ឋិលេខពិសេស ដែលមានសិទ្ធិលើមូលបត្រ។

-ជាអ្នកតំណាងស្របច្បាប់ ប្រសិនបើបុគ្គលដែលបានចែងនៅក្នុងចំណុច ១ គឺជាបុគ្គលម្នាក់គ្មានលទ្ធភាពអនុវត្តពាណិជ្ជកិច្ចបានដោយមូលហេតុណាមួយ។

-ជាបុគ្គលដែលមានសិទ្ធិចុះហត្ថលេខាតាមច្បាប់ជាធរមាន ឬតាមលិខិតប្រគល់សិទ្ធិ។

-ជាភ្នាក់ងារដែលបានទទួលការអនុញ្ញាតក្នុងន័យថាបុគ្គលដែលបានរៀបរាប់នៅក្នុងចំណុច (១) ដល់ចំណុច (៣) អាចធ្វើសកម្មភាពតាមរយៈភ្នាក់ងារបាន។

តាមរយៈបិដ្ឋិលេខរបស់ខ្លួន អ្នកធ្វើបិដ្ឋិលេខត្រូវបានសន្មតថាគ្មានកាតព្វកិច្ចធានាថាមូលបត្រនោះនឹងត្រូវបានទទួល ស្គាល់ដោយអ្នកចេញមូលបត្រនោះទេ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ។ បិដ្ឋិលេខតែមួយផ្នែកនៃឯកតានៅលើមូលបត្រ ដែលអ្នកចេញបានបញ្ជាក់ថាអាចឱ្យមានការផ្ទេរដាច់ដោយឡែកពីគ្នាបានគឺមានប្រសិទ្ធភាព ក្នុងការធ្វើបិដ្ឋិលេខបន្តទៅលើផ្នែកដទៃទៀតបាន។ បិដ្ឋិលេខពិសេស ឬបិដ្ឋិលេខចំហលើមូលបត្រមួយមិនអាចចាត់ទុកជាការផ្ទេរបានទេ បើសិនជាគ្មានការប្រគល់មូលបត្រដែលមានបិដ្ឋិលេខនោះទេ។ បិដ្ឋិលេខចុះនៅលើឯកសារដោយឡែកអាចចាត់ទុកជាការផ្ទេរបានលុះត្រាតែ មានការប្រគល់មូលបត្រផង និងឯកសារដោយឡែកនោះផង។ បិដ្ឋិលេខនៃមូលបត្រនៅក្នុងទម្រង់គាហកៈ មិនប៉ះពាល់ដល់សិទ្ធិនៃការចុះបញ្ជី របស់អ្នកកាន់កាប់ភាគហ៊ុនឡើយ ម្ចាស់មូលបត្រអាចតវ៉ាពីសុពលភាពនៃបិដ្ឋិលេខទៅនឹងអ្នកចេញមូលបត្រ ឬទៅអ្នកទិញផ្សេងទៀតដែលមានឆន្ទៈ ល្អក្នុងការទទួលមូលបត្រថ្មី ដែលត្រូវបោះចេញ ឬចុះបញ្ជីផ្ទេរជាថ្មី។ អ្នកចេញមូលបត្រណា ដែលចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិមូលបត្រ ដែលមានបិដ្ឋិលេខមិនត្រឹមត្រូវ អ្នកចេញ មូលបត្រនោះត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជី ដែលមិនត្រឹមត្រូវនោះ។ បុគ្គលដែលធានាលើហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខលើមូលបត្រធានាថាការចុះហត្ថលេខានៅពេលនោះជា :

-ហត្ថលេខាត្រឹមត្រូវ

-អ្នកចុះហត្ថលេខាគឺជាបុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខ

-អ្នកចុះហត្ថលេខាមានសិទ្ធិស្របច្បាប់ក្នុងការចុះហត្ថលេខា ប៉ុន្តែបុគ្គលដែលធានាលើហត្ថលេខារបស់ អ្នកធ្វើបិដ្ឋិលេខមិនធានាអះអាងនូវសិទ្ធិស្របច្បាប់នៃការផ្ទេរដោយឡែកណាមួយឡើយ អ្នកចេញមូលបត្រ មិនត្រូវតម្រូវ យកការធានាលើបិដ្ឋិលេខជាលក្ខខណ្ឌសម្រាប់ការចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិឡើយ ។

ការប្រគល់មូលបត្រទៅឱ្យអ្នកជាវកើតឡើងនៅពេលដែល :

-អ្នកជាវម្នាក់ ឬបុគ្គលម្នាក់ ដែលបានចាត់តាំងដោយអ្នកជាវនោះទទួលកាន់កាប់មូលបត្រ ។

-អ្នកជើងសារបស់អ្នកជាវទទួលកាន់កាប់មូលបត្រ ដែលមានបិដ្ឋិលេខទៅឱ្យអ្នកជាវ ឬដែលចេញក្នុងនាមរបស់អ្នកជាវ

-អ្នកជើងសារបស់អ្នកជាវ ធ្វើការអះអាងបញ្ជាក់អំពីការទិញទៅឱ្យអ្នកជាវ ហើយនៅក្នុងកំណត់ហេតុរបស់អ្នកជើងសាបញ្ជាក់លើអត្តសញ្ញាណរបស់មូលបត្រជាក់លាក់មួយជារបស់អ្នកជាវនោះ

-យោងទៅតាមមូលបត្រ ដែលមានបញ្ជាក់អត្តសញ្ញាណ ដែលត្រូវ ផ្ទេរកម្មសិទ្ធិក្នុងពេលតតិយជននៅមានភាពជាម្ចាស់នៅឡើយ តតិយជននោះត្រូវបានទទួលស្គាល់ខ្លួនជាអ្នកកាន់កាប់ប័ណ្ណឱ្យអ្នកជាវ

បើគ្មានការព្រមព្រៀងផ្សេងទេ ការលក់មូលបត្រមួយធ្វើឡើងដោយការផ្លាស់ប្តូរ ឬតាមរយៈអ្នក-ជើងសា :

-អតិថិជនជាអ្នកលក់ ត្រូវបំពេញភារកិច្ចរបស់ខ្លួនក្នុងការផ្ទេរនៅពេលខ្លួនត្រូវផ្ទេរកម្មសិទ្ធិភាពជាម្ចាស់ទៅឱ្យអ្នកជើងសារបស់អ្នកលក់ ឬទៅឱ្យបុគ្គលដែបានចាត់តាំងដោយអ្នកជើងសារបស់អ្នកលក់នោះឱ្យកាន់កាប់ជំនួសខ្លួន ។

-អ្នកជើងសារបស់អ្នកលក់រួមមានអ្នកជើងសាជាប់ទាក់ទងដែលធ្វើសកម្មភាពឱ្យអតិថិជនជាអ្នកលក់ ត្រូវបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធ្វើការផ្ទេរភាពជាម្ចាស់នៃមូលបត្រទៅឱ្យអ្នកជើងសារបស់អ្នកទិញ ឬឱ្យទៅបុគ្គលដែលបាន ចាត់តាំងដោយអ្នកជើងសារបស់អ្នកទិញ ឬដោយឥទ្ធិពលនៃភាពជាក់ស្តែងនៃការលក់ស្របតាមបទប្បញ្ញត្តិនៃការ ដោះដូរ ដែលបទប្បញ្ញត្ត ិនោះធ្វើឱ្យមានពាណិជ្ជកម្មកើតឡើង។ ប្រសិនបើគ្មានការព្រមព្រៀងផ្សេងទេ ភារកិច្ច របស់អ្នកផ្ទេរកម្មសិទ្ធិក្នុងការប្រគល់មូលបត្រទៅឱ្យអ្នកជាវក្រោមកិច្ចសន្យានៃ

ការទិញគឺមិនទាន់គ្រប់គ្រាន់ទេ លុះ ត្រាតែបុគ្គលនោះ ផ្ទេរមូលបត្រក្នុងបែបបទអាចដោះដូរបានទៅឱ្យអ្នកជាវ ឬឱ្យទៅបុគ្គលដែលបានប្រគល់សិទ្ធិដោយ អ្នកជាវ ឬដោយសំអាងនូវការទទួលដឹងឮ ដែលត្រូវធ្វើឡើងទៅអ្នកជាវ ថាមូលបត្រនោះត្រូវខ្លួនកាន់កាប់ជំនួស។ ប្រសិនបើមូលបត្រដែលត្រូវបានផ្ទេរកម្មសិទ្ធិ ដោយមិនត្រឹមត្រូវពីបុគ្គលណាមួយ ក្នុងមូលហេតុណាក៏ដោយរួមទាំង អសមត្ថភាពរបស់បុគ្គលនោះផង បុគ្គលនោះអាចធ្វើការទាមទារទៅអ្នកពាក់ព័ន្ធណាមួយ លើកលែងតែ ចំពោះ អ្នកទិញដោយសុចរិតដើម្បី :

-ទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រនោះ។

-កាន់កាប់ភាពជាម្ចាស់លើមូលបត្រថ្មី បញ្ជាក់ច្បាស់នូវសិទ្ធិ ដូចគ្នាទាំងអស់ ឬមួយផ្នែក។

-ទាមទាររាល់ការខូចខាតទាំងឡាយ។

ប្រសិនបើមូលបត្រ ដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយមិនត្រឹមត្រូវដោយមូលហេតុ ធ្វើបិដ្ឋិលេខមិនមានការអនុញ្ញាតត្រឹមត្រូវ នៅពេលនោះម្ចាស់មូលបត្រអាចទាមទារមកវិញបាននូវភាពជាម្ចាស់នៃមូលបត្រនោះ ឬទាមទារឱ្យចេញ មូលបត្រថ្មីមួយទៀតទោះបីចំពោះអ្នកទិញដោយសុចរិតក៏ដោយ ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថា បិដ្ឋិលេខនោះគ្មានប្រសិទ្ធភាពមែន។ សិទ្ធិក្នុងការទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រ ត្រូវអនុវត្តយ៉ាងជាក់លាក់ ដែលការផ្ទេរកម្មសិទ្ធិត្រូវបានទប់ស្កាត់ហើយមូលបត្រនោះត្រូវបានដកហូតយកមកតម្កល់ទុកវិញ ដើម្បីរង់ចាំបណ្តឹងតវ៉ា។ បើគ្មានការព្រមព្រៀងផ្សេងទេ អ្នកផ្ទេរកម្មសិទ្ធិត្រូវផ្តល់ឱ្យអ្នកជាវនូវភស្តុតាងអំពីសិទ្ធិក្នុងការផ្ទេររបស់ខ្លួន ឬផ្តល់ នូវតម្រូវការណាមួយផ្សេងដែលចាំបាច់ដើម្បីទទួលបានការចុះបញ្ជីនូវការផ្ទេរមូលបត្រនោះ។ ប៉ុន្តែប្រសិនបើការផ្ទេរ កម្មសិទ្ធិនោះមិនមែនជាការផ្ទេរដែលមានបង់តម្លៃនោះ អ្នកផ្ទេរកម្មសិទ្ធិមិនចាំបាច់បង្ហាញភស្តុតាងដូចមានចែង ខាងលើនេះទេ លុះត្រាតែអ្នកជាវបានបង់តម្លៃសមស្រប និង សោហ៊ុយចាំបាច់ផ្សេងៗទៀត។ ប្រសិនបើអ្នកផ្ទេរ កម្មសិទ្ធិខកខានក្នុងការអនុវត្ត ការទាមទារចាំបាច់របស់អ្នកជាវក្នុងរយៈពេលសមស្របមួយ ពេលនោះអ្នកទិញអាច ប្រកែក ឬបដិសេធការផ្ទេរកម្មសិទ្ធិនោះបាន។ មូលបត្រ ឬភាគលាភនៃផលប្រយោជន៍ផ្សេងៗមិនអាចរឹបអូសបានទេ លុះត្រាតែបុគ្គលដែលធ្វើការរឹបអូសនោះ បានទទួលសិទ្ធិជាម្ចាស់លើមូលបត្រដែលត្រូវរឹបអូសនោះ។ ពេលណាដែលមូលបត្រ

នៅក្នុងទម្រង់ចុះបញ្ជីត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រ ត្រូវចុះបញ្ជីនូវ ការផ្ទេរកម្មសិទ្ធិនោះ ក្នុងករណីដូចតទៅ :

-មូលបត្រមានបិដ្ឋិលេខរបស់បុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខ ។

-មានការធានាសមហេតុផលថា បិដ្ឋិ លេខនោះមិនក្លែងបន្លំ ហើយមានសុពលភាព ។

-ច្បាប់ទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការប្រមូលពន្ធដារត្រូវបានអនុវត្ត ។

-ការផ្ទេរកម្មសិទ្ធិ នោះ គឺស្របតាមច្បាប់ ឬផ្ទេរទៅឱ្យអ្នកជាវពិតប្រាកដ ។

នៅពេលអ្នកចេញមូលបត្រមានភារកិច្ចចុះបញ្ជី ការផ្ទេរកម្មសិទ្ធិមូលបត្រពេលនោះ អ្នកចេញមូលបត្រត្រូវទទួល ខុសត្រូវចំពោះបុគ្គលដែលបានបង្ហាញមូលបត្រសម្រាប់ឱ្យចុះបញ្ជីនូវការខាតបង់ ដែលកើតឡើងពីការពន្យារពេល មិនសមហេតុសមផលក្នុងការចុះបញ្ជី ឬពីការខកខានឬការប្រកែកក្នុងការចុះបញ្ជីលើការផ្ទេរនោះ។ អ្នកចេញមូលបត្រមិនទទួលខុសត្រូវចំពោះម្ចាស់មូលបត្រ ឬបុគ្គលផ្សេងៗ ដែលទទួលការខាតបង់បណ្តាលមកពី ការចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិមូលបត្រឡើយ ប្រសិនបើបិដ្ឋិលេខចាំបាច់មានចារលើមូលបត្រហើយ អ្នកចេញមូលបត្រនោះបានធ្វើការយកចិត្តទុកដាក់ក្នុងការកំណត់នូវភាពគ្រប់ជ្រុងជ្រោយនៃបិដ្ឋិលេខនោះ។ នៅពេលមូលបត្រត្រូវបានបាត់បង់ ឬត្រូវបានបំផ្លាញ ហើយម្ចាស់មិនបានជូន ដំណឹងជាលាយលក្ខណ៍-អក្សរពីមូល ហេតុទៅអ្នកចេញមូលបត្រនៅក្នុងពេលសមស្របទេ ក្រោយពីខ្លួនបានដឹងពីការបាត់បង់ ការបំផ្លាញនោះហើយពេល នោះអ្នកចេញមូលបត្របានចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិមូលបត្រនោះមុន ការទទួលសេចក្តីជូនដំណឹងពីម្ចាស់មូលបត្រ ម្ចាស់មូលបត្រនោះត្រូវអស់សិទ្ធិក្នុងការទាមទារមូលបត្រថ្មីពីអ្នកចេញមូលបត្រ ។

នៅពេលម្ចាស់មូលបត្រជូនដំណឹងថាមូលបត្រត្រូវបានបាត់បង់ ឬ ត្រូវបានបំផ្លាញ ពេលនោះអ្នកចេញមូលបត្រត្រូវចេញមូលបត្រថ្មីជំនួសមូលបត្រដើម ប្រសិនបើម្ចាស់មូលបត្រនោះ :

-ស្នើសុំមុនពេលអ្នកចេញមូលបត្របានជូនដំណឹងថាមូលបត្រនោះ ត្រូវបានទទួលសិទ្ធិដោយអ្នកទិញពិតប្រាកដរួចទៅហើយ ។

-យកមូលបត្រសងការខូចខាតមកបង្ហាញអ្នកចេញមូលបត្រ ។

-យល់ព្រមទទួលនូវរាល់លក្ខខណ្ឌតម្រូវ ដែលបានបង្គាប់ដោយអ្នកចេញមូលបត្រ។ ក្រោយពីការចេញឱ្យនូវមូលបត្រថ្មី ក្រោមកថាខណ្ឌខាងលើ ប្រសិនបើអ្នកទិញ មូលបត្រដើមពិតប្រាកដបង្ហាញមូលបត្រដើមនោះ ដើម្បី ចុះបញ្ជីផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រត្រូវចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិនោះ។ ក្នុងការបន្ថែមសិទ្ធិណាមួយ ទៅលើមូលបត្រសងការខូចខាត អ្នកចេញមូលបត្រអាចត្រួតពិនិត្យឡើងវិញបាននូវមូលបត្រថ្មីដែលបានចេញឱ្យពីបុគ្គលម្នាក់ ទៅបុគ្គលម្នាក់ទៀត។

## ច- អ្នកថែរក្សាទ្រព្យសម្បត្តិ និងរបាយការណ៍ហិរញ្ញវត្ថុ

នៅពេលដែលមានដំនើរការក្រុមហ៊ុន ត្រូវមានអ្នកគ្រប់គ្រងក្រុមហ៊ុន ដែលមានទួនាតីរីទៅតាមការកំណត់នៅក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ភាគហ៊ុន ឬមានកំណត់នៅក្នុងច្បាប់ជាធរមាន បន្ទាប់មកត្រូវធ្វើរបាយកការណ៍ហិរញ្ញវត្ថុ ដើម្បីដឹងអំពីចំណូល-ចំណាយ និងប្រតិបត្តិការផ្សេងៗ។

### ១- អ្នកថែរក្សាទ្រព្យសម្បត្តិ

លើកលែងតែមានការអនុញ្ញាតពីតុលាការ អ្នកទទួលរក្សាទ្រព្យសម្បត្តិមិនអាចអនុញ្ញាតឱ្យប្រកបពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនបានឡើយ។ អនុលោមតាមសិទ្ធិរបស់ឥណទាយក អ្នកទទួលរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនអាចទទួលចំណូលអំពីទ្រព្យសម្បត្តិ និងអាចធ្វើការសងបំណុលដែលពាក់ព័ន្ធជាមួយទ្រព្យសម្បត្តិនោះ។ អ្នកទទួលរក្សាទ្រព្យ សម្បត្តិក៏អាចដឹងផងដែរពីអត្ថប្រយោជន៍នៃមូលបត្ររបស់ម្ចាស់មូលបត្រ ដែលបានតែងតាំងខ្លួន។ តុលាការអាចអនុញ្ញាតឱ្យអ្នកទទួលរក្សាទ្រព្យសម្បត្តិ ប្រកបពាណិជ្ជកិច្ចក្រុមហ៊ុនបាន ក្នុងគោលបំណងការពារ មូលបត្រទាំងឡាយរបស់បុគ្គលដែលបានតែងតាំងខ្លួន។ អ្នកទទួលរក្សាទ្រព្យសម្បត្តិនោះគឺជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ។ ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវបានតែងតាំងដោយតុលាការ ឬដោយលិខិតណាមួយរបស់ក្រុមហ៊ុនសិទ្ធិ របស់អភិបាលទាំងឡាយត្រូវអស់តម្លៃរហូតដល់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះត្រូវបានបញ្ចប់។ អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងដោយតុលាការត្រូវអនុវត្តទៅតាមការណែនាំរបស់តុលាការ។ អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងតាមសេចក្តីសម្រេចណាមួយផ្សេង ត្រូវអនុវត្តទៅតាមសេចក្តីសម្រេចនេះ និងតាមការណែនាំរបស់តុលាការ។ អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិត្រូវ :

-ប្រតិបត្តិដោយស្មោះត្រង់ និងដោយបំណងល្អហើយរក្សាទុកដាក់ទ្រព្យសម្បត្តិដែលស្ថិតក្នុងការកាន់កាប់របស់ខ្លួន ឬធ្វើការត្រួតពិនិត្យត្រឹមត្រូវតាមរបៀបពាណិជ្ជកម្ម ។

-ជូនដំណឹងជាបន្ទាន់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអំពីការតែងតាំង និងការបំពេញ សិទ្ធិរបស់ខ្លួន ។

-ថែរក្សា និងត្រួតពិនិត្យទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនស្របទៅតាមបញ្ជារបស់តុលាការ ឬតាមលិខិតស្នាម ដែលខ្លួនត្រូវបានតែងតាំង ។

-បើក និងរក្សាទុកគណនីធនាគារក្នុងនាមរបស់ខ្លួនជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសម្រាប់ទឹកប្រាក់ក្រុមហ៊ុន ដែលបានមកដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

-រក្សាទុកគណនីពិស្តារពីកិច្ចការជំនួញទាំងអស់ ដែលបានសំរេចឡើងដោយខ្លួនឯង ដែលជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

-រក្សាទុកគណនីទាំងឡាយនៃការគ្រប់គ្រង និងសម្រាប់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រួតពិនិត្យក្នុងពេលម៉ោងធ្វើអាជីវកម្ម ។

-រៀបចំយ៉ាងហោចណាស់ម្តងក្នុងមួយឆមាសនូវរបាយការណ៍ហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ខ្លួន បន្ទាប់ពីកាលបរិច្ឆេទដែលខ្លួនត្រូវបានតែងតាំង ។

-ផ្តល់នូវគណនីចុងក្រោយនៃការគ្រប់គ្រង ដើម្បីបំពេញបញ្ចប់ភារកិច្ចរបស់ខ្លួន ។

តាមការស្នើសុំដោយអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិឬការស្នើសុំដោយបុគ្គលដែល មានផលប្រយោជន៍ តុលាការត្រូវចេញបញ្ជា ដោយយល់ថាគួរបញ្ចូលបន្ថែមដោយគ្មានកម្រិតនូវ :

-ដីកាតែងតាំង ដីកាតែងតាំងជំនួស ឬដីកាបញ្ចប់សិទ្ធិអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិនិ ដីកាដែលឱ្យសច្ចានុម័តលើគណនីរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

-ដីកាកំណត់សេចក្តីជូនដំណឹង ដែលត្រូវផ្តល់ដល់បុគ្គលណាម្នាក់ ឬដីកាបញ្ជូនសេចក្តីជូនដំណឹងដល់បុគ្គលណាម្នាក់

-ដីកាកំណត់ប្រាក់ឧបត្ថម្ភដល់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ

-ដីកាកំណត់ទិសដៅដល់រាល់បញ្ហាទាក់ទងទៅនឹងភារកិច្ចរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ។

២- របាយការណ៍ហិរញ្ញវត្ថុ

អភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ដោយរបាយការណ៍នោះ ត្រូវមានទាំង :

-របាយការណ៍ហិរញ្ញវត្ថុ ដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន។ នៅក្នុងឆ្នាំដំបូងនៃអត្ថិភាពរបស់ក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុត្រូវចាប់ផ្តើមពិនិត្យពីពេលក្រុមហ៊ុនមានអត្ថិភាព និងបញ្ចប់នូវកាលវិច្ឆេទមិនលើសពី ៦ ( ប្រាំមួយ) ខែមុនមហាសន្និបាតប្រចាំឆ្នាំ ។

-របាយការណ៍របស់សវនករ

-ព័ត៌មានផ្សេងទៀត ដែលធ្វើទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ឬកិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ហ៊ុន

យោងតាមសំណើរបស់ខ្លួន ម្ចាស់ហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបាន ដោយមិនគិតថ្លៃ។ អភិបាលទទួលយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយការយល់ ព្រមនោះត្រូវមានហត្ថលេខារបស់អភិបាលម្នាក់ ឬច្រើននាក់។ ក្រុមហ៊ុនមិនត្រូវចេញឱ្យបោះផ្សាយ ឬធ្វើចរាចរឯកសារនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានឡើយ។ ក្រុមហ៊ុនអាចធ្វើកិច្ចការខាងលើបានលុះត្រាតែរបាយ-ការណ៍ហិរញ្ញវត្ថុនោះមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និង ត្រូវអមដោយរបាយការណ៍របស់សវនករផង។ ក្រុមហ៊ុនត្រូវបញ្ជូនឯកសាររបាយការណ៍ហិរញ្ញវត្ថុ និងឯកសារស្វែងយល់ទាំងឡាយទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬមុនការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហា-សន្និបាតប្រចាំឆ្នាំនោះ លើកលែងតែម្ចាស់ហ៊ុនណាដែលបានជូនដំណឹងទៅក្រុមហ៊ុនជាលាយលក្ខណ៍អក្សរថាខ្លួនមិនត្រូវការ ឯកសារទាំងនោះទេ។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបោះចេញមូលបត្រប្រភេទណាមួយទៅសាធារណជន ដែល ត្រូវបានកាន់កាប់ដោយបុគ្គលលើសពីម្នាក់ ត្រូវផ្ញើឯកសាររបាយ-

ការណ៍ហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ របាយ-ការណ៍ និងឯកសារទាំងឡាយត្រូវផ្ញើទៅគ្រប់ម្ចាស់ហ៊ុន យ៉ាងយូរ ២១ (ម្ភៃមួយ) ថ្ងៃ មុនមហាសន្និបាតម្ចាស់-ហ៊ុនប្រចាំឆ្នាំ ឬផ្ញើជាបន្ទាន់ បន្ទាប់ពីការចុះហត្ថលេខាលើ សេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ។ ម្ចាស់ហ៊ុនត្រូវតែងតាំងសវនករមួយរូប ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំលើកទីមួយ និងនៅមហាសន្និបាតប្រចាំឆ្នាំនីមួយៗ។ សវនករ ត្រូវកាន់តំណែងរហូតដល់ការបិទមហាសន្និបាតនៃឆ្នាំបន្ទាប់ ប្រសិនបើសវនករថ្មីមិនបានតែងតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនទេ សវនករដែលកំពុងកាន់តំណែង ត្រូវបន្តរហូតដល់សវនករថ្មីត្រូវបានតែងតាំង។ ម្ចាស់ហ៊ុននៃក្រុមហ៊ុនដែលមិនបានចេញមូលបត្រប្រភេទណាមួយទៅឱ្យសាធារណជន ឬដោយគ្មានមូលបត្រ ដែល កាន់ដោយបុគ្គលលើសពីម្នាក់ អាចធ្វើសេចក្តីសម្រេចមិនតែងតាំងសវនករបាន។ សោហ៊ុយចំណាយសម្រាប់សវនករ អាចត្រូវបានកំណត់ឡើងដោយសេចក្តីសម្រេចសាមញ្ញរបស់ម្ចាស់ហ៊ុន ឬបើមិន ដូច្នេះទេ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល។ម្ចាស់ហ៊ុនទាំងឡាយអាចដកហូតសវនករពីមុខតំណែងបាន លើកលែងតែសវនករត្រូវបានតែងតាំងដោយតុលាការ ឬដោយសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតពិសេស។ នៅក្នុងអង្គប្រជុំដូចគ្នានោះម្ចាស់ហ៊ុនអាចតែងតាំងសវនករជំនួសបាន។ នៅពេលណា ដែលមានភាពទំនេរនៃតំណែងសវនករ ក្រុមប្រឹក្សាភិបាលត្រូវ កោះប្រជុំមហាសន្និបាតពិសេសនៃម្ចាស់ហ៊ុន ដើម្បីបំពេញភាពនៅទំនេរនោះ ដោយត្រូវធ្វើឡើងក្នុងរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃបន្ទាប់ពីមានភាពទំនេរនោះ។ សវនករដែលត្រូវតែងតាំងដើម្បីបំពេញភាពទំនេរនោះ ត្រូវកាន់កាប់តំណែងបន្តជំនួសអាណត្តិដែល មិនទាន់ផុតកំណត់របស់សវនករមុន។ ប្រសិនបើក្រុមហ៊ុនមិនទាន់មានសវនករ តាមការស្នើសុំរបស់ម្ចាស់ហ៊ុន ឬមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃ ក្រសួងពាណិជ្ជកម្ម តុលាការអាចតែងតាំង និងដាក់កំណត់ដោះស្រាយចំណាយសម្រាប់សវនករ ដែលបានកាន់ តំណែងរហូតដល់សវនករថ្មីត្រូវបានតែងតាំងដោយម្ចាស់ហ៊ុនទាំងឡាយ។ សវនករត្រូវធ្វើការត្រួតពិនិត្យ លើចំណុចដែលខ្លួនយល់ថាចាំបាច់ដើម្បីរាយការណ៍ជូនម្ចាស់ហ៊ុនទាំងឡាយ លើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រ-កម្ពុជា។ តាមការស្នើសុំរបស់ សវនករនៃក្រុមហ៊ុនមួយ អភិបាលមុន ឬអភិបាលបច្ចុប្បន្នអ្នកគ្រប់គ្រងក្រុមហ៊ុនបុគ្គលិក ឬភ្នាក់ងាររបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានការបកស្រាយបំភ្លឺ និងសៀវភៅបញ្ជី និងកំណត់ហេតុ

ទាំងឡាយ ដែលសវនករនោះចាត់ទុកជាការ ចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ។ សវនកររបស់ក្រុម-ហ៊ុន មានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាត ម្ចាស់ហ៊ុន និងចូលរួមដើម្បីដឹងឮនូវកម្មវត្ថុ ដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករ ដែលចេញសោហ៊ុយ ចំណាយដោយក្រុមហ៊ុន។ ប្រសិនបើអភិបាល ឬម្ចាស់-ហ៊ុន ទោះបីជាម្ចាស់ហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្ន ឬពីមុនក្នុងរយៈពេលយ៉ាងតិច ១០(ដប់)ថ្ងៃ មុន មហាសន្និបាតសវនករបច្ចុប្បន្ន ឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះ នឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ។

## កថាខណ្ឌទី ៧: ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងការរំលាយក្រុមហ៊ុន

នៅពេលដែលចាប់ផ្តើមបង្កើតក្រុមហ៊ុន និងដំណើរការរួចរាល់ហើយ ការបញ្ចប់ ឬការរំលាយ ឬការកែប្រែ អាចនឹងត្រូវបំពេញទៅតាមស្ថានភាពជាក់ស្តែងនៃការណ៍ទាំងនោះ។

### ក- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

ក្រុមហ៊ុនមូលធន អាចធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួនគ្រប់ពេលវេលាបាន។ ក្រុមហ៊ុនមូលធនត្រូវធ្វើការកែប្រែលក្ខន្តិកៈតាមសេចក្តីសម្រេចពិសេស។ អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនមានសិទ្ធិបោះឆ្នោតជាប្រភេទ ឬជាស៊េរីដាច់ដោយឡែកពីគ្នា នៅពេលដែលសេចក្តីស្នើសុំធ្វើការកែប្រែលក្ខន្តិកៈនោះក្នុងគោលបំណង :

-បន្ថែម កែប្រែ ឬដកហូតនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុន

-បង្កើន ឬបន្ថយនូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន តាមប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុននោះ

-បង្កើននូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន ដែលមានសិទ្ធិចំពោះប្រភេទ ឬស៊េរីដែលមានសិទ្ធិ ឬឯកសិទ្ធិស្មើ ឬក៏លើសពីប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ

-បង្កើតប្រភេទថ្មីនៃប័ណ្ណដែលស្មើ ឬលើសពីប័ណ្ណភាគហ៊ុននៃប្រភេទ ឬស៊េរីរបស់អ្នកកាន់កាប់នោះ

-បង្កើតប្រភេទនៃប័ណ្ណភាគហ៊ុនណាមួយដែលមានសិទ្ធិ ឬឯកសិទ្ធិតូចជាង ឬស្មើ ឬលើសប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ

-បន្ថយគណនីដើមទុនចុះបញ្ជីនៃប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ។ ទោះបីជាលក្ខន្តិកៈក្រុមហ៊ុនចែងថាប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនជាក់លាក់ មួយគ្មានសិទ្ធិក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុន នោះមានសិទ្ធិបោះឆ្នោតជានិច្ចទៅតាមប្រភេទ ឬស៊េរីដាច់ដោយឡែកពីគ្នា លើការកែប្រែណាមួយ ទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលកែប្រែដោយផ្ទាល់ ឬដោយប្រយោល ឬប៉ះពាល់ទៅនឹង សិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ។ សិទ្ធិ ក្នុងការបោះឆ្នោតដែលបានអនុញ្ញាតក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនេះ មិនត្រូវបានលុបចោលបន្ថយ ឬដាក់កម្រិតដោយលក្ខន្តិកៈរបស់ ក្រុមហ៊ុន ឬតាមរបៀបណាមួយផ្សេងទៀតឡើយ។ លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីមហាសន្និបាតធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវផ្ញើជូនទៅម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោត យ៉ាងតិច ២០(ម្ភៃ)ថ្ងៃ មុនពេលបើកមហាសន្និបាត។ លិខិតជូនដំណឹងនេះត្រូវ ផ្ញើភ្ជាប់ជាមួយសេចក្តី ព្រាងអត្ថបទដែលស្នើសុំធ្វើការកែប្រែលក្ខន្តិកៈ។ ការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចធ្វើបានចំពោះ :

-ការផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន

-ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្មឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន

-ការបែងចែកសាជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ

-ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ

-ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬ ទាបជាងប្រភេទភាគហ៊ុន ដែលមានរួចហើយ

-ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតម្លៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលបានអនុញ្ញាត។ ដើមទុនចុះបញ្ជី មិនអាចកាត់បន្ថយឱ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជី

ដំបូងបានឡើយដូច ដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន។ ការបន្ថយដើមទុនមិនត្រូវហួសពី ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការកែប្រែត្រូវបានកំណត់នៅក្រសួងពាណិជ្ជកម្ម។ បើក្នុងរយៈពេលនេះមានការតវ៉ាជំទាស់ពីម្ចាស់បំណុល ដែលគ្មានវិវាទជាមួយក្រុមហ៊ុន ម្ចាស់បំណុលនេះត្រូវបានសងប្រាក់ទាំងស្រុងមុនការបន្ថយដើមទុនដែលអាចអនុវត្តទៅបាន

-ការកែប្រែថិរវេលានៃអត្ថិភាពរបស់ក្រុមហ៊ុន

-ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី

-ការកែប្រែចំនួនកូរ៉ុម

-បន្ថែមបទប្បញ្ញត្តិណាមួយ ដែលច្បាប់នេះអនុញ្ញាតឱ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន

គ្រប់ឯកសារស្តីពីការធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីកាលបរិច្ឆេទនៃការកែប្រែលក្ខន្តិកៈ ឬចំណុចកែប្រែទាំងឡាយដែលមហាសន្និបាតម្ចាស់ហ៊ុនបានសម្រេចព្រមទាំងមានចុះ-ហត្ថលេខារបស់ ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលណាម្នាក់ដែលទទួលសិទ្ធិពីប្រធានក្រុមប្រឹក្សាភិបាល។ ឯកសារទាំងនេះត្រូវ តម្កល់ទុកនៅ ក្រសួងពាណិជ្ជកម្មយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីមហាសន្និបាតបានសម្រេច។ ពេលបានទទួលឯកសារធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់អំពីការកែប្រែលក្ខន្តិកៈនោះ។ ការកែប្រែលក្ខន្តិកៈមានប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុង វិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម។ ប្រសិនបើការកែប្រែលក្ខន្តិកៈបានបញ្ជាក់អំពីកាលបរិច្ឆេទមួយទៀត កាលបរិច្ឆេទនោះមិនឱ្យលើសពី ៩០(កៅសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទកំណត់របស់វិញ្ញាបនបត្រឡើយ។

## ខ- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

ក្រុមហ៊ុនពីរ ឬច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួម ចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន និងក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម ដោយក្រុមហ៊ុនដែលទទួលបន្តធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី។ ក្រុមហ៊ុនដើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញ វិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន

នីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវ ផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់។ កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី :

-ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

-លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម

-បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុន ដើមឱ្យទៅជាភាគហ៊ុន ឬ មូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម

-របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬកម្មសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុន ត្រូវទទួលក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ

-ព័ត៌មានមានដទៃទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹងដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

-ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើង និងដើម្បីផ្តល់ដល់ការគ្រប់គ្រង ព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យ ម្ចាស់ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ :

-នៅក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

-លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

-ក្រុមហ៊ុនដើមនីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០(ម្ភៃ) ថ្ងៃមុន

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ។ ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុន

ណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិ ដោយឡែកក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌនៃប្រភេទ ឬស៊េរីនៃភាគហ៊ុនផ្សេងៗ។ អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងច្បាប់នេះមិនអាចបដិសេធ ឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ។ អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត ត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្ម ដែលមាន ជាអាទិ៍ :

-កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

-សេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការរំលាយក្រុមហ៊ុន បញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ

-លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត

-សេចក្តីប្រកាសរបស់អភិបាល ឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម សេចក្តីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ : ក្រុមហ៊ុនដើមនិងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមានលទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង ,ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម ,គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាតដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ ,លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើម ហើយគ្មាន ម្ចាស់បំណុលណាមួយធ្វើការជំទាស់ ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។ ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការ រំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ :

-ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេ ត្រូវចូលជាធរមាន

-កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មី ដែលបន្តធ្វើអាជីវកម្ម

-ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ

-កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយ ដែលពាក់ព័ន្ធ ដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម

-លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈ សម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្មក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើមមានសិទ្ធិទាមទារឱ្យមានការវាយតម្លៃ លើ តម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម ។ ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើការវាយតម្លៃម្ចាស់ហ៊ុនទាំងនោះត្រូវ បំពេញលក្ខខណ្ឌ ដូចតទៅ :

-មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគហ៊ុន នៅក្នុងក្រុមហ៊ុនដើមណាមួយ

-នៅក្នុងពេលបោះឆ្នោត ម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រការ រំលាយក្រុមហ៊ុនបញ្ចូលគ្នាទេ

-ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយលក្ខណ៍អក្សរចំពោះក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម

-នៅពេលដែលធ្វើការទាមទារវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់ប័ណ្ណភាគហ៊ុនរបស់ខ្លួនទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត នៅពេលមានការទាមទារវាយតម្លៃលើតម្លៃភាគហ៊ុន ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនិងម្ចាស់ហ៊ុន ដែលធ្វើការទាមទារនេះ ត្រូវចរចាគ្នាដើម្បីសម្រុះសម្រួលរក តម្លៃសមរម្យមួយក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ ដើម្បីឱ្យ មានការព្រមព្រៀងលើតម្លៃសមរម្យមួយសម្រាប់ភាគហ៊ុនទាំងនោះ ។ តម្លៃសមរម្យត្រូវកំណត់តាមការពិនិត្យគ្រប់កត្តាដែលពាក់ព័ន្ធទាំងអស់ លើកលែងតែតម្លៃណាមួយដែលមានកំណត់រួចហើយនៅក្នុងកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ។ លក្ខន្តិកៈរបស់ក្រុមហ៊ុនដើមណាមួយ ឬកិច្ចព្រម-ព្រៀងនៃ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាអាចចែងថា គ្រប់វិវាទក្នុងការវាយតម្លៃ នឹងត្រូវសម្រេចដោយមជ្ឈត្ត-កម្ម ។ មុននឹង មជ្ឈត្តករចេញសេចក្តីសម្រេចចុងក្រោយ ម្ចាស់ហ៊ុនអាចដកបណ្តឹងទាមទាររបស់ខ្លួន ក្នុងការវាយតម្លៃនៅពេលណា មួយក៏បាន ។ ក្នុងករណីនេះ ម្ចាស់ហ៊ុននោះត្រូវមានសិទ្ធិទទួលពីក្រុមហ៊ុនថ្មី ដែលទទួលធ្វើ

អាជីវកម្មបន្តនូវតម្លៃសមមូល ដែលក្រុមហ៊ុនបានកំណត់ពីមុន។ ប្រសិនបើមិនអាចព្រមព្រៀងគ្នាលើតម្លៃសមរម្យណាមួយបានទេ ភាគីទាំងពីរត្រូវប្រគល់ជូនតុលាការដែលមានសមត្ថកិច្ចសម្រេចពីតម្លៃសមរម្យមួយ ហើយម្ចាស់ហ៊ុន ដែលទាមទារត្រូវទទួលទៅតាមចំនួននោះ។

## គ- ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជី

-ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយ អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់។ ក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិនិងគ្មានបំណុល អាចធ្វើការរំលាយបាន តាមរយៈសេចក្តីសម្រេចចិត្ត ពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយត្រូវធ្វើតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ។ ក្រុមហ៊ុនត្រូវបញ្ជូនសេចក្តីសម្រេចរំលាយក្រុមហ៊ុនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រង ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។ នៅពេលបានទទួលសេចក្តីសម្រេចរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុនឱ្យដល់ក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវបានចាត់ទុក ថាលែងមានអត្ថិភាពតទៅទៀត ចាប់ពីថ្ងៃចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុន។ អភិបាលឬម្ចាស់ភាគហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោត នៅពេលមហាសន្និបាតម្ចាស់ហ៊ុនអាចស្នើឱ្យជម្រះបញ្ជីនិង រំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត។ លិខិតជូនដំណឹងស្តីពីការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងបំណងជម្រះបញ្ជី ឬរំលាយក្រុមហ៊ុនដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុននោះ។ ក្រុមហ៊ុនដែលមានព្រទ្យសម្បត្តិ និង/ឬមានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្តីសម្រេចចិត្តពិសេសមួយរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ។ ក្នុងករណីដែលក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ត្រូវធ្វើការជម្រះបញ្ជី និងរំលាយតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ដោយមិនគិតថា ម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតទេ ប្រសិនបើ :

-ម្ចាស់ហ៊ុនអនុញ្ញាតឱ្យអភិបាលធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលរបស់ក្រុមហ៊ុនតាមសេចក្តីសម្រេចពិសេស ឬសេចក្តីសម្រេចសាមញ្ញ ។

-ក្រុមហ៊ុនបានធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលមុនពេលបញ្ជូនលក្ខន្តិកៈនៃការរំលាយក្រុមហ៊ុនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ ក្រោយពីមានការយល់ព្រម លើសេចក្តីសម្រេចជម្រះបញ្ជី និងរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសពី បំណងរំលាយជាទម្រង់លម្អិតទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នៅពេលទទួល សេចក្តីប្រកាសពីបំណងរំលាយ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្រ បញ្ជាក់ពីបំណងរំលាយក្រុមហ៊ុននោះ។ នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់បំណងនៃការរំលាយក្រុមហ៊ុនក្រុមហ៊ុនត្រូវបញ្ឈប់ការធ្វើអាជីវកម្មលើកលែងតែចំពោះការពន្យារចាំបាច់សម្រាប់ការជម្រះបញ្ជី ប៉ុន្តែនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន នៅតែមានសុពលភាពរហូតដល់ ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយជាស្ថាពរ។ ក្រោយពេលចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវ :

-ផ្ញើលិខិតជូនដំណឹងស្តីពីបំណងរំលាយជាបន្ទាន់ទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន

-ចុះផ្សាយលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់សម្រាប់រយៈពេល២(ពីរ)សប្តាហ៍ជាប់ៗគ្នានៅក្នុងសារព័ត៌មានដែលបោះផ្សាយ ឬចែកចាយ ក្នុងកន្លែងដែលក្រុមហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយ ដទៃទៀត ដូចបានកំណត់ក្នុងបទបបញ្ញារបស់ក្រសួងពាណិជ្ជកម្ម។

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុនត្រូវ :

-ប្រមូលទ្រព្យសម្បត្តិ

-រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ហ៊ុន

-បំពេញកាតព្វកិច្ចទាំងឡាយ

-ធ្វើសកម្មភាពផ្សេងទៀត ដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី និងក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ ទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬជាវត្ថុទៅឱ្យម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ។ នៅគ្រប់ពេលក្នុងអំឡុងពេលនៃការជម្រះបញ្ជីរបស់ក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន

នៃក្រសួងពាណិជ្ជកម្ម ឬជនដែលមានការពាក់ព័ន្ធផលប្រយោជន៍ អាចស្នើទៅតុលាការ ដើម្បីឱ្យការជម្រះបញ្ជីក្រោមការត្រួតពិនិត្យរបស់តុលាការ ។អ្នកដាក់ពាក្យសុំត្រូវផ្តល់ឱ្យក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងស្តីពីការអនុវត្ត ហើយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិបង្ហាញតុលាការដោយផ្ទាល់ ឬតាមរយៈតំណាង។ នៅពេលជម្រះបញ្ជីត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន។ សេចក្តីសម្រេចស្តីពីការរំលាយត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នៅពេលទទួលសេចក្តីសម្រេច ស្តីពីការរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ដែលជាហេតុនាំឱ្យក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួនចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន។ ប៉ុន្តែ បទប្បញ្ញត្តិស្តីពីការរំលាយ និងការជម្រះបញ្ជីខាងលើ មិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលដាក់ពាក្យសុំក្ស័យធនទៅតុលាការឡើយ។

ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មម្នាក់ ឬច្រើននាក់ តាមការចាំបាច់ ដើម្បីឱ្យបំពេញតួនាទីស្របតាមច្បាប់នេះ។ ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្រ ឬបញ្ជាក់អំពីសកម្មភាពណាមួយរបស់ក្រុមហ៊ុន។ វិញ្ញាបនបត្រនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹង ឬឯកសារផ្សេងៗ ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងក្រុមហ៊ុនត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទទួលយក ឯកសារថតចម្លងផ្សេងៗទាំងនោះបាន ដោយ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារ ឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬហេតុការណ៍ពិត ដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់ ដែលមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ក្រសួងពាណិជ្ជកម្មអាចធ្វើសេចក្តីណែនាំដែលមានចំណុចដូចខាងក្រោម :

-ការតម្រូវឱ្យរៀបរាប់ហេតុផលសំខាន់ៗដោយលម្អិត តាមការអនុញ្ញាតនៃច្បាប់នេះ

-ការតម្រូវឱ្យមានការបង់ថ្លៃឈ្នួលចំពោះការតម្កល់ទុក ការត្រួតពិនិត្យ ឬការថតចម្លងឯកសារណាមួយ ឬចំពោះ សកម្មភាពណាមួយ

-ការរៀបរាប់ពីមាតិកាតាមប្រព័ន្ធអេឡិចត្រូនិច ឬទម្រង់បែបបទនៃលិខិតជូនដំណឹងដទៃទៀត ព្រមទាំងឯកសារ ចាំបាច់ដែលត្រូវផ្ញើជូន ឬចេញដោយក្រសួងពាណិជ្ជកម្ម

-ការប្រតិបត្តិដែលទាក់ទងដល់ការបញ្ជូន ឬការចេញនូវលិខិតជូនដំណឹងនិងឯកសារផ្សេងៗ

-ការរៀបរាប់ពីវិធាននានា ដែលទាក់ទងដល់ការលើកលែងមួយចំនួន ដែលអនុញ្ញាតដោយច្បាប់ និងលក្ខន្តិកៈ និងផែនការរំលាយក្រុមហ៊ុន ត្រូវផ្ញើទៅឱ្យក្រសួងពាណិជ្ជកម្ម ត្រូវមានហត្ថលេខាដោយអភិបាលម្នាក់ ឬអ្នកគប់គ្រងម្នាក់របស់ក្រុមហ៊ុន ឬដោយស្ថាបនិកម្នាក់ក្នុងករណីដែលតម្រូវដោយលក្ខន្តិកៈ។ ក្រោយពីបានទទួលនូវឯកសារ ឬផែនការតាមទម្រង់កំណត់ហើយនោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវ :

-កត់ត្រាទុកកាលបរិច្ឆេទនៃការតម្កល់ទុក , ចេញវិញ្ញាបនបត្រ, តម្កល់ទុកនូវវិញ្ញាបនបត្រនិងឯកសារ ឬសេចក្តីប្រកាស រូបថត ព័ត៌មានអេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬសេចក្តីប្រកាស ផ្ញើវិញ្ញាបនបត្រ និងឯកសារ ឬសេចក្តីប្រកាស រូបថត ព័ត៌មាន អេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬសេចក្តីប្រកាសទៅឱ្យក្រុមហ៊ុន ឬតំណាងរបស់ក្រុមហ៊ុន ចុះផ្សាយនូវលិខិតជូនដំណឹងនៃការ ចេញវិញ្ញាបនបត្រនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម។ វិញ្ញាបនបត្រដែលបានចេញដោយក្រសួងពាណិជ្ជកម្ម អាចចុះកាលបរិច្ឆេទនៅថ្ងៃដែលទទួលឯកសារ ឬផែនការ ឬដីការបស់តុលាការដែលបញ្ជាឱ្យចេញវិញ្ញាបនបត្រ ឬនៅថ្ងៃបន្ទាប់ទៀត ដែលបានបញ្ជាក់ដោយតុលាការ ឬបុគ្គល ដែលបានចុះហត្ថលេខាលើឯកសារ ឬផែនការនោះ។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃ ក្រសួងពាណិជ្ជកម្មអាចផ្តល់ឱ្យបុគ្គលណាម្នាក់នូវវិញ្ញាបនបត្រ និងឯកសារចាំបាច់ដែលក្រុមហ៊ុនបានផ្ញើមកឱ្យក្រសួងពាណិជ្ជកម្ម ស្របតាមច្បាប់ជាធរមាន។ ប្រសិនបើវិញ្ញាបនបត្រដែលចេញឱ្យក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មាន កំហុសឆ្គងដោយអចេតនាណាមួយនោះ អភិបាល ឬម្ចាស់ហ៊ុនត្រូវបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុន នៃក្រសួងពាណិជ្ជកម្ម និងដើម្បីកែតម្រូវឡើងវិញតាមច្បាប់ជាធរមាន។ បើមានហេតុផលត្រឹមត្រូវ ក្រសួងពាណិជ្ជកម្មអាចបដិសេធវិញ្ញាបនបត្រដែលខុស និងចេញវិញ្ញាបនបត្រដែលត្រឹមត្រូវជំនួសវិញ និងវិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ ត្រូវមានកាលបរិច្ឆេទតែមួយ ដូចវិញ្ញាបនបត្រចាស់ដែរ។ ប្រសិនបើវិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ មានការកែប្រែ លក្ខខណ្ឌផ្សេងពីវិញ្ញាបនបត្រដើមនោះមន្ត្រីទទួលបន្ទុកគ្រប់គ្រង

ក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវផ្តល់លិខិតជូនដំណឹងជាបន្ទាន់ចំពោះការកែប្រែនោះ នៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម។ បុគ្គលណាមួយដែលបានបង់ថ្លៃឈ្នួលរួចហើយ បុគ្គលនោះមានសិទ្ធិ ត្រួតពិនិត្យឯកសារនានាដែលបានផ្ញើទៅក្រសួងពាណិជ្ជកម្មនៅគ្រប់ម៉ោងធ្វើការ ហើយអាចធ្វើការថតចម្លង ឬដកស្រង់របាយការណ៍ផ្សេងៗបាន។ ការផ្តល់ឯកសារ ឬថតចម្លងឯកសារដល់បុគ្គលណាម្នាក់ មិនត្រូវបានអនុវត្តចំពោះរបាយការណ៍ស៊ើបអង្កេតរបស់តុលាការទេ។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចផ្តល់ឱ្យបុគ្គលណាម្នាក់នូវច្បាប់ចម្លង ឬច្បាប់ចម្លង ដែលមានការបញ្ជាក់របស់ឯកសារនានា ស្របតាម លក្ខខណ្ឌនៃមាត្រានេះ។ នៅពេលដែលឯកសារត្រូវបានរក្សាទុក ដោយក្រសួងពាណិជ្ជកម្ម ហើយឯកសារនោះមានទម្រង់ជាលាយលក្ខណ៍អក្សរ ត្រូវមានលក្ខខណ្ឌដូចតទៅនេះ :

-ក្រសួងពាណិជ្ជកម្មត្រូវផ្តល់ឯកសារចម្លងដែលតម្រូវឱ្យផ្តល់ស្របតាមច្បាប់ជាទម្រង់ឯកសារដែលអាចអានបាន

-របាយការណ៍ដែលស្រង់ចេញពីឯកសារតម្កល់ទាំងនេះ ប្រសិនបើមានការបញ្ជាក់ពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មជាភស្តុតាង ដែលមានតម្លៃដូចឯកសារដើមដែរ។ ក្រសួងពាណិជ្ជកម្មមិនមានកាតព្វកិច្ចផ្តល់ឯកសារនានា ក្រៅពីវិញ្ញាបនបត្រ និងផែនការរំលាយក្រុមហ៊ុនដែលបានភ្ជាប់មកជាមួយ ក្រោយរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃដែលបានទទួល។

### ផ្នែកទី ២: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

បទបញ្ញត្តិជាមូលដ្ឋាន ដែលអនុវត្តនៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺឆ្លើយតបជាមួយបទដ្ឋាន ដែលអនុវត្តនៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត លើកលែងតែ បទបញ្ញត្តិខ្លះដែលច្បាប់ចង្អុលជាក់លាក់ថាមិនអាចអនុវត្តនៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដូចជា :

-ក្រុមហ៊ុនអាចមានសមាជិកភាគហ៊ុនពី ០២(ពីរ)នាក់-៣០ (សាមសិប)នាក់ ។ ប៉ុន្តែ បុគ្គលម្នាក់ក៏អាចបង្កើតក្រុមហ៊ុនបានដែរ ដែលមានឈ្មោះថាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត មានលក្ខខណ្ឌដូចគ្នាទៅនឹងលក្ខខណ្ឌទាំងឡាយរបស់ក្រុមហ៊ុន ឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែលក្ខខណ្ឌស្តីពីទំនាក់ទំនងរវាងសមាជិកភាគហ៊ុន។

-ក្រុមហ៊ុននោះមិនអាចអនុញ្ញាតឱ្យលក់ភាគហ៊ុន ឬមូលបត្រដទៃទៀត ជាសាធារណៈបានឡើយ។ ប៉ុន្តែ អាចអនុញ្ញាតឱ្យធ្វើអនុប្បទានទៅសមាជិកភាគហ៊ុនសមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន និងក្នុងករណីធ្វើអនុប្បទានទៅឱ្យតតិយជនត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃទៀតតាមសំឡេងភាគច្រើន។

-ក្រុមហ៊ុននោះអាចមានការរឹតត្បិតមួយ ឬច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់។

-ក្រុមហ៊ុនត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចាប់ពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទជាក់លាក់ ដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

-ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមិនអាចបើកក្នុងទម្រង់ជា ក្រុមហ៊ុនធានារ៉ាប់រង ឬធនាគារ ឬក្រុមហ៊ុនឥណទាន (ទម្រង់នេះសម្រាប់តែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត) បានឡើយ។

និយាយជារួម ក្រុមហ៊ុនមូលធន ត្រូវបានសិក្សាស្ថិតក្រោមទម្រង់ក្រុមហ៊ុនជាក់លាក់ ០២ គឺ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើវិចារណាកិច្ចគតិយុត្តទៅលើ ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ នៅក្នុងក្របខណ្ឌនៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត យើងធ្វើការសិក្សាទៅលើ នីតិវិធីនៃការបង្កើតក្រុមហ៊ុន និងសិទ្ធិរបស់ក្រុមហ៊ុន រីឯដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត យើងធ្វើការសិក្សាទៅលើ ការចុះបញ្ជីពាណិជ្ជកម្ម សៀវភៅបញ្ជី កំណត់ហេតុ ការប្រកាសប្រតិវេទន៍ អភិបាលក្រុមហ៊ុន ម្ចាស់ហ៊ុន ភាគហ៊ុន ភាគលាភ មូលបត្រ អ្នកថែរក្សាទ្រព្យសម្បត្តិ និងរបាយការណ៍ហិរញ្ញវត្ថុ។ នៅក្នុងចំណុចនេះ យើងត្រូវធ្វើការពិចារណា ឱ្យបានស៊ីជម្រៅទៅលើ កត្តានីមួយៗ ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ៈក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅកម្ពុជា ដោយត្រូវបញ្ជាក់នៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ដោយត្រូវជូនដំណឹងពីទីស្នាក់ការចុះបញ្ជី ទីតាំង បើមានការផ្លាស់ប្តូរត្រូវជូនដំណឹងនៅក្នុងអំឡុងពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ នេះបើយោងតាមមាត្រា ១០៨ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម។

សៀវភៅបញ្ជីៈក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ខ្លួននូវ លក្ខន្តិកៈ និងគ្រប់ប្រការកែប្រែទាំងអស់ កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចទាំងឡាយរបស់ម្ចាស់ភាគហ៊ុន ឯកសារនៃសេចក្តីជូន-ដំណឹងតម្រូវឱ្យផ្ញើ ឬតម្កល់ទុកជាឯកសារ និងបញ្ជីមូលបត្រ ( មាត្រា១០៩នៃច្បាប់សហគ្រាសពាណិជ្ជកម្ម) ។

កំណត់ហេតុៈក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងអស់ និងសេចក្តីសម្រេចរបស់គណៈកម្មាភិបាលឱ្យបានសព្វគ្រប់ ដោយរក្សាទុកនៅទីស្នាក់ការចុះបញ្ជី ហើយត្រូវរក្សាទុកសម្រាប់រយៈពេល ១០ ឆ្នាំ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ។

ការប្រកាសប្រតិវេទន៍ៈក្រុមហ៊ុនត្រូវរៀបចំសំណុំឯកសារសម្រាប់ប្រកាសពន្ធប្រចាំឆ្នាំនៅនាយកដ្ឋានពន្ធដារ ដោយមានវិក្ក័យបត្រសម្រាប់ជាបន្ទាល់ នៅក្នុងការបញ្ជាក់ពីប្រតិបត្តិការផ្នែកហរិញ្ញវត្ថុរបស់ក្រុមហ៊ុន ទាំងចំណូល និងចំណាយ ដើម្បីបង្ហាញពីផលចំណេញសរុប សម្រាប់ជាមូលដ្ឋាននៃការគិតពន្ធ ។

អភិបាលក្រុមហ៊ុនៈនៅពេលទទួលបានវិញ្ញាបនបត្របញ្ជាក់ពីការបង្កើតក្រុមហ៊ុន ក្រុមប្រឹក្សាភិបាល ត្រូវចាប់ផ្តើមមហាសន្និបាតលើកទី ១របស់ម្ចាស់ហ៊ុននៅក្នុងអំឡុងពេល ០១ ឆ្នាំ បន្ទាប់ពីក្រុមហ៊ុននោះត្រូវបានបង្កើត ។

ម្ចាស់ភាគហ៊ុនៈក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬច្រើននាក់ រីឯក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលក្រុមហ៊ុនយ៉ាងតិច ០៣នាក់ ដោយម្ចាស់ភាគហ៊ុនត្រូវបោះឆ្នោតជ្រើសរើសអភិបាល តាមរយៈសេចក្តីសម្រេចសាមញ្ញនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ។

ភាគហ៊ុនៈភាគហ៊ុននីមួយៗត្រូវចុះបញ្ជីទៅតាមបែបបទដែលមានកំណត់នៅក្នុងច្បាប់ ដោយចារឹកលើបណ្ណ័ ហើយក្រុមហ៊ុនមិនត្រូវចេញបណ្ណ័ភាគហ៊ុនណាមួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើបណ្ណ័នោះទេ ហើយនៅក្នុងករណីលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃបណ្ណ័ភាគហ៊ុន ក្រុមហ៊ុនត្រូវបោះចេញយ៉ាងហោចណាស់ ១000 ភាគហ៊ុន និងតម្លៃចារឹកលើបណ្ណ័មិនតិចជាង ៤000 រៀល/បណ្ណ័ ។

ភាគលាភៈក្រុមហ៊ុនទទួលបានចំណូលពីប្រតិបត្តិការរបស់ខ្លួន និងត្រូវបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន ទៅតាមចំណែករបស់ខ្លួនដែលមានកំណត់នៅក្នុងលក្ខន្តិកៈ លើកលែងតែ មានមូលហេតុសមស្របដើម្បីជាទុនបម្រុង ។

មូលបត្រៈជាលិខិតស្នាមដែលចេញដោយក្រុមហ៊ុន ដែលមានបញ្ជាក់ពីការចុះបញ្ជី គំរូបណ្ណ័ ប្រភេទបណ្ណ័ ភស្តុតាងបញ្ជាក់ភាគហ៊ុន និងអត្ថប្រយោជន៍ផ្សេងៗដែលជាកាតព្វកិច្ចរបស់ក្រុមហ៊ុន ។

អ្នកថែរក្សាទ្រព្យសម្បត្តិៈគឺជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមការតែងតាំងពីតុលាការ ដើម្បីធ្វើការងារជំនួសអភិបាល ដោយមានតួនាទីតាមការណែនាំរបស់តុលាករ និងច្បាប់នៅក្នុងការគ្រប់គ្រងក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុៈអភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាមឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ដោយរបាយការណ៍នោះ ត្រូវបញ្ជាក់អំពីរបាយការណ៍ហិរញ្ញវត្ថុដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន របាយការណ៍របស់សវនករ និងព័តិមានផ្សេងទៀតដែលធ្វើទោតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ឬកិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ភាគហ៊ុន។ ចំណែកឯការរំលាយក្រុមហ៊ុន យើងធ្វើការសិក្សាទៅលើការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការជម្រះបញ្ជីក្រុមហ៊ុន។

លើសពីនេះទៅទៀត ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក៏អនុវត្តតាមបទបញ្ញត្តិនៃក្រុមហ៊ុនមហាជនទទួខុសត្រូវមានកម្រិត ផងដែរ លើកលែងតែ ចំណុចជាក់លាក់ ដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដូចជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចបើកក្រុមហ៊ុនក្នុងទម្រង់ ជាក្រុមហ៊ុនឥណទាន ឬក្រុមហ៊ុនធានារ៉ាប់រង ឬធនាគារ (ទម្រង់ក្រុមហ៊ុននេះសម្រាប់តែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត) បាននោះឡើយ។ មួយវិញទៀត ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចលក់ភាគហ៊ុន ឬមូលបត្រដទៃទៀត ជាសាធារណៈបានឡើយ ហើយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចមានការរឹតត្បិតមួយ ឬច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់។

## ជំពូកទី ៣ៈ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស

ក្រុមហ៊ុនពាណិជ្ជកម្មបរទេសគឺជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ និងបានមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនពាណិជ្ជកម្មបរទេសអាចមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន តាមបែបបទផ្សេងៗដូចតទៅ ការិយាល័យតំណាងពាណិជ្ជកម្ម ឬសាខាក្រុមហ៊ុនពាណិជ្ជកម្ម ឬបុត្រសម្ព័ន្ធ។

ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស ត្រូវចាត់ទុកថាកំពុងធ្វើ

សកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះបានធ្វើសកម្មភាពនានា ដូចជា ជួលការិយាល័យ ជួលកន្លែងផលិត ឬកែច្នៃ ឬសេវាដែលមានរយៈពេលចាប់ពី (០១) មួយខែឡើងទៅ ឬជួលបុគ្គលិកសម្រាប់បម្រើការងារឱ្យក្រុមហ៊ុន ដែលមានរយៈពេលចាប់ពីមួយខែឡើង ឬធ្វើសកម្មភាពដទៃណាមួយទៀត ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេស។ គ្រប់ក្រុមហ៊ុនបរទេសនានាធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះ ជាក្នុងរូបភាពណាមួយក៏ដោយ ក៏ត្រូវស្ថិតនៅក្រោមច្បាប់ និងយុត្តាធិការរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជាជាដាច់ខាត។ ក្រុមហ៊ុនបរទេសទាំងនោះត្រូវបំពេញទម្រង់បែបបទនៃការចុះបញ្ជីពាណិជ្ជកម្ម ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។

## ផ្នែកទី ១: សាខាក្រុមហ៊ុន

សាខាក្រុមហ៊ុនអាចធ្វើសកម្មភាពបានដូចការិយាល័យតំណាងពាណិជ្ជកម្មដែរ។ លើសពីនេះទៀត សាខាក្រុមហ៊ុនអាចទិញនិងលក់ជាប្រចាំបាននូវទំនិញ និងសេវាកម្ម ព្រមទាំងធ្វើសកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែច្នៃ និងការស្ថាបនាដូចសហគ្រាសក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់ហាមឃាត់ចំពោះរូបវន្តបុគ្គលនិង/ឬ នីតិបុគ្គលបរទេស។ ទ្រព្យសកម្មរបស់សាខាគឺជាទ្រព្យសកម្មរបស់ ក្រុមហ៊ុនដើម ហើយក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើកាតព្វកិច្ចរបស់សាខា។ សាខាក្រុមហ៊ុន ត្រូវគ្រប់គ្រង ដោយនាយកគ្រប់គ្រងម្នាក់ ឬច្រើននាក់ ដែលត្រូវតែងតាំង និងដកហូតដោយក្រុមហ៊ុនដើម។ នាមករណ៍របស់សាខា គឺជានាមករណ៍របស់ក្រុមហ៊ុនដើម ដោយនៅពីលើ ឬនៅពីមុខនាមករណ៍នោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុន" ដោយ "សាខាក្រុមហ៊ុន" អាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម។

ឧទាហរណ៍ : សាខាក្រុមហ៊ុន Chryslar Motor Incorporation ដែលមានតួនាទីធ្វើការចែកចាយរថយន្ត ម៉ាក Chryslar នៅទូទាំងប្រទេសកម្ពុជា។

## ផ្នែកទី ២: ការិយាល័យតំណាង

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម អាចធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ជាអាទិ៍ : ទី ១ ទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅធ្វើឱ្យ

អតិថិជនទាំងនោះបានស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន ទី ២ ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម និងផ្តល់ព័ត៌មានទាំងនេះជូនទៅក្រុមហ៊ុនដើមនៅបរទេស ទី ៣ សាវជ្រាវទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទី ៤ ឃោសនាផលិតផល តាំងពិព័រណ៍ពាណិជ្ជកម្ម បង្ហាញផលិតផល នៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៍ដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទី ៥ ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឱ្យការតាំងពិព័រណ៍ពាណិជ្ជកម្ម ទី ៦ ជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក ដើម្បីបម្រើការងារ ទី ៧ ចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុកក្នុងនាមក្រុមហ៊ុនដើម។ ប៉ុន្តែការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម មិនអាចធ្វើសកម្មភាពទិញ លក់និងធ្វើសេវាជាអាជីពប្រចាំ ឬសកម្មភាពពាក់ព័ន្ធនឹងប្រតិបត្តិការផលិតកែច្នៃ និងសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ។ ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូប ឬច្រើនរូបដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម។ នាមករណ៍របស់ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ជានាមករណ៍របស់ក្រុមហ៊ុនដើមនៅឯបរទេស។ នៅខាងលើ ឬនៅពីមុខនាមករណ៍នេះត្រូវសរសេរដាក់ថា ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម។ ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម។

ឧទាហរណ៍ : មន្ទីរពេទ្យ Bumrumprak Hospital បានបើកការិយាល័យតំណាងមួយឈ្មោះថា ការិយាល័យតំណាងមន្ទីរពេទ្យ Bumrumprak Hospital ដែលមានទីស្នាក់នៅតាមផ្លូវព្រះមុនីវង្ស ក្បែរវិទ្យាល័យវត្តកោះ ដែលការិយាល័នេះ មានតួនាទី ធ្វើទំនាក់ទំនងពាណិជ្ជកម្ម និងសកម្មភាពផ្សេងៗ ដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

## ផ្នែកទី ៣: បុត្រសម្ព័ន្ធ

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានភាគហ៊ុនយ៉ាងតិច ៥១(ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ។ បុត្រសម្ព័ន្ធ គឺក្រុមហ៊ុនពាណិជ្ជកម្មបរទេស មាននីតិបុគ្គលិក

លក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើម ចាប់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម តាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬជាក្រុមហ៊ុនមូលធន។ បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចធ្វើគ្រប់សកម្មភាពពាណិជ្ជកម្មជាមុខរបរជាប្រចាំរបស់ខ្លួន ដូចក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាហាមឃាត់ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលបរទេស តែប៉ុណ្ណោះ។

ម្ចាស់ហ៊ុនអាចប្តឹង ឬធ្វើអន្តរាគមន៍ក្នុងនាម និងសិទ្ធិរបស់ក្រុមហ៊ុន ដោយម្ចាស់ហ៊ុនត្រូវបំពេញគ្រប់លក្ខខណ្ឌ ដូចជា : ជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុន ឬអ្នកស្នងមរតករបស់ម្ចាស់ហ៊ុន នៅក្នុងអំឡុងពេលដែលការប្តឹងតវ៉ានោះ កំពុងកើតមានឡើងដោយសារពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ឬមិនបានបោះឆ្នោតគាំទ្រ ឬមិនបានឱ្យសច្ចានុម័តតាមរបៀបណាផ្សេងទៀតឡើយ ឬបានតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការដោះស្រាយជម្លោះហើយដែលក្រុមប្រឹក្សាភិបាលដោះស្រាយមិនបាន ឬផ្តល់លិខិតជូនដំណឹងទៅឱ្យក្រុមប្រឹក្សា-ភិបាល មុនពេលដាក់បណ្តឹងទៅតុលាការ ឬបណ្តឹងជំនួសមុខ បន្ទាប់ពីបាននៅតុលាការ មិនត្រូវបានដោះស្រាយដោយគ្មានការព្រមព្រៀងពីតុលាការឡើយ។ រាល់ប្រាក់សំណងដែលបានមកពីបណ្តឹងនេះ ត្រូវជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ប្រសិនបើបណ្តឹងបានផ្តល់ផលដល់ក្រុមហ៊ុន ម្ចាស់ហ៊ុនដែលបានធ្វើបណ្តឹងជំនួសមុខ អាចស្នើសុំទៅតុលាការ ដើម្បីឱ្យខ្លួនបានទទួលសំណងសមស្រប។

រាល់អភិបាលនិងអ្នកគ្រប់គ្រងក្រុមហ៊ុនដែលកំពុងអនុវត្តតួនាទីរបស់ខ្លួនត្រូវ :

-ធ្វើសកម្មភាពស្មោះត្រង់ក្នុងបំណងល្អ ដើម្បីឱ្យមានផលប្រយោជន៍ខ្ពស់ដល់ក្រុមហ៊ុន

-អនុវត្តដោយយកចិត្តទុកដាក់ ព្យាយាម និងជំនាញ ដូចបុគ្គលដែលមានមធ្យ័តអនុវត្តក្នុងកាលៈទេសៈមួយដូចគ្នាដែរ។ លក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អាចចែងថាគ្រប់ជម្លោះដែលកើតមានឡើងរវាងអភិបាល និងរវាងម្ចាស់ហ៊ុនត្រូវបញ្ជូនទៅមជ្ឈមណ្ឌលមជ្ឈត្តកម្ម។

ឧទាហរណ៍ : ក្រុមហ៊ុន KFC គឺជាក្រុមហ៊ុនមានលក្ខណៈជាបុត្រសម្ព័ន្ធ ដោយសារមានក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម នៅកូរ៉េ ដែលជាក្រុមហ៊ុនស្ថិតនៅបរទេស និងមកធ្វើពាណិជ្ជកិច្ច នៅស្រុកខ្មែរ ដែលមានលក្ខណៈជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន KFC។

និយាយជារួម ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចបង្កើតឡើងក្នុងទម្រង់ជា សាខាក្រុមហ៊ុន ការិយាល័យតំណាង និងបុត្រសម្ព័ន្ធ ហើយទម្រង់នីមួយៗ មាននីតិបុគ្គលិកលក្ខណៈផ្សេងៗគ្នា ដោយសារតែសាខាក្រុមហ៊ុនអាចទិញនិងលក់ជាប្រចាំបាននូវទំនិញ និងសេវាកម្ម ព្រមទាំងធ្វើសកម្មភាពដែលទាក់ទងទៅនឹង ការផលិត ការកែច្នៃ និងការស្ថាបនាដូចសហគ្រាសក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់ហាមឃាត់ ចំពោះរូបវន្តបុគ្គលនិង/ឬ នីតិបុគ្គលបរទេស។ មួយវិញទៀត សម្រាប់ការិយាល័យតំណាង អាចធ្វើទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅ ធ្វើឱ្យអតិថិជនទាំងនោះបានស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន ឬ ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម និងផ្តល់ព័ត៌មានទាំងនេះ ជូនទៅក្រុមហ៊ុនដើមនៅបរទេស ឬស្រាវជ្រាវទីផ្សារនៅក្នុងព្រះ-រាជាណាចក្រកម្ពុជា ឬឃោសនាផលិតផល តាំងពិព័រណ៌ពាណិជ្ជកម្ម បង្ហាញផលិតផល នៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៌ដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬទិញ និងរក្សាទុកទំនិញមួយចំនួនសម្រាប់គោលដៅបម្រើឱ្យការតាំងពិព័រណ៌ពាណិជ្ជកម្ម ឬជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក ដើម្បីបម្រើការងារ ឬចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុកក្នុងនាមក្រុមហ៊ុនដើម។ លើសពីនេះទៅទៀត បុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានភាគហ៊ុនយ៉ាងតិច ៥១%(ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ ដែលមាននីតិបុគ្គលិលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើម។/

# សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការសិក្សា និងស្រាវជ្រាវនៃកិច្ចការទាំងនេះ បានបង្ហាញឱ្យឃើញថា ការសិក្សានៃនីតិក្រុមហ៊ុន គឺសិក្សាអំពីមជ្ឈដ្ឋានការងាររបស់នីតិក្រុមហ៊ុន ដែលលើកឡើងអំពី សហគ្រាសសាធារណៈ សហគ្រាសពហុជាតិ និងសហគ្រាសពាណិជ្ជកម្ម។ ការសិក្សាអំពីសហគ្រាសសាធារណៈ ត្រូវបានបង្ហាញពីសញ្ញាណទូទៅនៃសហគ្រាសសាធារណៈ និងប្រភេទនៃសហគ្រាសសាធារណៈ ដែលតាមរយៈនេះ សញ្ញាណទូទៅនៃសហគ្រាសសាធារណៈត្រូវនិយាយអំពី អត្ថន័យនៃសហគ្រាសសាធារណៈ សិទ្ធិនិងកាតព្វកិច្ចសហគ្រាសសាធារណៈ និងការត្រួតពិនិត្យសហគ្រាសសាធារណៈ ដែលនៅក្នុងចំណុចនេះផ្តោតជាសំខាន់ទៅលើថាសហ-គ្រាសសាធារណៈ គឺជាសហគ្រាស ដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ដែលសហគ្រាសសាធារណៈ មានបេសកម្មបង្កលក្ខណៈ ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ នៅក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។

សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ដោយក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈ ដែលគេហៅកាត់ថាក្រុមប្រឹក្សាភិបាល ជាអង្គការ ដឹកនាំខ្ពស់បំផុត នៅក្នុងសហគ្រាសាធារណៈ ហើយបំពេញមុខងារ ប្រកបដោយស្វ័យភាពបរិបូរណ៍ ហើយចំនួន សមាជិកនៃក្រុមប្រឹក្សាភិបាលមិនត្រូវលើស ពី ០៧ នាក់ឡើយ។ រីឯសិទ្ធិ និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ គឺធ្វើការបរិយាយអំពីភារកិច្ច និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា និងកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលតាមរយៈនេះ សហគ្រាសសាធារណៈ មានភារកិច្ចធ្វើកំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល ថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ របាយការណ៍ស្តីពីសកម្មភាពតុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ របាយ-ការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា។ មួយវិញទៀត ការត្រួតពិនិត្យសហគ្រាសសាធារណៈ ផ្តោតជាសំខាន់ទៅលើស្ថាប័នរដ្ឋដែលគ្រប់គ្រងសេវាសាធារណៈ និងស្ថាប័នឯកជនដែលគ្រប់សេវាសាធារណៈ ដែលនៅក្នុងក្របខណ្ឌនេះ ស្ថាប័នរដ្ឋដែលគ្រប់គ្រងសេវានេះ ត្រូវធ្វើការមួយចំនួន ដូចជា ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលមានចែងនៅក្នុងច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន, ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល, ការតាមដានការប្រព្រឹត្តទៅ និងករអភិវឌ្ឍន៍របស់សហគ្រាស, ប្រក្រតីភាពនៃ

សកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស ហើយស្ថាប័នឯកជនដែលគ្រប់គ្រងសេវានេះ អាចធ្វើទៅលើសេវាមួយចំនួនដូចជាៈ បរិបទទូទៅនៃការប្រគល់សេវាសាធារណៈ(ទី១- ផ្សព្វផ្សាយជាសាធារណៈ ទី ២- ការគ្រប់គ្រង សេវាសាធារណៈត្រូវមានរយៈពេលមួយជា កំណត់ និងទី ៣- នៅក្នុងកិច្ចសន្យាសម្បទាន ត្រូវបន្ថែមតម្លៃខ្លះ ទៅតាមស្ថានភាពជាក់ស្តែង) និង សម្បទានលើសេវាសាធារណៈត្រូវមានស្ថានភាពជា( លក្ខណៈសេវាសាធារណៈ សម្បទានិកជាអ្នកទទួលខុសត្រូវសម្បទានិក យកចំណូលពីអតិថិជន រដ្ឋនៅតែមានសិទ្ធិត្រួតពិនិត្យសេវាសាធារណៈនិងអំណាចរបស់សម្បទានិក ត្រូវបានកម្រិតដោយខហួសប្រមាណ) ។ ប្រភេទនៃសហគ្រាសសាធាណៈត្រូវបានបែងចែកជា ០៣ ផ្នែក គឺគ្រឹះស្ថានសាធារណៈ មានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះ។ ចាប់ផ្តើមពីចំណុចនេះ គ្រឹះស្ថានសាធារណៈ មានលក្ខណៈសេដ្ឋកិច្ចគឺជាគ្រឹស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ចគឺជានីតិបុគ្គលនៃនីតិសាធារណៈដែល មានស្វ័យភាពហិរញ្ញវត្ថុ ហើយគ្រឹះស្ថាននេះ ផលិតផលទំនិញ ឬធ្វើសេវាសម្រាប់ទីផ្សារ។ គ្រឹះស្ថានសាធារណៈដែល មានលក្ខណៈសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរមក្តារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ដោយអនុក្រឹត្យនេះកំណត់ ជាអាទិ៍ : ភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ និងវិធាននៃការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន។ រីឯក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុន ទាំងអស់ជារបស់រដ្ឋ។ ក្រុមហ៊ុនរដ្ឋត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យ តាមការស្នើរមក្តារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ដោយអនុក្រឹត្យនេះ នឹងកំណត់ ជាអាទិ៍ កម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្ត ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែល ត្រូវអនុវត្ត និងសមាសភាពក្រុមប្រឹក្សាភិបាល។ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយ រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុនដោយមានការព្រមព្រៀងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាត់ចែងឈ្មោះ នៅក្នុងបញ្ជីពាណិជ្ជកម្ម និងបំពេញបែបបទទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។ ដោយឡែកក្រុមហ៊ុនចម្រុះគឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើង តាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម

ហើយដើមទុនត្រូវបានកាន់កាប់រួមគ្នា ដោយនីតិបុគ្គល ឬរូបវន្តបុគ្គល ឬបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ។ កាលណាភាគកម្មសាធារណៈលើសពី ៥១% នៃដើមទុន ឬសិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះ ត្រូវបានចាត់ទុកជាគ្រឹះស្ថានសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រ៉ាប់រងខាងផ្នែករដ្ឋបាលលើភាគកម្មសាធារណៈ ហើយប្រតិបត្តិការហិរញ្ញវត្ថុអំពីភាគកម្មសាធារណៈ ត្រូវបានធ្វើឱ្យសម្រេចដោយអនុលោមតាមបញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុ ជាធរមាន។ បដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃក្រុមហ៊ុននីតិពាណិជ្ជកម្ម រដ្ឋ គ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនរដ្ឋ ត្រូវបានលើកលែងការតម្កល់ភាគហ៊ុនធានាសម្រាប់តំណាងនៅក្នុងក្រុមប្រឹក្សាភិបាលសហគ្រាស ដែលខ្លួនបានចូលរួម។

ម្យ៉ាងវិញទៀត សហគ្រាសពហុជាតិ យើងធ្វើការសិក្សាទៅលើវដ្តជីវិតនៃសហគ្រាសពហុជាតិ ដែលបង្កើតជាខ្សែចង្វាក់នៃវិវឌ្ឍនាការរបស់ក្រុមហ៊ុន គឺការបង្កើតសហគ្រាសពហុជាតិ ដំណើរការសហគ្រាសពហុជាតិ និងការរំលាយសហគ្រាសពហុជាតិ។ នៅក្នុងការបង្កើតសហគ្រាសពហុជាតិ យើងធ្វើការពិចារណាទៅលើសារធាតុនៃសហគ្រាសពហុជាតិ និងសណ្ឋាន នៃសហគ្រាសពហុជាតិ ដែលតាមរយៈនេះ សារធាតុនៃសហគ្រាសពហុជាតិ យើងធ្វើវិចារណកិច្ចគតិយុត្តទៅលើ អត្ថន័យ លក្ខណៈសំគាល់នៃសហគ្រាសពហុជាតិ និងរចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ។ នៅពេលយើងលើកពី អត្ថន័យនៃសហគ្រាសពហុជាតិត្រូវបានពន្យល់ថាជាសហគ្រាសដែលមានសាខាជាអ្នកផលិត-លក់ និងផ្តល់សេវា នៅក្នុងប្រទេសមួយ ឬច្រើន។ សហគ្រាសពហុជាតិធ្វើការកែច្នៃ និងបង្កើតទំនិញថ្មីៗ នៅក្នុងប្រទេសដើមកំណើត របស់ខ្លួនរួចធ្វើការផលិតនៅបរទេស។ ប៉ុន្តែយោងតាមអត្ថន័យរបស់រាជរដ្ឋាភិបាលនៃបណ្តារដ្ឋសមាជិកអង្គការ សហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍(OECD)សហគ្រាសពហុជាតិ ជាបណ្តាក្រុមហ៊ុនដែលនៅក្នុង នោះមានក្រុមហ៊ុនផ្សេងៗ ដែលអាចជាកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិរបស់រដ្ឋ ឬជាកម្មសិទ្ធិរួមគ្នារវាងរដ្ឋ និង ឯកជន។ ក្រុមហ៊ុនទាំងនេះមាននៅតាមបណ្តាប្រទេសផ្សេងៗគ្នា និងមានទំនាក់ទំនងជាមួយក្រុមហ៊ុនមួយ ឬ ច្រើន ដែលមានឥទ្ធិពលទៅលើក្រុមហ៊ុនមួយទៀត។ រីឯលក្ខណៈសំគាល់នៃសហគ្រាសពហុជាតិ គេពិចារណា ទៅលើលក្ខណៈ ០៤ យ៉ាង :**ប្រព័ន្ធនៃការគ្រប់គ្រង**(សំដៅទៅលើចំនួនប្រទេសដែលសហគ្រាសពហុជាតិដំណើរ ការនៃមុខជំនួញ ព្រមទាំងភាពជាកម្មសិទ្ធិនៃកម្មវត្ថុពាណិជ្ជកម្ម។ ចំពោះសហគ្រាសពហុជាតិ ភាគច្រើន ម្ចាស់កម្មសិទ្ធិជាប្រទេស ដែលមានទីស្នាក់ការ

កណ្តាល និងអាចមានដាក់ភាគហ៊ុននៅតាមបណ្តាប្រទេសផ្សេងៗ។ **ការមើលឃើញជារួម** (ជាការមើលឃើញជាទូទៅចំពោះសហគ្រាសពហុជាតិទៅលើភាគរយនៃចំណូល ឬប្រាក់ចំណេញប្រចាំឆ្នាំ និងកម្មសិទ្ធិផ្សេងៗ ព្រមទាំងនិយោជិតដែលមានសញ្ជាតិបរទេសជាដើម។ **អត្តចរិកក្រុមហ៊ុន** (ភាពចម្រុះជាតិសាសន៍នៃអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងរង្វង់ក្រុមហ៊ុនអន្តរជាតិ និងសហគ្រាសពហុជាតិរបស់សហគមន៍អឺរ៉ុប ភាគច្រើនមានថ្នាក់ដឹកនាំសញ្ជាតិបរទេស រីឯសហរដ្ឋអាមេរិក ជាប្រទេសដែលមានលក្ខណៈលើកលែង ព្រោះថ្នាក់ដឹកនាំជាន់ខ្ពស់ភាគច្រើនមានសញ្ជាតិអាមេរិក តែម្តង។ **ការសម្របសម្រួល** (ក្រុមហ៊ុនមួយ ដែល របៀបនៃការគ្រប់គ្រងជំនួញរបស់ខ្លួនមាន ០២ របៀប គឺ Multiple-domestic និង Global ។ Multiple-domestic គឺជាប្រភេទក្រុមហ៊ុនដែលសម្របខ្លួន ទៅតាមទីផ្សារផ្សេងៗគ្នា ដែលបង្ហាញយ៉ាងជាក់លាក់ពីបណ្តុំ សាខា ជាច្រើនរបស់ក្រុមហ៊ុននោះ។ រីឯក្រុមហ៊ុន Global គឺជាក្រុមហ៊ុនបង្កើតជាផលិតផលស្តង់ដារ សម្រាប់ គ្រប់គ្រងប្រទេស ដែលចាត់ទុករាល់បណ្តាប្រទេស លើពិភពលោក ជាទីផ្សារតែមួយ និងមិនសម្របផលិតផល របស់ខ្លួន ទៅតាមសារធាតុផ្សេងៗគ្នានៃប្រទេស នោះឡើយ។ ដោយឡែក រចនាសម្ព័ន្ធនៃសហគ្រាសពហុជាតិ គឺផ្តោតទៅលើលក្ខណៈ ០៤ យ៉ាង (ប្រភេទនៃទីផ្សារ ដែលសហគ្រាសពហុជាតិបណ្តាក់ទុន ការប្រកួតប្រជែង លើទីផ្សារ ដែលត្រូវជ្រើសរើសប្រភេទផលិតផល ឬទំនិញ ឬសេវា ដែលត្រូវបានបណ្តាក់ទុនដោយសហគ្រាស ពហុជាតិ និងតម្រូវការ ដែលឈានទៅដល់ផលិតផលទំនិញ ឬសេវា)។សណ្ឋាននៃសហគ្រាសពហុជាតិ ត្រូវលើកឡើងពី ជម្រើសនៃសហ-គ្រាសពហុជាតិ មូលហេតុនៃការបណ្តាក់ទុននៅបរទេស រូបភាពនៃការបណ្តាក់ទុនរបស់សហគ្រាសពហុជាតិ សញ្ជាតិនៃសហគ្រាស និងការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា។ ជម្រើសនៃសហគ្រាសពហុជាតិ ផ្តោតទៅលើក្រុមហ៊ុនពាណិជ្ជកម្ម តែម្នាក់ឯង, ក្រុមហ៊ុនសហកម្មសិទ្ធិ, ក្រុមហ៊ុនសាជីវកម្ម, ក្រុមហ៊ុនពាណិជ្ជកម្មទទួលភារៈគ្រប់គ្រងក្រុមហ៊ុន ឯកភាពទទួលភារៈគ្រប់គ្រង និងក្រុមហ៊ុន Franchise។ ចំណែកឯ មូលហេតុនៃការបណ្តាក់ទុននៅបរទេសគឺឈានទៅដល់កម្រិតនៃការជោគជ័យនៃទីផ្សារ ,ការប្រកួតប្រជែងនៃទីផ្សារ ដែលជាដៃគូរប្រកួតប្រជែង ,កាត់បន្ថយចំណាយ ដោយសហគ្រាសពហុជាតិកាត់បន្ថយទៅតាមតម្លៃពលកម្ម និងពន្ធដារ, ទប់ស្កាត់ការនាំចូលនៅ ក្នុងប្រទេសដើមកំណើត តាមរយៈការបង្កើតសាខា ព្រមទាំងទប់ស្កាត់ការរីកដុះដាលទីផ្សារ ចំពោះទំនិញ គូ ប្រកួតប្រជែងលើទំនិញនាំចេញរបស់ខ្លួន ទៅកាន់ប្រទេសទទួលទំនិញនាំចូល។

មួយវិញទៀត រូបភាពនៃការ បណ្តាក់ទុនរបស់សហគ្រាសពហុជាតិ ធ្វើឡើងតាមរយៈ( ការិយាល័យតំណាងពាណិជ្ជកម្ម ,សាខាសហគ្រាស ពាណិជ្ជកម្ម និងបុត្រសម្ព័ន្ធ) ។ រីឯសញ្ជាតិនៃសហគ្រាសពហុជាតិ អាស្រ័យលើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មដោយក្រុមហ៊ុននឹងទទួលបានបុគ្គលភាពគតិយុត្តសញ្ជាតិខ្មែរក្នុងករណី( ក្រុមហ៊ុនសហកម្មសិទ្ធិនោះមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅកម្ពុជា និងអត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ត្រូវជាកម្មសិទ្ធិ កាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ) ។ យ៉ាងណាក៏ដោយ ដំណើការរបស់សហគ្រាសពហុជាតិ ត្រូវបង្ហាញតាមរយៈសញ្ញាណទូទៅនៃសហគ្រាសពហុជាតិ និងទំនាក់ទំនងនៃសហគ្រាសពហុជាតិ ដែលតាមរយៈនេះ សញ្ញាណទូទៅនៃសហគ្រាសពហុជាតិលើកឡើងពី ភាគហ៊ុន ការបង់ពន្ធ និងការមិនបានបង់ពន្ធ ដែលនាំឱ្យមានពិន័យនៅពេលមិនគោរពកាតព្វកិច្ចដែលតម្រូវដោយច្បាប់ ដើម្បីទទួលបាននូវភាពស្រប ច្បាប់នៃសកម្មភាពពាណិជ្ជកិច្ចរបស់ខ្លួន នៅក្នុងដែនដីរដ្ឋបាលជាក់លាក់ណាមួយ ។ មួយវិញទៀត នៅពេលចង់បញ្ចប់ដំណើរការរបស់ក្រុមហ៊ុន អាចធ្វើឡើងតាមមធ្យោបាយរំលាយសហគ្រាសបហុជាតិ ដែលការរំលាយនេះ ធ្វើឡើងតាមរយៈមូលហេតុនៃការរំលាយ និងការជម្រះបញ្ជី ។

លើសពីនេះទៅទៀត សហគ្រាសពាណិជ្ជកម្ម យើងត្រូវធ្វើវិចារណកិច្ចគតិយុត្តទៅលើក្រុមហុនសហ-កម្មសិទ្ធិ ក្រុមហ៊ុនមូលធន និងក្រុមហ៊ុនពាណិជ្ជកម្មបរទេស ។ នៅក្នុងក្របខណ្ឌ័នៃក្រុមហ៊ុនសហកម្មសិទ្ធិ មានទម្រង់ក្រុមហ៊ុនពីរ គឺក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវសិក្សាទៅលើ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដំណើរការក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលនៅក្នុងក្របខណ្ឌនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺផ្តោតទៅលើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរ លុះត្រាតែ : ក្រុមហ៊ុនសហកម្មសិទ្ធិ ទូទៅមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយអត្ថប្រយោជន៍ នៅក្នុងក្រុមហ៊ុនចាប់ពី ៥១% ឡើងទៅ ត្រូវបានកាន់កាប់ដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែល មានសញ្ជាតិខ្មែរ ។ នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករ ទូទៅម្នាក់ ឬច្រើននាក់ ហើយនៅខាងក្រោយ ឬខាងក្រោម

នាមករណ៍នោះត្រូវបន្ថែមពាក្យថា "ក្រុមហ៊ុនសហ កម្មសិទ្ធិករទូទៅ" ដោយក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅពេលធ្វើ ពាណិជ្ជកិច្ច ហើយសហកម្មសិទ្ធករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវ ចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក ឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្ម សិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយ នៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។

រីឯដំណើរការនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គេធ្វើការពិចារណាទៅលើទំនាក់ទំនងរវាងសហកម្មសិទ្ធិករ ទូទៅ និងសហកម្មសិទ្ធិករទូទៅ ទំនាក់ទំនងក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅ និងតតិយជន និងការផ្ទេរសិទ្ធិជា សហកម្មសិទ្ធិករទូទៅ។ នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ទ្រព្យសម្បត្តិ ជាភាគទុន សហ កម្មសិទ្ធិករទូទៅនោះ ត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុន សហកម្មសិទ្ធិទូទៅ។ នៅពេលសហកម្មសិទ្ធិករទូទៅបានយល់ព្រមបង់ភាគទុននូវចំនួនទឹកប្រាក់ណាមួយ ហើយ ខកខានមិន បានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលខុសត្រូវចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គល នោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀត ដែលត្រូវទាមទារពីសហកម្មសិទ្ធិករទូទៅនោះ។ នៅពេល សហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមដាក់ភាគទុន ជាចំណេះដឹង ជាសេវា ឬជាសកម្មភាព សហកម្មសិទ្ធករ ទូទៅនោះ ត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ។ កិច្ចសន្យាជាលាយ លក្ខណ៍អក្សរ សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ប្រសិនបើ ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ ជាចំណេះដឹង ជាសេវា ឬជាសកម្មភាព។ ដើមទុនរបស់ក្រុមហ៊ុន សហកម្មសិទ្ធិទូទៅ រួមមានភាគទុនជាសាច់ប្រាក់ និងជាវត្ថុ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្ម សិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬភាគទុនជាសកម្មភាពនោះទេ។ ដើមទុនរបស់ ក្រុមហ៊ុន សហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ។

ម្យ៉ាងវិញទៀត ការរំលាយ និងការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ យើងធ្វើការសិក្សាទៅលើ :

មូលហេតុដែលមានចែងក្នុងកិច្ចសន្យា (គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់, គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត, តាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ) និងតុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់។ អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិ ដែលនៅសេសសល់ឱ្យ ទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិ របស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឱ្យតតិយជននោះវិញ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច។

លើសពីនេះទៅទៀត ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនាមករណ៍របស់ក្រុមហ៊ុន សហកម្មសិទ្ធិមានកម្រិត ត្រូវបញ្ចូលឈ្មោះរបស់សហកម្មសិទ្ធិករ ទូទៅម្នាក់ ឬច្រើននាក់ និងនៅខាងក្រោយ ឬក្រោមនាមករណ៍នោះ ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ហើយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវប្រើឈ្មោះនោះក្នុងខណៈដែលខ្លួនធ្វើអាជីវកម្ម។សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាទុកនូវកំណត់ហេតុដែលមានឈ្មោះ អាសយដ្ឋានរបស់សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ និងព័ត៌មានដែលទាក់ទងទៅនឹងការបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាកំណត់ហេតុទុកនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ។ សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីការតម្កល់ទុក និងការផ្សព្វផ្សាយដែលតម្រូវឱ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះអនុវត្ត ផងដែរ។

ចំណែកឯក្រុមហ៊ុនមូលធន មានសណ្ឋានពីរប្រភេទ ផងដែរ គឺ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសរត្រូវមានកម្រិត នៅក្នុងក្រុមហ៊ុនមហាជន ទទួលខុសត្រូវមានកម្រិត ត្រូវធ្វើវិចារណាកិច្ចគតិយុត្តទៅលើ ការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមាន កម្រិត ដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងការរំលាយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ នៅក្នុងក្របខណ្ឌ័នៃការបង្កើតក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត យើងធ្វើការសិក្សាទៅលើនីតិវិធីនៃការ

បង្កើតក្រុមហ៊ុន និងសិទ្ធិរបស់ក្រុមហ៊ុន រីឯដំណើរការក្រុមហ៊ុនមហាជនទទួលខុសត្រូវមាន កម្រិត យើងធ្វើការសិក្សាទៅលើការចុះបញ្ជីពាណិជ្ជកម្ម សៀវភៅបញ្ជី កំណត់ហេតុ ការប្រកាសប្រតិវេទន៍ អភិបាលក្រុមហ៊ុន ម្ចាស់ហ៊ុន ភាគហ៊ុន ភាគលាភ មូលបត្រ អ្នកថែរក្សាទ្រព្យសម្បត្តិ និងរបាយការណ៍ហិរញ្ញវត្ថុ។ នៅក្នុងចំណុចនេះ យើងត្រូវធ្វើការពិចារណា ឱ្យបានស៊ីជម្រៅទៅលើកត្តានីមួយៗ ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម :ក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅកម្ពុជា ដោយត្រូវបញ្ជាក់នៅក្នុងលក្ខន្តិកៈ ក្រុមហ៊ុនដោយត្រូវជូនដំណឹងពីទីស្នាក់ការចុះបញ្ជី ទីតាំង បើមានការផ្លាស់ប្តូរត្រូវជូនដំណឹងនៅក្នុងអំឡុងពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរ នេះបើយោងតាមមាត្រា ១០៨ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម។ សៀវភៅបញ្ជីៈក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ខ្លួននូវ លក្ខន្តិកៈ និងគ្រប់ប្រការកែប្រែទាំងអស់ កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចទាំងឡាយរបស់ម្ចាស់ភាគហ៊ុន ឯកសារនៃសេចក្តីជូន-ដំណឹងតម្រូវឱ្យផ្ញើ ឬតម្កល់ទុកជាឯកសារ និងបញ្ជីមូលបត្រ ( មាត្រា១០៩នៃច្បាប់សហគ្រាសពាណិជ្ជកម្ម) ។ កំណត់ហេតុៈក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងអស់ និងសេចក្តីសម្រេចរបស់គណៈកម្មាភិបាលឱ្យបានសព្វគ្រប់ ដោយរក្សាទុកនៅទីស្នាក់ការចុះបញ្ជី ហើយត្រូវរក្សាទុកសម្រាប់រយៈពេល ១០ ឆ្នាំ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ។ ការប្រកាសប្រតិវេទន៍ៈក្រុមហ៊ុនត្រូវរៀបចំសំណុំឯកសារសម្រាប់ប្រកាសពន្ធប្រចាំឆ្នាំនៅនាយកដ្ឋានពន្ធដារ ដោយមានវិក្កយបត្រសម្រាប់ជាបន្ទាល់ នៅក្នុងការបញ្ជាក់ពីប្រតិបត្តិការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ទាំងចំណូល និងចំណាយ ដើម្បីបង្ហាញពីផលចំណេញសរុបសម្រាប់ជាមូលដ្ឋាននៃការគិតពន្ធ។ អភិបាលក្រុមហ៊ុនៈនៅពេលទទួលបានវិញ្ញាបនបត្របញ្ជាក់ពីការបង្កើតក្រុមហ៊ុន ក្រុមប្រឹក្សាភិបាល ត្រូវចាប់ផ្តើមមហាសន្និបាតលើកទី ១របស់ម្ចាស់ហ៊ុននៅក្នុងអំឡុងពេល ០១ ឆ្នាំ បន្ទាប់ពីក្រុមហ៊ុននោះត្រូវបានបង្កើត។ ម្ចាស់ភាគហ៊ុនៈក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬច្រើននាក់ រីឯក្រុមហ៊ុនមហា ជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលក្រុមហ៊ុនយ៉ាងតិច ០៣នាក់ ដោយម្ចាស់ភាគហ៊ុនត្រូវបោះឆ្នោត ជ្រើសរើសអភិបាល តាមរយៈសេចក្តីសម្រេចសាមញ្ញនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ ភាគហ៊ុនៈភាគហ៊ុននីមួយៗត្រូវចុះបញ្ជីទៅតាមបែបបទដែលមានកំណត់នៅក្នុងច្បាប់ដោយចារឹកលើបណ្ណ័ ហើយក្រុមហ៊ុនមិនត្រូវចេញបណ្ណ័ភាគហ៊ុនណាមួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើ

បណ្ណ័នោះទេ ហើយនៅក្នុងករណីលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃបណ្ណ័ភាគហ៊ុន ក្រុមហ៊ុនត្រូវបោះចេញយ៉ាងហោចណាស់ ១០០០ ភាគហ៊ុន និងតម្លៃចារឹកលើបណ្ណ័មិនតិចជាង ៤០០០ រៀល/បណ្ណ័។ ភាគលាភៈ ក្រុមហ៊ុនទទួលបានចំណូលពីប្រតិបត្តិការរបស់ខ្លួន និងត្រូវបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន ទៅតាមចំណែករបស់ខ្លួនដែលមានកំណត់នៅក្នុងលក្ខន្តិកៈ លើកលែងតែ មានមូលហេតុសមស្របដើម្បីជាទុនបម្រុង។ មូលបត្រៈ ជាលិខិតស្នាមដែលចេញដោយក្រុមហ៊ុន ដែលមានបញ្ជាក់ពីការចុះបញ្ជី គំរូបណ្ណ័ ប្រភេទបណ្ណ័ ភស្តុតាងបញ្ជាក់ភាគហ៊ុន និងអត្ថប្រយោជន៍ផ្សេងៗដែលជាកាតព្វកិច្ចរបស់ក្រុមហ៊ុន។ អ្នកថែរក្សាទ្រព្យសម្បត្តិៈគឺជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមការតែងតាំងពីតុលាការ ដើម្បីធ្វើការងារជំនួសអភិបាល ដោយមានតួនាទីតាមការណែនាំរបស់តុលាករ និងច្បាប់នៅក្នុងការគ្រប់គ្រងក្រុមហ៊ុន។ របាយការណ៍ហិរិញ្ញវត្ថុៈអភិបាលត្រូវបង្ហាញរបាយការណ៍ហិរិញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ដោយរបាយការណ៍នោះ ត្រូវបញ្ជាក់អំពីរបាយ-ការណ៍ហិរិញ្ញវត្ថុដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធ បច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន របាយការណ៍របស់សវនករ និងព័ត៌មានផ្សេងទៀតដែលធ្វើទៅតាមស្ថានភាព ហិរិញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬកិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ភាគហ៊ុន។ ចំណែកឯការរំលាយក្រុមហ៊ុន យើងធ្វើការសិក្សាទៅលើការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការជម្រះបញ្ជីក្រុមហ៊ុន។

លើសពីនេះទៅទៀត ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក៏អនុវត្តតាមបទបញ្ញត្តិនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ផងដែរ លើកលែងតែ ចំណុចជាក់លាក់ ដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដូចជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចបើកក្រុមហ៊ុនក្នុងទម្រង់ ជាក្រុមហ៊ុនឥណទាន ឬក្រុមហ៊ុនធានារ៉ាប់រង ឬធនាគារ (ទម្រង់ក្រុមហ៊ុននេះសម្រាប់តែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត) បាននោះឡើយ។ មួយវិញទៀត ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចលក់ភាគហ៊ុន ឬមូលបត្រដទៃទៀត ជាសាធារណៈបានឡើយ ហើយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចមានការរឹតត្បិតមួយ ឬច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់។

បន្ថែមពីនេះទៅទៀត ការសិក្សាទៅលើក្រុមហ៊ុនពាណិជ្ជកម្មបរទេស ត្រូវស្ថិតក្រោមទម្រង់បី គឺ សាខាក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម និងបុត្រសម្ព័ន្ធ។ សាខាក្រុមហ៊ុនអាចទិញនិងលក់ជាប្រចាំបាននូវទំនិញ និងសេវាកម្ម ព្រមទាំងធ្វើសកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែច្នៃ និងការស្ថាបនាដូចសហគ្រាសក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់ហាមឃាត់ ចំពោះរូបវន្តបុគ្គលនិង/ឬ នីតិបុគ្គលបរទេស។ ទ្រព្យសកម្មរបស់សាខាគឺជាទ្រព្យសកម្មរបស់ ក្រុមហ៊ុនដើម ហើយក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើកាតព្វកិច្ចរបស់សាខា។ សាខាក្រុមហ៊ុន ត្រូវគ្រប់គ្រង ដោយនាយក គ្រប់គ្រងម្នាក់ ឬច្រើននាក់ ដែលត្រូវតែងតាំង និងដកហូតដោយក្រុមហ៊ុនដើម។ នាមករណ៍របស់សាខា គឺជានាមករណ៍របស់ក្រុមហ៊ុនដើម ដោយនៅពីលើ ឬនៅពីមុខនាមករណ៍នោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុន" ដោយ "សាខាក្រុមហ៊ុន" អាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម។ រីឯការិយាល័យតំណាងអាចធ្វើសកម្មភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ជាអាទិ៍ : ទី ១ ទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅធ្វើឱ្យអតិថិជនទាំងនោះបានស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន ទី ២ ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម និងផ្តល់ព័ត៌មានទាំងនេះជូនទៅក្រុមហ៊ុនដើមនៅបរទេស ទី ៣ សាវជ្រាវទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទី ៤ ឃោសនាផលិតផលតាំងពិព័រណ៍ពាណិជ្ជកម្ម បង្ហាញផលិតផល នៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៍ដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទី ៥ ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឱ្យការតាំងពិព័រណ៍ពាណិជ្ជកម្ម ទី ៦ ជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក ដើម្បីបម្រើការងារ ទី ៧ ចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុកក្នុងនាមក្រុមហ៊ុនដើម។ ប៉ុន្តែការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម មិនអាចធ្វើសកម្មភាពទិញ លក់និងធ្វើសេវាជាអាជីពប្រចាំ ឬសកម្មភាពពាក់ព័ន្ធនឹងប្រតិបត្តិការផលិតកែច្នៃ និងសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ។ ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូប ឬច្រើនរូបដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម។ នាមករណ៍របស់ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ជានាមករណ៍របស់ក្រុមហ៊ុនដើមនៅឯបរទេស និងនៅខាងលើ ឬនៅពីមុខ

នាមករណ៍នេះត្រូវសរសេរដាក់ថា ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម។ ដោយឡែកបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានភាគហ៊ុនយ៉ាងតិច ៥១(ហាសិបមួយ)ភាគរយ ត្រូវបាន កាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ។ បុត្រសម្ព័ន្ធ គឺក្រុមហ៊ុនពាណិជ្ជកម្មបរទេស មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើម ចាប់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម តាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬជាក្រុមហ៊ុនមូលធន។ បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចធ្វើគ្រប់សកម្មភាពពាណិជ្ជកម្មជាមុខរបរ ជាប្រចាំរបស់ខ្លួន ដូចក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកដែរ លើកលែងតែសកម្មភាព ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាហាមឃាត់ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលបរទេស។

បើទោះបីជាមានចំណុចវិជ្ជមាននៅក្នុងក្របខណ្ឌនៃទ្រឹស្តី និងអត្ថបទច្បាប់ក៏ដោយ ប៉ុន្តែបញ្ហានៅតែកើតមានឡើងដដែល គឺភាពមិនច្បាស់លាស់នៃការអនុវត្ត ប្រសិទ្ធភាពនៃការអនុវត្ត ដោយឃើញពីចំណុចខ្វះខាតយ៉ាងនេះ ខ្ញុំមានយោបល់មួយចំនួន ដើម្បីធ្វើឱ្យអត្ថបទច្បាប់នេះ និងការអនុវត្តមានប្រសិទ្ធភាព ដែលអាចអនុវត្តប្រកបដោយតម្លាភាព ហើយចូលរួមលើកតម្កើងគំនិតច្នៃប្រឌិត និងតម្លៃគតិយុត្ត គឺ :

-ផ្សព្វផ្សាយអត្ថបទច្បាប់ដែលពាក់ព័ន្ធនឹងនីតិក្រុមហ៊ុន និងអប់រំដល់អ្នកពាក់ព័ន្ធ ឱ្យស្គាល់អំពីតម្លៃនៃគំនិតប្រាជ្ញាគតិយុត្ត

-ពង្រឹងការចុះបញ្ជីពាណិជ្ជកម្ម និងបង្កើតប្រកាសដែលមានកំណត់នៅក្នុងច្បាប់ រួមជាមួយនឹងសេចក្តីណែនាំផ្សេងៗ ដែលមានប្រយោជន៍ពាក់ព័ន្ធនឹងក្រុមហ៊ុន

-ផ្តល់នូវអប្បហារចំពោះអ្នកចុះអនុវត្ត និងបង្ក្រាបអ្នកក្លែងបន្លំ ឬបំពានកម្មសិទ្ធបញ្ញា

-លើកទឹកចិត្តឱ្យមានការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈការផ្តល់នូវជំនួយផ្សេងៗ និងលុបបំបាត់ចោលនូវឱកាសពុករលួយ និងការិយាល័យធិបតេយ្យ

-ពង្រឹងមន្ត្រីអនុវត្ត និងដាក់ទណ្ឌកម្មទៅតាមទំហំនៃកំហុស ហើយលើកទឹកចិត្តដល់អ្នកអនុវត្តឱ្យត្រឹមត្រូវ ដោយផ្តល់នូវមេដាយការងារ ឬប័ណ្ណសរសើរ រួមជាមួយរង្វាន់លើកទឹកចិត្តផ្សេងៗ

-បង្ហាញពីតម្លាភាព និងសុឆន្ទៈ នៅក្នុងការអនុវត្តច្បាប់

-ធ្វើឱ្យមានលក្ខណៈជាសកលភាវូបនីយកម្មនៃនីតិក្រុមហ៊ុន ដើម្បីក្លាយជាបមាណីយអន្តរជាតិ

-ធ្វើក្រមកម្មទៅលើវិធានស្តីពីតុលាការពាណិជកម្ម

-ធ្វើក្រមកម្មនៃបទបញ្ញត្តិនីតិក្រុមហ៊ុន

-កំនត់ពីវិសាលភាពនៃអំណាចតុលាការពាណិជ្ជកម្មឱ្យបានច្បាស់លាស់ ។/

# បញ្ជីឯកសារយោង

## I- ឯកសារគតិយុត្ត

១/រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២/ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រម្ពុជា ចុះថ្ងៃទី ០៨ ធ្នូ ២០០៧

៣/ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រម្ពុជា ចុះថ្ងៃទី ០៦ កក្កដា ២០០៦

៤/ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ២៦ មិថុនា ១៩៩៥

៥/ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ១៨ វិច្ឆិកា ១៩៩៩

៦/ច្បាប់ស្តីពីសភាពាណិជ្ជកម្មកម្ពុជា ចុះថ្ងៃទី ១៦ ឧសភា ១៩៩៥

៧/ច្បាប់ស្តីពីវិសោធកម្មលើច្បាប់ស្តីពីសភាពាណិជ្ជកម្មកម្ពុជា ចុះថ្ងៃទី ២៣ សីហា ២០០៦

៨/ច្បាប់ស្តីពីសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា ចុះថ្ងៃទី

៩/ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី ២២ ឧសភា ១៩៩៦

១០/ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៩ តុលា ១៩៩៩

១១/ច្បាប់ស្តីពីការធានារ៉ាប់រង ចុះថ្ងៃទី ២០ មិថុនា ២០០០

១២/ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ចុះថ្ងៃទី ២១ មិថុនា ២០០០

១៣/ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី ០៧ កុម្ភះ ២០០២

១៤/ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដេលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី ២២ មករា ២០០៣

១៥/ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចុះថ្ងៃទី ០៥ មីនា ២០០៣

១៦/ច្បាប់ស្តីពីធនក្ស័យ ចុះថ្ងៃទី ០៨ ធ្នូ ២០០៧

១៧/ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី ១៩ មិថុនា ២០០៥

១៨/ច្បាប់ស្តីពីការវិនិយោគ ចុះថ្ងៃទី ០៤ សីហា ១៩៩៤

១៩/ច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ០៨ មករា ១៩៩៧

២០/ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី ១២ ឧសភា ២០០៦

២១/ច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ចុះថ្ងៃទី ០៦ មេសា ២០០៧

២២/ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ តុលា ១៩៨៨

២៣/ច្បាប់ស្តីពីការបោះពុម្ពផ្សាយ និងមូលបត្រមហាជន ចុះថ្ងៃទី ១៩ តុលា ២០០៧

២៤/ច្បាប់ស្តីពីការធានារ៉ាប់រង ចុះថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ ២០០១

២៥/សេចក្តីព្រៀងច្បាប់ស្តីពីអ៊ី-ពាណិជ្ជកម្ម

២៦/សេចក្តីព្រៀងច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់

២៧/សេចក្តីព្រៀងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម

២៨/ សេចក្តីព្រៀងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិនៃការទូទាត់

២៩/សេចក្តីព្រៀងច្បាប់ស្តីពីការប្រកួតប្រជែង

៣០/ សេចក្តីព្រៀងច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម

៣១/ អនុក្រិត្យស្តីពីការធានារ៉ាប់រង ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១

៣២/ ប្រកាសស្តីពីវិធានការចាំបាច់មួយចំនួនសម្រាប់គ្រប់គ្រងការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦

៣៣/ ប្រកាសស្តីពីការចេញវិញ្ញាបនបត្របញ្ជាក់ពីប្រភពដើមនៃការដឹកជញ្ជូនទិញតាមផ្លូវអាកាស ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨

៣៤/ ប្រកាសស្តីពីការអនុវត្តផែនការកំណែទម្រង់ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ០៨-កញ្ញា-២០០៦

៣៥/ ប្រកាសស្តីពីការចេញវិញ្ញាបនបត្រស្តីពីប្រភពដើម វិក្កយបត្រពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤

៣៦/ ប្រកាសអន្តរក្រសួងស្តីពីការកែប្រែការគ្រប់គ្រងថ្លៃនាំចេញ និងតម្លៃពាក់ព័ន្ធ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧

៣៧/ ប្រកាសស្តីពីតម្រូវការឯកសារសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៦

៣៨/ ប្រកាសអន្តរក្រសួងស្តីពីថ្លៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧

៣៩/ប្រកាសស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន ចុះថៃទី ១៦ ខែ តុលា ឆ្នាំ ២០០២

៤០/ ប្រកាសស្តីពីការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២

៤១/ ប្រកាសស្តីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២


រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

៤២/ ប្រកាសស្តីពីការប្រកាសប្រទិវេទន៏ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ចុះថ្ងៃទី ០៧-មេសា-២០០៨

៤៣/ ប្រកាសស្តីពីការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ២៣ សីហា ២០០៤

៤៤/ ប្រកាសស្តីពីបែបបទ និងនីតិវិធី កែប្រែលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី ២០ មិថុនា ២០០៦

៤៥/ ប្រកាសស្តីពីវិមជ្ឈការនៃការចុះបញ្ជីពាណិជ្ជកម្មទៅសាខាពាណិជ្ជកម្មខេត្ត-ក្រុង ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧

៤៦/ ប្រកាសស្តីពីការចេញវិញ្ញាបនបត្រស្តីពីប្រភពដើមនៃសិប្បកម្ម ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤

៤៧/ ប្រកាសស្តីពីការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ចុះថ្ងៃទី ០៥ កក្កដា ២០០៦

៤៨/ ប្រកាសស្តីពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ០៧ សីហា ២០០៧

៤៩/ សារាចរណ៍ណែនាំស្តីពីការតម្កល់ប្រាក់ទុកនៅធានាគាររបស់ក្រុមហ៊ុនពាណិជ្ជកម្ម ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤

៥០/ សារាចរណ៍ណែនាំស្តីពីការផ្តល់អាជ្ញាប័ណ្ណធានារ៉ាប់រងបណ្តោះអាសន្ន ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០២

៥១/ សេចក្តីជូនដំណឹងស្តីពីឯកសារតម្រូវសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ២០ មិថុនា ២០០៦

៥២/ សេចក្តីជូនដំណឹងស្តីពីប្រការសំខាន់ៗនៃលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី ២០ មិថុនា ២០០៦

៥៣/ សេចក្តីជូនដំណឹងស្តីពីការអនុវត្តផែនការកំណែទម្រង់ការចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ០៨ កញ្ញា ២០០៦

## II- ឯកសារសៀវភៅ

១/វចនានុក្រម សម្តេចព្រះសង្ឃរាជ **ជួន ណាត**

២/សទ្ទានុក្រមពាក្យច្បាប់ពាណិជ្ជកម្ម

៣/សៀវភៅណែនាំសិក្សាស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម

៤/សៀវភៅណែនាំសិក្សាស្តីពីកាដោះស្រាយវិវាទក្រៅផ្លូវតុលាការ

៥/សៀវភៅណែនាំសិក្សាស្តីពីច្បាប់សហគ្រាសពាណិជ្ជកម្ម

៦/សៀវភៅណែនាំសិក្សាស្តីពីធនក្ស័យ

៧/សៀវភៅណែនាំសិក្សាស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

៨/សៀវភៅណែនាំសិក្សាស្តីពីក្រុមហ៊ុនមហាជន ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសហកម្មសិទ្ធិ

៩/សៀវភៅណែនាំសិក្សាស្តីពីកម្មសិទ្ធិបញ្ញា


រក្សាសិទ្ធិគ្រប់បែបយ៉ាង ©

១០/សៀវភៅណែនាំសិក្សាស្តីពីមូលដ្ឋានគ្រឹះនៃច្បាប់ពាណិជ្ជកម្ម

១១/សៀវភៅណែនាំសិក្សាស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

១២/អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការដឹកជញ្ជូនទំនិញតាមផ្លូវទឹក ចុះថ្ងៃទី ៣១ មីនា ១៩៧៨

១៣/អនុសញ្ញាស្តីពីការដឹកជញ្ជូនទំនិញមានលក្ខណៈអន្តរជាតិតាមផ្លូវគោក ចុះថ្ងៃទី ០២ មិថុនា ១៩៦១

១៤/ពិធីសារទីក្រុងហ្សឺណែវស្តីពីការដឹកជញ្ជូនទំនិញមានលក្ខណៈអន្តរជាតិតាមផ្លូវគោក ចុះថ្ងៃទី ០៥ កក្កដា ១៩៧៨

១៥/ក្រមរដ្ឋប្បវេណីកម្ពុជា " **ចាស់** " ឆ្នាំ ១៩២០

១៦/ក្រមពាណិជ្ជកម្មកម្ពុជា ឆ្នាំ ១៩៥០

១៧/ក្រមពាណិជ្ជកម្មអាឡឺម៉ង់

១៨/ក្រមពាណិជ្ជកម្មជប៉ុន

១៩/ក្រមពាណិជ្ជកម្មកូរ៉េ

២០/ក្រមពាណិជ្ជកម្មបារាំង

## III- **ឯកសារ INTERNET**

១/ www.moc.gov.kh

២/ www.cas.go.jp

៣/ www.wipo.int

៤/ www.copyright.gov/wipo

៥/en.wikipedia.org/wiki/**Commercial law**

៦/www.hg.org/commerc.html

៧/www.un.org/News/Press/docs//2008/gal3346.doc.htm

៨/www.hotfrog.com/Products/**Commercial**-**Law**

៩/**commercial**-**law**.blogspot.com/

១០/www.eur.nl/english/prospective/master/programmes/**commercial_law**

១១/www.jus.uio.no/lm/**law**.sites/**commercial**.**law**.html

១២/content.mycareer.com.au/salary-centre/legal/**commercial**/vic

១៣/www.allbusiness.com

១៤/legal-dictionary.thefreedictionary.com/Bill+of+health%3B+**commercial**+**law**

១៥/ww.lac**law**yers.com.au/legal/Business-%5Band%5D-**Commercial**-**Law**

១៦/www.ucc**law**.blogspot.com

១៧/**commerciallaw**attorney.resourcesforattorneys.com

១៨/www.martindale.com/**commercial**-**law**/c-austria/all-**law**-firms.htm

១៩/unjobs.org/tags/**commercial**-**law** -

២០/www.conseil-concurrence.fr/doc/code_commerce_gb.pdf

២១/www.llmstudy.com/editorial/llmbusiness

២២/www. Businesslawquestions.com